អ្នកស្រី ត្រឹង ងា

# អរិយធម៌ខ្មែរ



## ថ្នាក់ បញ្ចប់

(កម្មវិធីថ្មី)

›om Uch

អ្នកស្រី ត្រឹង ងា

សាស្ត្រាចារ្យបរិញ្ញានៅវិទ្យាល័យភ្នំដូនពេញ
អតីតនិស្សិតសាលាគរុវិជ្ជាជាន់ខ្ពស់

# អរិយធម៌ខ្មែរ

កម្មវិធីថ្មី

## សំរាប់ថ្នាក់បញ្ចប់គ្រប់ផ្នែក

*

ការផ្សាយរបស់អ្នកនិពន្ធ

បោះពុម្ពលើកទី ៣
(ដោយមានបន្ថែម និងកែសំរួល

គ.ស. ១៩៧៤ រក្សាសិទ្ធិ ព.ស. ២៥១៨

# មាតិកា

សេចក្តីផ្តើម (គោលបំណងនៃការសិក្សាអរិយធម៌ខ្មែរ) ទំព័រ 5

## ផ្នែកទី ១

### ជំពូកទី ១

អរិយធម៌ជាអ្វី ? . . . . . . . 8

មេគធាងនៃអរិយធម៌ . . . . . . . 11

ទំនាក់ទំនងរវាងវប្បធម៌និងសន្តមធម៌ . . . . . 15

### ជំពូកទី ២

ទំនាក់ទំនងរវាងអរិយធម៌ខ្មែរនិងអរិយធម៌បរទេស . . 19

ដើមកំណើត . . . . . . . . 24

## ផ្នែកទី ២ : វប្បធម៌

### ជំពូកទី ១ : សាសនា

ព្រាហ្មណ៍សាសនា . . . . . . . 29

ពុទ្ធសាសនា . . . . . . . 49

វិវត្តន៍នៃព្រាហ្មណ៍សាសនា និងពុទ្ធសាសនា . . . 67

### ជំពូកទី ២ : ភាសា-អក្សរ-អក្សរសិល្ប៍

ភាសា . . . . . . . . 73

អក្សរ . . . . . . . . 91
អក្សរសិល្ប៍ . . . . . . . 100
ជំពូកទី ៣ : សិល្បៈ
សញ្ញាណនៃស្ថាបត្យកម្ម . . . . . . 117
រូបចំលាក់បុរាណ . . . . . . . 130
ភ្លេង . . . . . . . . 149
របាំប្រពៃណី . . . . . . . 158
ជំពូកទី៤ : ជំនឿ - ទំនៀមទំលាប់ - ប្រពៃណី
នៅពេលកើត . . . . . . . 169
នៅពេលរៀបការ . . . . . . . 175
នៅពេលស្លាប់ . . . . . . . 191
បុណ្យផ្សេងៗ . . . . . . . 202
ផ្នែកទី ៣ សង្គមធម៌
របបសង្គមខ្មែរ
នយោបាយខ្មែរ . . . . . . . 216
សេដ្ឋកិច្ចខ្មែរ . . . . . . . 221
សង្គមកិច្ចខ្មែរ . . . . . . . 228
ផ្នែកទី៤
គំហែលពិសេសនៃអរិយធម៌ខ្មែរ . . . . . 231

# សេចក្ដីផ្ដើម

នៅក្នុងលោកនេះ ជាតិសាសន៍ណាក៏ដោយសុទ្ធតែមានអរិយធម៌ជាមូលដ្ឋាននៃប្រទេសជាតិរៀងៗខ្លួន ។ ប្រទេសណាដែលមានអរិយធម៌លូតលាស់ជឿនលឿន ត្រូវបានចាត់ទុកជាអរិយប្រទេស ។

ខ្មែរមានអរិយធម៌របស់ខ្លួនយ៉ាងជាក់លាក់ណាស់ ។ ប្រវត្តិសាស្ត្របានប្រាប់យើងថា ជាតិខ្មែរបានកសាងអរិយធម៌មួយដ៏ខ្ពង់ខ្ពស់ ហើយល្បីល្បាញសុះសាយពេញពិភពលោក ហើយដែលនៅសល់កេរដំណែលរហូតមកដល់សព្វថ្ងៃនេះ ដូចជាប្រាង្គប្រាសាទមានចំនួនរាប់រយ សិលា-ចារឹកមានចំនួនរាប់ពាន់ផ្ទាំង បារាយនិងបណ្ដាញព្រែកជីក វត្ថុបុរាណជាច្រើនមានរូបបដិមា រូបចំលាក់ជាដើម ។ អរិយធម៌ខ្មែរបានឡើងដល់កំរិតជាកំពូល(apogée) នៅសម័យអង្គរ ជាហេតុនាំអោយអ្នកប្រវត្តិសាស្ត្រចាត់ទុកថា ប្រទេសខ្មែរក្នុងសម័យនោះ ជាមហាអំណាចមួយនៅភូមិភាគអាស៊ីអគ្នេយ៍យើងនេះ ។ អ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ បាន

បង្ហូរទឹកខ្មៅជាច្រើនដើម្បីពិពណ៌នាពន្យល់និងកោតសរសើរពីអរិយធម៌អង្គរ ជាពិសេសពីប្រាសាទអង្គរវត្ត ដែលគេបានមូលមតិចាត់ទុកជាជាអច្ឆរិយវត្ថុមួយក្នុងពិភពលោក ។

អាស្រ័យហេតុនេះ គប្បីខ្មែរគ្រប់រូបព្យាយាមសិក្សាអរិយធម៌ជាតិរបស់ខ្លួនដើម្បីអោយបានស្គាល់ប្រភព លក្ខណៈផ្ទាល់ និងតំលៃនៃអរិយធម៌នោះ ។ គឺការដឹងនិងស្គាល់តំលៃ ហើយនិងធាតុផ្សេង ៗ យ៉ាងជាក់ច្បាស់នៃអរិយធម៌ជាតិនេះហើយ ដែលនាំអោយយើងមានមោទនភាព (fierté) ហើយចិត្តស្រលាញ់អរិយធម៌ជាតិរបស់យើងក៏កើតមានឡើង ។ ដរាបណាយើងមានចិត្តស្រលាញ់ ដរាបនោះយើងមុខជាព្យាយាមលើកតំកើង ហើយខិតខំថែរក្សា ការពារអរិយធម៌ជាកេរមត៌ក ដែលដូនតាបានកសាងទុកមកអស់ពេលច្រើនសតវត្ស អោយបានគង់វង់យូរអង្វែងតទៅទៀត ។ អំពើបែបនេះ ជាកត្តាដាស់យើងជាពលរដ្ឋខ្មែរអោយមានមនសិការជាតិឡើង និងផ្តល់អោយយើងគ្រប់គ្នានូវកម្លាំងចិត្តជាតិនិយមក្នុងការប្រយុទ្ធតស៊ូនឹងពួកសត្រូវឈ្លានពានដើម្បីការពារទឹកដី និងថែរក្សាជាតិសាសន៍ខ្មែរអោយនៅគង់វង់ក្នុងឋានៈជារដ្ឋប្រកបដោយឯករាជ្យ និងសម្បូរណភាពទឹកដី ។

ការស្គាល់ត្រឹមតែអរិយធម៌ជាតិរបស់ឯង ពុំទាន់គ្រប់គ្រាន់ទេ លុះត្រាតែបានស្គាល់អរិយធម៌បរទេសថែមទៀតទើបប្រសើរ ។ រៀនអរិយធម៌បរទេស ពុំមែនរៀនដើម្បីធ្វើតាមគេទាំងស្រុង និងបណ្តោយអោយ



គេបំបាត់លក្ខណៈជាតិឯងទេ ប៉ុន្តែត្រូវចេះស្រូបយកគំនិតសំខាន់ៗមកផ្សំផ្គុំរិះកលៃបញ្ចូលជាមួយអរិយធម៌ជាតិ អោយកាន់តែល្អប្រសើរឡើង ដូចជាក្នុងការរៀបចំស្រុកទេស ការរស់នៅ ការអប់រំ ទំនាមទំលាប់ជាដើម ។ ការធ្វើអោយមានលក្ខណៈជាតិបែបនេះ ពុំមែនមានចំពោះតែការសិក្សាអរិយធម៌បរទេសប៉ុណ្ណោះទេ គឺមានចំពោះឥទ្ធិពលនៃអរិយធម៌បរទេសដែលជះមកលើអរិយធម៌ជាតិក្នុងពេលមានទំនាក់ទំនងគ្នា រឺក្នុងពេលទទួលការគ្រប់គ្រងនៃបរទេសផងដែរ ។ ឯការប៉ះទង្គិចគ្នារវាងអរិយធម៌ជាតិនិងអរិយធម៌បរទេស គេចាត់ទុកជាការធម្មតា ព្រោះគេបានសង្កេតឃើញថា អរិយធម៌របស់ប្រទេសធំ ៗ ដែលរីកចំរើន គឺសុទ្ធតែជាផលរួមនៃអរិយធម៌ជាច្រើនដូចជាអរិយធម៌អឺរ៉ុប-អាមេរិក-រុស្ស៊ី-ចិន-ជប៉ុនជាដើម ។

*

* *

# ផ្នែកទី ១

## ជំពូកទី ១

## ១-អរិយធម៌ជាអ្វី ?

### ក-តាមន័យសព្ទជាតិ.-

អរិយធម៌ < អរិយ + ធម៌

អរិយ = ប្រសើរ ខ្ពង់ខ្ពស់ ថ្លៃថ្នូរ រុងរឿង...

ធម៌ = ធាតុ វិធី ធម៌ភាព សភាវៈទ្រទ្រង់...

ដូចនេះ **អរិយធម៌** គឺធម៌ទាំងឡាយណាដែលជាសភាពនិងតំលៃនៃការលូតលាស់ ដុះដាលរីកចំរើនល្អប្រសើរ ខ្ពង់ខ្ពស់ ថ្លៃថ្នូរក្នុងការរស់នៅរបស់មនុស្សក្នុងសង្គម ដែលប្រកបដោយរបៀបរៀបរយល្អ - គ្រឿងប្រដាប់ប្រើប្រាស់គ្រប់គ្រាន់ - ជំនឿ - ចំណេះ - ចំណង់ចំណូលចិត្តគ្រប់បែបយ៉ាងក្នុងគោលដៅស្វែងរកសុខៈ ។



### ខ-តាមន័យទស្សនៈ.-

ពាក្យអរិយធម៌ត្រូវគ្នានឹងពាក្យបារាំង Civilisation ដែលមានធាតុសំខាន់ៗ ដូចតទៅនេះ :

— ការរស់នៅរបស់សង្គមមនុស្សក្នុងស្រុកដែលជារដ្ឋ

— ច្បាប់ទំលាប់គ្រប់គ្រងពលរដ្ឋ និងរៀបចំការរស់នៅអោយបានស្រួលស្រួល

— អង្គការស្ថាប័នផ្សេងៗដែលទ្រទ្រង់ច្បាប់ និងការរស់នៅក្នុងសង្គមបែបជារដ្ឋនេះឯង ។

ការធ្វើអោយមានសភាពជាសង្គម ជារដ្ឋប្រកបដោយរបៀបរៀបរយអាចរស់នៅបានជាមួយគ្នាតាមច្បាប់ទំលាប់ ពោលគឺមិនរយោរយោព្រៃផ្សៃនេះហើយដែលជាន័យដើមរបស់ពាក្យ Civilisation ។ គេអាចបង្រួមធាតុនៃ Civilisation ជា ២ ពួក គឺ :

— ធាតុដែលជា **សភាព** : ការរស់នៅ របៀបរស់នៅ ច្បាប់ទំលាប់អង្គការរបស់រដ្ឋ ។

— ធាតុដែលជា **តំលៃ** : តំលៃល្អ - អាក្រក់ - ចំរើន - រៀបរយ - ចេះច្បាប់ទំលាប់ - ចេះរបៀបរស់នៅ ចេះគួរសម គោរពគ្នាទៅវិញទៅមក ហើយនិងតំលៃទាក់ទងទៅនឹងសេចក្ដីសុខចំរើន ។

នៅមានទស្សនៈប្លែកៗគ្នាច្រើនបែបយ៉ាងទៀត ចំពោះន័យនៃពាក្យអរិយធម៌នេះ ។ អ្នកប្រាជ្ញខ្លះមានទស្សនៈប្រហែលគ្នានឹងទស្សនៈដែលបានរៀបរាប់រួចមកហើយ គឺសំដៅយកការចំរើនលូតលាស់នៃជនជាតិណាមួយដែលផ្ទុយនឹងសភាពព្រៃផ្សៃ ។ អ្នកប្រាជ្ញខ្លះទៀតយល់ថា អរិយធម៌ជាការជឿនលឿនរីកចំរើនខាងសតិប្រាជ្ញា ខ្លះថាជាការជឿនលឿនរីកចំរើនខាងគ្រឿងសម្ភារៈនេះវិញទេ ។ ឯអ្នកប្រាជ្ញមួយពួកទៀតបានមូលមតិគ្នាយល់ថា អរិយធម៌គឺជាសភាពពិតប្រាកដនៃការរស់នៅ ទំនៀមទំលាប់ ចិត្តគំនិត អង្គការ ច្បាប់ផ្សេងៗព្រមទាំងគ្រឿងប្រដាប់របស់ជនជាតិនីមួយៗ ។ តាមន័យខាងក្រោយនេះ អរិយធម៌ពុំសំគាល់នូវតំលៃ រឺ កំរិតខ្ពង់ខ្ពស់របស់ជនជាតិណាមួយទេ ។ ជនជាតិណាក៏មានអរិយធម៌របស់ខ្លួនដែរ គ្រាន់តែប្លែកគ្នាត្រង់លក្ខណៈលូតលាស់ចំរើនជាងមុននោះ ។

## យោបល់រួម.-

ទោះបីមានមតិប្លែកៗគ្នាយ៉ាងនេះក៏ដោយ ក៏យើងអាចបង្រួមសេចក្តីថា **អរិយធម៌** សំគាល់នូវការរស់នៅ ការរៀបចំជីវភាពនៃសង្គមមនុស្សអោយបានប្រកបទៅដោយសេចក្តីសុខចំរើនលូតលាស់តាមវិធីផ្លូវចិត្តនិងផ្លូវកាយ ។ ដូចនេះ គោលដៅនៃអរិយធម៌គឺ **សុខៈ** ដំណើរទៅកាន់សុខៈ គឺសេចក្តីចំរើនលូតលាស់ ឯវិធីសំរេចសុខៈ គឺផ្លូវចិត្តផង ផ្លូវកាយផង ពោលគឺ **វប្បធម៌** និង **សង្គមធម៌** នេះឯង ។

# ២-មែកធាងនៃអរិយធម៌

- **អរិយធម៌**
  - **វប្បធម៌**
    - ចំណេះដឹង
      - ជំនឿ
      - សាសនា
      - វិជ្ជា-វិទ្យាសាស្ត្រ
    - កំណត់ផ្សាយ
      - ភាសា-អក្សរ-សញ្ញា
      - អក្សរសាស្ត្រ-អក្សរសិល្ប៍
      - សិល្បៈ-ពត៌មាន (វិទ្យុ ទូរទស្សន៍ . . .
    - អនុវត្តន៍
      - ទំនៀមទំលាប់-ប្រពៃណី
      - ការសិក្សា-ការអប់រំ (ប្រដៅ-ទូន្មាន)
      - កីឡា-ល្បែង-កំសាន្ត-ច្បាប់
  - **សង្គមធម៌**
    - គ្រឿងសង្គម
      - ប្រដាប់រស់នៅ (លំនៅ-ចំណីអាហារ-សំលៀកបំពាក់ . . .)
      - ប្រដាប់គិចនិច (មាស៊ីន : សំទង់-បង្កើតផល-ធ្វើដំណើរ . . . .)
      - មុខរបរ (-វិជ្ជាជីវៈ)
    - របបសង្គម
      - សេដ្ឋកិច្ច(កសិកម្ម-ឧស្សាហកម្ម-ពាណិជ្ជកម្ម)
      - សង្គមកិច្ច(សន្តិសុខ-សុខភាព-ការងារ...)
      - នយោបាយក្នុងប្រទេស (របៀប-របប-ច្បាប់គ្រប់គ្រង-ច្បាប់រដ្ឋ . . .) នយោបាយក្រៅប្រទេស (ទំនាក់ទំនងទូត-សង្គ្រាម...)
    - ទំរង់សង្គម
      - ស្នូលសង្គម (គ្រួសារ)
      - វណ្ណៈសង្គម (វណ្ណៈជាតិកំណើត-វណ្ណៈការងារ-វណ្ណៈចំណេះវិជ្ជា)
      - អង្គការសង្គម (ស្ថាប័នផ្សេងៗ : ស្ថាប័ននយោបាយ-ស្ថាប័នវប្បធម៌...)

តាមតារាងខាងលើនេះ វប្បធម៌និងសង្គមធម៌ជាផែកធានដ៏សំខាន់ ហើយនិងជាមូលដ្ឋាននៃអរិយធម៌ ។ តើសាខាទាំងពីរនេះមានន័យដូចម្តេចខ្លះ?

## ក–ន័យនៃពាក្យវប្បធម៌.—

### តាមន័យសព្ទជាតិ.—

វប្បធម៌ < វប្ប + ធម៌

វប្ប = ការសាបព្រោះ ការបណ្តុះពូជ ការបង្កបង្កើត...

ធម៌ = ធាតុ វិធី ធម៌ភាព សភាវៈទ្រទ្រង់...

វប្បធម៌ = ធម៌ទាំងឡាយណាដែលទ្រទ្រង់នូវការសាបព្រោះបណ្តុះពូជអោយលេចជាលទ្ធផលជាផ្លែផ្កា ។

### តាមន័យវចនានុក្រមខ្មែរ.—

វប្បធម៌សំគាល់នូវការផ្សាំ ការបណ្តុះចំណេះវិជ្ជានិងប្រាជ្ញាស្មារតីអោយបានចំរើនលូតលាស់ដោយវិទ្យាសាស្ត្រដោយសិល្បៈផ្សេងៗ ។

### តាមន័យភាសាបារាំង.—

វប្បធម៌ត្រូវនឹងពាក្យបារាំង Culture ។

**— ន័យដើម Culture = le travail des terres ( ការងារទាំងឡាយទាក់ទងនឹងដី-ដំណាំផ្សេងៗ) ។**



— ន័យក្លាយ Culture = le travail de l'esprit (ការបណ្តុះបណ្តាលចិត្តគំនិត – វិជ្ជា ឧ. la culture des lettres et des sciences ; la culture des arts...) ។

= l'instruction et l'éducation ( ការសិក្សាអប់រំបណ្តុះមនោសញ្ចេតនា ឧ.la culture du cœur et des sentiments) ។

### តាមន័យទស្សនសព្ទ.—

— តាមបែបអាល្លឺម៉ង់ kultur សំដៅយកតែការចំរើនលូតលាស់ផ្លូវចិត្តតែប៉ុនោះ ។

— តាមបែបបារាំង Culture សំគាល់ការបង្កើនរឺជាលទ្ធផលនៃការបង្កើននេះឯង ឧ. la culture physique ; la culture intellectuelle. ។

### យោបល់រួម.—

ទោះបីមាននិយមន័យច្រើនបែបយ៉ាងនេះក៏ដោយ ក៏ន័យដើមពិតប្រាកដរបស់ពាក្យវប្បធម៌បានក្លាយទៅជាសំគាល់នូវសភាព រឺធម៌ទាំងឡាយណាដែលអាចបណ្តុះបណ្តាល បង្កើនអោយបានផលល្អប្រសើរចំរើនលូតលាស់ឡើងទៀត ទុកណាតាមផ្លូវវិជ្ជា - ចិត្តគំនិត - កាយក៏ដោយ ។

### សេចក្តីសង្ខេប.—

* ជួនកាលគេប្រើពាក្យ "វប្បធម៌ទូទៅ" (la culture générale) សំគាល់ចំណេះចេះដឹងសំខាន់ៗ ដែលម្នាក់ៗត្រូវដឹងដើម្បីរស់បានស្រួលក្នុងសង្គមមនុស្ស ។

* ជួនកាលគេប្រើពាក្យ "វប្បធម៌" ភ្ជាប់ជាមួយនឹងពាក្យ "អរិយធម៌" ឧ. វប្បធម៌អរិយធម៌ខ្មែរ វប្បធម៌អរិយធម៌អឺរ៉ុប ។ គេនិយមប្រើពាក្យបែបនេះ ដោយគេមានទស្សនៈយល់ថា វប្បធម៌សំគាល់ធម៌ដែលបណ្ដុះបណ្ដាលអោយលូតលាស់ចំរើនប្លែកពីធម្មជាតិមនុស្សធម្មតា ឯអរិយធម៌សំដៅយកលក្ខណៈសង្គមណាដែលភ្ញាក់រលឹក ទំលូតលាស់ ហើយកែប្រែចំរើនប្លែកអំពីធម្មជាតិនៃសង្គមមនុស្សធម្មតា ។ តាមទស្សនៈនេះ វប្បធម៌និងអរិយធម៌មានលក្ខណៈរួមមួយ គឺការភ្ញាក់រលឹក ការបណ្ដុះបណ្ដាលអោយលូតលាស់នេះឯង ។ ចំណែកការនិយមប្រើពាក្យ "អរិយធម៌" តែឯងវិញ សំអាងទៅលើអរិយធម៌ដែលធំជាងវប្បធម៌ ។ កាលណាគេលឺពាក្យ "អរិយធម៌" កាលនោះគេដឹងថា មានវប្បធម៌ផង សង្គមធម៌ផងនៅក្នុងនោះដែរ ។ ចុះសង្គមធម៌មានន័យប្លែកយ៉ាងណាខ្លះពីវប្បធម៌និងអរិយធម៌ ?

## ខ - ន័យនៃពាក្យសង្គមធម៌.-

ពាក្យថា **សង្គម** (la société) សំដៅយកធម្មជាតិមនុស្សរស់នៅរួមគ្នា មានទីលំនៅ មានរបររកស៊ី មានរបៀបបែបបទក្នុងការទាក់ទង



គ្នាជាដើម ។

ឯពាក្យ សង្គមធម៌ (le social) សំគាល់ធម៌ទាំងឡាយណាដែលជាធាតុ វិធី ធម៌ភាពរៀបចំសង្គមមនុស្សអោយមានសភាព មាំរឹងនិងលក្ខណៈចំរើនលូតលាស់ បានសេចក្ដីថា រៀបចំសង្គមមនុស្សអោយរស់នៅបានស្រួល ប្រកបដោយគ្រឿងសម្ភារៈគ្រប់គ្រាន់ផង សភាពលក្ខណៈល្អប្រសើរថែមទៀតផង ។

រួចមកហើយ យើងបានដឹងថា អរិយធម៌មានវប្បធម៌និងសង្គមធម៌ជាមធ្យោបាយ រឺវិធីដើម្បីសំរេចនូវសុខៈ ។ ក្នុងដំណើរទៅកាន់គោលដៅនេះ តើវប្បធម៌ រឺ សង្គមធម៌ ដែលមានឥទ្ធិពលជាង ?

*

* *

# ៣ - ទំនាក់ទំនងរវាងវប្បធម៌ និងសង្គមធម៌

មានមតិច្រើនយ៉ាងដែលអោយតំលៃប្លែកគ្នាទៅលើវប្បធម៌ និង សង្គមធម៌ ។

មតិទី ១.– អ្នកខ្លះយល់ថា កម្លាំងអរិយធម៌ស្ថិតលើវប្បធម៌ ពោលគឺវប្បធម៌ជាបុព្វហេតុនៃការជឿនលឿនរបស់មនុស្ស ។ គេបានអះអាងថា ចំណេះចេះដឹងមានវិជ្ជា សាសនា អក្សរ អក្សរសិល្ប៍ ការសិក្សាអប់រំជាដើម ជាកម្លាំងវប្បធម៌អាចកែប្រែសង្គមមនុស្សអោយមានជីវិតជីវភាពខ្ពង់ខ្ពស់ មានចរិយាថ្លៃថ្នូរ មានច្បាប់ទំលាប់ត្រឹមត្រូវ មានការគ្រប់គ្រងរៀបរយ ។ល។

មតិទី ២.– អ្នកខ្លះយល់ផ្ទុយថា កម្លាំងអរិយធម៌ស្ថិតនៅលើសង្គមធម៌នេះវិញទេ ពោលគឺសង្គមធម៌ជាបុព្វហេតុនៃការជឿនលឿន ព្រោះសង្គមធម៌អាចកែប្រែផ្លាស់ប្តូរជីវភាព ទាំងទស្សនៈ ចិត្តគំនិត ចំណង់ចំណូលចិត្តរបស់មនុស្សម្នាក់ៗផង របស់សង្គមទាំងមូលផង ។ យ៉ាងណាមិញ ប្រដាប់ប្រើប្រាស់បែបណា របៀបបង្កើតផលនិងចែកផលបែបណា ច្បាប់គ្រប់គ្រងសង្គម វិធីរៀបចំសង្គម ព្រមទាំងមនោសាស្ត្រសង្គមក៏យ៉ាងនោះដែរ ។ អោយតែផ្លាស់ប្តូរ សង្គមកិច្ច នយោបាយបាន ទស្សនៈ ចិត្តគំនិត ចំណង់ចំណូលចិត្តក៏ផ្លាស់ប្តូរទៅតាមនោះដែរ ។ វណ្ណៈមនុស្ស សាសនា ជំនឿ ។ល។ ក៏បាត់ដោយខ្លួនឯង ដោយសារការផ្លាស់ប្តូរសង្គមធម៌នេះឯង ។

រួមសេចក្តីមក ទស្សនៈទាំងពីរខាងលើនេះ មានលក្ខណៈត្រូវខ្លះខុសខ្លះ ពីព្រោះជួនកាលកម្លាំងអរិយធម៌ស្ថិតនៅក្នុងវប្បធម៌ ជួនកាលនៅក្នុងសង្គមធម៌ ប៉ុន្តែពុំមែនស្ថិតដាច់គ្នានៅតែខាងវប្បធម៌តែឯង រឺ



ខាងសង្គមធម៌តែឯងនោះទេ ។ ការពិតវប្បធម៌និងសង្គមធម៌ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ មានឥទ្ធិពលលើគ្នាទៅវិញទៅមក ប្រៀបបាននឹងការអាស្រ័យគ្នាទៅវិញទៅមករវាងចិត្តនិងកាយដូចនោះដែរ ។ យ៉ាងណាមិញ ៖

សង្គមធម៌ដែលលូតលាស់ចំរើនទៅបាន ក៏អាស្រ័យវប្បធម៌នេះឯង ដូចជាគ្រឿងប្រើប្រាស់ផ្សេងៗ ( ផ្លូវកាយ ) ផលិតឡើងដោយការគិតគូរប្រាជ្ញា ចំណេះវិជ្ជា ( ផ្លូវចិត្ត ) របស់មនុស្ស ។ ឯវប្បធម៌ក៏ត្រូវពឹងពាក់លើសង្គមធម៌ដូចនោះដែរ ដូចជាសិល្បៈ អក្សរសិល្ប៍ សាសនា វិទ្យាសាស្ត្រ ( ផ្លូវចិត្ត ) ដែលលូតលាស់សាយភាយក៏អាស្រ័យទៅលើគ្រឿងសម្ភារៈ គ្រឿងពិសោធ អង្គការសង្គម ( ផ្លូវកាយ ) ជាដើម ។ ក្រៅពីនេះ ធម៌ទាំងពីរអាចកែប្រែគ្នា ផ្លាស់ប្តូរគ្នាបានថែមទៀត ។ ដូចជា ជួនកាលជីវភាពរស់នៅជួបប្រទះនឹងការលំបាកវេទនាខ្លាំងពេក មានការអត់បាយ មានរោគប្រចាំកាយជាដើម ជំរុញមនុស្សអោយខំស្វះស្វែងរកមធ្យោបាយដោះស្រាយ ដោយពឹងផ្អែកទៅលើវិធីសាសនា រឺជំនឿផ្តេសផ្តាសលើខ្មោច-អារក្ស-អ្នកតា-ទេវតា-អាទិទេព ជាដើម ។ ជួនកាលជីវភាពរស់នៅខ្ពង់ខ្ពស់សម្បូណ៌សប្បាយ មានគ្រឿងប្រើប្រាស់ មានថ្នាំកែរោគគ្រប់គ្រាន់ ក៏អាចបំបាត់វិធីសាសនានិងជំនឿងប់ងុលខ្លាំងពេកទៅលើទេវអាទិទេព ។ ឯទំលាប់ប្រើសាសនាយូរយារមកហើយ ក៏អាចមានឥទ្ធិពលទៅលើសង្គមមនុស្សបានដែរ ដោយអប់រំមនុស្សអោយទទួលជីវភាព

ត្រឡប់ វេទនាគ្រប់បែបយ៉ាងរបស់ខ្លួនរីឯធ្វើអោយមនុស្សប្រាសចាកការតស៊ូប្រឆាំងនឹងកម្លាំងធម្មជាតិក៏មានដែរ ។ ប៉ុន្តែទុកណាសង្គមធម៌ក្តី វប្បធម៌ក្តី មានកម្លាំងឈ្នះគ្នាក្នុងកាលៈទេសៈខ្លះក៏ដោយ ក៏ពុំមែនជាកម្លាំងដាច់ខាតដែលម្នាក់ឯងអាចទប់ទល់ រឺកែប្រែសង្គមមនុស្សបានទាំងអស់នោះទេ ។

សន្និដ្ឋានសេចក្តីមកឃើញថា អរិយធម៌ដែលអាចផុះដាល ចំរើនលូតលាស់ទៅបាន ក៏ដោយអាស្រ័យទៅលើវប្បធម៌ផង សង្គមធម៌ផង ដែលបេទាក់ទងគ្នា ពឹងផ្អែកគ្នាទៅវិញទៅមកជាដាច់ខាត ។ វប្បធម៌ស្វែងរកសុខៈអោយមនុស្សតាមផ្លូវចិត្ត ឯសង្គមធម៌ស្វែងរកសុខៈអោយមនុស្សតាមផ្លូវកាយរឺផ្លូវសម្ភារៈ ។ ធម៌ទាំងពីរនេះមានគោលដៅតែមួយដូចគ្នា គឺបំរើសេចក្តីសុខស្រួលរបស់មនុស្សនេះឯង ។

ក្រៅពីទំនាក់ទំនងនិងឥទ្ធិពលទៅវិញទៅមកបែបនេះ វប្បធម៌និងសង្គមធម៌នៅមានទំនាក់ទំនងជាមួយ វប្បធម៌សង្គមធម៌បរទេសថែមទៀត។

*

* *



# ជំពូកទី ២

## ១- ទំនាក់ទំនងរវាងអរិយធម៌ខ្មែរ និងអរិយធម៌បរទេស

ជាតិសាសន៍ណាក៏ដោយ ពុំដែលមានអរិយធម៌សុទ្ធសាធតែឯកឯងឡើយ លើកលែងតែជាតិសាសន៍នោះស្ថិតដាច់ឆ្ងាយពីគ្មានការទាក់ទងជាមួយជាតិសាសន៍ឯទៀត ៗ ។ ការប៉ះទង្គិចគ្នារវាងជាតិសាសន៍មួយទៅនឹងជាតិសាសន៍ផ្សេង ៗ ទៀត រមែងមានការទទួលឥទ្ធិពលគ្នាទៅវិញទៅមកជាដរាប ។ យ៉ាងណាមិញ ជនជាតិខ្មែរដែលធ្លាប់មានអរិយធម៌ល្បីល្បាញយូរយារមកហើយ ក៏តែងបានទទួលឥទ្ធិពលអរិយធម៌បរទេសជាច្រើនដែរ ។ តើខ្មែរបានទាក់ទងជាមួយជនជាតិណាខ្លះ ? ហើយទទួលឥទ្ធិពលអ្វីខ្លះ ? យើងសូមបញ្ជាក់ជូនដោយសង្ខេបក្នុងតារាងខាងក្រោមនេះ :

**មូលធម៌ខ្មែរ-មន**
**(មុន គ.ស.)**

- ជឿព្រលឹង-អារក្ស-អ្នកតា
- ទុកស្ត្រីជាធំ
- បាចទឹកបញ្ចូលស្រែ
- ផ្សាំងសត្វ
- កប់ខ្មោចក្រោមផ្នូដុល-ក្នុងក្រឡ
- ភាសាមានអន្តរបទ ( infixe )

។ ល ។

១- ឥទ្ធិពលឥណ្ឌា ( ស.វ.ទី ១ )
- ទស្សនៈរាជាធិបតេយ្យ
- សាសនា
- ភាសា អក្សរ អក្សរសិល្ប៍
- សិល្បៈ
- ទំនាមទំលាប់ ច្បាប់ ...

២- ឥទ្ធិពលចិន ( ស.វ.ទី ៣ )
- ជំនួញ
- ល្បាយជាតិសាសន៍
- ល្ខោន ...

៣- ឥទ្ធិពលចាម-ជ្វា ( ស.វ.ទី ៥ )
- ស្ថាបត្យកម្ម (ប្រាសាទភ្នំ?) និង ក្បាច់លំអ (រាហូ) ...

៤- ឥទ្ធិពលថៃ-យួន ( ស.វ.ទី ១៣ )
- ពាក្យពេចន៍ ...

៥- ឥទ្ធិពលអឺរ៉ុប ( ស.វ.ទី១៦)
- វិទ្យាសាស្ត្រ-បច្ចេកទេស
- ទំលាប់ (ចាប់ដៃ-ស្លៀកពាក់...)
- លទ្ធិប្រជាធិបតេយ្យ-កិច្ចការរដ្ឋបាល



តើការទទួលឥទ្ធិពលបរទេសបែបនេះមានលក្ខណៈយ៉ាងណាដែរ ?

ពិតមែនតែមានឥទ្ធិពលបរទេសទៅលើអរិយធម៌ខ្មែរយ៉ាងនេះក៏ដោយ ក៏ខ្មែរពុំនិយមយកមកអនុវត្តតាម រឺចម្លងតាមទាំងស្រុងដែរ ។ ខ្មែរតែងយកឥទ្ធិពលទាំងនោះមកច្នៃ រឺផ្សំផ្សំអោយមានលក្ខណៈជាតិ (ជាតូបនីយកម្ម) ដើម្បីអោយស្របស្រួលនឹងទស្សនៈខ្មែរ និងការរស់នៅរបស់ខ្មែរជាដរាប ។ រីឯលក្ខណៈបរទេសណា ផ្នែកណាដែលមិនស្រុះស្រួល មិនស៊ីគ្នានឹងទស្សនៈខ្មែរ នឹងចំណង់ចំណូលចិត្តខ្មែរទេ ត្រូវខ្មែរផាត់ចោល រឺក៏ត្រូវសាបរលាបខ្លួនឯងទៅវិញ ។ អាស្រ័យៈដោយការចេះសំរួល ការចេះកាត់តែអោយមានលក្ខណៈជាតិបែបនេះហើយ ទើបអរិយធម៌ជាតិមានការចំរើនលូតលាស់កាន់តែប្រសើរឡើង ។ ប៉ុន្តែវត្តមាននៃអរិយធម៌បរទេស ក្នុងអរិយធម៌ខ្មែរជាហេតុនាំអោយមានមតិខ្លះយល់ច្រលំថា អរិយធម៌ខ្មែរពុំមានកំណើតដើមរបស់ខ្លួនទេ គឺមានប្រភពអំពីអរិយធម៌បរទេស ជាពិសេសអរិយធម៌ឥណ្ឌា ដូចមាន :

* ទស្សនៈ លោក J. Taupin នៅក្នុងសៀវភៅ Etude sur la littérature khmère: « La littérature et la langue khmères sont filles du sanskrit » បានសេចក្តីថា « អក្សរសិល្ប៍និងភាសាខ្មែរជាកូននៃភាសាសំស្ក្រឹត » ។

* ទស្សនៈលោក Pierre Loti នៅក្នុងសៀវភៅ Pèlerin d' Angkor: «Le peuple khmer, rameau détaché de la grande race aryenne.»

ប្រែថា «ប្រជារាស្ត្រខ្មែរជាមែកធាងដែលបែកចេញមកពីមហាអំបូរអារ្យ» ។

* ទស្សនៈលោក ពៅ ឈិន នៅក្នុងសៀវភៅអរិយធម៌ខ្មែរ-មន : « អរិយធម៌របស់ខ្មែរនិងមននោះមុនដំបូងបានមកពីឥណ្ឌា » ។

* ទស្សនៈលោក ឈឹម ក្រសេម នៅក្នុងសៀវភៅពង្សាវតាររបស់លោក ក៏ខំទាញថាខ្មែរមកពីឥណ្ឌាដែរ ។

តាមពិតខ្មែរយើងមានអរិយធម៌ពិសេសរបស់ខ្លួន តាំងពីមុនមានទំនាក់ទំនងជាមួយបរទេសម៉្លេះ ។ មានមតិអ្នកប្រាជ្ញខ្លះក៏បានបញ្ជាក់អំពីរឿងនេះដែរដូចជា :

* លោក B.P. Groslier នៅក្នុងសៀវភៅ Angkor, Hommes et pierres បានសរសេរថា « Cette culture revêt une importance extrême, car elle constitua un substrat commun aux différents peuples de l' Asie du Sud-Est. Et s'il n' y avait eu à l'origine cette civilisation des moussons, l'Inde non plus que la Chine n'auraient pu rayonner comme elles l'ont fait : une graine a besoin de terreau pour germer.» ប្រែថា : « អរិយធម៌នេះ (អរិយធម៌អូស្ត្រូអាស៊ី រឺអរិយធម៌ខ្យល់រដូវ) មានសារៈសំខាន់ខ្លាំងណាស់ព្រោះជាមូលដ្ឋានរួមរបស់ជនជាតិផ្សេង ៗ នៅអាស៊ីអាគ្នេយ៍ ។ ហើយប្រសិនបើគ្មានអរិយធម៌ខ្យល់រដូវនៅខាងដើមទេ ប្រទេសឥណ្ឌាក៏ដូចជាប្រទេសចិន មិនអាចផ្សព្វផ្សាយឥទ្ធិពលបានដូចដែលខ្លួនបានធ្វើរួចមកហើយនោះទេ : គ្រាប់ពូជត្រូវការមានដីដើម្បីដុះដាលបាន » ។



* លោក Maurice Glaize អតីតអភិរក្សអង្គរ បានសរសេរជាអាទិ៍នៅក្នុងសៀវភៅ Les monuments du groupe d' Angkor: «Ce n'est nullement, comme certains le croient, un peuple d'origine purement indienne qui serait venu, à la suite de migrations, se fixer dans une région vide d'habitants, ou en aurait éliminé les éléments indigènes par des massacres ou des déportations en masse: le peuple khmer est un peuple autochtone hindouisé» បានសេចក្តីថា : « មិនមែនដូចអ្នកខ្លះបានយល់នោះទេ ថាជាប្រជារាស្ត្រមួយដែលមានដើមកំណើតជាឥណ្ឌាសុទ្ធសាធ ហើយដែលបានមកតាំងនៅក្នុងតំបន់មួយគ្មានមនុស្ស រឺក៏បានកំចាត់ពួកអ្នកស្រុកអោយដោយការសម្លាប់រង្គាល រឺការនិរទេសទាំងហ្វូង : ប្រជារាស្ត្រខ្មែរគឺជាអ្នកស្រុកដើម ដែលបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌា » ។

មុននឹងសិក្សាអំពីមែកធាងសំខាន់ ៗ នៃវប្បធម៌និងសង្គមធម៌ខ្មែរតទៅទៀត គប្បីយើងលើកយកដើមកំណើតជាតិខ្មែរមកបញ្ជាក់ជាមុនសិន ។

*

*        *

# ២-ដើមកំណើតជាតិខ្មែរ[1]

បញ្ហាដើមកំណើតជាតិខ្មែរនេះ មានចោទឡើងរៀងរាល់ពេលដែលគេធ្វើការសិក្សាស្រាវជ្រាវអំពីអរិយធម៌ខ្មែរ ។ យ៉ាងណាមិញ សព្វថ្ងៃនេះ ឥទ្ធិពលដែលបរទេសបានគ្របដណ្ដប់មកលើស្ទើរតែរកយល់ថាខ្មែរនេះជាអ្វីពុំបានទៅហើយ ទើបអ្នកសិក្សាស្រាវជ្រាវនិយមទាញភ្ជាប់ខ្មែរទៅនឹងជាតិណាមួយដែលគេយល់ថាមានអរិយធម៌ខ្ពង់ខ្ពស់ជាងខ្មែរ ។

ជាយូរយារមកហើយ អ្នកធ្វើការសិក្សាស្រាវជ្រាវពីខ្មែរ បានខិតខំដោះស្រាយនូវបញ្ហាដ៏សំខាន់នេះ ហើយបានបញ្ចេញជាយោបល់ប្លែកៗគ្នា ហើយជួនកាលក៏ផ្ទុយគ្នាស្រឡះតែម្ដង ។ ប៉ុន្តែ យើងអាចប្រមូលយោបល់ទាំងនោះបានជាពីរប្រភេទ ៖

**យោបល់ទី ១.–** ទទួលថាជាតិខ្មែរជាជាតិអន្តោប្រវេសន៍ (race-immigrée) ចេញពីប្រទេសឥណ្ឌា ហើយបានលុកលុយដណ្ដើមយកទឹកដីរបស់ជាតិដើមមួយ (race autochtone) គឺជនជាតិក្នុងអំបូរម៉ាឡាយូ-ប៉ូលីណេស៊ីយែន (race malayo-polynésienne) នេះឯង ។ ទស្សនៈនេះត្រូវបានបង្កើតឡើងមុនគេដោយលោក Hendrick Kerns ។



បន្ទាប់មកទៀត ក៏មានអ្នកស្រាវជ្រាវខ្លះយល់ស្របតាម ដូចជាលោក Adhémard Leclère និងលោក Pierre Gourou ជាដើម ។ លោក Pierre Gourou បានទាំងបញ្ជាក់ថាជនជាតិ មន-ខ្មែរ ប្រហែលជាត្រូវពួកទ្រាវិឌ រឺពួកអារ្យច្រានចេញពីប្រទេសឥណ្ឌា ហើយដោយមាននៅសេសសល់ក្រុមខ្លះ ដូចជាពួកមុណ្ឌាបានមកលុកលុយប្រទេសភូមា ប្រទេសសៀម និង ប្រទេសកម្ពុជា ។

គេអាចបន្ថែមទៅក្នុងក្រុមអ្នកស្រាវជ្រាវទីមួយនេះ នូវឈ្មោះលោក Etienne Aymonier ដែលយល់ថាក្រុម មន-ខ្មែរ-មុណ្ឌា មានទីតាំងដើមនៅជើងភ្នំទីបេ ហើយក្រោយមកបានបំបែកជាពីរក្រុម មួយក្រុមគឺ "មន-ខ្មែរ" ចូលមកតាំងនៅក្នុងភូមិភាគអាស៊ីអគ្នេយ៍ ឯមួយក្រុមទៀតគឺ "មុណ្ឌា" ចូលទៅនៅក្នុងប្រទេសឥណ្ឌារហូតដល់សព្វថ្ងៃ ។

**យោបល់ទី២.–** ទទួលស្គាល់ថា ជាតិខ្មែរជាជាតិពិសេសមួយស្ថិតនៅក្នុងក្រុម មន-ខ្មែរ ហើយបានមកកើតឡើងនៅភូមិភាគអាស៊ីអគ្នេយ៍នេះតាំងពីបុរាណមក ។ នេះគឺជាយោបល់របស់លោក Bernard Philippe Groslier (បច្ចុប្បន្នអភិរក្សអង្គរ) និងលោក Marcel Talabot ជាដើម ។ លោកទាំងពីរនេះយល់ឃើញថា ក្នុងសម័យបុព្វប្រវត្តិសាស្ត្រដ៏យូរលង់មកហើយ មានមនុស្សជាច្រើនក្រុមបានធ្វើដំណើរពីខាងជើងចុះមកភូមិភាគអាស៊ីអគ្នេយ៍ ដូចជាពួកអូស្ត្រាឡូអ៊ីដ (Australoides)

មេឡាណេស៊ីយាំង (Mélanésiens) និងឥណ្ឌូណេស៊ីយាំង (Indonésiens) ។ អំបូរ មន-ខ្មែរ បានកើតឡើងដោយការកាត់ផ្សំរវាងពួកឥណ្ឌូណេស៊ីយាំង និង ពួកមេឡាណេស៊ីយាំង ហើយបានរស់នៅរាយប៉ាយលើទឹកដីដែលលាតសន្ធឹងពីឥណ្ឌូចិន ជ្រោយម៉ាឡាយូរហូតដល់ព្រំប្រទល់ប្រទេសឥណ្ឌា ។

គួរកត់សំគាល់ថា យោបល់នៃក្រុមទីពីរនេះ មានលក្ខណៈស្របទៅនឹងទស្សនៈរបស់ខ្មែរ ពីព្រោះបើយើងសំអាងទៅលើរឿងព្រេងខ្មែរក៏ដោយ លុះត្រាតែមាននាងនាគនៅស្រុកខ្មែរនេះឯង ទើបព្រះថោង (ដែលគេថាមកពីស្រុកឥណ្ឌា) បានជួបប្រភពគ្នាដោយបានគ្រប់គ្រងស្រុកគោកធ្លកនេះដែរ ។ បានសេចក្តីថា លុះត្រាតែមានជាតិខ្មែរនៅលើកោះគោកធ្លកនេះដែរ ទើបឥណ្ឌាអាចផ្សាយអរិយធម៌របស់ខ្លួនបានខ្លះចូលក្នុងស្រុកខ្មែរ ។

សេចក្តីក្នុងរឿងព្រេងនេះសអោយឃើញទៀតថា ចំពោះខ្មែរយើង ជាតិខ្មែរមានប្រភពនៅក្នុងស្រុកខ្មែរនេះឯង ។

រួចមកហើយ យើងបានឃើញថា ចំពោះបញ្ហាដើមកំណើតនៃជាតិសាសន៍ខ្មែរនេះ អ្នកប្រាជ្ញអន្តរជាតិបានបញ្ចេញសម្មតិកម្មច្រើនបែបច្រើនយ៉ាងណាស់ តែលោកបានស្របយោបល់គ្នាត្រង់ចំណុចដែលថា ខ្មែរជាជាតិមួយស្ថិតនៅក្នុងអំបូរពិសេសមួយគឺអំបូរមន-ខ្មែរនេះឯង ។

* * *

# ផ្នែកទី២ : វប្បធម៌

## ជំពូកទី១

## សាសនា

ពាក្យ សាសនា ជាពាក្យប្រើក្លាយមកពីពាក្យ សាសន បានន័យថា ពាក្យបណ្តាំ រឺការទូន្មានប្រៀនប្រដៅរបស់គ្រូអាចារ្យណាមួយក្នុងលោក ។ អត្ថន័យនៃពាក្យសាសនា រឺលទ្ធិសាសនា ពុំមែនស្ថិតនៅត្រង់ជំនឿរឺបញ្ញត្តិសីលធម៌និងការគោរពប្រណិបតន៍ប៉ុណ្ណោះទេ គឺត្រូវមានអង្គការពិសេសមួយ សំរាប់ទ្រទ្រង់ថែរក្សាលទ្ធិសាសនាអោយមានស្ថិរភាពតាំងនៅជាស្ថាពរវែងឆ្ងាយតរៀងទៅ ។

សាសនាមានច្រើនណាស់នៅក្នុងលោក ដូចជា (2) :

— សាសនាព្រាហ្មណ៍ រឺព្រហ្មញ្ញសាសនា ( Brahmanisme) មានកំណើតនៅប្រទេសឥណ្ឌា

(1) (2) . . . ជាលេខយោងទៅឯកសារពិគ្រោះដែលមានចុះក្នុងបញ្ជីនៅខាងចុងសៀវភៅនេះ ។

- សាសនាព្រះពុទ្ធ ពុទ្ធសាសនា (Bouddhisme) មានកំណើតនៅប្រទេសឥណ្ឌា
- សាសនាគ្រិស្ត (Christianisme) មានកំណើតនៅប្រទេសស៊ីរី
- សាសនាអ៊ីស្លាម (Islam ou Islamisme) មានកំណើតនៅប្រទេសអារ៉ាប់
- សាសនាតៅ (Taoisme) មានកំណើតនៅប្រទេសចិន
- សាសនាស៊ិន្តូ (Shintoisme) មានកំណើតនៅប្រទេសជប៉ុន ។ល។

តើជនជាតិខ្មែរយើងមានសាសនាដែរ រឺទេ ?

គេតែងសង្កេតឃើញថា កាលណាមានភយន្តរាយ រឺមានបញ្ហាណាមួយកើតមានឡើង ហើយដែលមនុស្សដោះស្រាយដោយកម្លាំងប្រាជ្ញា រឺកម្លាំងកាយរបស់ខ្លួនពុំរួច ក៏កើតមានជំនឿទៅលើកម្លាំងក្រៅខ្លួន ថាមានវត្ថុខ្លាំងពូកែសក្តិសិទ្ធិផ្សេងៗអាចជួយសំរេចគោលបំណងខ្លួនបាន ។

ចំណែកជនជាតិខ្មែរយើង កាលដើមឡើយក៏មានជំនឿបែបនេះដែរ គឺនិយមគោរពកម្លាំងធម្មជាតិដោយយល់ថា ធម្មជាតិទាំងឡាយសុទ្ធតែមានព្រលឹងនិងមានកម្លាំងសក្តិសិទ្ធិដែលយើងមើលពុំឃើញ ។ គេបានយកដុំថ្មជាតំណាងកម្លាំងធម្មជាតិដែលគេគោរព ហើយគេហៅដុំថ្មនោះថា អ្នកតាដូចជាអ្នកតាទឹក អ្នកតាដី អ្នកតាភ្លើង អ្នកតាខ្យល់ អ្នកតាព្រៃភ្នំជាដើម ។ ក្រៅពីអ្នកតាតំណាងធម្មជាតិ មានអ្នកតាតំណាងមេបា រឺបុព្វបុរសដែលបានស្លាប់ទៅហើយ ហើយនៅចាំថែរក្សានិងផ្តល់សេចក្តីសុខដល់អ្នកស្រុក



ដូចជាអ្នកតាដំបងដែក អ្នកតាក្រហមក អ្នកតាជំទាវម៉ៅ អ្នកតាយាយម៉ៅ ។ល។ សាសនាអ្នកតានិយមនេះពុំសូវល្អតលាស់ ព្រោះពុំមានអត្ថបទ (គម្ពីរ) ដែលកត់ត្រាទស្សនៈ ទ្រឹស្តី ដូចជាសាសនាដទៃទៀតឡើយ ។ ទោះបីគ្មានការចំរើនល្អតលាស់ក៏ដោយ ក៏សាសនាបែបនេះនៅតែរស់បន្តក្នុងចិត្តគំនិត និងក្នុងទំនាមទំលាប់ខ្មែររហូតមកដល់សព្វថ្ងៃនេះដែរ ។

លុះក្រោយមក នៅដើមគ្រិស្តសករាជ ទើបខ្មែរចាប់ផ្តើមទទួលឥទ្ធិពលសាសនាឥណ្ឌាធំៗពីរគឺព្រាហ្មណ៍សាសនានិងពុទ្ធសាសនា ។

តើសាសនាទាំងពីរនេះមានជំនឿសំខាន់ៗអ្វីខ្លះ ?

*

* *

# ១-ព្រាហ្មណ៍សាសនា

កាលដើមឡើយគេហៅ ព្រាហ្មណ៍សាសនា ថា ព្រហ្មញ្ញសាសនា ដែលសំគាល់ថា "សាសនារបស់ព្រះព្រហ្ម" រឺ «សាសនាតមកអំពីព្រះព្រហ្ម» ។ ពួកព្រាហ្មណ៍ដែលប្រកាន់ខ្លួនថាជាបុត្រព្រះព្រហ្មកាន់កាប់ ប្រតិបត្តិសាសនានេះ ទើបហៅថា «សាសនាព្រាហ្មណ៍»(2) ។

ព្រាហ្មណ៍សាសនា ទំនងជាបានផ្សាយចូលមកដល់ប្រទេសខ្មែរយើងមុនពុទ្ធសាសនា តាមរយៈពួកឈ្មួញឥណ្ឌាដែលធ្វើដំណើរតាមសំពៅមកទាក់ទងលក់ដូរជាមួយអ្នកស្រុក ។ ដោយពួកឈ្មួញទាំងនោះច្រើនតែជាអ្នកចេះដឹងខាងព្រាហ្មណ៍សាសនាផង ហើយដោយមានឈ្មួញខ្លះបានទាំងរៀបការជាមួយស្រីខ្មែរផង ម្ល៉ោះហើយឥទ្ធិពលសាសនាព្រាហ្មណ៍ ក៏បានជ្រួតជ្រាបយ៉ាងខ្លាំងទៅលើជនជាតិខ្មែរយើង ។

ម្យ៉ាងទៀត យើងបានដឹងតាមប្រវត្តិសាស្ត្រថា កាលណោះប្រទេសខ្មែរយើងគ្រប់គ្រងដោយព្រះនាង លីវ យី ហើយមានស្តេចឥណ្ឌាព្រះនាមហ៊ុន ទៀន បានលើកទ័ពមកច្បាំងដណ្តើមយកទឹកដីខ្មែរ ។ ក្រោយដែលមានជ័យជំនះលើព្រះនាង លីវ យី ព្រះបាទ ហ៊ុន ទៀន ក៏បានរៀបអភិសេកក្សត្រីអង្គនេះជាអគ្គមហេសី ហើយបានប្រកាសតាំងខ្លួនជាស្តេចព្រមទាំងបានរៀបចំទឹកដីខ្មែរតាមទស្សនៈពួកឥណ្ឌា (បែបព្រាហ្មណ៍) ថែមទៀត ។ ម្ល៉ោះហើយលទ្ធិព្រាហ្មណ៍ក៏រីកដុះដាលឡើងជាលំដាប់ ។

ព្រាហ្មណ៍សាសនានេះចែកជា ៣ **សម័យធំៗ គឺ :**

១- សម័យវេទនិយម (១៥០០ ឆ្នាំដល់ ៥៥០ ឆ្នាំ មុន គ.ស.)

២- សម័យព្រាហ្មណ៍និយម (៥៥០ ឆ្នាំមុន គ.ស. ដល់ ស.វ. ទី១០ នៃ គ.ស.)

៣- សម័យហិណ្ឌូនិយម (ស.វ. ទី ១០ រហូតមក) ។

តាមការស្រាវជ្រាវខាងប្រវត្តិសាស្ត្រគេបានដឹងថា សាសនា



ព្រាហ្មណ៍នេះត្រូវបាននាំចូលប្រទេសឥណ្ឌាដោយពួក អារ្យ ( Arya ) រឺ អារ្យ៉ែន (Aryan) ។ កាលពីដើម ជនជាតិអារ្យបានរស់នៅ Oxus ក្នុងភូមិភាគ Caucase និង ខ្ពង់រាបនៃ Pamir ដែលគេទុកជាដំបូលពិភពលោក នៅតាមឆ្នេរសមុទ្ទ Caspienne និងឆ្នេរសមុទ្រ Aral ។ ភូមិភាគទាំងនេះជាលំនៅឋាននៃសាខាមួយធំនៃមនុស្សបុរាណហៅ អារ្យ នេះឯង ។ បន្ទាប់មកពួកអារ្យបានចូលលុកលុយប្រទេសអឺរ៉ុបមួយផ្នែក ហើយមួយផ្នែកទៀតចូលលុកលុយប្រទេសឥណ្ឌាភាគខាងជើងប្រមាណជា១៥០០ ឆ្នាំមុន គ.ស. ។ ដូចនេះហើយ ទើបគេចាត់ទុកពួកអារ្យជាបុព្វបុរសនៃអំបូរឥណ្ឌូ-អឺរ៉ុប ។ នៅប្រទេសឥណ្ឌា ពួកទ្រាវិឌ ( Dravidiens ) ដែលជាម្ចាស់ស្រុកបានខិតខំច្បាំងណាស់ដែរ ប៉ុន្តែពុំអាចយកជ័យជំនះបាន ដោយសារពួកអារ្យមានគ្រឿងចម្បាំងជំនាញ ៗ ជាង ដូចជារថចម្បាំងទឹមដោយសេះមួយ រឺសេះពីរ រឺសេះច្រើនជាដើម ។ ពួកអារ្យក៏ចូលមកគ្រប់គ្រងពួកទ្រាវិឌ ហើយក៏បានចាប់ផ្សាយលទ្ធិសាសនាតែនៃពីពេលនោះមក(3) ។ ឯពួកព្រាហ្មណ៍ដែលមានភារៈថែរក្សានិងផ្សាយលទ្ធិសាសនានេះក៏បានរៀបចំកែខផ្លាស់ប្តូរទស្សនៈទ្រឹស្តី អោយកាន់តែប្រសើរឡើងតាមការនិយមរាប់អានក្នុងសម័យនីមួយៗថែមទៀត ។

ក- ព្រហ្មញ្ញ (Brahman) .-

នៅសម័យវេទនិយម ក្នុងទ្រឹស្តីបង្កើតលោកគេនិយមថា លោកកើតឡើងដោយសារអាទិទេព ។ ឯអាទិទេពធំៗបង្កើតលោកនោះ មាន

ឈ្មោះដូចតទៅនេះ :

– **បុរុស:** (តាមជំនឿនៅសម័យសំហិតា ; ១៥០០ ឆ្នាំមុន គ.ស.)

– **ប្រជាបតិ** (តាមជំនឿនៅសម័យព្រាហ្មណ: : ៧៥០ ឆ្នាំមុន គ.ស.)

– **ព្រហ្ម** (តាមជំនឿនៅសម័យឧបនិស័ទ : ៥៥០ ឆ្នាំមុន គ.ស.) ។

នៅសម័យឧបនិស័ទ គឺសម័យចុងវេទ គេចាប់ផ្តើមជឿទៅលើព្រះព្រហ្ម (Brahma) ថាជាអាទិទេពសាងលោក (សម័យដើមវេទព្រះព្រហ្មគ្រាន់តែជាទេវៈរាយរងប៉ុនោះ) ។ ជំនឿនេះរឹតតែមានតំលៃឡើងក្នុងសម័យព្រាហ្មណ៍និយម ដែលគេនិយមលើកតំកើងព្រះព្រហ្មជាអាទិទេពធំមួយរូបដែរ ហើយមានមុខងារជាអ្នកបង្កើតភាវៈទាំងឡាយមានលោកៈ ទឹក ដី ភ្លើង ខ្យល់ មនុស្ស សត្វ ធម្មជាតិជាដើម ។ ប៉ុន្តែការបង្កើតរបស់ព្រះព្រហ្មពុំមែនជាការដប់អោយកើតឡើងតែម្តងទេ គឺភាវៈទាំងឡាយកើតឡើងដោយធាតុល្អិតល្អន់បរិសុទ្ធរបស់ព្រះព្រហ្ម ដែលហៅថា **ព្រហ្មន** ។ ដូចនេះ នៅក្នុងព្រាហ្មណ៍សាសនា គេនិយមប្រើពាក្យ **ព្រហ្ម** សំគាល់អាទិទេព ឯពាក្យ **ព្រហ្មន**សំគាល់សភាវៈដើម (substance primordiale) នៃលោកៈ រឺសំគាល់សភាវៈដែលជាប្រភពកំណើតនៃភាវៈទូទៅទាំងអស់ ។ តាមគម្ពីរឧបនិស័ទ (គម្ពីរកើតចុងសម័យវេទនិយម ) ព្រហ្មនសំគាល់នូវព្រលឹងសាកល (âme universelle) រឺមេព្រលឹង ។ នៅក្នុងព្រលឹងធំនេះ មានព្រលឹងតូចៗល្អិតនៅរួមជាមួយហៅថា **អាត្មន** (âme individuelle) ។



## ២_ អាត្មន ( Atman ).–

តាមន័យដើម ពាក្យ **អាត្មន** (សំស្ក្រឹត) ត្រូវគ្នានឹងពាក្យ **អត្ត** **អាត្មា** (បាលី) សំគាល់ថាខ្លួន ។ លទ្ធិសាសនាព្រាហ្មណ៍និយមប្រើពាក្យ **អាត្មន** នេះសំគាល់ឯកធាតុពិសេស ដែលបែកចេញពីព្រហ្មនទៅបង្កើតភាវៈឯទៀតៗ ។ ធាតុព្រហ្មននិងធាតុអាត្មនជាធាតុតែមួយដូចគ្នា (ឯកសភាវៈ) ប្រៀបដូចទឹកសមុទ្រ ទឹកភ្លៀង ទឹកសន្សើម ទឹកស្ទឹង ទឹកទន្លេជាដើម គឺជាធាតុទឹកតែមួយ ។ ទឹកទាំងឡាយដែលបែកចេញពីទឹកមហាសមុទ្រ មិនឆាយនឹងបានត្រឡប់ទៅកាន់មហាសមុទ្រវិញបានភ្លាមទេ ព្រោះទឹកទាំងនោះត្រូវវិលវល់ជ្រាបចូលក្នុងដី រឺត្រូវយកទៅប្រើប្រាស់ ប៉ុន្តែទីបំផុតត្រូវបានទៅកាន់មហាសមុទ្រវិញ ក្រោយដែលបានវិលវល់អស់ពេលដ៏យូរ(3)។ យ៉ាងណាមិញក្នុងការបង្កើតភាវៈ មនុស្សរឺសត្វ អាត្មនដែលបានដាច់ចេញពីព្រហ្មនហើយ បានទៅសណ្ឋិតក្នុងរូបកាយមនុស្ស រឺសត្វនោះដែលកើតឡើងដោយផ្តុំផ្សំធាតុទឹក-ដី-ភ្លើង-ខ្យល់ ។ ពេលនោះ **កម្មន**ដែលជាអំពើ រឺកម្លាំងម្យ៉ាងក៏កើតមានឡើងដែរ ។ ឯមនុស្សរឺសត្វក៏ចាប់មានជីវិតមានចលនា ហើយក៏ត្រូវស្លាប់ទៅវិញនៅទីបំផុត ។ នៅពេលស្លាប់រូបកាយត្រូវវិនាសទៅវិញ ឯអាត្មនពុំស្លាប់ទេ ហើយចេញពីរូបកាយនោះដោយមានកម្លាំងកម្មនរុញច្រាន អោយទៅចូលក្នុងរូបកាយណាថ្មីទៀតយ៉ាងនេះរៀងរាបទៅតាមអំពើដែលបានកសាងពីមុនមក ។ ការវិលវល់

ចេញពីរូបមួយចូលទៅរូបមួយទៀតមិនចេះអស់ មិនចេះហើយនេះហើយហៅថា **សំសារៈ** ។ ដូចនេះ ឧបសគ្គដែលនាំអោយអាត្ម័នពុំឆាយបានវិលទៅជួបព្រហ្ម័នវិញគឺ **កម៌ន** នេះឯង ។

## គ - កម៌ន (Karman) . –

តាមន័យដើម ពាក្យ **កម៌ន** (សំស្រ្កឹត) ត្រូវគ្នានឹងពាក្យ **កម្ម** (បាលី) សំគាល់ថាអំពើល្អ ឬអាក្រក់ តាមផ្លូវកាយក្តី ចិត្តក្តី វាចាក្តី ។ កម៌នក្នុងសាសនាព្រាហ្មណ៍ សំគាល់ន័យច្រើនបែបយ៉ាងទៀត

– កម៌នសំគាល់បុព្វហេតុនៃការកើត-ស្លាប់ ព្រោះការកើត-ស្លាប់ជាអំពើដែលបន្តគ្នាក្នុងការបង្កើតភាវៈគ្រប់បែបយ៉ាង ។ គេនិយមថាអាទិទេពជាអ្នកផ្តើមបង្កើតពិតមែនហើយ ក៏ប៉ុន្តែតមកទៀតភាវៈទាំងនោះ ត្រូវប្រព្រឹត្តទៅតាមអានុភាពនៃកម៌ននេះឯង ។

– **កម៌នសំគាល់ទំនាក់ទំនងរវាងអំពើនិងផល** ។ អំពើដែលបានសាងមិនសាបសូន្យទេ តែងទាក់ទងគ្នាជានិច្ច ទោះក្នុងបច្ចុប្បន្នជាតិក្តី ។ ក្នុងន័យនេះហើយ ដែលខ្មែរយើងប្រើពាក្យ **កម្មផល** ។

– កម៌នសំគាល់ការផ្តល់ផលដែលជាវេន្ទាន់ ឬជាទោសពុំអាចហាមឃាត់បាន (ដូចព្រេងវាសនា) ។

## សេចក្តីសន្និដ្ឋាន. –



គេតែងនិយមចាត់ទុកកម៌នជាកម្លាំងម៉្យាង រុញច្រានអាត្ម័នអោយដាច់ចេញពីព្រហ្ម័ន បន្ទាប់មករុញច្រានអាត្ម័នអោយវិលវល់ក្នុងសំសារៈ ដែលធ្វើអោយអាត្ម័នជួបប្រទះនឹងសេចក្តីទុក្ខគ្រប់បែបយ៉ាង ។ បើចង់បានសេចក្តីសុខ ជាពិសេសសំរេចនូវបរមសុខ ( មោក្ស ) លុះត្រាតែអាត្ម័នអស់កម៌ន ទើបលែងវិលវល់ក្នុងការកើត-ស្លាប់ទៀត ហើយអោយទៅភ្ជាប់ខ្លួនជាមួយព្រហ្ម័នវិញ ។ ពេលនោះអាត្ម័នបានសុខរហូតឈប់មកកើតជាថ្មីទៀតហើយ ។ ដូចនេះ កម៌នហាក់ដូចជាសំគាល់សភាវៈអាក្រក់ទៅវិញ ។ ក្នុងន័យនេះហើយដែលខ្មែរយើងប្រើពាក្យ **កម្ម** ថាជាអំពើបាប ផលបាបដែលអាក្រក់ ដូចក្នុងឃ្លាថា: « ជាតិនេះខ្ញុំវេទកម្មក្រាស់ណាស់ » ។

## យោបល់រួម. –

គេចាត់ទុកជំនឿទៅលើ **ព្រហ្ម័ន-អាត្ម័ន-កម៌ន** ជាទ្រឹស្តីដ៏សំខាន់ចំពោះលទ្ធិសាសនាព្រាហ្មណ៍ ក្នុងការអធិប្បាយពន្យល់អំពីកំណកំណើតនិងការវិលកើតស្លាប់នៃសត្វលោក ហើយជាចំណងចងភ្ជាប់មនុស្សអោយមានជំនឿជ្រះមុតទៅលើអាទិទេពនេះឯង ។ តើការនិយមគោរពទេវៈអាទិទេពនៅក្នុងសម័យនិមួយ ៗ មានលក្ខណៈប្លែកគ្នាយ៉ាងដូចម្តេចខ្លះ ?

## ឃ - ទស្សនៈគោរពទេវៈ . –

កាលដើមឡើយ ជនជាតិដើមឥណ្ឌាមិនទាន់គោរពទេវៈទេ គឺ

គោរពនិងជឿទៅលើកម្លាំងធម្មជាតិ ( animisme ) ដូចបុព្វបុរសខ្មែរយើងដែរ ។ លុះក្រោយមកពួកអារ្យដែលមានជំនឿលើទេវៈបានផ្សាយឥទ្ធិពលនេះមកលើជនជាតិដើមឥណ្ឌា ។ ដូចនេះហើយទើបមានការគោរពទេវៈនៃជនជាតិឥណ្ឌាតាំងពីសម័យវេទនិយមមក ។ ឯទេវៈនីមួយ ៗ ក្នុងសម័យនោះមានមុខងារជាតំណាង រឺជាអ្នកបង្កើតធម្មជាតិនេះឯង ។ គេតែងនិយមថាពួកទេវៈ ស្ថិតនៅឯស្ថានទេវលោក (ស្ថានសួគ៌) ។ ប៉ុន្តែទេវៈខ្លះស្ថិតនៅលើកំពូលភ្នំ ក្នុងអាកាស ក្នុងទឹក លើដី ជាដើម ។ ឯការរស់នៅក្នុងទីកន្លែងខុសគ្នាបែបនេះ ក៏អាស្រ័យទៅលើមុខងារ ខ្ពស់ ទាប លក្ខណៈល្អអាក្រក់របស់ទេវៈនោះឯង ។ តើទេវៈទាំងនោះ មានឈ្មោះនិងមុខងារអ្វីខ្លះ ?

## ទេវៈសំខាន់ៗ.–

–ព្រះឥន្ទ្រ ជាទេវៈតំណាងផ្គរ-រន្ទះ ។ នៅដើមសម័យវេទ ពួកអារ្យបានលើកតំកើងព្រះឥន្ទ្រជាអាទិទេព (ទេវៈដើមគេ ធំជាងគេ) ប្រក្តិតលោកមានឋានៈនិងអំណាចខ្ពង់ខ្ពស់ណាស់ ។ លុះក្រោយមក (ចុងសម័យវេទ) គេលែងគោរពព្រះឥន្ទ្រជាទេវៈធំទៀតហើយ ព្រោះព្រះឥន្ទ្រមានគុណវិបត្តិ ។ គម្ពីរខ្លះបានចែងថា ព្រះឥន្ទ្រច្បាំងចាញ់គេញឹកញាប់ ចូលចិត្តសេពសុរា ឈ្មោភកាមគុណ (មានទេវៈស្រីអមច្រើនរយពាន់ ហើយព្រមទាំងបានលួចប្រពន្ធឫសីទៀតផង) ។



– ព្រះអគ្និ រឺ អគ្គី ជាតំណាងភ្លើង ជាសាក្សីនៃអំពើល្អរបស់មនុស្ស ។

– ព្រះវរុណ ជា ទេវៈបង្កើតភ្លៀងនិងទឹក ជាអ្នកចាំឃ្លាំមើលសេចក្តីល្អ-អាក្រក់របស់មនុស្សលោក ។ កាលណាគ្មានទឹកធ្វើស្រែចំការ អ្នកដែលមានជំនឿទៅលើព្រះវរុណ តែងនិយមបន់ស្រន់បួងសួងសុំទឹកភ្លៀងអំពីទេវៈនេះ ។

– ព្រះសូរ្យ ជាទេវៈបង្កើតកំដៅនិងពន្លឺ ជាចៅក្រមកាត់សេចក្តីអោយមនុស្សលោក ។

– ព្រះចន្ទ័ ជាទេវៈតំណាងសោភ័ណភាព ព្រោះមានរូបឆោមលោមពណ៌ល្អ ហើយជាអ្នកថែរក្សារុក្ខជាតិ ។ គេថាព្រះចន្ទ្រកើតពីទឹកសោម (ស្រាសោមដែលគេថ្វាយព្រះឥន្ទ្រ) ដូចនេះហើយបានជាមានឈ្មោះម្យ៉ាងទៀតជាព្រះសោម ។

– ព្រះយម ជាទេវៈ តំណាងមរណភាព ជាអ្នកធ្វើទោសមនុស្សដែលស្លាប់ទៅហើយដែលបានប្រព្រឹត្តអាក្រក់កាលនៅរស់ ។

– ព្រះវាយុ ជាទេវៈ បង្កើតខ្យល់ ជាអ្នកតំណាងកម្លាំងនិងល្បឿន ។

ក្រៅពីទេវៈទាំងនេះ នៅមានទេវៈច្រើនទៀតដែលពុំមានមុខងារច្បាស់លាស់ ។ ដូចនេះនៅក្នុងសម័យវេទនិយម គេនិយមគោរពរាប់អានទេវៈច្រើនអង្គ ។ ទស្សនៈ ដែលនិយមថាមានទេវៈច្រើនអង្គបែបនេះមានឈ្មោះហៅថា ទស្សនៈពហុទេវនិយម (Polythéisme) ។ លុះមកដល់ចុងសម័យវេទនិយម ទស្សនៈពហុទេវនិយមមានទំនោរ

(tendance) ទៅរកទស្សនៈគោរពអាទិទេពតែមួយអង្គវិញ ដែលមានឈ្មោះ ហៅថា ទស្សនៈឯកទេវនិយម (Monothéisme) គឺគេនិយមបង្រួមទេវៈច្រើនអង្គអោយនៅសល់តែមួយអង្គ ដែលចាត់ទុកជាអាទិទេពដើមបង្អស់ ហើយដែលបង្កើតទេវៈឯទៀតៗនិងអ្វីទាំងអស់ក្នុងលោក ។ ឯទេវៈដទៃទៀត នៅតែមានឈ្មោះដដែល គ្រាន់តែមានលក្ខណៈអន់ថយ ។ ឯអាទិទេពដែលពួកព្រាហ្មណ៍ចង់លើកតំកើងជាអាទិទេពធំ ជាអ្នកបង្កើតលោកនោះ គឺព្រះព្រហ្មនេះឯង ដូចមានអធិប្បាយក្នុងគម្ពីរឧបនិស័ទអំពីការជ្រើសរើសយកព្រះព្រហ្មជាអាទិទេពសាងលោក និងព្រហ្មន៍ជាសភាវៈដើម ។ នៅក្នុងទស្សនវិជ្ជាឥណ្ឌា មានទស្សនៈមិមំសា និងទស្សនៈវេទន្តក៏ចែងថាព្រះព្រហ្មជាអាទិទេពធំដែលបង្កើតទេវៈនិងសភាវៈឯទៀតៗដែរ ។ ចំណែកឯទស្សនៈ វៃសេសិកៈ-ន្យាយៈ-យោគៈ បានលើកតំកើងឥស្វរៈជាអាទិទេពធំជាងគេ ហើយគេថាឥស្វរៈនេះបានបែងភាគជាអាទិទេព ៣ ទៀតគឺ ព្រហ្ម វិស្ណុ សិវៈ ដែលបង្កើតបានជាទស្សនៈមួយឈ្មោះទស្សនៈត្រីមូរ្តិ(Trinité) ។ ពិតមែនតែមានទំនោរទស្សនៈឯកទេវនិយម (ឥស្វរៈ ជាអាទិទេពដើមគេបង្អស់) ក៏ដោយ ក៏នៅតែមានទំនាក់ទំនងទៅនឹងទស្សនៈពហុទេវនិយមថែមទៀត បានសេចក្តីថាអាទិទេព ៣ អង្គ ( ព្រហ្ម វិស្ណុ សិវៈ ) ស្ថិតនៅជាពហុភាព (Pluralité) ហើយមានឯកភាព ( Unité ) ទាក់ទងនៅនឹងអាទិទេពធំតែមួយគឺ ឥស្វរៈ ។ ដូចនេះឯកភាពទេវៈ ក្នុងសាសនាព្រាហ្មណ៍ជា



ឯកភាពនៅក្នុងពហុភាព ។

ទស្សនៈត្រីមូរ្តិនេះត្រូវបានគេនិយមរាប់អានតាំងពីសម័យព្រាហ្មណ៍និយមមកហើយរឹតតែមានតម្លៃខ្លាំងទៅទៀត នៅក្នុងសម័យហិណ្ឌូនិយម។

កាលដើមឡើយ អាទិទេពធំៗទាំងនោះពុំទាន់មានរូបរាងទេ គឺមានតែឈ្មោះ ។ លុះក្រោយមក ទើបមានរូបរាងជាតួអង្គដូចមនុស្ស មានតណ្ហា មានប្រពន្ធ មានកូន មានកេតនភ័ណ្ឌ (គ្រឿងសំគាល់ជាប់នឹងខ្លួន) មានយានជំនិះ ។ល។ អ្នកប្រាជ្ញខ្លះបានពិចារណាថា រឿងទេវៈដែលដូចគ្នានឹងរឿងមនុស្ស ក៏ដោយហេតុតែទស្សនៈទេវនិយម បានជាប់ប្រភពក្នុងមតិនិយមរបស់មនុស្សនេះឯង ។ គឺជាវិធី"ឪម៉ែកើតក្រោយកូន" ឬ"កូនកើតមុនឪម៉ែ" ព្រោះអាទិទេពជាអ្នកសាងលោកតែងតែកើតឡើងខាងក្រោយអ្នកដែលសាងខ្លួន (3) ។ ការធ្វើអោយអង្គអាទិទេពមានរូបជាការងាយស្រួលដល់ការគោរពនៃពួកសាសនិក ។ ចំពោះអាទិទេពព្រហ្ម វិស្ណុ សិវៈ ក្នុងសម័យព្រាហ្មណ៍និយម ក៏ដូចជាក្នុងសម័យហិណ្ឌូនិយម សុទ្ធតែបានទទួលការនិយមគោរពរាប់អានផ្សេងៗគ្នា ទៅតាមកន្លែងនិងតាមការចូលចិត្តរបស់បណ្តាជន ។ អ្នកដែលស្រលាញ់និងគោរពអាទិទេពអង្គណា តែងលើកតំកើងអាទិទេពអង្គនោះជា ជាអាទិទេពខ្ពង់ខ្ពស់ជាងគេ ។

## អាទិទេពក្នុងទស្សនៈត្រីមូរ្តិ : ព្រហ្ម វិស្ណុ សិវៈ

* **ព្រះព្រហ្ម** (Brahma). –

ព្រះព្រហ្មជាអាទិទេពគឺបង្កើតលោក(le créateur du monde) ប្រៀបបានទៅនឹងវិស្វករ រឺអ្នកស្ថាបនា ។ កាលដើមឡើយព្រះព្រហ្មជាសភាវៈធម៌គ្មានរូប គ្មានប្រពន្ធ គ្មានកូន ដូចមនុស្សលោកទេ ។ សភាវៈធម៌នោះមានលក្ខណៈស្អាតស្អំបរិសុទ្ធ ឥតជាប់ជំពាក់នឹងគ្រឿងសៅហ្មងផ្សេង ៗ ឡើយ ។ លុះក្រោយមកទើបគេបង្កើតអោយមានរូបរាងឡើងតាមការនិយមរាប់អាននៃប្រជាជន ហើយគេបានបញ្ជាក់ថា ព្រះព្រហ្មមានព្រះភក្ត្រ ៤ អាចក្រឡេកមើលទិសទាំង ៤ ក្នុងខណៈព្រមគ្នាបាន ។

មានគម្ពីរព្រាហ្មណ៍មួយ បានថ្លែងអំពីដើមកំណើតរបស់ព្រះព្រហ្ម ។ គេថាដំបូងបង្អស់ភាវៈគ្រប់យ៉ាងមានរួចស្រេចទៅហើយ ប៉ុន្តែជាសភាវៈឥតរូប ។ សភាវៈទាំងឡាយនោះបានផ្តុំផ្សំគ្នាឡើង ហើយក៏កើតជាស៊ុតមាសមួយយ៉ាងធំសម្បើមអណ្តែតនៅលើអាកាសអស់មួយម៉ឺនកល្ប ។ តមកស៊ុតនោះក៏បែកធ្លាយទៅ ព្រះព្រហ្មដែលស្ថិតនៅក្នុងស៊ុតមាសនោះបណ្តាលអោយបែកជាពីរចំហៀងៈ ផ្នែកលើកើតបានជាមេឃ (ទេវលោក) ឯផ្នែកក្រោមកើតបានជាផែនដី (មនុស្សលោក) ហើយព្រះព្រហ្មបានសាងអ្វី ៗ គ្រប់យ៉ាងទាំងក្នុងស្ថានទេវលោក ទាំងក្នុងស្ថានមនុស្សលោក ។

នៅក្នុងស្ថានមនុស្សលោក ព្រះព្រហ្មបានសាងភ្លើងឡើងដំបូងបង្អស់សំរាប់បំផ្លាញបាបអោយអស់ ហើយបានសាងទឹកសំរាប់រំលត់ភ្លើង តមក



ទើបបង្កើតអោយមាន ភ្នំ ជ្រោះ អូរ ស្ទឹង ទន្លេ សមុទ្រ បន្ទាប់មកទៀតមានរុក្ខជាតិ សត្វនានានិងមនុស្ស (3) ។

ទោះបីព្រះព្រហ្មបានចាប់កំណើតឡើងដោយលក្ខណៈណាក៏ដោយ (បែងភាគពីឥស្វរៈ រឺកើតចេញពីស៊ុតមាស) ការបង្កើតអោយមានព្រះព្រហ្មឡើងនេះជាគោលគំនិតមួយគាប់ប្រសើរណាស់របស់ពួកព្រាហ្មណ៍ ព្រោះមានកើតលទ្ធិសំខាន់ ៗ ដូចជា (3) :

– **លទ្ធិព្រហ្មចារ្យ** រឺ ព្រហ្មចារី ជាលទ្ធិសំរាប់ពួកព្រាហ្មណ៍ប្រព្រឹត្តធ្វើចិត្តអោយស្អាតបរិសុទ្ធដូចព្រះព្រហ្មដែរ ។ ដើម្បីសំរេចគោលបំណងនេះ ពួកព្រាហ្មណ៍បានលះបង់ទ្រព្យសម្បត្តិ ប្រពន្ធកូនទៅបួសជាសមណៈព្រាហ្មណ៍នៅក្នុងព្រៃស្ងាត់ ។

– **លទ្ធិអាត្ម័ន** ជាលទ្ធិសំរាប់អប់រំមនុស្សអោយចេះសំអិតសំអាងអាត្ម័នអោយបានស្អាតបរិសុទ្ធ ជូរផង់ ប្រាសចាកគ្រឿងសៅហ្មងទាំងឡាយដើម្បីបានទៅជួបព្រហ្មំវិញ ទើបបានសំរេចនូវបរមសុខ ។ ប្រយោជន៍នៃលទ្ធិអាត្ម័នគឺធ្វើអោយមនុស្សស្គាល់ខ្លួនឯង ពីខ្លួនឯង ចេះទទួលខុសត្រូវខ្លួនឯង ព្រោះខ្លួនឯងនេះហើយជាព្រះព្រហ្ម អំពើខ្លួនឯងនេះហើយជាអំពើរបស់ព្រះព្រហ្ម ។

– **លទ្ធិឧបនិស័ទ** ជាលទ្ធិដែលអធិប្បាយអំពីគោលនៃលទ្ធិព្រហ្មនិងលទ្ធិអាត្ម័ន ។ គោលសំខាន់ក្នុងលទ្ធិឧបនិស័ទ គឺការស្វែងរកវិធីដែលនឹងធ្វើឲ្យព្រលឹង (អាត្ម័ន) របស់មនុស្សវិលត្រឡប់ចូលទៅកាន់ព្រហ្មំ

ព្រហ្មទេវិញតែប៉ុណ្ណោះ ។ វិធីសំខាន់មានពីរប្រការ គឺ វិធីធ្វើ តបៈ និង វិធីធ្វើ យោគៈ ។ ធ្វើតបៈនៅដើមសម័យវេទនិយម គឺព្យាយាម បន់ស្រន់បួងសួងអាទិទេពអោយអាទិទេពអាណិត ពេញចិត្តនឹងជួយឲ្យបានសំរេចតាមសំណូមពរ ។ នៅចុងសម័យវេទនិយម តបៈគឺធ្វើអោយអាទិទេពក្តៅក្រហាយពុំបាននឹងចុះមកជួយ ។ លុះមកដល់សម័យព្រាហ្មណ៍និយម តបៈមានន័យប្រែប្រួលទៀតគឺធ្វើអោយក្តៅខ្លួនឯងវិញ បានសេចក្តីថា តបវិធីគឺវិធីអប់រំទូន្មានកាយអោយវេទនាដោយប្រការផ្សេងៗ ដូចជាឈរហាលថ្ងៃ ដេកលើបន្លាដែកគោល អត់អាហារជាដើម ។ ដោយយល់ឃើញថា តបវិធីពុំសូវមានប្រសិទ្ធិភាព ទើបគេបង្កើតយោគវិធីនេះឡើង ។ យោគវិធីគឺជាវិធីអប់រំទូន្មានចិត្តអោយនឹងនរ អោយស្អាតបរិសុទ្ធ អាចស្គាល់ខុសត្រូវដោយគេអនុវត្តនូវវិធីហាត់ដកដង្ហើមចេញចូលអោយបានស្រួល ធ្វើសមាធិជាដើម ។

* ព្រះវិស្ណុ (visnu).—

ព្រះវិស្ណុជាអាទិទេពគ្រប់គ្រងថែរក្សាលោក (le conservateur du monde) អោយបានគង់វង់សុខសាន្ត និងមានរបៀបរៀបរយ ។ ព្រះវិស្ណុមានឈ្មោះជាច្រើនទៀតគឺ : នារាយណ៍ (និយមហៅនៅស្រុកខ្មែរ) ភគវន្ត ហរិ អនន្ត ។ គម្ពីរខ្លះនិយាយថា ព្រះវិស្ណុមានកំណើតពីដំណក់ញើសថ្ងាសរបស់ព្រះព្រហ្មក្នុងពេលព្រះព្រហ្មកំពុងបំពេញតបៈ ។

ក្នុងមុខងារជាអ្នកគ្រប់គ្រងថែរក្សាលោក ព្រះវិស្ណុបែងភាគជា



អវតារ ចុះមកកើតក្នុងស្ថានមនុស្សលោក ហើយផ្ចាញ់ រឺបង្ក្រាបសភាវៈអាក្រក់ ដែលតែងតែបៀតបៀនបំផ្លិចបំផ្លាញសេចក្តីសុខរបស់មនុស្សលោក រឺធ្វើអោយខូចរបៀបរៀបរយដែលព្រះព្រហ្មបានតាក់តែងមក ។ តើអវតារព្រះវិស្ណុមានប្រភេទនិងមុខងារជាអ្វីខ្លះ ?

## អវតារវិស្ណុ.—

១-មត្ស្យ រឺ មច្ឆា អវតារជាត្រី ជួយស្រោចស្រង់មនុស្សលោកអោយរួចពីទឹកជំនន់ ដែលបង្កើតឡើងដោយយក្សឈ្មោះ ហយគ្រីវៈ ។

២-កូម៌ ជាអណ្តើក ជួយធ្វើកំណល់ទ្រភ្នំមន្ទរ នៅពេលដែលយក្សនិងទេវៈទាញនាគវាសុកៈដែលព័ទ្ធជុំវិញភ្នំ ដើម្បីបង្វិលកូរសមុទ្រទឹកដោះអោយរីង ក្នុងគោលបំណងយកទឹកអម្រឹតនិងវត្ថុស័ក្តិសិទ្ធិផ្សេងៗ ។

៣-វរាហ ជាជ្រូកព្រៃ ជួយមនុស្សអោយផុតអំពីការបៀតបៀនរបស់យក្សហិរណ្យយក្សដែលប្រាថ្នារំលាយលោកអោយទៅជាទឹកសមុទ្រ ។

៤-នរសិង្ហ ជាមនុស្សមានក្បាលជាសិង្ហ បានសំលាប់យក្សដែលជាប្អូនហិរណ្យយក្ស ព្រោះយក្សនេះបានដើររាតត្បាតទេវៈនិងមនុស្សតាមអំពើចិត្ត ។

៥-វាមន ជាមនុស្សតឿ បានបោកបញ្ឆោតយក្សពលិយកដែនដីបានវិញដោយឈានតែ ៣ ជំហានអោយផុតដែនដី

៦-បរសុរាម ជាមនុស្សកាន់ពូថៅដែលជាអំណោយព្រះសិវៈ បានជួយស្រោចស្រង់មនុស្សអោយផុតពីស្តេចកំណាចឈ្មោះកាតិវីរ្យ ដែលសង្កត់

សន្តិនមនុស្សឯទៀត ។

៧- រាម ជាព្រះរាមក្នុងរឿងរាមាយណៈ ជួយបង្ក្រាបពួកយក្សដែលបៀតបៀនមនុស្សល្អត្រង់និងអ្នកកាន់សាសនាព្រាហ្មណ៍ ។

៨- ក្រិស្ណ ជាមនុស្សខ្មៅ ជួយស្រោចស្រង់ជីវិតពួកគង្វាលគោអោយរួចផុតពីគ្រោះថ្នាក់ដោយរន្ទះបាញ់ ដោយលើកភ្នំគោវិធនធ្វើជាឆត្របាំងការពារ ។ ក្រិស្ណជាតួឯកនៅក្នុងរឿងមហាភារតៈបានសម្លាប់ឪពុកមាឈ្មោះកម្សៈ ដែលបានក្បត់ដណ្តើមរាជសម្បត្តិ ។

៩- កល្កិន ជាមនុស្សដែលមានក្បាលសេះ ជាអវតារទៅអនាគតនឹងចុះមកជួយកាត់ទោសមនុស្សប្រព្រឹត្តអាក្រក់ហើយផ្តល់រង្វាន់ដល់មនុស្សកសាងល្អ និងរៀបចំយុគថ្មីមួយអោយបានរុងរឿង ។

គម្ពីរខ្លះបាននិយាយថា ព្រះពុទ្ធសមណគោតម ក៏ជាអវតារព្រះវិស្ណុដែរ មានតួនាទីជាអ្នកជួយដាស់តឿនមនុស្សអោយស្គាល់ល្អ - អាក្រក់ ជឿបុណ្យ បាបជាដើម ។ តាមពិតព្រះពុទ្ធសមណគោតម ជាមនុស្សពុំមែនអាទិទេពទេ ប៉ុន្តែពួកព្រាហ្មណ៍បានបញ្ចូលព្រះពុទ្ធមកក្នុងពួកអវតារព្រះវិស្ណុ ដោយយល់ឃើញថា ព្រះពុទ្ធមានឥទ្ធិពលខ្លាំង មានឈ្មោះល្បីល្បាញ ដែលអាចចាត់ទុកជាមធ្យោបាយទាក់ទាញពួកពុទ្ធសាសនិកអោយមានជំនឿមកខាងសាសនាព្រាហ្មណ៍គណៈវិស្ណុវិញ ។

* **ព្រះសិវៈ (Çiva).–**

ព្រះសិវៈជាអាទិទេព បំផ្លាញលោកផង បង្កើតលោកផង (le



destructeur et le créateur du monde) គឺជាអ្នកតំណាងកំលាំងបំផ្លិចបំផ្លាញអោយអន្តរាយទៅវិញ (មរណភាពនិងការផ្តាច់អាត្មនអោយចេញពីកាយ) ដើម្បីបង្កើតឡើងទៀត ។

ព្រះសិវៈមានឈ្មោះច្រើនយ៉ាងទៀតគឺ : ឥស្វរ (និយមហៅនៅស្រុកខ្មែរ) ហរៈ មហេស្វរៈ រុទ្រៈ ឧគ្រៈ អឃោរៈ ភៃរវៈ ។ ចំពោះកំណើតរបស់ព្រះសិវៈ មានគម្ពីរឈ្មោះ វាយុបុរាណ បានថ្លែងថា ថ្ងៃមួយព្រះព្រហ្មនិងព្រះវិស្ណុកំពុងឈ្លោះគ្នាដោយចង់តាំងខ្លួនជាអ្នកបង្កើតពិភពលោកតែរៀងខ្លួន ស្រាប់តែមានសសរភ្លើងមួយធំផុសឡើងនៅចន្លោះអាទិទេពទាំងពីរនោះ ។ ដោយចង់ដឹងអំពីប្រភពនៃសសរភ្លើងនោះ ព្រះព្រហ្មក៏តំណែងខ្លួនជាសត្វស្វាបហោះទៅរកមើលផ្នែកខាងលើនៃសសរ ។ ឯព្រះវិស្ណុតំណែងជាជ្រូកព្រៃ ឈូសដីរកមើលផ្នែកខាងក្រោម ។ បន្ទាប់ពីរកមើលគល់និងចុងនៃសសរភ្លើងពុំឃើញអស់ពេលជាច្រើនពាន់ឆ្នាំមក អាទិទេពទាំងពីរក៏ទទួលស្គាល់សសរភ្លើងនោះជាអាទិទេពមានឫទ្ធានុភាពជាងខ្លួន ហើយក៏នាំគ្នាគោរពរាប់អានតមក ។ ក្រោយមកព្រះសិវៈក៏លេចចេញពីកណ្តាលសសរភ្លើងមក ហើយក៏ប្រាប់អោយដឹងថាអាទិទេពទាំងពីរនេះជាចំហាយចេញពីកាយព្រះអង្គ បានសេចក្តីថាព្រះព្រហ្មនិងព្រះវិស្ណុជាការបែងភាគរបស់ព្រះអង្គ ។ ដូចនេះពាក្យឥស្វរៈដែលយើងប្រើសំគាល់អាទិទេពដើមគេនោះគឺ សិវៈនេះឯង រីឥសូរដែលខ្មែរយើងនិយមហៅរហូតមកដល់សព្វថ្ងៃ (4) ។

អាស្រ័យលើជំនឿខាងលើនេះហើយបានជាគេសាងរូបសិវលិង្គ រឺលិង្គព្រះឥសូរជានិមិត្តរូបនៃសសរភ្លើងនោះដែលកើតឡើងឯង ( ស្វយម្ភូ ) រឺសាងសិវលិង្គតំកល់លើយោនីនាងឧមា ជានិមិត្តរូបនៃការបង្កើតលោកនៃព្រះសិវៈ ។ នៅប្រទេសខ្មែរ គេសាងរូបទាំងនេះតាំងពីមុនសម័យអង្គរម្លេះ ។ លុះមកដល់សតវត្សទី ៩ ទើបសាងរូបផ្សេង ៗ តំណាងព្រះសិវៈ ។

នៅប្រទេសឥណ្ឌា អ្នកដែលនិយមគោរពព្រះសិវៈតែងប្រារព្ធធ្វើពិធីសិវៈរាត្រី ដែលជាពិធីបុណ្យរំលឹកដល់រាត្រីដែលព្រះសិវៈបានអោយកំណើតលោក ។ គេភ្ជាប់ពិធីនេះទៅនឹងពិធីលាងបាប ។ គេនិយមធ្វើពិធីសិវរាត្រីនៅពេលយប់ ហើយក្នុងមួយឆ្នាំម្តង ។

“នៅវេលាយប់ ពួកព្រាហ្មណ៍នគរពារាណសីនាំគ្នាទៅវត្តព្រាហ្មណ៍ដែលជាទេវស្ថាន ធ្វើកិច្ចសូត្រមន្ត ចំរើនភាវនា នមស្ការទេវរូបនិងសិវលិង្គតាមប្រពៃណីរហូតអស់រាត្រី ។ ទៀបភ្លឺ ទើបនាំគ្នាយកក្អមស្ពាន់មួយ ៗ ម្នាក់ ទៅកាន់ស្ទឹងគង្គា អង្គុយដងយកមកសូត្រសេក ខ្ពុរមាត់លុបលាងខ្លួនប្រាណ ហើយចុះងូតមុជ អោយលិចក្បាលអស់រយៈ ៣ ដង ហើយមុជរេះយកដីមកដុសខ្លួនប្រាណនិងធ្វើបរិកម្មថា៖ « គង្គា ! គង្គា ! » ។ កិច្ចប៉ុននេះឈ្មោះថា បានជំរះលាងបាបអស់ពីខន្ធសន្តាន រួចហើយទើបដងទឹកយកមកកាន់ទេវស្ថានវិញ ។ ដល់ហើយ គេយកទឹកនោះទៅស្រោចស្រប់សិវលិង្គ ទើបត្រងទឹកដែលហូរចុះតាមទនៃបល្ល័ង្កឧមាយោនី



យកមកស្រោចក្បាល ស្រលាបខ្លួនប្រាណ ផឹកតាមសេចក្តីត្រូវការ ឈ្មោះថាបានសិរីសួស្តីជ្រះចង្រៃឧបទ្រពទាំងពួង ។

សំពាប់ស្រុកភូមិដែលនៅឆ្ងាយពីទន្លេគង្គា បើអ្នកណាបានទៅងូតម្តង ៗ តែងដងយកទឹកនោះមកផ្ញើញាតិមិត្ត អោយលុបលាងមុខមាត់ ស្រលាបខ្លួនប្រាណហើយបរិកម្មថា៖ “ គង្គា ! គង្គា ! ” សូមបីនៅឆ្ងាយ ៣០ យោជន៍ ក៏គង់រួចចាកបាបដែលខ្លួនបានធ្វើមក ៣ ជាតិហើយ ។

ហេតុនេះ ទើបពួកឥណ្ឌា ដែលមានសទ្ធាជ្រះថ្លាខ្លាំង វេលារៀបស្លាប់ អោយបានទៅស្លាប់ក្បែរទន្លេគង្គា ស្លាប់ហើយអោយគេដុតយកធាតុទៅគ្រវែង បាចសាចចោលក្នុងទន្លេនោះ ឈ្មោះថាបានជ្រះបាបឥតសេសសល់ ” (2) ។

នៅប្រទេសខ្មែរ ក្នុងសម័យដែលខ្មែរនិយមគោរពព្រះឥសូរជាធំ ក៏មានធ្វើពិធីសិវរាត្រីដែរ គឺធ្វើនៅខេត្តសៀមរាប ។ គេនាំគ្នាចុះទៅមុជទឹកលាងបាប ចង្រៃ ឧបទ្រព នៅក្នុងស្ទឹងសៀមរាបដែលគេសន្មតជាទន្លេគង្គា ។

រួចមកហើយ យើងបានដឹងត្រួស ៗ នូវទស្សនៈគោរពទេវៈនៅក្នុងសាសនាព្រាហ្មណ៍ គឺទស្សនៈ ពហុទេវនិយម ទស្សនៈឯកទេវនិយម និងទស្សនៈ ត្រីមូរតិ ។ នៅប្រទេសខ្មែរ ក្នុងសម័យដែលព្រាហ្មណ៍សាសនាលូតលាស់ ជនជាតិខ្មែរយើងក៏និយមគោរពតាមទស្សនៈទាំងនោះខ្លះដែរ ។ ក្នុងចំណោមអាទិទេពធំ ៗ ក្នុងទស្សនៈត្រីមូរតិ ព្រះឥសូរ

ត្រូវបានខ្មែរយើងនិយមគោរពរាប់អានផងដែរ ។ ចំណែករូបតំណាងតួអង្គទេវៈ អាទិទេព ព្រមទាំងប្រពន្ធ កូន គឺខ្មែរបានឆ្លាក់ជារូបបដិមាតិកល់ក្នុងប្រាសាទក៏មាន ជារូបចំលាក់ជាប់នឹងជញ្ជាំងប្រាសាទក៏មាន ប៉ុន្តែយើងមិនទាន់បានលើកយករូបចំលាក់ទាំងនោះមកបង្ហាញក្នុងពេលនេះទេ យើងនឹងលើកយកទៅសិក្សាក្នុងផ្នែកសិល្បៈ ( ចំលាក់បូរាណ ) វិញ ។

*

* *

# ២-ពុទ្ធសាសនា

ពុទ្ធសាសនាមានដើមកំណើតនៅប្រទេសឥណ្ឌាក្នុងសតវត្សទី ៦ មុន គ.ស ប្រហែលគ្នានឹងកំណើតព្រាហ្មណ៍និយម ( សម័យទី ២ នៃលទ្ធិសាសនាព្រាហ្មណ៍ ) ដែរ ។ លុះក្រោយមកក្នុងរជ្ជកាលព្រះបាទកនិស្កៈ ប្រមាណក្នុងសតវត្សទី ១ នៃគ.ស. ពុទ្ធសាសនាក៏បែកជាពីរ និកាយ (secte) គឺនិកាយ **ហីនយាន** និងនិកាយ **មហាយាន** ។

និកាយហីនយាន ( Petit véhicule ) បែកចេញទៅទិសខាងត្បូងនៃប្រទេសឥណ្ឌា (ទក្ខិណានិកាយ) ជាយានតូចចង្អៀត ( តាមន័យប្រៀបធៀប ) ដឹកសត្វលោកទៅកាន់និព្វានបានចំនួនតិច ពោលគឺក្របានសំរេចនិព្វានព្រោះវិន័យតឹងតែងម៉ត់ចត់ ។ និកាយហីនយាននិយមធម៌ចាស់ គឺគោរពប្រតិបត្តិតាមពុទ្ធវាទ ដែលព្រះពុទ្ធទ្រង់បានសំដែងរួចមកហើយ ( ក្នុងគម្ពីរត្រៃបិដក ) ។ និកាយនេះគោរពព្រះពុទ្ធសមណគោតមដែលត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ហើយដែលបានចូលបរិនិព្វានទៅហើយ។ សព្វថ្ងៃ ប្រទេសដែលនិយមពុទ្ធសាសនានិកាយហីនយាន មានប្រទេសខ្មែរ-សៀម-លាវ-ភូមា-ឥណ្ឌា (នេប៉ាល់) - សិរីលង្កា ។ ល ។

ឯនិកាយមហាយាន (Grand véhicule) បែកចេញទៅទិសខាងជើង (ឧត្តរនិកាយ) ជាយានធំ អាចផ្ទុកសត្វលោកបានច្រើនគ្នាទៅកាន់គោលដៅត្រឹមពោធិសត្វ ដែលអាចជួយណែនាំប្រោសសត្វលោកបាន ។ និកាយមហាយាននិយមធម៌ថ្មី គឺធម៌ដែលមានវិន័យធូរស្រាល ហើយគោរពប្រតិបត្តិតាមលទ្ធិអាចារិយវាទ (តាមគ្រូអាចារ្យរបស់ខ្លួនៗគ្នា) ពុំមែនតាមពុទ្ធវាទដូចនិកាយហីនយានឡើយ ។ ដូចនេះនិកាយមហាយានពុំគោរពព្រះពុទ្ធជាធំទេ តែគោរពពោធិសត្វដូចជាពោធិសត្វ អវលោកិតេស្វរៈ រឺលោកេស្វរៈ មញ្ជុស្រី មៃត្រេយ ប្រជ្ញាបារមិតា ជាដើម ។ សព្វថ្ងៃប្រទេសដែលនិយមពុទ្ធសាសនាមហាយាន មានប្រទេសយួន-ជប៉ុន-ទីបេ-ឥណ្ឌូណេស៊ី ។ល។

នៅសតវត្សទី ៣ (មុនគ.ស.) ក្នុងរជ្ជកាលព្រះបាទអសោក ពុទ្ធសាសនាត្រូវបានផ្សព្វផ្សាយពាសពេញទាំងក្នុងប្រទេសឥណ្ឌា ទាំងក្រៅប្រទេស ។ តាមប្រវត្តិសាស្ត្រ គេបានដឹងថា នៅពុទ្ធសតវត្សទី ៣ (ព.ស. ២៣៤) គឺតាំងពីមុន គ.ស. ៣០០ឆ្នាំម្ល៉េះ ព្រះបាទ អសោក ពុទ្ធសាសនិកដ៏ឆ្នើមក្នុងប្រទេសឥណ្ឌា បានបញ្ជូនសមណទូតពីរអង្គគឺព្រះ សោណត្ថេរ និងព្រះឧត្តរត្ថេរ អោយនាំយកពុទ្ធសាសនាថេរវាទ (ហីនយាន) មកផ្សាយនៅសុវណ្ណភូមិ (អាស៊ីអគ្នេយ៍) ។ តាមសិលាចារឹកវ៉ូកាញ់ (នៅយួនខាងត្បូង) ទំនងជាពុទ្ធសាសនាចូលមកប្រតិស្ឋានក្នុងប្រទេសខ្មែរនៅសតវត្សទី ២ នៃគ្រិស្តសករាជ ក្នុងរជ្ជកាលព្រះបាទ ស្រីមារៈ រឺ ហ្វាន់ចេម៉ែន(5) ។



មុននឹងលើកយកគោលសំខាន់ៗក្នុងពុទ្ធសាសនាមកសិក្សា គប្បីយើងស្គាល់ព្រះពុទ្ធនិងឆាកជីវិតរបស់ព្រះអង្គសិន ។

## ក- ពុទ្ធប្រវត្តិសង្ខេប (6)(7)(8).-

## ១ - កំណើត

- ព្រះរាជវង្ស : វង្សគោតម

ព្រះបិតានាម សុទ្ធោទនី ជាកជានៃបក្សសម្ព័ន្ធ សាក្យៈ សោយរាជ្យនៅនគរ កបិលពស្តុ នៅឥណ្ឌាប៉ែកខាងជើង សព្វថ្ងៃនៅក្នុងតំបន់នេប៉ាល់ ។
ព្រះមាតានាម សិរិមហាមាយា បុត្រីមហាក្សត្រនៃបក្សសម្ព័ន្ធ កោឡិយៈ នៅនគរ ទេវទហៈ នៅជាប់ព្រំដែននគរ កបិលពស្តុ ។
ព្រះពុទ្ធនាម សិទ្ធត្ថ រឺ សិទ្ធាថ៌ (និយមហៅនៅស្រុកខ្មែរ) ។
ព្រះអគ្គមហេសីនាម ពិម្ពាយសោធរា បុត្រីស្តេច សុប្បពុទ្ធ ។
ព្រះរាជបុត្រនាម រាហុលកុមារ ។

- មូលហេតុនៃកំណើត :

ព្រះនាងសិរិមហាមាយាបានយល់សប្តិឃើញដំរីសមួយមានភ្លុក៦ ចុះពីស្ថានលើមក ហើយចូលក្នុងផ្ទៃព្រះនាងផ្នែកខាងស្តាំ ។ តាមទំនាយថា ព្រះនាងនឹងបានបុត្រប្រុសមួយអង្គ ប្រកបដោយបុណ្យបារមីយ៉ាងលើសលុប ។ តាមរឿងនិទានខ្លះថា ទេវបុត្ត សន្តុសិត យាងចុះពីស្ថានតុសិតមកចាប់ផ្ទៃព្រះនាង ។

– កំណើត :

– ព្រះពុទ្ធប្រសូតនៅថ្ងៃសុក្រ ១៥ កើត ពេញបូណ៌មីខែពិសាខ ឆ្នាំច នៅក្រោមដើមសាលព្រឹក្សក្នុងព្រៃ លុម្ពិនី ដែលស្ថិតនៅចំព្រំប្រទល់នៃនគរ កបិលពស្តុ និងនគរទេវទហៈ ។

– គេថាមានការអស្ចារ្យកើតឡើងមុននិងក្រោយពេលប្រសូត ។

– ប្រសូតបាន៥ថ្ងៃ ព្រាហ្មណ៍ ៨ នាក់ថ្វាយព្រះនាមព្រះឱរសថា សិទ្ធាថ៌ ដែលមានន័យថា "អ្នកសំរេចប្រយោជន៍គ្រប់យ៉ាង" ហើយព្រាហ្មណ៍ ៧ នាក់លើកម្រាមដៃពីរ ទាយថា : "បើព្រះកុមារស្ថិតនៅជាក្សត្រ នឹងបានជាស្ដេចចក្រពត្តិ បើចេញសាងព្រះផ្នួស នឹងបានត្រាស់ជាព្រះពុទ្ធ" ប៉ុន្តែព្រាហ្មណ៍ម្នាក់ទៀតឈ្មោះកោណ្ឌញ្ញ នៅក្មេងជាងគេ លើកតែម្រាមដៃមួយហើយទាយថា : "ព្រះកុមារពិតជាបានត្រាស់ជាព្រះពុទ្ធមិនខាន" ។

– ៧ ថ្ងៃក្រោយពេលប្រសូត ព្រះមាតាទ្រង់សោយទិវង្គត ទៅកើតនៅស្ថានតុសិត ឯព្រះកុមារក៏ត្រូវបានព្រះមាតុច្ឆារបស់ព្រះអង្គព្រះនាមមហាបជាបតិ គោតមី បីបាច់ថែរក្សាតមក ។

## ២ – ការត្រាស់ដឹង

– រាជាភិសេក :

– ព្រះជន្មបាន ១៦ ឆ្នាំ ទ្រង់បានរៀបអភិសេកជាមួយព្រះនាងពិម្ពាយសោធរា ។



ព្រះបិតាបានចាត់អោយសង់ប្រាសាទបីថ្វាយព្រះអង្គ គង់ទៅតាមរដូវទាំងបី ( ក្ដៅ-រងា-រំហើយ ) ។

– ទេពនិមិត្តទាំង ៤ យ៉ាង :

– ដោយអផ្សុកខ្លាំងពេក ព្រះអង្គបានចេញទៅក្រសាលក្នុងឧទ្យានដែលស្ថិតនៅក្នុងបរិវេណវាំង ។ ក្នុងពេលចេញទៅក្រសាលទាំងបួនលើក ព្រះអង្គបានទតឃើញទេពនិមិត្ត (ទេវតាចុះមកនិមិត្តខ្លួន) ៤ យ៉ាងដែរ :

លើកទី ១ ទតឃើញ មនុស្សចាស់

លើកទី ២ ទតឃើញ មនុស្សឈឺ

លើកទី ៣ ទតឃើញ មនុស្សស្លាប់

លើកទី ៤ ទតឃើញ មនុស្សបួស ។

មនុស្សទាំង ៤ ប្រភេទនេះ បានធ្វើអោយព្រះអង្គកើតក្ដីសង្វេគ ហើយយល់ច្បាស់អំពីបញ្ហាជីវិតរបស់សត្វលោក ។ មនុស្សប្រភេទទី ៤ ធ្វើអោយព្រះអង្គសោមនស្សចង់សាងផ្នួស ។

– ការសាងផ្នួស :

– ក្នុងព្រះជន្ម ២៩ ឆ្នាំ ព្រះសិទ្ធាថ៌មានការនឿយណាយក្នុងជីវភាពរបស់ព្រះអង្គ ហើយមានសេចក្ដីខ្ពើមរអើមលោកសន្និវាសនេះកាន់តែខ្លាំងឡើងៗ ។

– ព្រះអង្គសព្វព្រះរាជហឫទ័យចង់ដោះស្រាយបញ្ហាជីវិត ហើយចង់ជ្រើសរើសការសាងផ្នួសជាមធ្យោបាយដើម្បីសំរេចនូវសម្មាសម្ពោធិញ្ញាណ ។

– ទីបំផុត ព្រះអង្គលះបង់ព្រះរាជវង្ស ហើយលួចចេញទៅសាងផ្នួសទាំងកណ្ដាលរាត្រីស្ងាត់ ទោះបីព្រះបិតាបិទការពារគ្រប់មាត់ច្រកយ៉ាងណាក៏ដោយ ។

– ក្រោយដែលបានដឹងថា ព្រះសិទ្ធាត្ថយាងទៅបួសក្នុងព្រៃមក កោណ្ឌញ្ញព្រាហ្មណ៍និងកូនព្រាហ្មណ៍ឯទៀត ៤ នាក់ មានសទ្ធាជ្រះថ្លាទៅបួសដែរ ហើយតាមបំរើព្រះអង្គ ។ អ្នកបួសទាំង ៥ អង្គនេះហៅថា បញ្ចវគ្គិយ ។

– ក្រោយពីបានសាកល្បងតបធម៌ជាមួយតាបសពីរនាក់ (អ្នកបួសក្នុងសាសនាព្រាហ្មណ៍)ឈ្មោះ អាឡារតាបស និង ឧទកតាបសពុំបានលទ្ធផលល្អ ព្រះអង្គក៏ខំប្រឹងតស៊ូស្វែងរកសច្ចធម៌តែមួយព្រះអង្គឯង ។

**– ការត្រាស់ដឹង :**

– ក្រោយពីធ្វើទុក្ករកិច្ច (កិច្ចដែលត្រូវបំពេញដោយលំបាក) អស់ ៦ វស្សាមក ព្រះអង្គបានយាងចាកចេញពី រាជគ្រឹះ (ធានីរដ្ឋមគធៈ) ធ្វើដំណើរទៅដល់ស្រុក ពោធិគយា ក្នុងរដ្ឋមគធៈ ។

– ព្រះអង្គទ្រង់តាំងសមាធិ នៅក្រោមដើមពោធិព្រឹក្សក្បែរស្ទឹង នេរញ្ជរា ហើយទ្រង់បានផ្ចាញ់ មារ ។

– ព្រះអង្គបានត្រាស់ជាព្រះពុទ្ធ នៅថ្ងៃពុធ ១៥ កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា ក្នុងព្រះជន្ម ៣៥ វស្សា ។

## ៣ – ធម្មទេសនា



លុះបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណហើយ ព្រះពុទ្ធទ្រង់សំដែងធម្មទេសនាទូន្មានសត្វលោកដោយពុំប្រកាន់វណ្ណៈឡើយ ។

– មនុស្សជាច្រើនបានចូលទៅសុំបួសរៀនក្នុងសំណាក់ព្រះអង្គ ។

- ព្រះអង្គតែងបំពេញពុទ្ធកិច្ច ៥ ប្រការជានិច្ចអស់រយៈពេល ៤៥ ឆ្នាំ :
  - នៅពេលព្រឹក ទ្រង់និមន្តបិណ្ឌបាត្រ
  - នៅពេលរសៀល ទ្រង់សំដែងធម្មទេសនាដល់សាធារណជន
  - នៅពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ
  - នៅពេលកណ្ដាលអធ្រាត្រ ទ្រង់ដោះស្រាយប្រស្នានៃពួកទេវតា
  - នៅពេលជិតភ្លឺទ្រង់ប្រមើលទតនូវសត្វលោកដែលមានភព្វ និងឥតភព្វ ។

## ៤_បរិនិព្វាន

– ដល់ពេលចេញវស្សាទី ៤៥ នៅថ្ងៃ ១៥ កើត ពេញបូណ៌មី ខែ មាឃ ឆ្នាំម្សាញ់ ព្រះពុទ្ធទ្រង់ដាក់អាយុសង្ខាររបស់ព្រះអង្គដោយប្រាប់មារថា ព្រះអង្គនឹងចូលបរិនិព្វានក្នុងរវាង ៣ ខែទៀត ។

– ពួកសាវ័កទាំងឡាយ ជាពិសេសអានន្ទ កាលបើបានដឹងថាព្រះអង្គបានកំរិតអាយុសង្ខាររួចទៅហើយ ពុំអាចកែប្រែបាន ក៏សោយសោកយ៉ាងខ្លាំងស្តាយព្រះពុទ្ធអង្គ មិនទាន់ចង់អោយព្រះអង្គចូលបរិនិព្វានឡើយ ។

– ព្រះអង្គយាងទៅដល់នគរកុសិនារា ហើយទ្រង់យាងចូលទៅកាន់សាលវ័ន ហើយទ្រង់ត្រាស់អោយអានន្ទរៀបចំគ្រែថ្វាយព្រះអង្គផ្ទុំ ( ផ្ទុំផ្អៀង

ទៅខាងស្តាំ ព្រះបាទជង្គង់ត្រួតលើព្រះបាទស្តាំ) ។ នៅបច្ឆិមរាត្រី ព្រះអង្គទ្រង់ត្រាស់ដល់ភិក្ខុទាំងឡាយថា : "ម្នាលភិក្ខុទាំងឡាយឥឡូវនេះតថាគតហៅអ្នកទាំងឡាយមកប្រាប់ថា អ្វីដែលកើតឡើងហើយ ដែលមានហើយ ដែលផ្គុំផ្សំហើយតែងមានធម៌ភាពនឹងរលត់ទៅវិញជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងប្រយោជន៍អោយសំរេចដោយកិរិយាមិនធ្វេសប្រហែសចុះ" ។ ព្រះអង្គមានពុទ្ធដីកាតែប៉ុននោះ ទ្រង់ក៏រំលត់សង្ខារនៅពេលនោះទៅ ។

– ព្រះពុទ្ធចូលបរិនិព្វាននៅថ្ងៃអង្គារ ១៥ កើតពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ ( ៥៤៣ មុនគ.ស. ) ក្នុងព្រះជន្ម ៨០ វស្សា ។

ការសិក្សាពុទ្ធប្រវត្តិនេះ នាំអោយយើងស្គាល់ព្រះពុទ្ធច្បាស់ គឺពុំមែនអាទិទេពទេ ជាមនុស្សរស់នៅក្នុងសង្គមមនុស្ស ត្រាស់ដឹងសព្វនូវបញ្ហាមនុស្ស ហើយបានអប់រំណែនាំមនុស្សអោយស្គាល់ល្អ- អាក្រក់ សុខ-ទុក្ខ គ្រប់បែបយ៉ាង ។ ព្រះពុទ្ធរលត់ខន្ធទៅក៏ពិតមែន ប៉ុន្តែទស្សនៈទ្រឹស្តីរបស់ព្រះអង្គគង់នៅ ហើយត្រូវបានយកមកអនុវត្តរហូតមកដល់សព្វថ្ងៃ ។

តទៅទៀតយើងសូមលើកយកទស្សនៈទ្រឹស្តីសំខាន់ ៗ ខ្លះរបស់ព្រះពុទ្ធ មកអធិប្បាយដោយសង្ខេប ។

## ខ – អរិយសច្ចៈ (Nobles vérités)(9). –



អរិយសច្ចៈ គឺការពិតដ៏ប្រសើរ ដ៏ខ្ពង់ខ្ពស់ ។ អរិយសច្ចៈដែលព្រះពុទ្ធអង្គពិចារណារកឃើញមាន ៤ ប្រការ ( ហៅថា អរិយសច្ចៈ ៤ ចតុរារិយសច្ចៈ ) គឺ: ទុក្ខអរិយសច្ចៈ សមុទយអរិយសច្ចៈ និរោធអរិយសច្ចៈ និងមគ្គអរិយសច្ចៈ ។

### ១- ទុក្ខអរិយសច្ចៈ . –

គឺទុក្ខជាសេចក្តីពិតដែលកើតមានដល់មនុស្ស - សត្វគ្រប់ៗរូបហើយពុំអាចចៀសផុតបានឡើយ គ្រាន់តែខុសគ្នាត្រង់អ្នកខ្លះមានទុក្ខតិចអ្នកខ្លះមានទុក្ខច្រើន ។ ទុក្ខធំៗមាន :

– ជាតិទុក្ខ គឺទុក្ខព្រោះមានកំណើត (តាំងពីនៅក្នុងផ្ទៃម្តាយម៉្លេះ)
– ព្យាធិទុក្ខ គឺទុក្ខព្រោះមានជម្ងឺផ្សេងៗមកបៀតបៀន
– ជរាទុក្ខ គឺទុក្ខព្រោះចាស់គ្រាំគ្រា ទ្រុឌទ្រោម
– មរណទុក្ខ គឺទុក្ខព្រោះស្លាប់ (មានការចុកចាប់ រឺពិបាកខ្លាំងនៅពេលស្លាប់) ។

ក្រៅពីទុក្ខធំៗទាំង៤យ៉ាងនេះ នៅមានទុក្ខជាច្រើនប្រភេទទៀត ដូចជាទុក្ខកើតឡើងដោយព្រាត់ប្រាស-មិនបានសំរេចបំណងណាមួយ- សោកស្តាយ ។ល។

### ២- សមុទយអរិយសច្ចៈ . –

គឺទុក្ខជាសេចក្ដីពិត ដែលកើតឡើងមកអំពីហេតុ ឫសគល់ពិតប្រាកដ ។ ឯហេតុដែលនាំអោយមានទុក្ខមាន ២ ជំ ។ គឺ តណ្ហា (désir) និង អវិជ្ជា (ignorance) ។ អវិជ្ជាគឺសេចក្ដីល្ងង់ខ្លៅ ឬមិនដឹងមិនយល់នូវហេតុដែលនាំអោយមានទុក្ខ ។ អវិជ្ជានេះនាំអោយកើតមានតណ្ហាឡើង ។ តណ្ហាគឺ សេចក្ដីស្រេកឃ្លាន សេចក្ដីប្រាថ្នា សេចក្ដីលោភ ចង់មាន ចង់បានអ្វីៗគ្រប់បែបយ៉ាងមិនចេះឆ្អែត មិនចេះចប់ ។ តណ្ហានេះជាឫសគល់ចម្បងដែលនាំអោយមានទុក្ខគ្រប់ប្រការ ហើយនាំអោយមានកំណើតថ្មីបន្តគ្នាមិនដាច់ ( renaissances successives ) ។

៣- និរោធអរិយសច្ចៈ .-

គឺការរួចស្រឡះ ឬការរំលត់ទុក្ខជាសេចក្ដីពិត ។ កន្លែងរំលត់ទុក្ខគឺនិព្វាន ។ ដើម្បីបំបាត់ទុក្ខអោយអស់រលីង ត្រូវបំបាត់ឫសរំលើងឫសគល់នៃទុក្ខពោលគឺបំបាត់អវិជ្ជា រំលាយតណ្ហាប្រៀបបានទៅនឹងការរំលើងឫសកែវដើមឈើអោយអស់ ទើបដើមឈើនោះលែងដុះលូតលាស់ទៀតបាន ។ យ៉ាងណាមិញ កាលណាឫសគល់នៃទុក្ខរលាយរលត់អស់ហើយ ទុក្ខនានាក៏ពុំអាចកើតទៀតបានឡើយ ។ តើរំលត់ទុក្ខដោយវិធីណាខ្លះ ?

៤.មគ្គអរិយសច្ចៈ .-

គឺផ្លូវ ឬមធ្យោបាយនាំអោយផុតទុក្ខជាសេចក្ដីពិត ។ ដើម្បីរំលត់ទុក្ខ



ហើយទៅដល់និព្វាន ព្រះពុទ្ធបានបញ្ជាក់ថាត្រូវប្រកាន់យកផ្លូវកណ្ដាល (មជ្ឈិមាបដិបទា) ហើយប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវមគ្គៈ ៨ យ៉ាង (អដ្ឋង្គិកមគ្គ) ។ មគ្គៈទាំង៨នោះគឺ :

– សម្មាទិដ្ឋិ : ការយល់ឃើញត្រូវ ( compréhension juste ) គឺការយល់ឃើញពិតនូវសភាវធម៌ទាំងពួង ឃើញតាមអរិយសច្ចៈ ទាំង ៤ ហើយពេញចិត្តនិងយល់ព្រមប្រតិបត្តិតាមផ្លូវត្រូវ ដើម្បីបំបាត់នូវអវិជ្ជានិងតណ្ហា ។

– សម្មាសង្កប្ប : ការត្រិះរិះត្រូវ (pensée juste) គឺត្រិះរិះក្នុងការមិនព្យាបាទ មិនបៀនបៀនចំពោះមនុស្ស-សត្វទូទៅ ។ ការត្រិះរិះត្រឹមត្រូវនាំអោយជួបប្រទះផលល្អនិងសេចក្ដីសុខចំរើន ។

– សម្មាវាចា : វាចាត្រឹមត្រូវ (parole juste) គឺសំដីត្រឹមត្រូវវៀរចាកវចីទុច្ចរិត ៤ យ៉ាង :

១- មុសាវាទ (ពាក្យមិនពិត)

២- បិសុណាវាទ (ពាក្យស៊កសៀត ញុះញង់ បំបែកបំបាក់)

៣- ផរុសវាទ (ពាក្យជេរប្រទេច តិះដៀល ដៀមដាម)

៤- សម្ផប្បលាវាទ (ពាក្យផ្ដេសផ្ដាស ឡេះឡោះ កំប្លែង សើចលេងឥតប្រយោជន៍) ។

– សម្មាកម្មន្ត : ការងារត្រឹមត្រូវ (action juste) គឺប្រព្រឹត្តល្អវៀរចាកកាយទុច្ចរិត ៣ យ៉ាង :

១- បាណា (ការសម្លាប់សត្វមានជីវិត)

២- អទិន្នា (ការលួចទ្រព្យអ្នកដទៃ)

៣- កាមេ (ការប្រព្រឹត្តលួចប្រពន្ធ - កូនគេខុសច្បាប់) ។

— **សម្មាអាជីវ** : ការចិញ្ចឹមជីវិតត្រឹមត្រូវ (moyens d'existence juste) គឺវៀរចាកការចិញ្ចឹមជីវិតខុសគន្លងធម៌ដូចជា លួចប្លន់ទ្រព្យសម្បត្តិ ធ្វើជំនួញទុច្ចរិតជាដើម ។

— **សម្មាវាយាម** : ការព្យាយាមត្រឹមត្រូវ (effort juste) គឺព្យាយាមខាងផ្លូវចិត្តគំនិត ដូចជាការពារមិនអោយមានបាបអកុសល រីសាយ៉ាងកើតឡើងក្នុងសន្ដានចិត្តនិង ព្យាយាមខាងផ្លូវកាយដូចជាការព្យាយាមធ្វើអំពើល្អគ្រប់បែបយ៉ាង ព្យាយាមរក្សាអំពើល្អដែលកើតឡើងជាដើម ។

— **សម្មាសតិ** : សតិត្រឹមត្រូវ (attention juste) គឺការរំលឹកនឹកឃើញនិងដឹងខ្លួនជានិច្ច ។ គេចាត់ទុកសតិ ជាឆ្មាំទ្វារដ៏ប្រសើរក្នុងការឃ្លាំមើលនិងការពារ កុំអោយគ្រឿងវិញ្ញាណ មានភ្នែក ត្រចៀក អណ្ដាត ច្រមុះ កាយ ទទួលអារម្មណ៍អាក្រក់បាន ។

— **សម្មាសមាធិ** : ការធ្វើសមាធិត្រឹមត្រូវ (concentration juste) គឺការចំរើនឈានភាវនាដើម្បីតំកល់ចិត្តអោយនឹង មិនអោយរវើរវាយអណ្ដែតអណ្ដូង ពោលគឺតាំងចិត្តអោយស៊ប់ជានិច្ចក្នុងអារម្មណ៍តែមួយ ។

ផ្លូវមធ្យោបាយ ទាំង ៨ ខាងលើនេះ បង្រួមមកបានដល់ : **សីល-សមាធិ-បញ្ញា** ។



| | | |
|---|---|---|
| សម្មាវាចា<br>សម្មាកម្មន្ត<br>សម្មាអាជីវៈ | សម្មាវាយាម<br>សម្មាសតិ<br>សម្មាសមាធិ | សម្មាសង្កប្ប<br>សម្មាទិដ្ឋិ |
| **សីល** | **សមាធិ** | **បញ្ញា** |

## ឥ- ទស្សនៈកម្មផល. —

ទស្សនៈកម្មផលនេះមានទំនាក់ទំនងទៅនឹងការវិលកើត - ស្លាប់នៃសត្វលោក ។

នៅក្នុងព្រាហ្មណ៍លទ្ធិ ភាវៈកើតឡើងដោយមានអាទិទេពជាអ្នកបង្កើត ។ ចំណែកនៅក្នុងពុទ្ធលទ្ធិ ភាវៈកើតឡើងដោយខ្លួនឯង តាមច្បាប់ធម្មជាតិ ។ ចំពោះមនុស្សរឺសត្វ ធាតុដែលនាំអោយកើតរឺស្លាប់ គឺ ខន្ធ ទាំង ៥ (រូបក្ខន្ធ - វេទនាខន្ធ - សញ្ញាខន្ធ - សង្ខារក្ខន្ធ - វិញ្ញាណក្ខន្ធ) ពោលគឺធាតុទាំងឡាយដែលបានជួបប៉ះទង្គិចគ្នា ផ្គុំផ្សំគ្នា ហើយកកើតឡើង ។ ភាវៈដែលមានកំណើតឡើងហើយបែបនេះ រមែងមានការប្រែប្រួល ចាត់ធំ ហើយទ្រុឌទ្រោម រួចរលត់ខន្ធទាំង ៥ ទៅវិញ (ស្លាប់) រួចហើយទើបមានការប៉ះទង្គិចផ្គុំផ្សំគ្នាឡើងជាថ្មីទៀត (ជីវិតថ្មី) យ៉ាងនេះរៀងដរាបទៅ ។ ក្នុងទស្សនៈនេះគេចាត់ទុកការស្លាប់ ជាខណៈមួយដែលខន្ធទាំង ៥ ត្រូវរលាយ ហើយចាត់ទុកការកើត ជាខណៈមួយដែលខន្ធទាំង ៥ ផ្គុំផ្សំជាថ្មីឡើងវិញ ។ ខន្ធទាំង ៥ នៃមនុស្ស-សត្វត្រូវរលាយរលត់ទៅវិញនៅពេលស្លាប់គឺពិតមែនហើយ ប៉ុន្តែនៅសល់ថាមពល រឺ ចំហាយនៃខន្ធ

ដែលបានប៉ះទង្គិចនូវធាតុឯទៀតៗបណ្ដាលអោយកើតមានជារូបមួយឡើងទៀត ។ ថាមពលដែលចំហាយនៃជីវិតចាស់នេះមានឈ្មោះថា កម្មផល នេះឯង ។ ដូចនេះឃើញថាជីវិតចាស់មានទំនាក់ទំនងនឹងជីវិតថ្មី ។ ជីវិតចាស់និងជីវិតថ្មីដូចគ្នាផង ប្លែកគ្នាផង ។ ដូចគ្នា ត្រង់ជីវិតថ្មីទទួលចំហាយកម្មផលពីជីវិតចាស់ ប៉ុន្តែពុំដូចរឺប្លែកត្រង់ជីវិតថ្មីមានការកសាងការអប់រំថ្មីៗទៀត ។ ទស្សនៈពុទ្ធនិយមបានយល់ឃើញថា សត្វលោកទាំងឡាយរមែងវិលកើត វិលស្លាប់ មិនចេះអស់មិនចេះហើយក្នុងសំសារៈ ។ កាលបើកើតឡើងហើយ រមែងមាន ចាស់ - ឈឺ - ស្លាប់ ហើយនៅពេលរស់ រមែងជួបប្រទះនឹងទុក្ខសោក រោគាព្យាធិ និងសេចក្ដីលំបាកវេទនាផ្សេងៗ ។ ឯការដែលនាំអោយផុតចាកជរា ព្យាធិ មរណៈ និងទុក្ខសោកផ្សេងៗបាន គឺមិនចាប់កំណើតតទៅទៀត ។ តើត្រូវធ្វើដូចម្ដេចដើម្បីកុំអោយកើតទៀត ? ព្រះសិទ្ធាថ៌ទ្រង់បានចេញទៅសាងព្រះផ្នួសដោយមានព្រះបំណងនឹងស្រាវជ្រាវរកអោយឃើញ នូវគោលដៅនេះដែរ ។ ក្រោយដែលព្រះអង្គត្រាស់ដឹងហើយ ព្រះអង្គបានសំដែងថា ដរាបណាផលនៃកម្មមិនទាន់ផុតរលត់ទេ ដរាបនោះសត្វលោកនៅតែត្រូវកើតតទៅទៀត ។ បើចង់បំបាត់កំណើត ត្រូវបំបាត់ផលនៃកម្មសិន ទើបកំណើតរលត់ទៅឯង ។ ដូចនេះ កម្មផលជាមូលដ្ឋានសំខាន់ណាស់ក្នុងទស្សនៈពុទ្ធនិយម ។ តើកម្មផលក្នុងពុទ្ធសាសនាមានន័យនិងលក្ខណៈ



ដូចម្ដេចខ្លះ ?

ពាក្យថា *កម្ម* បានន័យថា អំពើ ការងារ រឺ ភារកិច្ច ដែលមនុស្សម្នាក់ៗ បានប្រព្រឹត្តដោយកាយក្ដី - ចិត្តក្ដី-វាចាក្ដី ។ ឯកម្មដែលសំគាល់នូវអំពើនោះចែកចេញជា ៣ យ៉ាងគឺ :

— *កុសលកម្ម* គឺអំពើជាកុសល

— *អកុសលកម្ម* គឺអំពើជាអកុសល

— *អព្យាកតកម្ម* គឺអំពើជាអព្យាក្រឹត្យ ។

ឯពាក្យថា *ផល* គឺផ្លែផ្កាដែលលេចចេញមកអំពីកម្ម ។ បើកម្មល្អផលក៏ល្អ បើកម្មអាក្រក់ ផលក៏អាក្រក់ ។ មនុស្សជាអ្នកកសាងកម្មខ្លួនឯង ហើយត្រូវទទួលយកផលនៃកម្មនេះខ្លួនឯងដែរ ។ ដូចនេះ តាមទស្សនៈពុទ្ធនិយមមនុស្សដែលមានលក្ខណៈល្អ-អាក្រក់-ល្ងង់-ឆ្លាត-មាន-ក្រ-ខ្មៅ-ស-។ល។ គឺមកពីការកសាងរឺអំពើរបស់មនុស្សម្នាក់ៗ នេះឯង ។ ម្យ៉ាងទៀតអំពើល្អនិងអំពើអាក្រក់ពុំអាចលុបលាងរឺសងគ្នាបានទេ ។ អំពើល្អរមែងផលិតផល ល្អ អំពើអាក្រក់រមែងផលិតផលអាក្រក់ ។ ប្រសិនបើអំពើនោះល្អផង អាក្រក់ផង លទ្ធផលក៏ល្អផងអាក្រក់ផងដែរ ។ ឯផលនៃកម្មមិនសាបសូន្យទេ គ្រាន់តែបានទទួលយូររឺឆាប់ប៉ុណ្ណោះ :

— កម្មខ្លះផ្ដល់ផលភ្លាមៗ ក្នុងបច្ចុប្បន្នជាតិ

— កម្មខ្លះផ្ដល់ផលក្នុងជាតិខាងមុខ បន្ទាប់ពីជាតិបច្ចុប្បន្ននេះ

— កម្មខ្លះទៀតផ្តល់ផលក្នុងជាតិជាលំដាប់តៗទៅទៀត ។

រួចមកហើយនេះ យើងបានឃើញថាកម្មនិងផលទាក់ទងគ្នាជាដរាប លើកលែងតែកម្មម្យ៉ាងឈ្មោះ **អហោសិកម្ម** គឺកម្មគន្លងហួសទៅហើយ ហើយមិនផ្តល់ផលដល់អ្នកធ្វើ (ដូចជាកម្មរបស់ព្រះខីណាស្រព) ។ ដូចនេះ ទ្រឹស្តីកម្មផល គឺជាទ្រឹស្តីអំពីទំនាក់ទំនងរវាងហេតុនិងផលនេះឯងហើយ មានលក្ខណៈ ស្របតាមវិទ្យាសាស្ត្រថែមទៀត ព្រោះវិទ្យាសាស្ត្របានអះអាងថា ហេតុនិងផលទាក់ទងគ្នាជានិច្ច ។ ហេតុតូច ផលតូច ហេតុធំ ផលធំ ហេតុល្អ ផលល្អ ហេតុអាក្រក់ ផលអាក្រក់ ។ល។

អាស្រ័យដោយហេតុនិងផលទាក់ទងគ្នាជាដរាបបែបនេះហើយទើប ព្រះពុទ្ធលើកយកទ្រឹស្តីភ្ជាប់ហេតុទៅនឹងផលនេះ មកអធិប្បាយពន្យល់អោយកាន់តែច្បាស់ នូវបុព្វហេតុនៃការកើត-ស្លាប់របស់សត្វលោក ។ ទ្រឹស្តីនេះមានឈ្មោះថា **ទ្រឹស្តីបដិច្ចសមុប្បាទ** ។

## ឃ- ទ្រឹស្តីបដិច្ចសមុប្បាទ.—

គឺជាធម៌ភាពភ្ជាប់ហេតុទៅនឹងផល(Loi de la causalité) ។ ធម៌ភាពនេះទ្រទ្រង់ធម្មជាតិ-មនុស្ស-សត្វជាដើម ដែលកើតឡើងក្នុងលោកនេះ ។ ទ្រឹស្តីបដិច្ចសមុប្បាទបានបញ្ជាក់ថា :

— បើនេះមាន នោះក៏មាន

— បើនេះគ្មាន នោះក៏គ្មាន

— បើនេះរលត់ នោះក៏រលត់ ។ល។



ដូចនេះពុំមានភាវៈណាមួយ កើតឡើងដាច់តែឯង ដោយគ្មានហេតុបច្ច័យទាក់ទងគ្នានោះទេ ហើយពុំមានភាវៈណាសំខាន់ជាងគេ រឺជាភាវៈដើមគេដូចភាវៈ **ព្រហ្មន** ក្នុងព្រាហ្មណ៍លទ្ធិឡើយ ។ ចំពោះដំណើរកើត-ស្លាប់នៃមនុស្ស ទ្រឹស្តីបដិច្ចសមុប្បាទបានលើកយកការទាក់ទងគ្នារវាងបុព្វហេតុទាំង ១២ មកពន្យល់ដូចតទៅនេះ :

១- **អវិជ្ជា** (ignorance) នាំអោយកើតសង្ខារ

២- **សង្ខារ** (formation) នាំអោយកើតវិញ្ញាណ

៣- **វិញ្ញាណ** (conscience) នាំអោយកើតនាមរូប

៤- **នាមរូប** (mentalité et physique)នាំអោយកើតអាយតនៈ

៥- **អាយតនៈ** (sens) នាំអោយកើតផស្សៈ

៦- **ផស្សៈ** (contact sensoriel) នាំអោយកើតវេទនា

៧- **វេទនា** (sensation) នាំអោយកើតតណ្ហា

៨- **តណ្ហា** (désir,soif) នាំអោយកើតឧបាទាន

៩- **ឧបាទាន** (attachement) នាំអោយកើតភព

១០- **ភព** (existence) នាំអោយកើតជាតិ

១១- **ជាតិ** (naissance) នាំអោយកើតជរា

១២- **ជរា** (vieillesse) នាំអោយកើតមរណៈ (mort) ។

បើមានធាតុណាមួយកើតឡើង ធាតុឯទៀត ៗ រឺភាវៈឯទៀត ៗ ក៏កើតឡើងបន្តបន្ទាប់គ្នា ដូចជា **អវិជ្ជា** កាលបើកើតមានហើយ អវិជ្ជានោះ

នាំអោយកើតសង្ខារ ឯសង្ខារនាំអោយកើតវិញ្ញាណតទៅទៀតហូរហែរហូតដល់នាំអោយមាន ជរា មានមរណៈ ។ ផ្ទុយទៅវិញបើអវិជ្ជារលត់ សង្ខារក៏រលត់ រលត់តៗគ្នាលុះត្រាតែអស់រលីងដែលហៅថានិរោធពោលគឺការជ្រះស្រឡះ ការរលត់រលាយអស់នូវសេសសល់នៃការកើត-ស្លាប់ រឺនៃទុក្ខនេះឯង ។

ទំនាក់ទំនងគ្នាទៅវិញទៅមកបែបនេះ មានសភាពដូចច្រវាក់ដែលប្រទាក់គ្នាជាកម្រង ( chaine de causalité ) រឺជារង្វង់មូលពុំមានចុងពុំមានដើមហើយដែលមានចលនាវិលចុះវិលឡើងមិនចេះចប់ ។

រួចមកហើយ យើងបានដឹងនូវគោលសំខាន់ៗខ្លះ នៅក្នុងព្រាហ្មណ៍សាសនានិងពុទ្ធសាសនា ។ សាសនាទាំងពីរនេះ ដែលបានមកប្រតិស្ឋាននៅក្នុងប្រទេសខ្មែរយើងតាំងពីយូរយារណាស់មកហើយ តើមានវិវត្តន៍ (évolution) យ៉ាងណាខ្លះដែរ ?

*

* *

# ៣- វិវត្តន៍នៃព្រាហ្មណ៍សាសនានិងពុទ្ធសាសនា(5)(10)

## ក- សម័យនគរភ្នំ ( ស.វ. ទី ១ ដល់ ៦ ).—

នៅសម័យនោះ មានការគោរពព្រាហ្មណ៍សាសនាផង ពុទ្ធសាសនាផង ។ អ្នកខ្លះកាន់សាសនាព្រាហ្មណ៍ ខ្លះទៀតកាន់សាសនាព្រះពុទ្ធ ។

ខាងសាសនាព្រាហ្មណ៍ គេនិយមគោរពព្រះឥសូរជាធំ ឯព្រះវិស្ណុ ព្រះហរិហរៈ ( ឥសូរនិងនារាយណ៍រួមគ្នា ) ព្រះព្រហ្ម ក៏មានគេគោរពខ្លះដែរ ។ ខាងសាសនាព្រះពុទ្ធ គេពេញចិត្តនឹងពុទ្ធសាសនាថេរវាទ ( និកាយហីនយាន ) ។ នៅស.វ. ទី២ ពុទ្ធសាសនាចំរើនលូតលាស់ជាងព្រាហ្មណ៍សាសនា ។

## ខ- សម័យចេនឡា ( ស.វ. ទី៦ ដល់ ៨ ).—

នៅសម័យចេនឡា គេឃើញព្រាហ្មណ៍សាសនាលូតលាស់ជាងពុទ្ធសាសនារហូតមកដល់ស.វ.ទី១២ ។ ប៉ុន្តែ ពុទ្ធសាសនាហីនយានមិនសាបសូន្យភ្លាមទេ ជាភស្តុតាង គេប្រទះឃើញព្រះពុទ្ធរូបនៅព្រៃកប្បាស ដែលបានសាងឡើងនៅស.វ.ទី៧ និងសិលាចារឹកជាច្រើនទៀត ។ នៅចុងស.វ.ទី៧ ពុទ្ធសាសនាមហាយានក៏ផ្សាយចូលមកដល់ស្រុកខ្មែរ ហើយលូតលាស់រហូតដល់ស.វ.ទី១៣ ប៉ុន្តែមិនសូវឃើញមានរូបបដិមាពោធិសត្វលោកេស្វរៈទេ គេប្រទះឃើញមានមួយនៅក្រមួនស (កម្ពុជាក្រោម) និងមួយទៀតនៅប្រាសាទតាកៀម (សៀមរាប) ។ ដល់ស.វ.ទី៨ ព្រាហ្មណ៍សាសនានៅតែលូតលាស់ទៀត ។

## គ – សម័យមហានគរ (ស.វ.ទី៩ ដល់ ១៥).–

នៅស.វ.ទី៩ព្រាហ្មណ៍សាសនាកាន់តែលូតលាស់ ព្រោះព្រះបាទជ័យវរ្ម័នទី ២ ទ្រង់សព្វព្រះទ័យកាន់ព្រាហ្មណ៍សាសនា និយមព្រះឥសូរជាធំ ។ ព្រះអង្គទ្រង់បានចាត់ចែងអោយអញ្ជើញព្រាហ្មណ៍ដ៏ប្រសើរម្នាក់ឈ្មោះ ហិរណ្យទាម ជាអ្នកប្រាជ្ញចេះចប់ត្រៃវេទអោយមកជួយរៀបចំធ្វើពិធី ទេវរាជ (Culte du Roi-Dieu) ដើម្បីប្រកាសឯករាជ្យដល់ប្រទេសកម្ពុជាហើយធ្វើព្រះរាជាអោយទៅជា ព្រះរាជចក្រពត្រាធិរាជ នៅលើភ្នំគូលែន ។ ព្រះអង្គទ្រង់បានអោយគេសាងលិង្គ ព្រះឥសូរតំកល់





ពិធីទេវរាជ

(រូបដកស្រង់ពីប្រជុំទស្សនាវដ្តី)

ក្នុងប្រាសាទភ្នំទុកជាទីគោរព ។ ពិធីតំកល់លិង្គព្រះឥសូរនេះក៏បានទៅជាមូលដ្ឋាននៃការសាងប្រាសាទភ្នំតមកទៀត ។

នៅចុង ស.វ.ទី ៩ (គ.ស. ៨៨៩) ព្រះបាទ យសោវរ្ម័នទី ១ ទ្រង់បានឡើងសោយរាជ្យបន្តមកទៀត ហើយទ្រង់កាន់ព្រាហ្មណ៍សាស

នា និយមព្រះឥស្វរជាធំ ប៉ុន្តែព្រះអង្គទ្រង់ប្រោសប្រាណពុទ្ធសាសនាដែរ ជាភស្តុតាង ព្រះអង្គបានសាងអាស្រមជាច្រើនកន្លែងសំរាប់អោយអ្នកកាន់សាសនាទាំង ៣ ប្រភេទ (ពុទ្ធសាសនាហីនយាន ពុទ្ធសាសនាមហាយាននិងព្រាហ្មណ៍សាសនា)ទៅរៀនអំពីសាសនារហូតដល់ទស្សនវិជ្ជានៅទីនោះ ។ ក្នុងរជ្ជកាលតៗមក មានព្រះរាជាជាច្រើនអង្គនិយមព្រាហ្មណ៍សាសនាគោរពព្រះឥស្វរជាធំដែរ ។

លុះដល់ ស.វ. ទី ១២ ក្នុងរាជ្យព្រះ **បាទសុរិយាវរ្ម័នទី២** (គ.ស. ១១១៣) មានការប្រែប្រួលខ្លះក្នុងព្រាហ្មណ៍សាសនា គឺព្រះរាជាអង្គនេះជាព្រាហ្មណ៍សាសនិក គោរពព្រះវិស្ណុជាធំ ។ គេប្រទះឃើញក្បាច់ចំលាក់ជារឿងនៅតាមជញ្ជាំងប្រាសាទអង្គរវត្ត ទាក់ទងទៅនឹងអវតារព្រះវិស្ណុ ដូចជាចំលាក់រឿងរាមាយណៈ មហាភារតៈ ជាដើម ។ នៅចុង ស.វ. ទី ១២ គេបានសង្កេតឃើញមានការរេមកកាន់ពុទ្ធសាសនាវិញ ។

នៅ ស.វ. ទី ១៣ ពុទ្ធសាសនា ចំរើនល្អលាស់ម្តងវិញ ។ ព្រះ **បាទជ័យវរ្ម័នទី ៧** ជាពុទ្ធសាសនិកដ៏ឆ្នើម ទ្រង់កាន់ពុទ្ធសាសនាមហាយាន គោរពព្រះពោធិសត្វលោកេស្វរៈនិងប្រជ្ញាបារមិតា តាមប្រពៃណីព្រះវរបិតា ។ព្រះអង្គទ្រង់បានផ្លាស់ប្រពៃណីដែលធ្លាប់គោរព**ទេវរាជ**តាំងពីរាជ្យព្រះ**បាទជ័យវរ្ម័នទី២** មក ហើយគោរព **ពុទ្ធរាជ** (Culte du Roi-Bouddha) វិញ ។ ទោះបីព្រះអង្គជាពុទ្ធសាសនិកយ៉ាងមុតមាំក៏ដោយ ក៏ព្រះអង្គនៅតែប្រោសប្រាណព្រាហ្មណ៍សាសនាដែរ ។ ព្រះ



អង្គបានសាងប្រាសាទជាច្រើនដើម្បីឧទ្ទិសថ្វាយព្រះពុទ្ធសាសនា មានប្រាសាទបាយ័នជាដើម ហើយគេបានសាងពុទ្ធបដិមាជារូបអង្គ **ពុទ្ធរាជ** តំកល់ក្នុងប្រាសាទបាយ័ននោះ ដើម្បីជាតំណាងព្រះអង្គកាលទ្រង់ចូលទីវង្គតទៅ ។ ចំណែកឯពោធិសត្វលោកេស្វរៈសមន្តមុខ ដែលនៅគ្រប់កំពូលបែរព្រះភក្ត្រញញឹមស្រស់ប្រិមប្រិយទៅគ្រប់ទិសទាំង៤ (ហៅញញឹមបាយ័ន) ក៏ទុកដូចជារូបអង្គ **ពុទ្ធរាជ** ដែរ ។

ក្រោយរជ្ជកាល **ព្រះបាទជ័យវរ្ម័នទី ៧** ព្រះរាជាដែលសោយរាជ្យជាតំណរាជវង្សត្រឡប់មកកាន់សាសនាព្រាហ្មណ៍គណៈឥស្វរវិញ ។ គេសង្កេតឃើញមានប្រតិកម្មនៃសាសនាព្រាហ្មណ៍ ដោយមានការបំផ្លាញព្រះពុទ្ធរូប (វាយបំបែក ខ្វះរីដាប់យកពុទ្ធរូបចេញ) ។

លុះមកដល់ចុង ស.វ. ទី ១៣ ពុទ្ធសាសនាមហាយានក៏សាបរលាបទៅ ហើយមកដល់ ស.វ. ទី ១៤ ព្រាហ្មណ៍សាសនាក៏បាត់បង់ទៅទៀត នៅសល់តែពិធីខ្លះក្នុងរាជវាំង ។ ចំណែកឯពុទ្ធសាសនាភាសាបាលី (ដែលនាំចូលមកនៅ ស.វ. ទី ១២) ក៏បានលូតលាស់ដុះដាលចំរើនយ៉ាងក្រៃលែងរហូតមកដល់សម័យបច្ចុប្បន្ននេះ ។

រួមសេចក្តីមក យើងសង្កេតឃើញថា សាសនាដែលចូលមកប្រតិស្ឋានក្នុងប្រទេសខ្មែរយើងនេះមានវិវត្តន៍ច្រើនលើក ច្រើនគ្រាណាស់ ដោយហេតុថា ព្រះរាជាដែលសោយរាជ្យតៗគ្នានោះ និយមគោរពសាសនាខុសៗគ្នា ។ ម្ល៉ោះហើយសាសនាត្រូវតែផ្លាស់ប្តូរទៅតាមការ

និយមក្នុងសម័យនោះដែរ ។ បើរាជាអង្គណានិយមកាន់សាសនាណាមួយ សាសនានោះក៏ចំរើនរុងរឿងទៅ ហើយសាសនាឯទៀតក៏ត្រូវអន់ថយ រឺអាប់អោន ។

អាស្រ័យដោយខ្មែរយើងបានទទួលកាន់សាសនាព្រាហ្មណ៍ និងសាសនាព្រះពុទ្ធច្រើនសតវត្សមកហើយ ហើយទោះបីព្រាហ្មណ៍សាសនា និងពុទ្ធសាសនាមហាយានសាបរលាបទៅវិញក៏ដោយ ក៏ឥទ្ធិពលនៃសាសនាទាំងនោះបានចាក់រឺសយ៉ាងមាំក្នុងសន្តានចិត្តខ្មែរ ក្នុងសង្គមខ្មែរ ដូចជាក្នុងផ្នែកជំនឿ -សិល្បៈ-ទំនាមទំលាប់-ប្រពៃណី-ភាសា-អក្សរ-អក្សរសិល្ប៍ជាដើម ។

*

* *

# ជំពូកទី២

# ភាសា-អក្សរ-អក្សរសិល្ប៍

## ១- ភាសា

ភាសា គឺពាក្យសម្តីដែលយើងនិយាយ ប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដើម្បីសំដែងនូវឆន្ទៈ សញ្ចេតនា ចិត្តគំនិតអ្វីមួយ ។ នៅក្នុងលោកយើងនេះ គ្រប់ជាតិសាសន៍សុទ្ធតែមានភាសាផ្ទាល់របស់ខ្លួន សំរាប់ប្រើទាក់ទងគ្នានៅក្នុងសង្គមជាតិរៀង ៗ ខ្លួន ។ ភាសានៃជាតិសាសន៍នីមួយ ៗ មានកំណើតឡើងដំណាលគ្នានឹងកំណាកំណើតនៃជាតិសាសន៍នោះដែរ ហើយបានវិវត្ត ប្រែប្រួល ចំរើនល្អតលាស់ រឺ អន់ថយទៅតាមសង្គមមនុស្សនោះថែមទៀត ។ ភាសាវិទូបានសិក្សាស្រាវជ្រាវអំពីភាសាទាំងអស់ក្នុងលោកឃើញថា ភាសាមានចំនួនច្រើនណាស់ បើរាប់ទាំង

ភាសាតូច-ធំ-ស្លាប់-រស់ មានចំនួន ពីពីរពាន់ប្រាំរយទៅបីពាន់ប្រាំរយភាសា ។ ក្នុងចំណោមភាសាទាំងនោះ ភាសាវិទូបានធ្វើប្រភេទវិភាគ ចែកភាសាជាក្រុម រឺ អំបូរ ។ ភាសាដែលអាចស្ថិតនៅក្នុងអំបូរជាមួយគ្នាបាន លុះត្រាតែមានលក្ខណៈពិសេសប្រហែល ៗ គ្នា ។ អំបូរភាសាធំ ៗ មានចំនួន ២០ ដូចជា :

- អំបូរឥណ្ឌូ-អឺរ៉ុប គឺជាអំបូរភាសាមួយ ទូលំទូលាយក្នុងបណ្ដាអំបូរភាសាក្នុងលោក គ្របដណ្ដប់លើទ្វីបអឺរ៉ុបជិតតែទាំងអស់ និងលើមួយភាគធំនៃប្រទេសឥណ្ឌា ។
- អំបូរខ្មែរ-មន គឺជាអំបូរធំសំខាន់មួយនៅទ្វីបអាស៊ីអគ្នេយ៍ ។
- អំបូរ ម៉ាឡាយ៉ូ-ប៉ូលីនេស៊ី គឺជាអំបូរធំគួរសម ស្ថិតនៅតាមកោះ និងនៅទៀបកោះ ក្នុងភាគខ្លះនៃមហាសមុទ្រប៉ាស៊ីហ្វិក និងនៃមហាសមុទ្រឥណ្ឌា (១) ។

ចំពោះភាសាខ្មែរយើង តើមានប្រភព-វិវត្តន៍និងលក្ខណៈពិសេសយ៉ាងណាទៅដែរ ?

## ក.ប្រវត្តិនៃភាសាខ្មែរ.–

(១) សូមអានអត្ថបទ «អំបូរភាសាក្នុងលោក» របស់លោក គង់ អ៊ីន និងលោក ឡុច ផ្លែង ចុះផ្សាយក្នុងទស្សនាវដ្ដីខេមរយានកម្ម ឆ្នាំទី ៣ លេខ ១ ខែតុលា ឆ្នាំ ១៩៦៩ ទំព័រ 85 ។



ដូចយើងបានពោលរួចមកហើយថា ភាសាមានកំណើតដំណាលគ្នានឹងកំណើតមនុស្ស ។ យ៉ាងណាមិញ ប្រវត្តិសាស្ត្រខ្មែរបានចែងថា ជាតិសាសន៍ខ្មែរមានយូរយារណាស់មកហើយ ( ប្រមាណ ៣០០០ ឆ្នាំមុន គ.ស. ) គឺជាជាតិសាសន៍ដែលធ្លាប់មានអរិយធម៌រុងរឿងក្នុងចំណោមជាតិសាសន៍ដទៃ ក្នុងភូមិភាគអាស៊ីអគ្នេយ៍ ។ ដូចនេះភាសាខ្មែរ ដែលមានប្រភពជាប់គ្នានឹងជាតិកំណើតមនុស្សខ្មែរ ក៏កើតមានតាំងពីយូរណាស់មកហើយដែរ ។ ក្រោយដែលបានសិក្សាស្រាវជ្រាវអំពីភាសាខ្មែរអស់ពេលជាយូរមក ភាសាវិទូបរទេសបានបញ្ចូលភាសានេះ ទៅក្នុងអំបូរភាសាធំមួយក្នុងចំណោមអំបូរភាសានៅទ្វីបអាស៊ីអគ្នេយ៍ គឺអំបូរ ខ្មែរ-មន នេះឯង ។ តាមលោក ពីណូវ H.J.Pinnow អំបូរភាសាខ្មែរ-មនជាក្រុមភាសាមួយដែលគួរចាប់អារម្មណ៍ជាងគេក្នុងបណ្ដាភាសាអាស៊ី ភាគខាងត្បូង ( អំបូរភាសា អូស្ត្រូអាស៊ី : អំបូរភាសាម៉ាឡាយូ-ប៉ូលីនេស៊ី អំបូរភាសា ថៃ-វៀតណាម អំបូរភាសាខ្មែរ-មន) ព្រោះជាភាសាដែលមានប្រវត្តិអក្សរប្លែកពីភាសាដទៃទៀតដែលទើបតែមានភាសាសរសេរ ហើយខ្លះទៀតនៅតែគ្មានអក្សរសរសេរដដែល (11) ។

ចំពោះពាក្យ ខ្មែរ-មន នេះធ្វើអោយយើងមានចំងល់តទៅទៀតថា តើមន ជាអ្វី? ហើយនៅឯណា? តើមានជាតិសាសន៍ខ្មែរនិងមនពីរនេះទេ រឺដែលនៅក្នុងអំបូរនេះ ?

តាមការស្រាវជ្រាវ គេបានដឹងថា នៅក្នុងអំបូរ ខ្មែរ-មន ពុំមែន

មានតែជាតិ **ខ្មែរ** និងជាតិ **មន** ប៉ុណ្ណោះទេ គឺមានជាតិជាច្រើនទៀតដែលរស់នៅក្នុងប្រទេសនានានៃអាស៊ីអគ្នេយ៍ ហើយដែលមានភាសាស្រដៀងគ្នាក្នុងផ្នែក **សូរសាស្ត្រ** ( la phonétique ) **រូបសាស្ត្រ** (la morphologie ) និង **និរុត្តិសាស្ត្រ** ( la sémantique ) ។ ឯជនជាតិទាំងនោះមានជាអាទិ៍ :

— សេណូយ សេម៉ាង . . . នៅសហពន្ធម៉ាឡេស៊ីយ៉ា
— ប៉ាឡោង វ៉ា . . . នៅប្រទេសភូមា
— ខ្មុ អាឡាក់ ល្មិត . . . នៅប្រទេសលាវ
— ស្ទៀង កួយ ព័រ ស្អូច ជង ព្នង . . . នៅសាធារណរដ្ឋខ្មែរ
— ម្នង បាហ្នារ សេដង់ ព្រៅ . . . នៅប្រទេសវៀតណាម ។

ក្នុងចំណោមជនជាតិទាំងនោះ មានតែជនជាតិ **ខ្មែរ** និង **មន** ទេ ដែលមាន**អរិយធម៌ខ្ពង់ខ្ពស់**ជាងគេ ពីព្រោះជនជាតិទាំងពីរនេះរស់នៅត្រង់តំបន់វាលទំនាបនៃទន្លេ ដែលមានដីជាតិអាចប្រកបរបរកសិកម្មបានយ៉ាងប្រសើរ ហើយមានទំនាក់ទំនងជាមួយនឹងបរទេសជាច្រើនថែមទៀត ។ ជនជាតិ **ខ្មែរ**រស់នៅត្រង់តំបន់វាលទំនាបនៃទន្លេមេគង្គ ឯជនជាតិ **មន**រស់នៅត្រង់តំបន់មេណាម(ប្រទេសសៀម)និងតំបន់វាលទំនាបនៃទន្លេឥរាវតី (ប្រទេសភូមាសព្វថ្ងៃ) ។ ឯជនជាតិក្រៅពីនោះច្រើនរស់នៅតាមព្រៃភ្នំ ។ អាស្រ័យដោយអរិយធម៌នៃជនជាតិ **ខ្មែរ** និង **មន** លូតលាស់រុងរឿងនេះ ហើយ ទើបគេនិយមប្រើពាក្យ **មន-ខ្មែរ** (តាមទស្សនៈអ្នកប្រាជ្ញបរទេស)



រឺ ខ្មែរ-មន (តាមទស្សនៈខ្មែរ) ដូចពាក្យអំបូរខ្មែរ-មន អរិយធម៌ខ្មែរ-មន ជាដើម ។ ប៉ុន្តែចាប់ពីសតវត្សទី១៦មក ជនជាតិមនក៏បានបាត់បង់ទឹកដីនិងអធិបតេយ្យរបស់ខ្លួនរហូតមក ដូចជាជនជាតិចាមសព្វថ្ងៃនេះដែរ(12) ។

## ១-វិវត្តន៍នៃភាសាខ្មែរ. —

ភាសាក៏ដូចជាធាតុឯទៀតៗនៃអរិយធម៌ដែរ តែងប្រែប្រួលចំរើនលូតលាស់រីកចំរើនស្របតាមការរស់នៅរបស់មនុស្សក្នុងសង្គម ។ គេបានកត់សំគាល់ឃើញថា ភាសាសរសេរវិវត្តពុំទាន់ភាសានិយាយទេ ។

ចំពោះកំណកំណើតភាសាខ្មែរ ដែលមានជីវិតរហូតមកដល់សម័យបច្ចុប្បន្ននេះ អ្នកប្រាជ្ញខាងភាសាបានសង្កេតឃើញ មានវិវត្តន៍ ៣ លើកធំៗគឺ :

—ភាសាខ្មែរបុរាណ ( តាំងពីកំណកំណើតមកដល់ ស.វ. ទី ១៥ )
—ភាសាខ្មែរកណ្តាល ( ស.វ. ទី ១៦ ដល់ ស.វ. ទី១៩)
—ភាសាខ្មែរបច្ចុប្បន្ន ( ស.វ.ទី ២០ . . . ) ។

នៅសម័យអាណាព្យាបាលបារាំង វិវត្តន៍នៃភាសាខ្មែរត្រូវបានបន្ថយល្បឿន ហើយរត់ទៅសំងំក្នុងវត្តអារាមដែលមានព្រះសង្ឃជួយថែរក្សាទុកអោយ ។ គេបង្ខំអោយរៀនភាសាបារាំងជាយាន ជាផ្លូវការ ដែលជាហេតុនាំអោយខូចប្រយោជន៍ដល់ភាសាជាតិនេះឯង ។

នៅសម័យឯករាជ្យ ភាសាខ្មែរត្រូវបានប្រកាសអោយប្រើជាផ្លូវការ

កំណើតគណៈកម្មការវប្បធម៌ មហាវិទ្យាល័យគរុកោសល្យ (អតីតវិជ្ជា-ស្ថានជាតិគរុកោសល្យ) មហាវិទ្យាល័យអក្សរសាស្ត្រ វិជ្ជាស្ថានជាតិខេមរយានកម្ម ជំរុញអោយមានការបង្កើតពាក្យពេចន៍ថ្មី ៗ ជាច្រើនទៀតដើម្បីប្រើការអោយទាន់សម័យនិយម ។ ក្រៅពីពាក្យកំណើត ពាក្យបង្កើតថ្មី គេប្រទះឃើញពាក្យបរទេសជាច្រើននៅលាយឡំក្នុងភាសាខ្មែរ ។

ឯល្បាយភាសានេះកើតឡើងនៅពេលដែលខ្មែរមានទំនាក់ទំនងជាមួយនឹងបរទេស ដូចជាទាក់ទងក្នុងកិច្ចការទូត-ទេសចរណ៍-ពាណិជ្ជកម្មសិក្សាអប់រំ-ជំនឿសាសនា ។ល។ គេបានកត់សំគាល់ឃើញថាភាសាមានអាយុវែងកាលណា ល្បាយភាសាក៏កាន់តែមានច្រើនឡើង ៗ សឹងរកភាពសុទ្ធរបស់ខ្លួនពុំឃើញ ។ ឯភាសាបរទេសដែលនៅលាយឡំច្រើនជាងគេក្នុងភាសាខ្មែរយើងសព្វថ្ងៃ គឺភាសាបាលីនិងសំស្ក្រឹត ។ ភាសាបាលីហូរចូលមកក្នុងភាសាខ្មែរ តាមរយៈពុទ្ធសាសនាហីនយាន ឯភាសាសំស្ក្រឹតហូរចូលតាមរយៈពុទ្ធសាសនាមហាយាននិងព្រាហ្មណ៍សាសនា ។ ដោយជនជាតិខ្មែរយើងនិយមគោរពសាសនាឥណ្ឌាទាំងនេះហើយ បានជាភាសាបាលី-សំស្ក្រឹតព្រមទាំងក្បួនខ្នាតវេយ្យាករណ៍ មានឥទ្ធិពលខ្លាំងក្លាមកលើភាសាខ្មែរ ហើយចាក់រឹសតល់មកដល់សព្វថ្ងៃ ជាហេតុនាំអោយអ្នកខ្លះដែលមើលលក្ខណៈដើមនៃភាសាខ្មែរពុំឃើញ ហើយក៏តាំងចោទថាភាសាខ្មែរមានប្រភពពីភាសាបាលី-សំស្ក្រឹតនេះឯង ។ ការពិត ភាសាទាំងពីរនេះចូលមកក្រោយពេលដែលខ្មែរមានភាសាផ្ទាល់ខ្លួនរួចស្រេច



ទៅហើយ ។ ដូចនេះ ភាសាខ្មែរពុំមែនកើតចេញមកពីភាសាបាលីសំស្ក្រឹត រឺភាសាបាលី-សំស្ក្រឹតជាម្តាយនៃភាសាខ្មែរ ដូចទស្សនៈរបស់លោក J. Taupin ( La littérature et la langue khmères sont filles du sanskrit ) នោះទេ ។ ខ្មែរប្រើពាក្យបាលី-សំស្ក្រឹតជាពាក្យកម្ចី ដើម្បីបង្គ្រប់នូវកង្វះខាតតែប៉ុណ្ណោះ ។ រីឯពាក្យបាលីសំស្ក្រឹតនេះសោតទៀត ក៏ត្រូវកែប្រែទាំងសូរសព្ទ ទាំងរូបសព្ទ ដើម្បីអោយស្របស្រួលមកនឹងសំដីខ្មែរ ចំណង់ចំណូលចិត្តខ្មែរ ។ ខេមរនីយកម្មបែបនេះពុំមែនធ្វើចំពោះតែពាក្យបាលី-សំស្ក្រឹតប៉ុណ្ណោះទេ ភាសាបរទេសណាក៏ដោយ ដែលជ្រាបចូលមកក្នុងភាសាខ្មែរ ត្រូវទទួលការផ្លាស់ប្តូរអោយមានលក្ខណៈជាខ្មែរដែរ ។ ម្យ៉ាងទៀត ភាសាបាលី-សំស្ក្រឹត ស្ថិតដាច់អំពីអំបូរខ្មែរ-មន ព្រោះមាន វិភត្តិ (déclinaison) ដូចភាសានៃជនជាតិអឺរ៉ុបដែរ ។ ដូចនេះភាសាបាលី-សំស្ក្រឹតនៅក្នុងអំបូរឥណ្ឌូ-អឺរ៉ុប ឯណោះទេ ។

## គ-លក្ខណៈពិសេសនៃភាសាខ្មែរ.-

ដើម្បីបំផុសអោយឃើញលក្ខណៈពិសេសនៃភាសាខ្មែរ និងដើម្បីកុំអោយមានការយល់ច្រលំដូចទស្សនៈខាងលើតទៅទៀត យើងសូមធ្វើការប្រៀបធៀបចំណុចសំខាន់ ៗ ខ្លះនៃភាសាខ្មែរ ទៅនឹងភាសាខ្លះទៀត ជាពិសេសភាសាបាលី-សំស្ក្រឹត ។

## អំពីការបន្លឺសម្លេង.–

ក្នុងការបន្លឺសម្លេង ពាក្យខ្មែរក្តី មនក្តី ពុំមានសម្លេងឡើងចុះ រឺលើកដាក់ខ្ពស់ទាបទៅតាមសញ្ញាប្រើដាក់លើពាក្យ ដែលនាំអោយផ្លាស់ប្តូរន័យរបស់ពាក្យនោះទេ ។ នេះជាចំណុចសំខាន់មួយ ដែលបង្ហាញនូវសភាពប្លែកគ្នារវាងភាសាខ្មែរ-មន និងក្រុមភាសាចិន-យួន-សៀម-លាវ ដែលជាភាសាភ្ជាប់ងយទៅនឹងសម្លេងខ្ពស់ទាប រឺចុះឡើង(Langues toniques)។

## អំពីចំនួនព្យាង្គ.–

ពាក្យខ្មែរសុទ្ធ ច្រើនតែមានចំនួនព្យាង្គតិច- គឺសម្បូណ៌ពាក្យមួយព្យាង្គ ប្លែកអំពីពាក្យបាលី-សំស្ក្រឹត ដែលច្រើនតែមានចំនួនព្យាង្គច្រើន ។ ក្នុងករណីពាក្យខ្មែរសុទ្ធ២ព្យាង្គ រឺច្រើនព្យាង្គគេបានសង្កេតឃើញថា ការបន្លឺតែងមានទំនោរទៅរកការបង្រួញព្យាង្គច្រើន អោយនៅសល់តិចបំផុត ដោយបន្ទើរស្នូរ រឺបង្រួញស្នូរនៅព្យាង្គមុខ ហើយសង្កត់ស្នូរនៅព្យាង្គក្រោយដូចពាក្យ :

ប្រអប់ > ប្អប់ ត្របែក > តបែក

ក្រមា > កមា សៀវភៅ > សភៅ ។ល។

ទំនោរបង្រួញព្យាង្គនេះ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើពាក្យ បាលី សំស្ក្រឹត ដែលចូលមកលាយឡំក្នុងភាសាខ្មែរ ហើយដែលមានចំនួន



ព្យាង្គច្រើនដូចជា :

ជាតិ (Jati) អាន ជាត } ២ព្យាង្គនៅសល់ ១ ព្យាង្គ
ទុក្ខ: (Dukkha) អាន ទុក }

និរន្តរ: (Nirantara) អាន និរាន់ : ៤ ព្យាង្គនៅសល់ ២ ព្យាង្គ

សមាធិ (Samadhi) ក្លាយទៅជាស្មាធិ៍ : ៣ ព្យាង្គនៅសល់ ១ ព្យាង្គ ។

នៅមានវិធីច្រើនបែបយ៉ាងទៀត ដែលខ្មែរយកមកអនុវត្ត ដើម្បីកែប្រែបង្រួញព្យាង្គ បាលី-សំស្ក្រឹតអោយមានលក្ខណៈបែបខ្មែរឡើង (ខេមរនីយកម្មចំនួនព្យាង្គ) ។ លក្ខណៈកែប្រែនេះ សអោយឃើញថា ខ្មែរពុំមែនចេះតែទទួលយកពាក្យបរទេសមកប្រើទាំងស្រុងទេ ។

## អំពីស្រះ ព្យញ្ជនៈ ព្យាង្គ.–

ក្នុងការធ្វើប្រភេទវិភាគស្រះ ព្យញ្ជនៈ ព្យាង្គ អោយមានគូគ្នា ភាសាខ្មែរបានសំអាងទៅលើគោលពិសេសមួយគឺ ខ្យល់ អ-អ៊ ។ ភាសាមន គេចែកជាខ្យល់ អ-អេ ឯភាសាបាលីសំ-ស្ក្រឹតមានតែខ្យល់ អះ (a) មួយទេ ។ ចំពោះខ្យល់ អ-អ៊ រួចមកហើយ មានអ្នកខ្លះយល់ច្រលំថា ព្យញ្ជនៈណាដែលមានខ្យល់ អ ជាព្យញ្ជនៈ អឃោសៈ ឯព្យញ្ជនៈណាដែលមានខ្យល់ អ៊ ជាព្យញ្ជនៈ ឃោសៈ ។ ប៉ុនតែតាមការពិសោធន៍ ដោយគ្រឿងម៉ាស៊ីនថតសម្លេង គេបានដឹងថាព្យញ្ជនៈពួកខ្យល់ អ ក្តី ខ្យល់ អ៊ ក្តី ដែលមានសម្លេងមិនខ្ទរខ្ទារ (ថ្លង់) ហៅថាព្យញ្ជនៈ អឃោសៈ ។

ចំណែកព្យញ្ជនៈ ឃោសៈ វិញ គឺព្យញ្ជនៈពួកខ្យល់ អ ក្តី ខ្យល់ អ៊ឹ ក្តី ដែលមានសម្លេងខ្ទរខ្ទារ(លឺ) ។ ព្យញ្ជនៈខ្យល់លឺមានចំនួនតិចណាស់ៈ បប៊-ដឌ-មម-ណន-ញញ-ងង-វវ-ឡល-រ-យយ (11) ។ ដូចនេះខ្យល់ អ ពុំដូចគ្នានឹងខ្យល់ អឃោសៈ ទេ ហើយខ្យល់ អ៊ឹ ក៏ពុំដូចគ្នានឹងខ្យល់ ឃោសៈ ដែរ ។ ក្នុងការចែកមូលសទ្ទ (ស្រៈ-ព្យញ្ជនៈ-ព្យាង្គ) ខ្យល់ អ-អ៊ឹ បានចែកញែកមូលសទ្ទនោះជាគូៗ គ្នាដូចជា :

ក- ស្រៈ { ខ្យល់ អ : ា ិ ី ឹ ឺ ..... ោ . ៅ ំ ...
ខ្យល់ អ៊ឹ : ា ិ ី ឹ ឺ ..... ោ . ៅ ំ ...

**សេចក្តីសង្ខេប** — សញ្ញាស្រៈមានតែមួយបែប ប៉ុន្តែសំគាល់ខ្យល់ អ ផង ខ្យល់ អ៊ឹ ផង ។

ខ- ព្យញ្ជនៈ { ខ្យល់ អ : ក ខ ច ឆ ...
ខ្យល់ អ៊ឹ : គ ឃ ជ ឈ ...

**សេចក្តីសង្ខេប.** — ព្យញ្ជនៈនីមួយ ៗ ដែលយើងអាចបន្លឺបាន អាស្រ័យដោយមានខ្យល់ អ រឺ អ៊ឹ កប់នៅក្នុងព្យញ្ជនៈនោះ ប៉ុន្តែ ស្រៈកប់ រឺ ស្រៈអនុស័យ (voyelle inhérente) នោះពុំឃើញរូបរាងទេ ។ ក្នុងព្យញ្ជនៈ ក មានស្រៈកប់ "អ" ក្នុងព្យញ្ជនៈ គ មានស្រៈកប់ "អ៊ឹ" ។ ដោយសារមានស្រៈកប់នៅក្នុងនោះហើយ បានជាព្យញ្ជនៈមួយតួ អាចនៅជាព្យាង្គមួយបានដូចជា :



ក (កដៃ - កដប) គ (មនុស្សគ) ត (តជាប់គ្នា) ជាដើម ។

ប៉ុន្តែគេអាចផ្តាច់ស្រៈកប់ចេញពីតួព្យញ្ជនៈ កាលណាព្យញ្ជនៈនោះមានមុខងារជាតួប្រកប ដូចពាក្យ ភាច គិត (ច និង ត គ្មានស្រៈកប់គេមានតែខ្យល់ផុំ) ។

គ- ព្យាង្គ { ខ្យល់ អ : ក - កម - ចុក - ញាំ ...
ខ្យល់ អ៊ឹ : គ - គម - ជុក - ញ៉ាំ ...

**អំពីវិធីកំលាយពាក្យ.** —

ភាសាខ្មែរយើងមានវិធីពិសេសក្នុងកំលាយពាក្យដើម រឺ រឹស (Racine) អោយក្លាយជាពាក្យផ្សេងៗ ហើយមានន័យប្លែកៗគ្នា ប៉ុន្តែស្ថិតនៅក្នុងក្រុមញាតិតែមួយ ដូចឧទាហរណ៍ក្នុងតារាងកំលាយ ខាងក្រោមនេះ :

| រឹស (ដែលជាកិរិយាសព្ទ) | កើត | ចាំ | សិត | ចុក | ជាន់ |
|---|---|---|---|---|---|
| ការិយាបន្ត (ធ្វើអោយ រឺញុំាងអោយ) | បង្កើត | បញ្ចាំ | ផ្សិត | បញ្ចុក | បញ្ជាន់ |
| នាម (មនុស្ស រឺអ្នកធ្វើ) | ខ្មើត | ឆ្មាំ | ស្មិត | ឆ្មុក | ឈ្មាន់ |
| នាម (ប្រដាប់ប្រើប្រាស់) | ខ្នើត | ឆ្នាំ | ស្និត | ឆ្នុក | ឈ្នាន់ |
| នាម (សភាព រឺអំពើ) | កំនើត (កំណើត) | ចំនាំ (ចំណាំ) | សំនិត (សំណិត) | ចំនុក (ចំណុក) | ជំនាន់ |

នេះជាក្បួនកំលាយពាក្យមួយបែបដែលមានរឹសដើមជាកិរិយាសព្ទ ។

ឫសដែលជាគុណនាមក៏អាចកំលាយទៅជានាមបានដែរ ដូចជា :

ធំ > ទំហំ, ទាប > ទំនាប, ចាស់ > ចំណាស់ ; ខូច > កំហូច ។ល។

កំណើតពាក្យដែលក្លាយចេញពីឫសដើមបែបនេះ មានទំនាក់ទំនងទៅនឹងវិធីប្រើបទភ្ជាប់ រឺអព្ភាស (Affixe) ។ បទភ្ជាប់ប្រើដាក់ពីខាងមុខឫស ហៅថា **បទមុខ រឺ បុព្វបទ** (Préfixe) ដូចក្នុងពាក្យបង្កើត (បជាបុព្វបទ) ។ បទភ្ជាប់ណាដែលប្រើចុះកណ្ដាលឫស ហៅថា **បទកណ្ដាល រឺ បទស្នៀត រឺ អន្តរបទ** (Infixe) ដូចពាក្យ ឆ្នាំ ឆ្នាំ ចំនាំ (-ន- ជាបទកណ្ដាល) ។ បទកណ្ដាលខ្មែរ ប្លែកពីបទកណ្ដាលបាលី-សំស្ក្រឹត ដែលហៅថា **អាគម** (Augment) ។ អាគមគ្រាន់តែចុះមកសំរួលការភ្ជាប់សន្ធិ អោយពីរោះតែប៉ុណ្ណោះ; ពុំមែនចុះមកបំបែកឫសអោយមានន័យប្លែកដូចបទកណ្ដាលខ្មែរឡើយ ។

ឧទាហរណ៍ : អ + អត្ថ > អ + ន + អត្ថ > អនត្ថ (ន = អាគម)

ចតុ + អង្គ > ចតុ + រ + អង្គ > ចតុរង្គ (រ = អាគម) ។

ចំណែកឯបទភ្ជាប់ខាងចុងឫស ដែលហៅថា **បទចុង រឺ បច្ឆិមបទ** (Suffixe) ពុំឃើញមានប្រើក្នុងភាសាខ្មែរទេ ។

## អំពីលិង្គ វចនៈ.—

និយាយពីលិង្គ (genre) ក្នុងទីនេះ ពុំមែនសំដៅលិង្គរបស់មនុស្ស រឺសត្វទេ គឺលិង្គរបស់ពាក្យ (genre du mot) ។ ពាក្យដែល



ជានាម នៅក្នុងភាសាឥណ្ឌូ-អឺរ៉ុប សុទ្ធតែមានលិង្គសំគាល់ ។ នាមបាលី-សំស្ក្រឹតមានលិង្គបីយ៉ាងគឺ :

— **បុំលិង្គ** (ភេទប្រុស រឺ ឈ្មោល) (masculin)
— **ឥត្ថីលិង្គ** (ភេទស្រី រឺ ញី) (Féminin)
— **នបុំសកលិង្គ** (មិនមែនភេទប្រុស-ស្រី) (neutre) ។

គេសំគាល់លិង្គទាំង ៣ ប្រភេទដោយសារ **ការន្ត** (terminaison) គឺកំណត់ត្រង់ស្រៈដែលនៅខាងចុងនៃពាក្យ ។

— **ការន្តបុំលិង្គ** គឺ : អ-ឥ-ឦ-ឧ-ឩ, ឧ. មនុស្ស-មុនិ-សេដ្ឋី-គរុ-វិទូ...
— **ការន្តឥត្ថីលិង្គ** គឺ : អា-ឥ-ឦ-ឧ-ឩ, ឧ. វាចា-មុតិ-នារី-ធាតុ-វិធូ...
— **ការន្តនបុំសកលិង្គ** គឺ: អ-ឥ-ឧ ឧ. ផល-អដ្ឋិ-អាយុ ...

វចនៈ (nombre) របស់នាមក៏មានគ្រឿងសំគាល់ជាប់នឹងពាក្យដែរ ។

ឧ. មនុស្សោ (ឯកវចនៈ) មនុស្សា (ពហុវចនៈ) ⟹ មានមុខងារជាប្រធាន

មនុស្សំ (ឯកវចនៈ) មនុស្សេ (ពហុវចៈ) ⟹ មានមុខងារជាកម្មបទ

ក្នុងភាសាបារាំង គេសំគាល់លិង្គនិងវចនៈ របស់នាម ដោយសារមានពាក្យនៅពីខាងមុខ (articles : le-la-les-un-une-des) រឺទ្រង់ទ្រាយ (forme) នៃពាក្យនោះ ។

ឧ. la maison (n. fém, sing.) ; les cahiers (n.mas. plur.)

le cheval (n. mas. sing.); la jument (n. fém.sing.); les chevaux. (n.mas. plur.).

តើពាក្យខ្មែរមានលិង្គនិងវចនៈដែររឺទេ? សៀវភៅវេយ្យាករណ៍ខ្មែរ រួចមកហើយ ហើយដែលបានទទួលឥទ្ធិពលវេយ្យាករណ៍បាលី-សំស្ក្រឹត បានអធិប្បាយថាពាក្យខ្មែរមានលិង្គ-វចនៈដែរ ។ ប៉ុន្តែគ្មានគ្រឿងជាប់នឹងពាក្យប្រែទ្រង់ទ្រាយ សំរាប់សំគាល់ដូចភាសាឥណ្ឌូ-អឺរ៉ុបទេ គឺសំគាល់តាមន័យនៃពាក្យនោះរឺ ក៏បន្ថែមពាក្យពីក្រោយដូចជា :

ប្តី-ឪពុក-មនុស្សប្រុស-ឆ្កែឈ្មោល ... (បុំលិង្គ)

ប្រពន្ធ-ម្តាយ-មនុស្សស្រី-ឆ្កែញី ...(ឥត្ថីលិង្គ)

ក្មេង-ឆ្កែ-ផ្ទះ-បង-ប្អូន ... (អលិង្គ) ។

នៅមានលិង្គម្យ៉ាងទៀតហៅថា នបុំសកលិង្គ គឺពុំមែនប្រុស ពុំមែនស្រី ពុំមែនញី ពុំមែនឈ្មោល (គឺខ្ទើយ) ។

គេបានបញ្ជាក់ទៀតថា តាមបញ្ញត្តិនៃក្បួនហោរាថា នាមរបស់មនុស្សប្រុស និងងាររបស់មន្ត្រីគឺជាបុំលិង្គ ឯនាមរបស់ មនុស្សស្រី រឺនាមរបស់ ស្រុក-ភូមិ-ខេត្ត-វត្ត-នគរ និងឈ្មោះគ្រឿងលេងដូចជាអង្គុញ-បាយខុំ-ចត្រង្គ ជាដើម ជាឥត្ថីលិង្គ ។

ចំពោះវចនៈ គេសំគាល់ដោយមានពាក្យភ្ជាប់ពីក្រោយ ។

ឧ. សេះមួយ (ឯកវចនៈ) ; គោ៥ក្បាល (ពហុវចនៈ) ; ពពែមួយហ្វូង (ពហុវចនៈ) ។



ការអធិប្បាយបែបនេះ ពុំមានក្បួនខ្នាតច្បាស់លាស់ទេ ហើយការខំទាញភាសាខ្មែរ អោយមានលិង្គមានវចនៈ ដូចភាសាបាលី-សំស្ក្រឹត ក៏ឃើញថាមិនសមហេតុសមផលដែរ ។

បើយើងពិចារណាអោយបានម៉ត់ចត់ទៅ យើងនឹងឃើញថា ពាក្យខ្មែរគ្មានលិង្គ គ្មានវចនៈទេ ។ ប៉ុន្តែមានពាក្យសំរាប់សំគាល់ភេទរបស់មនុស្សប្រុស-ស្រី របស់សត្វ ញី-ឈ្មោល ដែលគេប្រើភ្ជាប់នឹងនាមដូចជា បងប្រុស-ក្មេងស្រី-មាន់ញី-ទាឈ្មោល និងពាក្យម៉ែ-ម្តាយ-ឪពុក-ជីដូន-ជីតា-មា-មីង-ពូ (ពាក្យបែបនេះមានចំនួនតិចណាស់) ។ ឯពាក្យសំរាប់សំគាល់វចនៈ ដូចពាក្យ: មួយ-ពីរ-ទាំងអស់-ទាំងឡាយ-ទាំងពួង-ហ្វូង ។ល។

តើមានប្រយោជន៍អ្វីដែលខំធ្វើអោយពាក្យខ្មែរ មានលិង្គ មានវចនៈ?

## អំពីសម្ព័ន្ធ.—

ប្រសិនបើយើងយល់ថាពាក្យខ្មែរ ត្រូវតែមានលិង្គ មានវចនៈ ជាការឥតប្រយោជន៍សោះ ហើយនាំអោយកាន់តែស្មុកស្មាញថែមទៀត ព្រោះក្នុងភាសាខ្មែរ ពាក្យពេចន៍នៅក្នុងឃ្លាប្រយោគពុំមានការប្រែប្រួល ផ្លាស់ប្តូររូបរាង ទៅតាមលិង្គវចនៈ បុរិសៈ កាល ឡើយ ។ ភាសាខ្មែរគឺជាភាសាអវិភត្តិ (langue indéclinale) ។ ផ្ទុយទៅវិញ ក្នុងភាសាអំបូរឥណ្ឌូ-អឺរ៉ុបពាក្យកិរិយាក្តី នាមក្តី គុណនាមក្តី កាលណាតែមានទំនាក់ទំនងគ្នា (accord) ក្នុងឃ្លាប្រយោគហើយ ត្រូវតែមានវិភត្តិជាងរាប់ បានសេចក្តី

ថា ត្រូវផ្លាស់ប្ដូររូបរាងអោយប្លែកពីធម្មតា ។

ឧ. អហំ កាឡំ សុនខំ បស្សាមិ (ឯកវចនៈ)
(ខ្ញុំ) (ខ្មៅ) (សុនខ) (ឃើញ)
មយំ កាឡេ សុនខេ បស្សាម (ពហុវចនៈ)
(យើង) (ខ្មៅ) (សុនខច្រើន) (ឃើញ) ។

ចំពោះរបៀបពាក្យក្នុងឃ្លាបាលីនេះ ពុំរៀបរយតាមលំដាប់លំដោយសោះ គេនិយមដាក់ច្របូកច្របល់គ្នា ប្លែកពីឃ្លាប្រយោគខ្មែរ ដែលមានលក្ខណៈសមហេតុ សមផល មានលំដាប់ លំដោយហូរហែគ្នាទៅតាមហេតុការណ៍ដូចឃ្លាថា :

ខ្ញុំ ឃើញ សុនខ ខ្មៅ
(ប្រធាន) (កិរិយា) (កម្មបទ) (លក្ខណៈនៃកម្មបទ)

ប្រសិនបើប្រធានមានចំនួនច្រើនទៅវិញ ក៏ពាក្យទាំងនោះពុំប្រែប្រួលរូបរាងដែរ ហើយប្រសិនបើចង់អោយឃ្លានោះមានន័យប្លែកពីមុន គេគ្រាន់តែថែមពាក្យខ្លះប៉ុណ្ណោះដូចជា :

យើងទាំងអស់គ្នាឃើញសុនខជាច្រើន

អាស្រ័យដោយភាសាខ្មែរគ្មានវិភត្តិបែបនេះហើយ បានជាយើងយល់ថា មិនចាំបាច់មានលិង្គនិងវចនៈ សំរាប់ពាក្យខ្មែរទេ យើងអាចចងក្រងឃ្លាប្រយោគបានយ៉ាងងាយ ព្រមទាំងមានលំដាប់លំដោយល្អផង។ លក្ខណៈពិសេសនេះបង្ហាញអោយឃើញថា ភាសាខ្មែរជាភាសាងាយ



សិក្សា ងាយយល់ជាងពពួកភាសាឥណ្ឌូ-អឺរ៉ុបឆ្ងាយណាស់ ។

## យោបល់រួមចំពោះភាសាខ្មែរ.—

ការលើកយកលក្ខណៈសំខាន់ៗ ខ្លះនៃភាសាខ្មែរ មកប្រៀបធៀបនឹងភាសាបរទេស មានភាសាបាលី-សំស្ក្រឹតជាដើម ឃើញថាប្លែកគ្នាឆ្ងាយណាស់ទាំងផ្នែកសូរ ផ្នែកសព្ទ-ផ្នែកសម្ព័ន្ធ ។ ភស្តុតាងទាំងនេះបានបញ្ជាក់ថាភាសាខ្មែរមានលក្ខណៈពិសេសរបស់ខ្លួន ពោលគឺពុំមែនកើតចេញអំពីភាសាណាមួយឡើយ ។ ទំនាក់ទំនងរវាងខ្មែរនិងបរទេសធ្វើអោយមានល្បាយភាសាបរទេសក្នុងភាសាខ្មែរក៏ពិតមែនហើយ ក៏ប៉ុន្តែការទទួលឥទ្ធិពលភាសាបរទេសនេះ តែងប្រព្រឹត្តទៅដោយការប្រែសំរួលអោយស្របស្រួលទៅនឹងភាសាជាតិជាដរាប គួរយ៉ាងដូចជាខេមរនីយកម្មចំពោះភាសាបាលី-សំស្ក្រឹត ដែលបានពោលនៅខាងលើរួចមកហើយ ។

ប្រសិនបើយើងបានដឹង បានយល់អំពីដើមកំណើតនិងក្បួនខ្នាតដ៏ប្រពៃនៃភាសាជាតិរបស់យើងហើយ តើយើងដែលជាខ្មែរ ត្រូវមានករណីយកិច្ចបែបណាដែរ? ទោះបីយើងមានការលំបាកខ្លះក្នុងការសរសេរ រឺនិយាយដោយសារឥទ្ធិពលបរទេសមកលើភាសាយើងយ៉ាងណាក៏ដោយ ក៏យើងត្រូវមានស្មារតីជាតិជានិច្ច លើកតំកើងភាសាជាតិ ដោយនាំគ្នានិយមប្រើភាសាជាតិ ក្នុងករណីណាដែលអាចជៀសវាងភាសាបរទេស

បាន ហើយខំការពារភាសាខ្មែរដោយកុំបន្ទាប់ កុំខំទាញបញ្ចូលទៅក្នុងក្បួនភាសាបរទេស ។ លើសពីនេះទៅទៀត ត្រូវខំពង្រីកនិងពង្រីកអោយកាន់តែដុះដាលឡើង ។ បើខ្មែរម្នាក់ៗមានស្មារតីជាតិបែបនេះមែន យើងសង្ឃឹមថា ភាសាជាតិយើង មុខជាមានការចំរើនល្អណាស់ ហើយនឹងបានជាគ្រឹះយ៉ាងមាំនៃជាតិខ្មែរជាពុំខាន ។

* * *

# ២- អក្សរ

ក្រោយដែលបានបង្កើតភាសា សំរាប់និយាយប្រាស្រ័យទាក់ទងគ្នាក្នុងការរស់នៅមក មនុស្សតែងរិះរកមធ្យោបាយបង្កើតនូវសញ្ញាផ្សេងៗ សំរាប់កត់ត្រាពាក្យសំដី រឿងរ៉ាវ ព្រឹត្តិការណ៍ផ្សេងៗថែមទៀត ។ សញ្ញានោះ លុះក្រោយមកក៏កើតបានជាតួអក្សរនេះឯង ។

## ក- ប្រវត្តិនៃអក្សរ(13) (14). —

ការសិក្សាស្រាវជ្រាវខាងប្រវត្តិអក្សរ បានអោយដឹងថា នៅប្រមាណ ៤០០០ ឆ្នាំមុនគ.ស. ជនជាតិអេស៊ីប(Egypte) បានបង្កើតតួអក្សរជាលើកដំបូងមុនគេ ប៉ុន្តែសញ្ញាតួអក្សរទាំងនោះ ពុំមែនជាតួអក្សរពិតប្រាកដដូចសព្វថ្ងៃនេះទេ គឺជាសញ្ញារូបវត្ថុ រូបសត្វ រូបមនុស្ស រូបរុក្ខជាតិ រូបផ្កា រូបផ្កាយ ជាដើម ដែលហៅថា សក្តិលេខ (Hiéroglyphe) ។ អក្សររូបបែបនេះ ពុំមានអ្នកណាអានរួចទេ ។ ទើបតែនៅឆ្នាំ១៨២៤ដល់ ១៨៤៤ លោក សំប៉ូល្យុង (Champollion) ចេះអានអក្សរជនជាតិអេស៊ីបនេះមុនគេ ។ បន្ទាប់មក គេបានរកឃើញអត្ថបទសិលាចារឹកជាសក្តិលេខចិន

មានអាយុប្រហែល ២០០០ ឆ្នាំមុនគ.ស. ។ លុះក្រោយមកទៀត ប្រវត្តិវិទូបានស្រាវជ្រាវរកឃើញថា ជនជាតិហ្វេនីស៊ី ( Phénicie ) ជាអ្នកបានសាងតួអក្សរសំរេចឡើងជាដំបូងបង្អស់ ហើយអក្សរហ្វេនីស៊ីនេះក៏បានទៅជាដើមត្រកូលនៃអក្សររបស់ជនជាតិផ្សេងៗទៀត ក្នុងលោកមានអក្សរក្រិក-ឡាតាំង និងអក្សរព្រាហ្មី (Brami) នៅប្រទេសឥណ្ឌា ។ តាមការស្រាវជ្រាវរបស់លោក **ឃ្យូស៊ី** មានអក្សរ ២ បែបបានកើតឡើងនៅប្រទេសឥណ្ឌាប្រមាណជា ១០០០ឆ្នាំមុនគ.ស. គឺអក្សរ **ព្រាហ្មី** និង **ខារោស្ត្រី** (Kharostri) ។ បណ្តាអក្សរទាំង ២ បែបនេះ បានផ្តល់ដើមកំណើតអក្សរឯទៀតជាច្រើននៅប្រទេសឥណ្ឌា ។ ឯតួអក្សរព្រាហ្មីនោះកើតចេញមកអំពីអក្ខរក្រមបុរាណអំបូរសេមីត ( L'ancien alphabet sémitique) ។ ក្នុងចំណោមអក្សរឥណ្ឌាជាច្រើនដែលកើតចេញពីអក្សរព្រាហ្មី អក្សរ **ទេវនាគរី** (Devanagari) រឺ **នាគរី** (Nagari) ត្រូវបានគេស្គាល់ជាងគេ ហើយដែលគេយកមកកត់ត្រាភាសាសំស្ក្រឹត ។ លុះក្រោយមក អក្សរទេវនាគរីក៏បានក្លាយទៅជាអក្សរសំរាប់ជនជាតិឥណ្ឌាប្រើជាផ្លូវការរហូតមកដល់សព្វថ្ងៃ ។

តើអក្សរខ្មែរមានដើមកំណើតពីអក្សរណាដែរ?

នៅសម័យនគរភ្នំ (ហ្វូណន) គេបានរកឃើញ សិលាចារឹកមួយនៅវ៉ូកាញ់ក្នុងភូមិភាគញ៉ាត្រាង (យួនខាងត្បូង) ដែលគេបានចាត់ទុកថាជាសិលាចារឹកខ្មែរដំបូងបង្អស់ ប៉ុន្តែសេចក្តីក្នុងសិលាចារឹកនេះជាភាសា



សំស្ក្រឹត ។ តាមការសិក្សាប្រៀបធៀបអក្សរខ្មែរបូរាណនេះទៅនឹងអក្សរឥណ្ឌាប៉ែកខាងត្បូង គេបានដឹងថាមានទ្រង់ទ្រាយដូចគ្នា ។ម្យ៉ាងទៀតគេបានរកឃើញនៅអូកែវ (កំពង់ផែរបស់ខ្មែរនៅមាត់សមុទ្រកម្ពុជាក្រោម) នូវប្រាក់កាក់របស់ឥណ្ឌា ដែលនៅលើនោះគេចារអក្សរព្រាហ្មីមានទ្រង់ទ្រាយដូចតួអក្សរខ្មែរបូរាណដែរ ។ ស្របតាមសម័យនោះ ខ្មែរនិងឥណ្ឌាមានទំនាក់ទំនងគ្នាញឹកញាប់ផង គេក៏សន្និដ្ឋានថា ខ្មែរបានខ្ចីយកតួអក្សរឥណ្ឌាព្រាហ្មីមកប្រើ ។

## ១- វិវត្តន៍នៃអក្សរខ្មែរ. —

អក្សរដែលខ្មែរយកគំរូតាមអក្សរឥណ្ឌាខាងត្បូងមកប្រើប្រាស់ក្នុងសម័យនោះ ពុំដូចគ្នានឹងអក្សរសម័យបច្ចុប្បន្ននេះទេ គឺត្រូវបានកែប្រែទ្រង់ទ្រាយចំនួន១០ដង (15) រួចមកហើយ ទើបបានជារូបរាងពិតប្រាកដដូចតួអក្សរដែលយើងប្រើប្រាស់សព្វថ្ងៃ ។តទៅទៀតយើងសូមលើកយកដំណើរវិវត្តន៍នៃព្យញ្ជនៈខ្មែរបូរាណចំនួន៣បែប មកបង្ហាញជូន ដូចតទៅនេះ៖

ព្យញ្ជនៈបែបទី ១ ( សម័យមុនអង្គរ )



ព្យញ្ជនៈបែបទី ២ (សម័យអង្គរ)



ព្យញ្ជនៈបែបទី៣ (សម័យក្រោយអង្គរ)



បើយើងប្រៀបធៀបតួព្យញ្ជនៈទាំង៣ បែប ឃើញមានសណ្ឋានខុសគ្នាឆ្ងាយ ហើយការតែឆ្ងាយណាស់ទៅទៀត នឹងតួព្យញ្ជនៈសម័យបច្ចុប្បន្ននេះ ។

— ព្យញ្ជនៈសម័យមុនអង្គរ : មានរាងគ្រោតគ្រាត មិនស្មើ មិនសម សក់ខ្លី ជើងខ្លីហើយមានចំនួនតិច

— ព្យញ្ជនៈសម័យអង្គរ : មានរាងសង្ហា មានសក់ជាក្បាច់ចេនា ជើងមានសីងគ្រប់តួ



— ព្យញ្ជនៈសម័យក្រោយអង្គរ : មានរាងទ្រេត សក់និងជើងវែង ៗ ។

ដំណើរវិវត្តន៍មានច្រើនលើកច្រើនគ្រា តួអក្សររឹតតែច្រើនឡើង រឹតតែងាយសរសេរឡើង ហើយរឹតតែល្អឡើង ប្រកបដោយក្បូរក្បាច់យ៉ាងសមរម្យ ។ នេះហើយជាស្នាដៃនៃបុព្វបុរសខ្មែរ ដែលមានទេពកោសល្យខាងកែសំរួលនិងខាងបង្កើតថ្មីដើម្បីបំពេញនូវកង្វះខាតនេះៗ ។

ក្រោយដែលមានកំណើតមាំមួនហើយ បន្ទាប់មកមានវិវត្តន៍ពេញរូបរាងមែនទែនហើយ តើអក្សរខ្មែរមានលក្ខណៈពិសេសរបស់ខ្លួនយ៉ាងណាទៅដែរ ?

## គ_ លក្ខណៈពិសេសនៃអក្សរខ្មែរ. —

អក្សរពុំមែនជាសញ្ញាដាច់ដោយចេញពីគ្នា ដែលគេចេះតែយកមកកត់សំគាល់សម្លេងក្នុងភាសានីមួយ ៗ នោះឡើយ ប៉ុន្តែអក្សរគឺជាកម្រងសញ្ញាដែលទាក់ទងគ្នាជាក្បួន ជាវិធីស្ថិតនៅលើមូលដ្ឋាន រឺ គោល ណាមួយជាដរាប ។ យ៉ាងណាមិញ អក្សរខ្មែរក៏ដូចនោះដែរ ពោលគឺជាក្បួននៃតួសញ្ញាដែលទាក់ទងគ្នាទៅលើមូលវិធី (Principe) ដ៏សំខាន់ ។

នៅក្នុងអក្សរខ្មែរគេនិយមភ្ជាប់ស្រៈនិងព្យញ្ជនៈអោយជាប់គ្នា ដែលជាហេតុនាំអោយមានទំនាក់ទំនងទៅវិញទៅមក រវាងស្រៈនិងព្យញ្ជនៈ។ ទំនាក់ទំនងនេះបណ្តាលអោយកើតមានស្រៈភប់ រឺ ស្រៈអនុស័យក្នុង

ព្យញ្ជនៈនេះឯង ។ ដូចយើងបានពោលក្នុងផ្នែកភាសារួចមកហើយថា ស្រៈកប់ខ្មែរមាន ២ ប្រភេទគឺ អ-អ៊ ។ ឯស្រៈកប់បាលីមានតែ ១ គឺ អៈ (a) ។ ដោយមានស្រៈអនុស័យ ២ បែបកប់នៅក្នុងព្យញ្ជនៈនេះហើយ ទើបនាំអោយមាន **ព្យញ្ជនៈអនុស័យ** (consonne inhérente) ២ បែបដែរ គឺព្យញ្ជនៈអនុស័យពួក អ ដូចជា ក ខ ច ឆ ដ ឋ ... និងព្យញ្ជនៈអនុស័យពួក អ៊ ដូច គ ឃ ជ ឈ ទ ធ ... ។ ចំណែក**ស្រៈនិស្ស័យ** (voyelle dépendante) ដូចជា ា ិ ី ឹ ឺ ុ ូ ក៏ចែកជា ២ ប្រភេទស្របទៅនឹងព្យញ្ជនៈអនុស័យពួក អ និងពួក អ៊ ដូចនេះទៀត ប៉ុន្តែមានសញ្ញាសំគាល់តែមួយបែប (ឧ. សញ្ញា ា សំគាល់ អា ផង អ៊ា ផង) ។

អាស្រ័យដោយមានស្រៈអនុស័យក្នុងព្យញ្ជនៈបែបខាងលើនេះហើយ ទើបព្យញ្ជនៈអនុស័យមួយតួៗអាចទៅជាព្យាង្គមួយបាន ។

ឧ. គ (គទល់) ខ (ខត្រី) ស (ពណ៌ស) ។

លក្ខណៈពិសេសនេះខុសប្លែកអំពីអក្សររ៉ូម៉ាំង (Romain) មានអក្សរបារាំងជាដើមដែលព្យញ្ជនៈមួយតួពុំអាចទៅជាព្យាង្គមួយបានទេ ដូចជាព្យញ្ជនៈ b-k-p-l ជាដើម ។ នឹងអាចទៅជាព្យាង្គមួយបាន លុះត្រាតែមានស្រៈប្រកបជាមួយ ។

ក្នុងអក្សរខ្មែរ ព្យញ្ជនៈ ២ តួ នៅរៀងគ្នា ក៏អាចទៅជាព្យាង្គមួយបានដែរ ដូចពាក្យៈ មក បង (តួ ម និងតួ ប ជាព្យញ្ជនៈដើមព្យាង្គ (consonne initiale) ឯតួ ក និងតួ ង ជាព្យញ្ជនៈប្រកប (consonne



finale) ។ ព្យញ្ជនៈដែលមានមុខងារជាខ្យល់ប្រកប ពុំមានស្រៈអនុស័យឡើយ គឺមានតែខ្យល់នៃព្យញ្ជនៈប៉ុណ្ណោះ ។ ពិតមែនតែពុំមានសញ្ញាសំគាល់ថាពុំមានស្រៈអនុស័យក្នុងព្យញ្ជនៈប្រកបដូចនេះក៏ដោយ ក៏ខ្មែរយើងពុំអាចច្រលំបានទេ ព្រោះគេអាចដឹងបានដោយសារន័យរបស់ពាក្យនោះ ឧ. ទូកង លើកដាក់លើក ពានាល ។

ចំណែកនៅក្នុងអក្សររ៉ូម៉ាំង ដែលនិយមផ្ដាច់ស្រៈចេញអំពីព្យញ្ជនៈ ហើយដែលពុំនិយមប្រើស្រៈអនុស័យ ព្យញ្ជនៈអនុស័យដូចខ្មែរនោះ ព្យញ្ជនៈ ២ រឺ ៣ តួនៅជិតគ្នាពុំអាចទៅជាព្យាង្គបានទេ ប៉ុន្តែជាព្យញ្ជនៈសំយោគ (ព្យញ្ជនៈផ្សំ) (groupe consonnantique) ទៅវិញ ឧ. tr (trouver), spl (splendeur) ។

រីឯព្យញ្ជនៈសំយោគខ្មែរ ពុំសរសេរតួព្យញ្ជនៈរៀងគ្នាដូចនេះទេ គឺសរសេរត្រួតព្យញ្ជនៈលើគ្នាទៅវិញ ជាបុព្វហេតុមួយយ៉ាងសំខាន់បណ្ដាលអោយមានការបង្កើតជា **ជើង** របស់ព្យញ្ជនៈឡើង ។ ដូចនេះហើយ បានជាយើងឃើញថា ព្យញ្ជនៈនីមួយៗនៅក្នុងសម័យបច្ចុប្បន្នសុទ្ធតែមានជើង ។ ការបង្កើតជើងនៃព្យញ្ជនៈនេះ គឺដើម្បីយកទៅសរសេរផ្ញើក្រោមព្យញ្ជនៈមួយទៀត អោយមានសភាពត្រួតគ្នា ផ្សំសម្លេងគ្នាជាព្យញ្ជនៈសំយោគគឺព្យញ្ជនៈផ្សំនេះឯង ។

ឧ. ខ្យ (ខ្យល់) ខ្ល (ខ្លី) ក្រ...

ក្រៅពីនេះ ជើងនៃព្យញ្ជនៈសំរាប់ប្រើជាព្យញ្ជនៈដើមព្យាង្គនៃព្យាង្គ

តំរួតថែមទៀត ។

ខ. ពន្យល់ : ពន់ (ព្យាង្គទី១) + យល់ (ព្យាង្គទី២)

ជើង ្យ ក្នុងពាក្យ "ខ្យល់" និងជើង ្យ ក្នុងពាក្យ "ពន្យល់" ពិតមែនតែមានរូបរាងដូចគ្នាក៏ដោយ ក៏ពុំមានមុខងារដូចគ្នាទេ ។ ក្នុងព្យញ្ជនៈសំយោគ ជើងព្យញ្ជនៈ គឺខ្យល់ផ្សំជាមួយនឹងព្យញ្ជនៈត្រួតលើ ។ ចំណែកឯជើងព្យញ្ជនៈក្នុងព្យាង្គតំរួតវិញ ពុំមែនជាសម្លេងផ្សំទេ គឺជាព្យញ្ជនៈដើមព្យាង្គនៃព្យាង្គតំរួតនេះឯង ។

យើងបានឃើញថា វិធីផ្ញើជើងនេះ ជាមែកធាងបែកចេញអំពីមូលវិធីអនុស័យស្រៈ-ព្យញ្ជនៈ (Principe des voyelles et consonnes inhérentes ) ហើយវិធីផ្ញើជើងនេះមានផលវិបាក (conséquence) សំខាន់ៗដែលប្រព្រឹត្តទៅនៅលើក្បួនវិធីដ៏ច្បាស់លាស់ណាស់ ។ ដោយក្បួនវិធីទាំងនោះវែងឆ្ងាយពេក យើងសូមមិនលើកយកមកអធិប្បាយក្នុងពេលនេះទេ ។

លក្ខណៈពិសេសមួយទៀតរបស់អក្សរខ្មែរយើង គឺព្យញ្ជនៈមានសក់ ។ តើសក់នោះមានប្រយោជន៍យ៉ាងណាដែរ ?

រួចមកហើយយើងបានឃើញគេយកសក់ "៊" ( អ្នកខ្លះហៅសក់ "ក" ) ដែលមានសណ្ឋានដូចជាលេខ៣ ហើយដែលបាលីហៅថាត្រីសព្ទ មកប្រើដាក់លើព្យញ្ជនៈពួក "អ" : ប ស ហ អោយទៅជាព្យញ្ជនៈពួក "អ៊" : ប៊ ស៊ ហ៊ វិញ ។ សក់របស់ព្យញ្ជនៈឯទៀតពុំឃើញយកមកប្រើ



ផងទេ ។ យើងយល់ថា ការធ្វើអោយព្យញ្ជនៈមានសក់ ពុំមែនជាការឥតប្រយោជន៍ឡើយ ផ្ទុយទៅវិញសក់ព្យញ្ជនៈ គឺជាក្បាច់ ដែលបុព្វបុរសយើងបានរចនាឡើង ដើម្បីលំអព្យញ្ជនៈនីមួយៗអោយមានសភាពសមសួនឡើង ។ ចំណែកអក្សរ សៀម-លាវ ដែលយកលំនាំអក្សរតាមខ្មែរយើង ហើយយកទៅកែប្រែលុបសក់ចេញ មើលទៅហាក់ដូចមនុស្សដែលមានក្បាល ប៉ុន្តែឥតសក់ដូចនោះដែរ ។

ក្រោយដែលបានសិក្សាអំពីប្រភព-វិវត្តន៍ និងលក្ខណៈពិសេសនៃអក្សរខ្មែរមក យើងបានឃើញថា ខ្មែរបានយកលំនាំតាមអក្សរឥណ្ឌាមកប្រើប្រាស់ជាលើកដំបូងក៏ពិតមែន ក៏ប៉ុន្តែបន្ទាប់មក ខ្មែរមានទេពកោសល្យខាងច្នៃអោយបានសមសួន ខាងបង្កើតថ្មីអោយសម្បូរគ្រប់គ្រាន់ ព្រមទាំងអោយមានក្បួនខ្នាត មានវិធីច្បាស់លាស់សំរាប់ជាតិខ្មែរយកទៅប្រើការបានយ៉ាងងាយក្នុងការកត់ត្រាគំនិត សញ្ញាណ ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ ។ល។

*

*   *

# ៣-អក្សរសិល្ប៍

អក្សរសិល្ប៍ (La littérature) គឺជាអត្ថបទរឿង ដែលគេតែងឡើងប្រកបដោយ **សិល្ប៍** ពោលគឺការប៉ិនប្រសប់ក្នុងការតែងរបស់អ្នកនិពន្ធដែលធ្វើអោយអ្នកអាន រឺ អ្នកស្ដាប់ចូលចិត្ត ជាប់អារម្មណ៍ រំភើបញាប់ញ័រទៅតាមបញ្ហារបស់រឿង ។

## ក- ប្រវត្តិនៃអក្សរសិល្ប៍ខ្មែរ.–

អក្សរសិល្ប៍ខ្មែរ មានកំណើតឡើងស្មើនឹងប្រវត្តិសាស្ត្រខ្មែរដែរ ព្រោះគេបានដឹងតាំងពីយូរលង់ណាស់មកហើយនូវការរស់នៅ របបគ្រប់គ្រង ព្រឹត្តិការណ៍ផ្សេងៗនៃសង្គមមនុស្សជាដើម ក៏ដោយសារអត្ថបទសរសេរ រឺ ចារទុកតាំងពីពេលនោះម្ល៉េះ ។ ជាភស្តុតាង គឺអត្ថបទចារនៅលើផ្ទាំងសិលា (សិលាចារឹក) ដែលមានចំណាស់ៗហើយដែលសេសសល់ គង់វង់រហូតមកដល់សព្វថ្ងៃនេះ ។ ក្រៅពីសិលាចារឹក នៅមានអត្ថបទអក្សរសិល្ប៍ជាច្រើនទៀត ដែលកត់ត្រាបន្តបន្ទាប់នៅលើសម្ភារៈផ្សេងៗដូចជា : ស្បែកសត្វ ស្លឹករឹត ក្រាំង ក្រដាស ។

អក្សរសិល្ប៍ខ្មែរ ក៏ដូចជា ភាសាខ្មែរ អក្សរខ្មែរដែរ តែងបានទទួល



ឥទ្ធិពលបរទេសដែលផ្សាយចូលមកជាហូរហែ ។ ឯអក្សរសិល្ប៍បរទេសដែលមានឥទ្ធិពលខ្លាំងជាងគេ គឺអក្សរសិល្ប៍សាសនានិយម មានអក្សរសិល្ប៍ព្រាហ្មណ៍និយមនិងអក្សរសិល្ប៍ពុទ្ធនិយមនេះឯង ។

## ១- វិវត្តន៍នៃអក្សរសិល្ប៍ខ្មែរ (16)(17) .–

គេចាត់ទុកអក្សរសិល្ប៍ជាកញ្ចក់មួយប្រភេទយ៉ាងសំខាន់របស់សង្គមមនុស្ស ។ តាមរយៈអក្សរសិល្ប៍ គេអាចឆ្លុះមើលការរស់នៅដ៏ជាក់ស្ដែងរបស់មនុស្សក្នុងសម័យនីមួយៗ ព្រោះអក្សរសិល្ប៍តែងតែប្រែប្រួលទៅតាមដំណើរវិវត្តន៍របស់សង្គមមនុស្សជាដរាប ។

ចំពោះអក្សរសិល្ប៍ខ្មែរ គេបានសង្កេតឃើញថា មានវិវត្តន៍យ៉ាងខ្លាំងទៅតាមសម័យកាលធំៗនៃប្រវត្តិសាស្ត្ររបស់ប្រទេសខ្មែរ ។ នៅសម័យអង្គរ គេបានដឹងច្បាស់ថាមហិទ្ធិឫទ្ធិខ្មែរបានឡើងដល់កំរិតជាកំពូល រីឯអក្សរសិល្ប៍ក៏រីកចំរើនខ្លាំងក្លាដែរ ប៉ុន្តែចុះថយវិញនៅពេលដែលស្រុកខ្មែរត្រូវឈ្លានពានពីសំណាក់បរទេស ។ លុះមកដល់ ស.វ.ទី១៨និង ១៩ ស្នាដៃអក្សរសិល្ប៍ក៏ស្ទុះងើបចំរើនឡើងបន្តិច ប៉ុន្តែត្រូវថយឥទ្ធិពលម្ដងទៀត នៅពេលដែលប្រទេសខ្មែរធ្លាក់ខ្លួននៅក្រោមអាណាព្យាបាលបារាំង រួចទើបចាប់លូតលាស់ចំរើនឡើងជាថ្មីនាសម័យខ្មែរបានឯករាជ្យ ។

### ១- អក្សរសិល្ប៍សម័យបុរាណ.–

## * មុនសម័យអង្គរ ( ស.វ. ទី១ ដល់៨ ).–

ដោយមានការផ្លាស់ប្តូររាជធានីញឹកញាប់ ដូចជាប្តូរពី **វ្យាធបុរៈ** ទៅ **ឦសានបុរៈ** រួចទៅ **យធបុរៈ** ជាដើម បានជាគេប្រទះឃើញសិលាចារឹកនៅពាសពេញអាណាចក្រ ។ នៅសម័យមុនអង្គរ គេនិយមប្រើភាសាសំស្ក្រឹតដែលគេចាត់ទុកជាភាសាជាន់ខ្ពស់ ( ភាសារបស់អ្នកប្រាជ្ញ ) ។ ដូចនេះហើយបានជាមានសិលាចារឹកខ្លះសរសេរជាភាសាសំស្ក្រឹតហើយតែងជាពាក្យកាព្យ ។ សិលាចារឹកជាភាសាសំស្ក្រឹតដែលមានចំណាស់ជាងគេ គឺសិលាចារឹក **វ៉ូកាញ់** ( ប្រមាណគ្រិស្តសតវត្សទី ២-៣ ) ។ អត្ថបទនៃសិលាចារឹកនេះ និយាយអំពីចិត្តសន្តោសរបស់ស្តេចមួយអង្គដែលគិតដល់សុភមង្គលរបស់ប្រជារាស្ត្រ ដោយធ្វើជាបទបញ្ជាទុកអោយមហាក្សត្រ ៗ មកប្រតិបត្តិតាម ។ សិលាចារឹកខ្លះទៀតដែលសរសេរជាភាសាខ្មែរបូរាណហើយជាពាក្យរាយ ចាប់មានតាំងពី ស.វ. ទី ៧ ។ ឯសិលាចារឹកចាស់ជាងគេ គឺសិលាចារឹក **អង្គរបូរី** ( គ.ស. ៦១១ ) ។ សិលាចារឹកនៅសម័យមុនអង្គរច្រើនទាក់ទងទៅនឹងប្រវត្តិសាស្ត្រហើយនិងសាសនា ។

## * សម័យអង្គរ (៨០២-១៤៣១).–

អក្សរសិល្ប៍នៅសម័យអង្គរ ពិតមែនតែបានទទួលបន្តបន្ទាប់គ្នានូវ



ឥទ្ធិពលនៃលទ្ធិវេទ លទ្ធិព្រាហ្មណ៍ និង ពុទ្ធសាសនា ប៉ុន្តែបានរក្សាលក្ខណៈជាខ្មែរ ។

ដោយយកតួអក្សរខ្មែរពិតប្រាកដជាឧបករណ៍ អក្សរសិល្ប៍ខ្មែរសម័យនោះ បានផ្តិតផ្ទាប់ទៅនឹងសម្ភារៈ ២ បែប :

– អក្សរសិល្ប៍ ដែលសរសេរដោយដីសបំពង់នៅលើស្បែកសត្វស្ងួតលាបពណ៌ខ្មៅ ។ អក្សរសិល្ប៍ ដែលសរសេរនៅលើសម្ភារៈបែបនេះមិនស្ថិតស្ថេរទេ ព្រោះពុំអាចធន់បាននឹងកំលាំងធម្មជាតិ មានភ្លៀងខ្យល់ និងការបំផ្លិចបំផ្លាញរបស់សត្វល្អិតបានឡើយ ។

– អក្សរសិល្ប៍ដែលចារនៅលើផ្ទាំងថ្មជាបន្ទះ រឺជាបង្គោល រឺជាសសរ ។

ក្នុងការសរសេរអត្ថបទអក្សរសិល្ប៍ អ្នកនិពន្ធប្រើភាសា ២ យ៉ាងគឺ .. ភាសាសំស្ក្រឹតនិងភាសាខ្មែរបូរាណ ។ អត្ថបទជាភាសាសំស្ក្រឹតច្រើនជាពាក្យកាព្យ និយាយអំពីកំណត់ហេតុក្នុងដំណើរប្រព្រឹត្តទៅនៃប្រវត្តិរបស់ស្តេច រឺមន្ត្រី រឺជាការអួតសរសើរចំពោះតួអង្គណាមួយក្នុងប្រវត្តិសាស្ត្រ ចំណែកអត្ថបទជាភាសាខ្មែរវិញ ច្រើនជាពាក្យឧទ្ទិស រឺជាបញ្ជីរាប់របស់ពល រាប់វត្ថុដែលគេបូជាសំរាប់បូជនីយដ្ឋានទាំងនោះ ។

សេចក្តីរុងរឿងនៃជនជាតិខ្មែរនាសម័យអង្គរ លទ្ធិព្រាហ្មណ៍និងពុទ្ធសាសនាមហាយាន បានផ្សាយឥទ្ធិពលទៅលើជីវភាព និងចិត្តគំនិតខ្មែរទូទៅ ។ ជីវភាពសប្បាយរីករាយដោយសារឫទ្ធានុភាពនេះឯងជាប្រភពគំនិតថ្មីៗល្អៗ សំរាប់អ្នកនិពន្ធក្នុងសម័យនោះ យកទៅប្រើតុបតែងស្នាដៃ

របស់ខ្លួន ។ គោលគំនិតសំខាន់ៗ នៅក្នុងស្នាដៃទាំងនោះ មានជាអាទិ៍ៈ

– សេចក្តីអង់អាចក្នុងសឹកសង្គ្រាម
– កិត្តិនាមវីរជនជាមេទ័ព
– សេចក្តីរំភើបចិត្តក្នុងជ័យជំនះ
– ការរៀបចំដីវិភាគក្នុងសង្គម
– ទំនាមទំលាប់
– ការរៀបរាប់ពីប្រាសាទថ្ម ។

នៅសម័យអង្គរ អត្ថបទសិលាចារឹកដែលគេប្រទះឃើញមានឈ្មោះអ្នកនិពន្ធគឺ :

– បណ្ឌិត **សិវសោម** : សិលាចារឹកប្រាសាទកណ្តាលដើមក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័ន ។
– បណ្ឌិត **យតិអមរភាវៈ** : សិលាចារឹកភ្នំបាយ៉ង់ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន ។
– បណ្ឌិត **និវាតរ** : សិលាចារឹកកំភីស ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន ។
– បណ្ឌិត **ភវិន្ទ្រៈ** : សិលាចារឹកប្រាសាទខ្នា ក្នុងរជ្ជកាលព្រះបាទសុរិយាវរ្ម័ន ។
– បណ្ឌិត **កវេន្ទ្រៈ** : សិលាចារឹកប្រាសាទទរ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ។



– ព្រះនាង ឥន្ទ្រទេវី : សិលាចារឹកប្រាសាទភិមានាកាស ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ។

ក្រៅពីអត្ថបទខ្លីៗ ទាំងនេះ ស្នាដៃឯកដ៏ល្បីល្បាញ គឺរឿងរាមកេរ្តិ៍ ដែលយកលំនាំតាមរឿងរាមាយណៈឥណ្ឌា ហើយដែលគេសរសេរជាភាសាខ្មែរបុរាណចំរុះភាសាសំស្ក្រឹត ។ គឺជារឿងចំបាំងរវាងមនុស្ស និងយក្ស ។ តួអង្គសំខាន់គឺ ព្រះរាមជាអវតារព្រះវិស្ណុ ដែលមានមហិទ្ធិឫទ្ធិខ្ពង់ខ្ពស់លើសមនុស្សធម្មតា ។ ប៉ុន្តែ អ្នកនិពន្ធរឿងរាមកេរ្តិ៍ខ្មែរ បានអោយមុខងារព្រះរាមមានលក្ខណៈប្លែកឆ្ងាយពីរាម (Rama) នៅក្នុងរឿងរាមាយណៈ ។

មានស្នាដៃមួយទៀតដែលគេពុំសូវស្គាល់ច្រើន ហើយពុំសូវល្បីល្បាញដូចរឿងរាមកេរ្តិ៍ទេ ប៉ុន្តែមានន័យច្រើនណាស់ដែរ គឺសាស្ត្រាត្រៃភូមិ រឺ ត្រៃភេទត្រៃភូមិ ។ អក្សរសិល្ប៍នេះនិយាយអំពីគំនិតរបស់មនុស្សជាន់ដើមក្នុងការកកើតទឹកដី ប្រវត្តិដើមនៃកំណើតមនុស្សលោក កំណើតសត្វលោកក្នុងភពទាំង ៣ គឺ ស្ថានសួគ៌ ស្ថានមនុស្ស និងស្ថាននរក ។ល។

ចំពោះការផ្សាយអក្សរសិល្ប៍ក្នុងសម័យអង្គរ គេបានសង្កេតឃើញពុំសូវបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឡើយ ព្រោះអត្ថបទអក្សរសិល្ប៍ភាគច្រើនដែលចារជាប់លើផ្ទាំងថ្មរលីស សរស្តម្ភ ត្រូវបានតំកល់ទុកក្នុងវាំងស្តេចនិងក្នុងប្រាសាទនានាដែលជាបូជនីយដ្ឋាន ។ ម្យ៉ាងទៀតការ

ប្រើភាសាសំស្ក្រឹតក្នុងអក្សរសិល្ប៍ខ្លះ ក៏ពុំអាចធ្វើអោយប្រជាពលរដ្ឋទាំងនោះយល់បានដែរ ព្រោះភាសាសំស្ក្រឹតសម័យនោះត្រូវបានចេះដឹងតែក្នុងជ្ឈដ្ឋានបញ្ញវន្តប៉ុណ្ណោះ ។ ដូចនេះ អក្សរសិល្ប៍សម័យអង្គរពុំមានការផ្សព្វផ្សាយរបស់ខ្លួនដល់គ្រប់មជ្ឈដ្ឋានឡើយ ។

## ២. អក្សរសិល្ប៍សម័យកណ្តាល .–

### * សម័យក្រោយអង្គរ (១៤៣១-១៨៦២)

កាលពីសម័យមុន អក្សរសិល្ប៍ខ្មែរកំពុងតែរីកចំរើន ស្រាប់តែមកដល់ពេលនេះត្រឡប់ជាសូន្យឈឹង មានសភាពងងឹតអាប់អួក្នុងប្រវត្តិ-សាស្ត្រខ្មែរ ដោយសារមានបច្ចាមិត្តមកកាតព្យាត បណ្តាលអោយមានចំបាំង មានភាពដុនដាបខាងសេដ្ឋកិច្ច **មានការអត់ឃ្លាន មានជំងឺឆ្លង** ហើយមានទំនាស់ទាស់ទែងគ្នាក្នុងស្រុកយ៉ាងច្របូកច្របល់ ។ ស្ថានភាពបែបនេះនាំអោយទន់ខ្សោយ និង យ៉ាប់យ៉ឺនដល់ប្រទេស និង ប្រជារាស្ត្រខ្មែរ ។

លុះមកដល់ ស.វ. ទី ១៧ ស្នាដៃអក្សរសិល្ប៍ក៏ចាប់ងើបឡើងវិញ ។ សម្ភារៈដែលគេប្រើសំរាប់កត់ត្រាអក្សរសិល្ប៍នៅសម័យនោះគឺ : ក្រាំង (សន្លឹកក្រដាសស្នាច់ក្រាស់បត់ជាផ្នត់ៗ) និងស្លឹករឹត (ហៅថាសាស្ត្រា) ។ ស្នាដៃអក្សរសិល្ប៍ពេលនេះបានជ្រួតជ្រាបដល់បណ្តាជនទូទៅហើយ ប៉ុន



តែជាអកុសល កេរដំណែលក្រាំង និង សាស្ត្រាស្លឹករឹតចេះតែវិនាសទៅ ដោយសារតែសង្គ្រាម និងការឈ្លានពានរបស់ខ្មាំងបរទេសដែលបានប្រមូលយកទៅ រឺដុតបំផ្លាញចោលតែម្តង ។

ចំណែកខាងជំនឿសាសនាវិញ ពុទ្ធសាសនាហីនយាន (ដែលនាំមកពីលង្កា) មានការចំរើនលូតលាស់យ៉ាងខ្លាំង ហើយមានជោគជ័យលើសាសនាព្រាហ្មណ៍និងពុទ្ធសាសនាមហាយាន ។ ឯភាសាបាលីដែលប្រើក្នុងពុទ្ធសាសនាហីនយាននេះ ក៏បានចូលមកជំនួសភាសាសំស្ក្រឹតទុកជាភាសារបស់អ្នកប្រាជ្ញវិញម្តង ។ រីឯទស្សនៈពុទ្ធសាសនា ក៏កាន់តែជ្រួតជ្រាបឡើងយ៉ាងជាប់រហាស់ដែរ ក្នុងសន្តានចិត្តរបស់ប្រជារាស្ត្រ និងអក្សរសិល្ប៍ខ្មែរ ។ នៅក្នុងពេលនេះដែរ គេបានសង្កេតឃើញមានស្នាដៃអក្សរសិល្ប៍សាមញ្ញកើតឡើង ដូចជារឿងព្រេង រឿងនិទានខ្លីៗដែលនាំអោយអ្នកស្រុកស្តាប់និងយល់បានយ៉ាងស្រួល ។

អ្នកនិពន្ធដ៏ល្បីឈ្មោះក្នុងគ្រានេះមានជាអាទិ៍ :

– អ្នកឧញ៉ាខ : សរសេរកំណាព្យ “ល្បើកអង្គរ” នៅគ.ស. ១៦០៩ (?) ដែលនិយាយអំពីភាពអស្ចារ្យក្នុងការកសាងប្រាសាទអង្គរវត្ត ។

– ព្រះរាជសម្ភារ : សរសេរកំណាព្យ “ច្បាប់រាជសម្ភារ” នៅគ.ស. ១៦២២ ជាច្បាប់ដំបូន្មាន “ហេមន្តមាស” នៅគ.ស. ១៦២៩ “ហិន-លក្ខណ៍សល” នៅគ.ស. ១៦៣០ និង “កាព្យនិរាស” នៅគ.ស. ១៦៦០ ជាកំណាព្យដែលព្រះអង្គបាននិពន្ធដោយព្រះទ័យសោកសៅរលឹកដល់ព្រះ

នាង បុប្ផាទត្តី ។

- ជ័យនន្ទ: សរសេរកំណាព្យជាភាសាខ្មែរមុនគេបង្អស់លើសិលាចារឹកនៅគ.ស.១៧០១(?) ដែលនិយាយអំពីប្រវត្តិ ទឹកចិត្ត និងសេចក្តីប្រាថ្នាទៅអនាគតរបស់ខ្លួន ។

ក្រៅពីនេះ នៅមានអត្ថបទជាច្រើនទៀត ដែលគេមិនស្គាល់ឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទនៃការតែងដូចជា :

- អក្សរសិល្ប៍បច្ចេកទេសនិងនីតិសាស្ត្រ ដែលអ្នកស្រាវជ្រាវបានដាក់ឈ្មោះអត្ថបទទាំងនោះថា "រាជក្រឹត្យក្រមផ្សេងៗ" មានទាំងអស់ ២៥ក្រម ។
- ច្បាប់ទូន្មានប្រដៅសីលធម៌ ដែលប្រជាជនស្គាល់និងដឹងគ្រប់គ្នា ដូចជា ច្បាប់កូនចៅ ច្បាប់ពាក្យចាស់ ច្បាប់ក្រម ច្បាប់កេរ្តិ៍កាល ជាដើម ។ ច្បាប់ទាំងនេះ មានន័យគ្រប់គ្រាន់ខាងអប់រំមនុស្សអោយចេះរស់នៅក្នុងសង្គមបានរៀបរយ និងមានការចេះដឹងសមរម្យ ។

ដោយសារឥទ្ធិពលទស្សនៈពុទ្ធសាសនា ការលំបាកវេទនាដោយសង្គ្រាម អ្នកនិពន្ធក្នុងសម័យនេះបានងាករេមកយកគោលគំនិត ដោះស្រាយបញ្ហាមនុស្សក្នុងលោកិយវិញ ដូចជាបញ្ហាទុក្ខសោក កំហុសមនុស្ស អំពើកុសល និង អកុសល ដែលមនុស្សធ្លាប់ជួបប្រទះក្នុងជីវភាពរាល់ថ្ងៃ។ ឯបញ្ហាអច្ឆរិយៈ ហួសពីកំលាំងមនុស្សធម្មតាក៏មានដែរ ប៉ុន្តែមាននៅតែលើតួអង្គសំខាន់ៗ ហើយដែលពុំមានគុណសម្បត្តិដូចតួអង្គអាទិទេពី



អវតារអាទិទេពក្នុងសម័យមុនឡើយ ។

នៅរវាងស.វ.ទី ១៨ និង ១៩ ដោយសារការវឹកវរចលាចលក្នុងស្រុកផងនិងដោយសារសង្គ្រាមឈ្លានពានពីបរទេសផង ការផ្សាយស្នាដៃអក្សរសិល្ប៍ ដែលមាននៅសល់ ពុំបានរីកសាយភាយទូលំទូលាយឡើយ ។ ម្យ៉ាងទៀតឥទ្ធិពលវប្បធម៌សំស្ក្រឹតនិងវប្បធម៌បាលី នាំមកនូវភាពច្របូកច្របល់និងជាឧបសគ្គនៃការរីកចំរើនអក្សរសិល្ប៍ខ្មែរ ។ ឯវិធីតែងពាក្យកាព្យ រឺ ពាក្យរាយក៏គ្មានឯកភាពដែរ ។ ដូចនេះចាំបាច់ត្រូវកែខៃស្ថានភាពចុះអន់ថយនេះឡើងវិញ ដូចជា :

- រៀបចំអោយមានក្បួនខ្នាតត្រឹមត្រូវឡើងវិញនូវក្បួនតែងកាព្យក្តី របៀបសរសេរពាក្យរាយក្តី
- ចាត់ចែងអោយមានការរៀនភាសាបាលីយ៉ាងជ្រាលជ្រៅ
- ចាត់ចែងអោយបកប្រែគម្ពីរ ខាងពុទ្ធសាសនានិងរឿងជាតកជាភាសាបាលី មកជាសាភាខ្មែរ ដែលជាហេតុនាំអោយអ្នកស្រុកងាយយល់ចេះចាំ ហើយនិយាយតមាត់ពីកន្លែងមួយទៅកន្លែងមួយ រហូតដល់រឿងរ៉ាវទាំងនោះក្លាយទៅជាអក្សរសិល្ប៍សាមញ្ញសំរាប់អ្នកស្រុកទូទៅ ។

បន្ទាប់មក ស្នាដៃអក្សរសិល្ប៍មួយចំនួន ពិសេសស្នាដៃជាប្រលោមលោក ពាក្យកាព្យ ក៏មានកំណើតឡើង ។ គេចារឿងរ៉ាវទាំងនោះនៅលើស្លឹករឹត ហើយដែលគេចំលងតៗគ្នា ចែកគ្នាអានបានសុសសាយពេញទាំងស្រុកភូមិ ។

ឯអ្នកនិពន្ធដែលគេបានស្គាល់ច្បាស់លាស់នោះមាន ៖

– **ឧកញ៉ាកោសាធិបតីកៅ** ៖ សរសេររឿង ក្រុងសុភមិត្រ (១៧៩៨) ។

– **ឧកញ៉ាព្រះឃ្លាំងនង** ៖ សរសេរច្បាប់សុភាសិត (១៧៩០) លោកនេយ្យជាតក (១៧៩៤) បុញ្ញសារសិរិសា (១៧៩៧) ភោគកុលកុមារ (១៨០៤) ។

– **ឧកញ៉ាសន្ធរវោហារម៉ុក** ៖ សរសេររឿងទេវន្ទ ល្បើកចចក រឿងទុំទាវ (មុនរឿងទុំទាវរបស់ភិក្ខុសោម) ។

– **ទិសេសង្ងួន** ៖ សរសេរល្បើកអក ល្បើកជុំចនិងត្រី ល្បើកដូងក ។

– **ព្រះអង្គឌួង** ៖ បានរៀនសូត្រចេះដឹងច្រើន ស្គាល់តំលៃពិតប្រាកដនៃអក្សរសាស្ត្រជាតិ ព្រមទាំងបានជួយបណ្ដុះបណ្ដាលឧបត្ថម្ភអោយបានរីកចំរើនឡើង ដូចជាបង្កើតអោយមានទីប្រជុំអ្នកប្រាជ្ញហៅថា "រាជបណ្ឌិត្យ" មានការប្រឡងប្រជែងស្នាដៃដែលតែងថ្មីៗជាដើម ។ ស្នាព្រះហស្តជាកាព្យឃ្លោងរបស់ព្រះអង្គ មានចម្ប៉ាថោង (១៨១០) រឿងកាកី (១៨១៥) ច្បាប់ស្រី (១៨៣៧) និងរឿងព្រះមហាវេស្សន្តរ (ជាពាក្យរាយ) ។

គោលគំនិតសំខាន់ៗ នៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរនាសម័យនោះគឺ ៖

– កម្មនិងផល

– ទំលាប់សភាពអច្ឆរិយៈហួសហេតុ ៖ តួអង្គចេះតស៊ូតពារការលំបាកពុំដកថយតែសំណាង - ឯតួអង្គទេវៈគ្រាន់តែបង្កើតអោយមានជាលំអ (រឿង



ក្រុងសុភមិត្រ) ។

– បញ្ចប់រឿងដោយប្រើវិធីផ្សេងពីសម័យមុនៗ ៖ តួអង្គនៅទីបញ្ចប់មានទុក្ខវេទនារឺស្លាប់ (រឿងកាកី-ទុំទាវ) ។ គំនិតថ្មីនេះទុកដូចជាគំនិតបដិវត្តន៍មួយក្នុងអក្សរសិល្ប៍ខ្មែរ ។

– បង្ហាញការទូន្មានបែបបញ្ចិតបញ្ចៀង - រិះគន់ - កំប្លែងដូចក្នុងរឿងល្បើកថ្មីមានរឿងធ្មេញជ័យ អាឡេវ ចៅចាក់ស្មុក សុភាទន្សាយជាដើម ។

## ៣ - អក្សរសិល្ប៍សម័យទំនើប. –

### * សម័យអាណាព្យាបាល (១៨៦៣ - ១៩៥៣). -

នៅក្រោមអាណាព្យាបាលបារាំង អក្សរសិល្ប៍ខ្មែរចុះអន់ថយអាប់រស្មី ។ ពុំសូវមានការនិយមប្រើអក្សរខ្មែរ ។ រីឯក្បួនខ្នាតអក្សរខ្មែរត្រូវរត់ទៅពួនសំងំនៅក្នុងវត្តអារាម មានព្រះសង្ឃជួយថែរក្សាអោយបានគង់វង្ស ។ ម្យ៉ាងទៀតវិជ្ជាជីវៈជាអ្នកនិពន្ធ ក៏ពុំដែលបានទទួលការលើកទឹកចិត្ត រឺការទំនុកបំរុងពីសំណាក់អាជ្ញាធរបារាំងដែរ ។

គេបានស្គាល់អ្នកនិពន្ធនិងស្នាដៃនៅសម័យនោះ ដូចជា ៖

– **ឧកញ៉ា សុត្តន្តប្រីជាឥន្ទ** ៖ សរសេរពាក្យកាព្យនិរាសអង្គរ (១៩២៦). រឿងគតិលោក (១៩២០) រឿងអំបែងបែក ។ល។

– **ឧកញ៉ានូកន** ៖ សរសេររឿងពិម្ពានិញ្វន (១៩២០) រឿងទាវឯក

(១៩៤២) រឿងអ៊ីណការី ។ល។

— អ្នកស្រីសិទ្ធិ : សរសេររឿង ពិម្ពាពិលាប (១៩២០) ។

— លោក ញ៉ុក ថែម : សរសេររឿង កុលាបប៉ៃលិន (១៩៣៦) រឿង បិសាចស្នេហា (១៩៤០) ។

— លោកគិមហាក់ : សរសេរកំណាព្យសេកសោមបណ្ឌិត (១៩៣៣) រឿងទឹកទន្លេសាប (១៩៤១) ៕

— លោករីម គិន : សរសេររឿងសូផាត (១៩៣៨) ។ល។

ក្នុងចំណោមស្នាដៃទាំងនេះ មានស្នាដៃខ្លះតាក់តែងឡើងទៅតាមទំរង់បែបប្រលោមលោកពួកបស្ចិមប្រទេស ដោយអ្នកនិពន្ធបានទទួលឥទ្ធិពលវប្បធម៌បារាំង ដូចជារឿងទឹកទន្លេសាប កុលាបប៉ៃលិន សូផាត គតិលោក ជាដើម ។

នៅជុំសម័យអាណាព្យាបាល គេបង្កើតអោយមានពុម្ពអក្សរខ្មែរ ហើយ .នការបោះពុម្ពសៀវភៅជាច្រើនដូចជាសៀវភៅធម៌អាថ៌ ច្បាប់បុរាណខ្លះ (ប៉ុន្តែត្រូវសុំអនុញ្ញាតពីរាជការអាណាព្យាបាល) ។ វចនានុក្រមខ្មែរក៏បានកំណើតឡើងដែរ ។ បន្ទាប់មកមានការបង្កើតទស្សនាវដ្ដីកម្ពុជសុរិយា និង ការប្រលងប្រជែងខាងអក្សរសាស្ត្រក្រុមពុទ្ធសាសនបណ្ឌិត្យ ។

* សម័យបច្ចុប្បន្ន (ចាប់ពី ១៩៥៣ រហូតមក).–

លុះមកដល់ គ.ស ១៩៥៣ ពេលបានឯករាជ្យភ្លាម អ្នកនិពន្ធបាន



ធូរស្រាលក្នុងចិត្តគំនិត ដោយបានទទួលនូវសេរីភាពក្នុងការកសាងអក្សរសិល្ប៍ថ្មីៗរបស់ខ្លួន ។ អក្សរសិល្ប៍ខ្មែរក៏បានឈានជើងទៅកាន់ការលូតលាស់ថ្មីមួយដែលមានលក្ខណៈនិងនិន្នាការជាតិនិយម សង្គមនិយម ប្រជាធិបតេយ្យនិងប្រជាប្រិយ ។ គ្រប់ប្រភេទនៃអក្សរសិល្ប៍ក៏បានកើតឡើង គឺប្រលោមលោក កំណាព្យ រឿងល្ខោន សៀវភៅបច្ចេកទេស សៀវភៅសិក្សាអប់រំ សៀវភៅទាក់ទងនឹងគំនិតទស្សនវិជ្ជា ។ល។

ក្រៅពីអ្នកនិពន្ធខ្លះ ដែលបានបញ្ចេញស្នាដៃតាំងពីជំនាន់អាណាព្យាបាលបារាំងមក មានអ្នកនិពន្ធថ្មីៗទៀតជាច្រើន ដែលបង្ហាញស្នាដៃដ៏ប៉ិនប្រសប់ស្ទួយពួតដៃនឹងរៀមច្បងរបស់ខ្លួន មានលោក នូ ហាច ឌៀប-ជុំ ហេង យ៉ាន់ ជាច់ ឆួន កែវ ខាន់សាក់ ឌុច ស៊ុំឌឹម ហ៊ែល សុំផា ឱ ឌូ ឡី ធាមតេង ម៉ា ឡាយខែម លាង-ហាប់អាន កៅ ស៊ុនលី ទិនឡូគោឌិន ប៊ីន ឆៃលាង អ្នកស្រីស៊ុយ ហៀង ស៊ឹម ឆណ្ណស៊ី ញ៉ោ អ៊ីកជាទី សុគន្ធឌីញ ។ល។

ចាប់ពី គ.ស.១៩៥៦ អ្នកនិពន្ធខ្មែរចេះតែកើនឡើងជាលំដាប់ ។ គឺនៅពេលនោះដែរ ដែលសមាគមអ្នកនិពន្ធខ្មែរមានកំណើតឡើង ។ សមាគមនេះមានគោលដៅដ៏សំខាន់ក្នុងការលើកតំកើង ពង្រីងនិងផ្សាយអក្សរសិល្ប៍ជាតិ ហើយបានចាត់ចែងអោយមានការប្រលងប្រជែងមួយឈ្មោះ « រង្វាន់ឥន្ទ្រទេវី » ក្នុងរវាង ៥ ឆ្នាំមុន ដើម្បីបង្កើនកិត្តិវិជ្ជា និង

លើកទឹកចិត្តអ្នកនិពន្ធក្នុងការប្រកបវិជ្ជាជីវៈយ៉ាងថ្លៃថ្នូររបស់ខ្លួន ។

គឺអាស្រ័យដោយបានទទួលនូវការចំរើនលូតលាស់សំខាន់ៗ ទាំងនោះហើយ ដែលអក្សរសិល្ប៍ខ្មែរសម័យថ្មីបន្តដំណើររបស់ខ្លួនឆ្ពោះទៅអនាគត ។

## គ-លក្ខណៈពិសេសនៃអក្សរសិល្ប៍ខ្មែរ.-

រួចមកហើយ យើងបានដឹងពីកំណាកំណើតឡើងនៃអក្សរសិល្ប៍ខ្មែរតាមដំណើរវិវត្តន៍នៃប្រវត្តិសាស្ត្រ ។ ការសិក្សាអក្សរសិល្ប៍តាមសម័យកាលហូរហែមកនេះ នាំអោយយើងបានស្គាល់លក្ខណៈសំខាន់ៗនៃអក្សរសិល្ប៍ខ្មែរទាំងនោះ ដូចជា :

- អក្សរសិល្ប៍ខ្មែរមានចំណាស់ ពោលគឺពុំមែនទើបនឹងកើតមានក្នុងសម័យថ្មីៗនេះទេ ។
- អក្សរសិល្ប៍ខ្មែរមានច្រើនប្រភេទ ព្រោះមានទំនាក់ទំនងសឹងគ្រប់វិស័យ មានវិស័យប្រវត្តិសាស្ត្រ-សាសនា-ល្ខោន-កំណាព្យ-ប្រលោមលោក-បច្ចេកទេស-ច្បាប់ជាដើម ។
- អក្សរសិល្ប៍ខ្មែរមានលក្ខណៈជាតិនិយម ។ ចំពោះអក្សរសិល្ប៍បរទេសដែលផ្សាយចូលមក ខ្មែរពុំនិយមរក្សាទុកទាំងដុលទេ ខ្មែរបានកាលៃលក្ខណៈបរទេសអោយស្របស្រួលនឹងលក្ខណៈរបស់ជាតិខ្លួន ឧ. រឿងរាមកេរ្តិ៍ រឿងជាតក ។



- អក្សរសិល្ប៍ខ្មែរមានលក្ខណៈពិតនិយម ។ អ្វីដែលហួសខុស ដែលអស្ចារ្យហួសវិស័យ ខ្មែរពុំនិយម ពុំចង់បានទេ ។ ខ្មែរនិយមអ្វីដែលពិត ឃើញនឹងភ្នែក (រូបិយ) ហើយប្រសិនបើមានអ្វីដែលអស្ចារ្យ គឺអស្ចារ្យដើម្បីពិតនេះឯង (ឧ. រឿងវេស្សន្តរ) ។ រឿងព្រេង ច្បាប់ផ្សេងៗរបស់ខ្មែរបានបង្ហាញពិតនិយមច្បាស់លាស់ណាស់ក្នុងការរស់នៅក្នុងសង្គម គឺអប់រំកូនខ្មែរ និងមហាជនខ្មែរ អោយចេះស្គាល់ល្អ-អាក្រក់ ចេះដោះស្រាយទំនាស់វិបត្តិផ្សេងៗ ជាដើមក្នុងសង្គម ដើម្បីយកជ័យជំនះក្នុងឆាកជីវិត ពោលគឺបានសំរេចសុភមង្គលគ្រប់បែបយ៉ាង ។

## យោបល់រួម.-

អក្សរសិល្ប៍មិនគ្រាន់តែជាកញ្ចក់សំរាប់ឆ្លុះមើលការរស់នៅរបស់សង្គមមនុស្សក្នុងសម័យកាលនីមួយៗប៉ុននោះទេ គឺជាមធ្យោបាយមួយយ៉ាងសំខាន់សំរាប់ផ្សាយវប្បធម៌ជាតិ ។ ដូចនេះ អ្នកនិពន្ធដែលមាននាទីជាអ្នកផ្សាយវប្បធម៌ គប្បីជ្រើសរើសយកគំនិត ទស្សនៈ យោបល់ល្អៗ ហើយសំខាន់ៗ ទៅតាក់តែងអត្ថបទរបស់ខ្លួន អោយបានជាទីចាប់ចិត្ត ចាប់អារម្មណ៍ ហើយជាគុណប្រយោជន៍ដល់អ្នកអានថែមទៀត ។ ហើយគួរគប្បីខំបង្កើនអក្សរសិល្ប៍អោយបានសំបូរគ្រប់វិស័យ ទាន់សេចក្តីត្រូវការរបស់យុវជន និងមហាជនស្របតាមការលូតលាស់ចំរើនរបស់អរិយ-

ធម៌ជាតិ ។ ចំណែកអ្នកអានវិញ មិនគ្រាន់តែយកការអានអក្សរសិល្ប៍ជា នាទីកំសាន្តតែអផ្សុកប៉ុណ្ណោះទេ គឺត្រូវចេះគិតពិចារណា ចេះទាញយក ពីអំណាននូវគំនិតល្អៗទុកជាមេរៀន ជាចំណេះចេះដឹង ជាការចំរើន ល្អតលាស់ដល់សតិប្រាជ្ញារបស់ខ្លួនទៀតផង ។

* * *

# ជំពូកទី៣

# សិល្បៈ

ពាក្យ សិល្បៈ (សំស្ក្រឹត) រឺ សិប្បៈ (បាលី) សំដៅយកការងារ ផ្សេងៗ ជំនាញ ហត្ថកម្មគ្រប់បែបយ៉ាងដែលមាន សិល្ប៍ ពោលគឺធ្វើ អោយមនុស្សចាប់ចិត្ត ចាប់អារម្មណ៍ ចង់មើល ចង់ឃើញ ចង់ស្តាប់ ។ សិល្បៈមានច្រើនប្រភេទណាស់ ដូចជាសិល្បៈរបាំ-ចំរៀង-ភ្លេង-ល្ខោន ក្បួន-ចំលាក់-គំនូរ-សំណង់-សូនរូប ។ល។ ដោយសិល្បៈមានន័យទូលំទូលាយ ហើយមានច្រើនប្រភេទបែបនេះ យើងពុំបានលើកយកមកពន្យល់-បរិយាយអោយបានសព្វគ្រប់ទេ យើងសូមលើកយកតែលក្ខណៈសំខាន់ៗ នៃសិល្បៈខ្មែរបុរាណខ្លះមកបង្ហាញប៉ុណ្ណោះ ។

## ១-សញ្ញាណនៃស្ថាបត្យកម្ម

( Notions d'architecture )

### ក-សម្ភារៈសំណង់និងបច្ចេកទេសសំណង់ (5).-

គេបានដឹងច្បាស់ថា សិល្បៈសំណង់ប្រាសាទបុរាណខ្មែរមានតាំងពី

សម័យហ្វូណនមកម៉្លេះ ហើយស្ថាបត្យសិល្បៈនេះចេះតែវិវត្តឆ្ពោះទៅមុខរហូតដល់សម័យបាយ័ន ។ ដើម្បីសំរួលដល់ការសិក្សា គេនិយមចែកសិល្បៈជារចនាបថ ( Style ) ដោយយកឈ្មោះប្រាសាទសំខាន់ៗ មកដាក់ឈ្មោះរចនាបថទាំងនោះដូចតទៅ :

១-រចនាបថ ភ្នំដា (ស.វ. ទី ១-៦ )

២-រចនាបថ សំបូរ (ពាក់កណ្ដាលទី ១ នៃស.វ.ទី ៧)

៣-រចនាបថ ព្រៃក្មេង (ពាក់កណ្ដាលទី ២ នៃស.វ.ទី៧ )

៤-រចនាបថ កំពង់ព្រះ ( ស.វ. ទី ៨ )

៥-រចនាបថ គូលែន (ពាក់កណ្ដាលទី ១ នៃស.វ.ទី ៩ )

៦-រចនាបថ ព្រះគោ ( ១ ភាគ ៤ ចុងក្រោយនៃស.វ.ទី ៩ )

៧-រចនាបថ បាខែង (ចុងស.វ.ទី ៩ និងដើមស.វ.ទី ១០ )

៨-រចនាបថ កោះកេរ ( ១ភាគ៤ ទី ២ នៃស.វ.ទី ១០)

៩-រចនាបថ បន្ទាយស្រី (ពាក់កណ្ដាលទី ២ នៃស.វ.ទី ១០)

១០-រចនាបថ ឃ្លាំង (ចុងស.វ.ទី ១០ និងពាក់កណ្ដាលទី១នៃស.វ.ទី១១)

១១-រចនាបថ បាពួន (ពាក់កណ្ដាលទី ២ នៃស.វ.ទី១១)

១២-រចនាបថ អង្គរវត្ត (ពាក់កណ្ដាលទី ១ នៃស.វ.ទី ១២ )

១៣-រចនាបថ បាយ័ន (ពាក់កណ្ដាលទី ២ នៃស.វ.ទី ១២ និងដើមស.វ. ទី ១៣) ។

* ស្ថាបត្យកម្មមុនសម័យអង្គរ (ស.វ.ទី ១ ដល់ ៨ ).-



— នៅក្នុងរចនាបថភ្នំដា : ដំបូងខ្មែរបាន ចោះភ្នំ ធ្វើជាប្រាសាទ (ប្រាសាទនៅភ្នំដា) ដូចនៅឥណ្ឌាដែរ ។

— នៅក្នុងរចនាបថសំបូរ : ប្រាសាទសង់ដាច់ៗពីគ្នាមានរាងតូចៗ ធ្វើអំពី ឥដ្ឋ ប្លុកបាយអមួយបែបដែលផ្សំឡើងដោយកំបោរនិងស្ករ ។ បាយអបែបនេះមិនសូវជាប់បានយូរទេ សព្វថ្ងៃរបេះធ្លាក់ស៊ើរអស់ទៅហើយ ។ ឯក្របទ្វារ-បង្អួច ផ្ដែរ (linteau) និងសសរពេជ្រ ( colonnette ) ធ្វើអំពី ថ្មភក់ ( grès ) ដែលជាថ្មភ្នំម្យ៉ាងដែលមានគ្រាប់ខ្សាច់ល្អិតៗផ្សំលាយជាប់គ្នាយ៉ាងរឹង ។ ថ្មភក់មានពណ៌ប្រផេះនិងកូលាប ។ ចំលាក់នៅលើថ្មភក់មានសភាពល្អណាស់ ។

— នៅក្នុងរចនាបថព្រៃក្មេង : ស្ថាបត្យកម្មមានលក្ខណៈប្រហែលគ្នានឹងស្ថាបត្យកម្មក្នុងរចនាបថសំបូរដែរ ។

— នៅក្នុងរចនាបថកំពង់ព្រះ : ប្រាសាទស្ទើរតែទាំងអស់សង់ដូចក្នុងសម័យមុនៗដែរ គឺសង់រាបនឹងដី លើកលែងតែប្រាសាទអកយំមួយដែលសង់ច្រើនជាន់មានរាងដូចចេតិយ ។

* ស្ថាបត្យកម្មសម័យអង្គរ (ស វ.ទី ៩ ដល់ ១៣).-

— នៅក្នុងរចនាបថគូលែន : ដូចសម័យមុនៗដែរ គេសង់ប្រាសាទអំពីឥដ្ឋនៅឡើយ ប៉ុន្តែគេនិយមសាងប្រាសាទភ្នំ ( ប្រាសាទមានរាងខ្ពស់ដូចភ្នំ រឺសាងនៅលើកំពូលភ្នំ ) ដើម្បីតំរូវទៅតាមពិធីទេវរាជ ( ក្នុងរាជ្យព្រះ

បាទជ័យវរ្ម័នទី ២) ។ គេចាត់ទុកសម័យគូលែនជាសម័យសិល្បៈរីកចំរើនឡើងវិញ (Renaissance) ដោយសារមានការសាកល្បងរចនាបញ្ចូលគ្នានៃសិល្បៈ ពីបុព្វអង្គរ ពីឥទ្ធិពល ចាម-ជ្វា អោយទៅជាសិល្បៈមួយថ្មី ប៉ុន្តែពុំទាន់មានលក្ខណៈច្បាស់លាស់ល្អនៅឡើយទេ ។

— នៅក្នុងរចនាបថព្រះគោ : គេសាងប្រាសាទអំពីឥដ្ឋនៅឡើយ ប៉ុន្តែគេសាងប្រាង្គជាច្រើននៅលើខឿនតែមួយ ( ព្រះគោ លលៃ ) ដើម្បីឧទ្ទិសចំពោះបុព្វបុរសមានព្រះមាតាបិតាជាដើម ។ មានការសាកល្បងសង់ប្រាសាទតូចៗអំពីថ្មភក់ចំនួន ១២ នៅលើជាន់ទី៤ នៃប្រាសាទបាគង។ សិល្បៈក្នុងរចនាបថនេះ មានលក្ខណៈខ្មែរសុទ្ធសាធ ហើយមានវិវត្តន៍ក្នុងសម័យក្រោយមកទៀត ។

— នៅក្នុងរចនាបថបាខែង ; មានប្លែកច្រើនគេបានសាងប្រាសាទធំៗអំពីថ្មភក់ មានច្រើនជាន់នៅលើខឿនខ្ពស់រាងសាជី (pyramide à gradin) ជាពិសេសគេនិយមសាងប្រាសាទនៅលើកំពូលភ្នំតែម្តង (ឧ. ប្រាសាទបាខែង) ។

— នៅក្នុងរចនាបថកោះកេ : មានលក្ខណៈដូចសម័យមុនដែរ ប៉ុន្តែគេបានសង្កេតឃើញមានប្រាសាទមួយក្នុងចំណោមប្រាសាទនៅកោះកេ សង់នៅលើខឿន៧ ជាន់ដែលមានកំពស់ប្រហែល ៣៥ ម. ។

— នៅក្នុងរចនាបថបន្ទាយស្រី ; មានលក្ខណៈស្អុតស្អាញ ច្របូកច្របល់គ្នា ប៉ុន្តែមានការចំរើនល្អគួរលាស់ថ្មីទៀត : មានបន្ទប់វែងៗ



សង់នៅជាន់ទី ១ ក្នុងប្រាសាទមេបុណ្យខាងកើត ។

— នៅក្នុងរចនាបថឃ្លាំង : គេលែងសាងប្រាសាទអំពីឥដ្ឋទៀតហើយ ។ សំណង់ប្រាសាទភ្នំនិងកំណើតថែវ (galerie) កាន់តែរីកចំរើនឡើងទៀតនៅក្នុងសម័យនេះ ។

— នៅក្នុងរចនាបថ បាពួន : ប្រាសាទភ្នំរឹតតែមានចំនួនច្រើនឡើងទៀតឯខឿនកាន់តែធំហើយកាន់តែខ្ពស់ ។

នៅក្នុងរចនាបថ អង្គរវត្ត : ស្ថាបត្យកម្មខ្មែរបានចំរើនឡើងដល់កំពូល ។ គេសាងប្រាសាទអង្គរវត្តជាប្រាសាទភ្នំអំពីថ្មភក់ (គ្រប់ប្រាសាទទាំងមូល) ។ គេជាមុននឹងសាងប្រាសាទអង្គរវត្តប្រកបដោយប្លង់ដ៏ល្អវិចិត្រ ស្ថាបត្យករខ្មែរ បានសាកល្បងសាងប្រាសាទបឹងមាលា ដែលមានប្លង់ដូចអង្គរវត្តដែរ ក៏ប៉ុន្តែប្រាសាទបឹងមាលានេះសង់នៅលើដីរាបស្មើ ។

— នៅក្នុងរចនាបថបាយ័ន : ស្ថាបត្យកម្មចុះអន់ថយបន្តិច ព្រោះប្រាសាទទាំងឡាយសាងដោយប្រញាប់ប្រញាល់ពេក ហើយថ្មក៏មិនសូវមានគុណភាពល្អដូចសម័យមុនឡើយ ។ ប្រាសាទទាំងឡាយសុទ្ធតែសង់នៅលើដីរាបស្មើបែបជាវត្តអារាម ( លើកលែងប្រាសាទបាយ័ន ) ដើម្បីសំរបទៅតាមទស្សនៈពុទ្ធសាសនា ។ លក្ខណៈពិសេសនៃរចនាបថនេះគឺប្រាង្គមុខបួនញញឹមប្រិមប្រិយ និងមាននាគអមសងខាងផ្លូវដែលឆ្លងគូចូលទៅកាន់ប្រាសាទ ។

**សង្ខេប** . — ក្រៅពីសម្ភារៈ ថ្មភ្នំ ឥដ្ឋ បាយអរ ថ្មភក់ មានថ្មបាយ

ក្រៀម (latérite) ដែលជាថ្មមានជាតិដែក មានសណ្ឋានគ្រាប់ៗជាប់គ្នាដូចបាយក្រៀម មានពណ៌ក្រហម ខ្មៅ ស្វាយ ។ ថ្មបាយក្រៀមធន់នឹងធាតុអាកាសគួរបែបយ៉ាង ។ គេមិនឆ្លាក់លើថ្មប្រភេទនេះទេ ប៉ុន្តែប្រើសង់កំពែង ជណ្តើរចុះទៅក្នុងស្រះ ខឿនប្រាសាទ និងជញ្ជាំងប្រាសាទខ្លះដែរ ។ ឯឈើក៏មានប្រើខ្លះដែរ ប៉ុន្តែជាសម្ភារៈបន្ទាប់បន្សំសំរាប់ធ្វើពិតាន គ្រឿងទ្រដំបូលនិងផ្តែរ ។ ក្រៅពីនេះគេច្រើនយកឈើទៅសាងវាំងស្តេចនិងពន្លាស្តេចនៅពេលបុណ្យទានម្តងៗ ។ សម្ភារៈឈើមិនអាចទប់ទល់បានយូរនឹងពេលវេលា ហើយនិងធាតុអាកាសឡើយ ។ ដូចនេះចំលាក់នៅលើឈើក៏មិនស្ថិតស្ថេរដែរ ។

## ១-រចនាសម្ពន្ធ (structure).–

– **ជញ្ជាំង** ធ្វើដោយថ្មភក់ រឺថ្មបាយក្រៀម ។ គេរៀបដុំថ្មដែលគេបានត្រដុសរំលីងហើយ ដោយដាក់បន្ទុបលើគ្នា (តាមបណ្តោយដុំថ្ម ហើយឆ្លាស់គ្នាក្នុងមួយជួរៗ) ។



– **ខ្លូត (voûte)** ជួនកាលគេយកឥដ្ឋ ជួនកាលគេយកថ្មដើម្បីសង់រូត (ដំបូលប្រាសាទ) ។ នៅស្រុកខ្មែរ គេធ្វើតែដោយរៀបផ្ទាំងថ្ម រឺឥដ្ឋអោយលៀនចេញពី



គ្នាបន្តិចម្តងៗរហូតជួបគ្នានៅដំបូលលើបង្អស់ (voûte à encorbellement) ។ ជួនកាលគេសង់ពិដានឈើបាំងមិនអោយមើលឃើញរូតបែបនេះ ។

– ទ្វារ.បង្អួច គេធ្វើក្របទ្វារប្រាសាទអំពីថ្មភក់ ។ ឯបង្អួច ជួនកាលមានរាងការេ ជួនកាលចតុកោណកែង ។ គេច្រើនធ្វើទ្វារបង្អួចបិទជិតដោយភាគ អំពីថ្មបាយក្រៀម ជួនកាលគេធ្វើជាចំរឹងអំពីថ្មភក់ដាក់បញ្ឈរតាមបង្អួច ។

នៅតាមជញ្ជាំងប្រាសាទខ្លះ សិល្បករបានឆ្លាក់ធ្វើទ្វារនិងបង្អួចបញ្ឆោត (fausses portes et fausses fenêtres) ។

– ផ្តែរ ច្រើនមានទំហំធំនិងទម្ងន់ធ្ងន់ ដែលទ្រដោយសសរពេជ្រ (colonnette) ពីរ ។ ធម្មតាគេធ្វើផ្តែរពីរជាន់ ។ ផ្តែរទី១ ជាផ្ទាំងថ្មធម្មតា (ផ្តែរសំរាប់ទ្រ) ។ ឯផ្តែរទី២ ជាផ្ទាំងថ្ម ដែលគេរចនាដោយក្បាច់ក្បូរ រឺរូបផ្សេងៗ ហើយដែលដាក់បិទពីមុខផ្តែរទី១ (ផ្តែរសំរាប់លំអ) ។ គេបានសង្កេតឃើញថាក្បាច់លំអនៅលើផ្តែរ និងលើសសរពេជ្រក៏មានវិវត្តន៍ប្តូរកែពីរចនាបថមួយទៅរចនាបថមួយដែរ ។

## ៣– រចនាសម្ពន្ធទូទៅ (structure générale).–

គេតែងចាត់ទុកថា ប្រាសាទជាលំនៅរបស់អាទិទេព ។ ប្រាង្គ

ប្រាសាទដែលជាលំនៅអាទិទេព ( sanctuaire ) មានទំហំតូច ។ អ្នកដែលអាចចូលទៅក្នុងប្រាង្គនោះបាន មានតែពួកព្រាហ្មណ៍បុរោហិត និងពួកថែរក្សាប្រាសាទ ។ គេច្រើននិយមធ្វើប្រាង្គអាទិទេពនោះ ជារាងសាជី ( Forme pyramidale ) ហើយគេចាត់ទុកថាជាតំណាងភ្នំព្រះសុមេរុ ដែលជាទេវស្ថានរបស់អាទិទេពក្នុងព្រាហ្មណ៍សាសនា ។ ប្រាង្គនេះស្ថិតនៅចំអ័ក្ស (axe) នៃប្រាសាទនិងនៅចំកណ្ដាលប្រាង្គឯទៀតៗ ដែលជាលំនៅរបស់ទេវៈរាយរង និងជាលំនៅរបស់យានជំនិះនៃអាទិទេព ។

ប្រាសាទខ្លះទៀតត្រូវគេសន្និដ្ឋានថាជាបណ្ណាល័យ ប៉ុន្តែអ្នកខ្លះបានអះអាងថាជាកន្លែងដែលគេទុកដាក់ប្រដាប់ប្រដាសំខាន់ៗ សំរាប់រៀបពិធីទៅវិញ ។

គេបានសង្កេតឃើញនៅក្បែរប្រាសាទមានស្រះមួយជានិច្ច ។ គេតែងធ្វើកំពែងព័ទ្ធជុំវិញប្រាសាទ ។ ប្រាសាទខ្លះមានកំពែងច្រើនជាន់ កំពែងខ្លះសំរាប់ចូលបានតែពួកព្រាហ្មណ៍បុរោហិត ខ្លះទៀតសំរាប់ពួកអ្នកនាំ ពួកភ្លេងជាដើម ។ នៅមាត់ជណ្ដើរឡើងទៅកាន់កំពែងនីមួយៗ មាន **គោបុរៈ** គឺជាទ្វារដែលមានដំបូលរាងដូចប្រាង្គកណ្ដាលដែរ ប៉ុន្តែតូចជាង ។ នៅពីមុខប្រាង្គកណ្ដាល មានថែវវ៉េរាំងដែលភ្ជាប់ទៅនឹងប្រាង្គនោះ ហើយដែលគេនិយមហៅថា **មណ្ឌប** ។

ជាទូទៅគេសង់ប្រាសាទបែរមុខទៅទិសខាងកើត ដោយគេនិយមជឿថាទិសខាងកើតជាទិសដែលកើតមានសេចក្ដីចំរើនរុងរឿង លើកលែង



ប្រាសាទអង្គរវត្តមួយ ដែលបែរមុខទៅទិសខាងលិចវិញ ។ មានសម្មតិកម្មជាច្រើនចំពោះការបែរមុខទៅលិចនៃប្រាសាទអង្គរវត្ត :

— អ្នកខ្លះថាបើធ្វើប្រាសាទអង្គរវត្តបែរមុខទៅកើត វាជិតស្ទឹងសៀមរាបពេកនាំអោយគ្មានកន្លែងធ្វើបុណ្យទាន ហើយផ្លូវចូលទៅកាន់រាជធានីអង្គរធំនោះនៅទិសខាងលិចស្រាប់ ។

— អ្នកខ្លះថាធ្វើបែរទៅកើត ហាក់ដូចជាបាំងទៅលើប្រាសាទសំខាន់ៗឯទៀត ។

— អ្នកខ្លះទៀតថា បានជាបុព្វបុរសយើងសាងអង្គរវត្តបែរមុខទៅខាងលិច ពីព្រោះប្រាសាទនេះជាប្រាសាទផ្នូររបស់ព្រះបាទសូរ្យវរ្ម័នទី ២ ។

## ឃ – ប្រភេទនៃប្រាសាទ.–

គេបានសង្កេតឃើញថា ប្រាសាទបុរាណមានច្រើនប្រភេទណាស់ :

— **ប្រាសាទដែលមានប្រាង្គតែមួយ ហើយសង់ជាប់តែឯង**

ឧ. ប្រាសាទភ្នំបាយ៉ង់ ប្រាសាទភ្នំបាសិត ប្រាសាទភូមិប្រាសាទ ។ល។

— **ប្រាសាទដែលមានប្រាង្គច្រើននៅលើខឿនតែមួយជាន់**

ឧ. ប្រាសាទព្រះគោ ប្រាសាទលលៃ ។ល។

— **ប្រាសាទដែលសង់លើដីរាប** ( temple à plat ) គ្មានខឿនទេ គឺសង់ផ្ទាល់ដីរាបស្មើ ។

ឧ. ប្រាសាទ ភូមិប្រាសាទ ប្រាសាទព្រះខាន់ ។ល។

– ប្រាសាទភ្នំ (temple-montagne) សង់ខ្ពស់ដូចភ្នំ មានទំហំធំ



ប្រាសាទបក្សីចាំក្រុង



មានទៀនច្រើនជាន់ ។ ប្រាសាទភ្នំមាន២យ៉ាង: ប្រាសាទភ្នំ ដែលសង់នៅលើភ្នំធម្មជាតិ ( montagne naturelle ) ដូ. ប្រាសាទបាខែង និងប្រាសាទភ្នំដែលសង់នៅលើដី (montagne artificielle) ដូ. ប្រាសាទបាគង ប្រាសាទបក្សីចាំក្រុង ប្រាសាទធំ ប្រាសាទប្រែរូប ប្រាសាទតាកែវ ប្រាសាទបាពួន ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ។ល។ គេសង់ប្រាសាទភ្នំ គឺ ដើម្បីតំណាងភ្នំនេះឯង ។ តាមទស្សនៈឥណ្ឌា គេនិយមគោរពភ្នំព្រះសុមេរុជាឋាននៃអាទិទេពឥសូរ ។ នៅស្រុកខ្មែរ តាមជំនឿលទ្ធិសាសនាព្រាហ្មណ៍អំពីអាទិទេព គេបានសាងរូបលិង្គតំណាងព្រះឥសូរ តំកល់នៅក្នុងប្រាសាទភ្នំខ្លះ មានប្រាសាទបាគង ប្រាសាទបាខែង ជាដើម ហើយដែលមានទំនាក់ទំនងនឹងពិធីទេវរាជថែមទៀត ។

## ខ - មុខងារប្រាសាទ :-

មតិខ្លះបានយល់ច្រលំថា ប្រាសាទដែលបុព្វបុរសយើងបានកសាងទុកមកគឺសំរាប់ជាលំនៅស្ថាន (រាជវាំង) របស់ព្រះមហាក្សត្រ ។ តាមពិតប្រាសាទខ្មែរបុរាណទាំងឡាយ ទោះជាប្រាសាទភ្នំក្ដី រឺ ជាប្រាសាទសង់លើដីរាបក្ដី ពុំមែនសំរាប់នៅទេ គឺ សំរាប់ :

– ឧទ្ទិសថ្វាយអាទិទេព រឺ ទេវៈផ្សេងៗ ក្នុងសាសនាព្រាហ្មណ៍ ដូចជាព្រះឥសូរ ព្រះនារាយណ៍ ជាដើម ។.

- ឧទ្ទិសថ្វាយពោធិសត្វ ក្នុងពុទ្ធសាសនា ដូចជាលោកេស្វរៈ (ពោធិសត្វខាងពុទ្ធសាសនាមហាយាន) ។
- ឧទ្ទិសថ្វាយទេវរាជ (តំកល់លិង្គព្រះឥស្វរក្នុងប្រាសាទជាតំណាងព្រះរាជា) ។
- ឧទ្ទិសថ្វាយបុព្វបុរសព្រះរាជា មានព្រះបិតា-មាតា និងវីរជនខ្លះ ។

## ច- តំលៃនៃស្ថាបត្យកម្មខ្មែរ.

ការសិក្សារួចមកហើយ បង្ហាញអោយឃើញថា សិល្បៈផ្នែកស្ថាបត្យកម្មខ្មែរមានវិវត្តន៍ឥតឈប់ឈរ ទៅកាន់ការលូតលាស់ចំរើនពីសម័យមួយទៅសម័យមួយទៀត ។ ការចំរើនលូតលាស់បែបនេះ សអោយឃើញថាបុព្វបុរសខ្មែរដែលជាស្ថាបត្យករ មានទេពកោសល្យខ្ពង់ខ្ពស់ណាស់ ។ ក្រៅពីទេពកោសល្យខាងច្នៃនិងផ្សំផ្សំសិល្បៈបរទេសជាមួយសិល្បៈរបស់ខ្លួនដើម្បីអោយកើតបានជាសិល្បៈមួយថ្មីទៀត មានរូបរាងនិងលក្ខណៈជាខ្មែរ នៅមានទេពកោសល្យខាងបង្កើតថ្មីស្របតាមទស្សនៈដែលជាមូលដ្ឋានទ្រទ្រង់សិល្បៈនោះថែមទៀត ។

នៅសម័យភ្នំដា ខ្មែរបានយកភ្នំធម្មជាតិមកលុងធ្វើជាប្រាសាទត្រាប់តាមឥណ្ឌាមែន ប៉ុន្តែនៅសម័យក្រោយមកទៀតបុព្វបុរសខ្មែរបានច្នៃគំនិតគោរពនៅលើទីខ្ពស់អោយចេញជារូបរាងប្រាសាទ (ប្រាសាទភ្នំ) មានជាន់ច្រើនជាន់ដើម្បីអោយខ្ពស់ដូចភ្នំធម្មជាតិ ។ ទស្សនៈគោរពនៅលើ



ទីខ្ពស់នេះ ខ្មែរយើងក៏ធ្លាប់មានរួចមកហើយដែរ មុនសាសនាព្រាហ្មណ៍ចូលមក គឺទស្សនៈគោរពអ្នកតានៅលើកំពូលភ្នំ ឬ នៅទីខ្ពស់ ។ លុះទស្សនៈឥណ្ឌាចូលមកក៏ស៊ីគ្នាតែម្តង ។ ឯបង្កាន់ដៃនាគនៅសងខាងផ្លូវទៅកាន់ប្រាសាទនីមួយ ៗ និងគូទឹកដែលព័ទ្ធជុំវិញប្រាសាទជានិមិត្តរូបនៃកំណូរសមុទ្រទឹកដោះក្នុងទស្សនៈឥណ្ឌានាសម័យដើមក៏បានក្លាយមកជានិមិត្តរូបនៃនយោបាយទឹកដ៏ប្រសើររបស់ខ្មែរនាសម័យអង្គរ ។ ត្រង់នេះបង្ហាញអោយឃើញថា សិល្បៈខ្មែរពុំគ្រាន់តែបំរើគំនិតនិមិត្តរូបនិយមក្នុងជំនឿសាសនាប៉ុណ្ណោះទេ គឺបំរើគំនិតមនុស្សនិយម (បំរើប្រយោជន៍មនុស្ស) ផងដែរ ។

អាស្រ័យដោយស្នាដៃដ៏ប៉ិនប្រសប់ ដ៏ឆើតឆាយរបស់ដូនតាយើងបែបនេះហើយ បានជាសិល្បៈស្ថាបត្យកម្មខ្មែរ មានតំលៃខ្ពង់ខ្ពស់ទាំងក្នុងប្រទេស ទាំងក្រៅប្រទេសដោយបានទទួលការកោតសរសើរ ស្ងប់ស្ងែងយ៉ាងក្រៃលែង ។

តំលៃបែបនេះក៏មានដែរនៅក្នុងសិល្បៈផ្នែកចំលាក់ ដែលយើងនឹងលើកយកមកសិក្សាតទៅទៀត ។

* *

*

# ២-រូបចំលាក់បូរាណ

ក្រៅពីសិល្បៈសំណង់ បុព្វបុរសខ្មែរបានទុកស្នាដៃខាងសិល្បៈចំលាក់ដែលគេបានប្រទះឃើញជាច្រើននៅតាមប្រាសាទខ្មែរបូរាណ ។

## ក-ប្រភេទចំលាក់.-





ក្បាច់លិបជារឿង



គេបានសង្កេតឃើញថា ចំលាក់បូរាណខ្មែរមាន ៣ យ៉ាងគឺ : ចំលាក់លិប រឺ ចំលាក់រាក់ ចំលាក់លៀន រឺ ចំលាក់ជ្រៅ និង ចំលាក់លោត (ក្លាយទៅជារូបបដិមា) ។

- **ចំលាក់លិប** (bas-relief) គឺក្បាច់ដែលគេឆ្លាក់នៅលើផ្ទាំងថ្មលូកចូលទៅក្នុងផ្ទៃថ្ម មើលទៅមិនសូវឃើញខ្ពស់ រឺផុសចេញខ្លាំងពីផ្ទៃថ្មទេ ។ គេច្រើនធ្វើក្បាច់បែបនេះនៅតាមជញ្ជាំងប្រាសាទ ។ ឧ. ក្បាច់លិបជារឿង (bas - relief à scènes) នៅតាមថែវជាន់ទី ១ នៃប្រាសាទអង្គរវត្ត ។
- **ចំលាក់លៀន** (haut-relief) គឺក្បាច់ដែលឆ្លាក់នោះលៀនចេញខ្ពស់ពីផ្ទៃថ្ម ព្រោះគេដាប់សាច់ថ្មអោយជ្រៅ មើលទៅរូបចំលាក់ហាក់ដូចផុសចេញពីផ្ទៃថ្ម ។ គេនិយមធ្វើចំលាក់លៀន នៅលើផ្តែរ លើសសរពេជ្រ លើជញ្ជាំង (ដូចរូបទេពអប្សរ) ។
- **ចំលាក់លោត** ( ronde-bosse) ម្តងនេះ គេឆ្លាក់រូបសត្វ រឺមនុស្សពុំមែននៅលើជញ្ជាំងទេ គឺដាច់ពីជញ្ជាំង ប៉ុន្តែផ្អែកជាប់នឹងជញ្ជាំងដោយទំរ ( stèle d' appui ) ព្រោះខ្លាចរលំដួល ។ លុះក្រោយមកទៀតគេឆ្លាក់រូប បដិមា ( statue ) ដាច់តែឯង ដោយមិនចាំបាច់មានទំរដូចមុនទៀតទេ ។

## ខ-ប្រធានចំលាក់.-

រូបចំលាក់បូរាណមានច្រើនបែបយ៉ាងណាស់ ក្នុងពេលនេះយើង



ទេពអប្សរ



សូមលើកយកតែរូបចំលាក់ដែលទាក់ទងទៅនឹងសាសនា និងប្រាសាទបុរាណមកសិក្សាតែប៉ុណ្ណោះ ។

* ពុទ្ធរូប (4) (5) . –

គេបានប្រទះឃើញមានពុទ្ធបដិមា តាំងពីក្នុងសម័យនគរភ្នំ ។ ក្នុងសិល្បៈខ្មែរ ព្រះពុទ្ធរូបគ្មានគ្រឿងអលង្ការទេ ហើយច្រើនមានកាយវិការ ( មុទ្រៈ រឺ មុទ្រា ) ប្លែក ៗ គ្នាដូចតទៅនេះ :

– ឈានមុទ្រៈ រូបគង់ភ្នែនមាននាគប្រក់ពីលើ បាតព្រះហស្តទាំងពីរលើហើយដាក់លើភ្លៅ គឺជាកាយវិការកំពុងធ្វើសមាធិ (geste de la méditation) ។

– ភូមិស្ប្រសិមុទ្រៈ រូបគង់ភ្នែន ព្រះហស្តឆ្វេងដាក់លើភ្លៅ ព្រះហស្តស្តាំដាក់លើក្បាលជង្គង់ហើយសំយុងចង្អុលព្រះហស្តទៅរកដី គឺជាកាយវិការយកព្រះធរណីជាសាក្សី ( geste de l' attestation de la terre ) ក្នុងពេលផ្ចាញ់មារ ។

– អភយមុទ្រៈ រូបឈរ ព្រះហស្តទាំងពីរលោដាក់ទៅមុខ ចង្អុលព្រះហស្តឡើងទៅលើ គឺជាកាយវិការបញ្ជាក់ថា កុំខ្លាច ( geste qui assure ) ។

– ធម្មចក្រមុទ្រៈ រូបគង់ភ្នែន ព្រះហស្តទាំងពីរបង្ហាញជាសញ្ញាបង្វិលកង់ចក្រ គឺជាកាយវិការសំដែងធម្មចក្រ ( geste de faire tourner la roue de la Loi ) ។

- វរមុទ្រ: រូបឈរ ព្រះហស្តលាដាក់ទៅមុខ ចន្លុលព្រះហស្តសំយុងទៅក្រោម គឺជាកាយវិការសប្បុរសធម៌ដាក់ទាន (geste de la charité ou du don) ។

- វិតក្កមុទ្រ: រូបឈរ ព្រះហស្តទាំងពីរលាបែរទៅមុខ បត់ចន្លុលព្រះហស្តកណ្ដាលមកភ្ជាប់នឹងមេដៃ គឺជាកាយវិការបង្ហាញថា ការដែលធ្វើរួចហើយធ្វើថែមទៀតអោយរឹតតែមាំមួនឡើង( geste de l'argumentation) រឺបង្ហាញការត្រិះរិះពិចារណា ។

ក្រៅពីរូបដែលមានកាយវិការទាំងនេះ គេបានសង្កេតឃើញមានពុទ្ធរូបគន់ភ្នែន មានរូបស្គាំងស្គមឃើញតែឆ្អឹង (ព្រះពុទ្ធធ្វើទុក្ករកិរិយា) និងពុទ្ធរូបផ្ទុំផ្អៀងទៅខាងស្តាំ ( ព្រះពុទ្ធចូលបរិនិព្វាន ) ។

នៅមានលក្ខណៈផ្សេង ៗ ទៀតដើម្បីសំគាល់ព្រះពុទ្ធរូបដូចជា :

- គ្រងចីវរ ទុកស្មាខាងស្តាំទទេ
- មានសញ្ញាមួយនៅចន្លោះភ្នែក
- មានពក រឺកន្ទុប ( protubérance ) នៅលើព្រះកេស
- មានសក់ច្រើនរួញ ហើយគួចត្របាញ់ជុំៗ
- មានមុខមូលរាងពងក្រពើ
- មានត្រចៀកធំ ៗ ហើយវែងធ្លាក់ទៅក្រោម
- មានទឹកមុខញញឹម ។





លោកេស្វរៈ

* ពោធិសត្វ ( ក្នុងពុទ្ធសាសនាមហាយាន).-

- លោកេស្វរៈ ជាពោធិសត្វជួយសង្គ្រោះ និងអោយសុខដល់សត្វលោក ។ គេឆ្លាក់រូបពោធិសត្វលោកេស្វរៈ គង់ ឈរ លើ ផ្កា ឈូក មាន ព្រះ ហស្តច្រើន ទ្រង់កេតនភណ្ឌផ្សេងៗ មានគម្ពីរ ខ្សែផ្កាំ ដប រឺ ថូ ផ្កាឈូកជាដើម មានគ្រឿងអលង្ការច្រើន មានផ្នួងសក់ធំ ៗ ហើយនៅលើផ្នួងសក់ មានព្រះពុទ្ធរូបមួយឈ្មោះ អមិតាភៈ ( Amitabha ) ។

- មញ្ជុស្រី ជាពោធិសត្វគុណាការ ។ គេធ្វើរូបមនុស្សកាន់សៀវភៅមួយ និងព្រះខាន់មួយ គង់លើសត្វគោ ។

សមន្តភទ្រ ជាពោធិសត្វគ្រប់គ្រងខ្ទាន់ (អ្នកកាន់) សាសនា ។ គេធ្វើរូប

មនុស្សគង់លើសត្វដំរី ។

– មៃត្រេយ ជាពោធិសត្វ ដែលនឹងបានត្រាស់ជាព្រះពុទ្ធ បន្ទាប់ពីព្រះពុទ្ធសមណគោតម ។

– **ក្សិតិគភ៌** ជាពោធិសត្វស្រង់មនុស្សពីនរក ។

– វជ្របាណិ ជាពោធិសត្វការពារសាសនា ។ គេធ្វើរូបមនុស្សកាន់រន្ទះ។

– ប្រជ្ញាបារមិតា ជាពោធិសត្វស្រី ជានិមិត្តរូបនៃប្រាជ្ញា ។



ព្រះព្រហ្ម

– មហេសី ; សរស្វតី

– បុត្រ ៣ : ទក្ស ភត្ថុ សន្ធិយា ។

* ព្រហ្ម. –

លក្ខណៈពិសេសសំគាល់ព្រះព្រហ្ម គឺ:

– ព្រះភក្ត្រ៤

– ព្រះហស្ត កាន់ គម្ពីរវេទ រឺផ្កាឈូក

– កេតនភណ្ឌ : ប៉ាន់រឺថូថាស ស្លាបព្រាវាជពិធី ខ្សែផ្កាំ ។ល។

– យានជំនិះ : សត្វហង្ស





លិង្គឥស្វរ

* ឥស្វរ. –

នៅមុនសម័យអង្គរ គេពុំប្រទះឃើញរូបចំលាក់ ជារូបមនុស្សតំណាងព្រះឥស្វរឡើយ គឺមានតែចំលាក់រូបលិង្គព្រះឥស្វរ ដែលគេឆ្លាក់អំពីថ្មពណ៌ប្រផេះ ហើយដែលមានរាងទៅដូចតទៅនេះ :

– ផ្នែកលើមានរាងមូលវែងដូចសសរ,

– ផ្នែកកណ្ដាលមានរាង ៦ ជ្រុង ជួនកាល ៨ ជ្រុងជាទំរ

– ផ្នែកក្រោមមានរាង៤ជ្រុងស្មើជាទំរដែរ ។

នៅលើរូបលិង្គខ្លះ គេឆ្លាក់មុខមនុស្ស ។ លិង្គដែលមានឆ្លាក់រូបបែបនេះ ហៅថា មុខលិង្គ ។

គេនិយមតំកល់លិង្គព្រះឥស្វរលើយោនីនាងឧមា (ទុកជាទំរ) ។

គេបានសង្កេតឃើញថា លិង្គព្រះឥស្វរ ដែលគេបានតាំងនៅក្នុងប្រាសាទបូរាណ ពុំមែនសុទ្ធតែតំណាងព្រះឥស្វរទាំងអស់ទេ យ៉ាងណាមិញ លិង្គដែលតំកល់ក្នុងប្រាសាទភ្នំ ដូចជា ប្រាសាទបាគង-បាខែង

ជាដើម ការបូជាគោរពទេវរាជ (សាសនាទេវរាជ : culte du Roi-Dieu) ។

លុះក្រោយមកទៀត ទើបមានការឆ្លាក់រូបមនុស្សផ្សេងៗ សំគាល់ព្រះឥសូរ គឺ :

– រូបដូចឥសី ដែលមានផ្នួងសក់ធំ ហើយមានខ្សែផ្កានៅក រឺនៅដៃ ។

– រូបដូចមហាក្សត្រគង់លើបល្ល័ង្ក មានគ្រឿងអលង្ការគ្រប់មុខ ។

– រូបដូចគ្រូពាំ ។



ព្រះឥសូរ

– រូបមនុស្សដែលមានផ្នួងសក់ លំអដោយចំណិតព្រះចន្ទ (រាងដូចកណ្ដៀវ) នៅពីមុខ ។

– រូបមនុស្សដែលមានភ្នែក ៣ : ភ្នែក ២ ដូចមនុស្សធម្មតា រីភ្នែកទី៣ នៅចំកណ្ដាលថ្ងាស ។

– រូបមនុស្សដែលមានមុខ១ដៃ២ ជួនកាលបែរភាគជាមុខ៥ដៃ១០ ហើយមានកេតនភណ្ឌសំខាន់ៗ ដូចជា : ត្រីសូល (ច្បូក) ខ្សែផ្កា ស្គរ ដប លលាដ៍ក្បាល ខ្សែ១ ចង្វាយជាដើម ។



គេច្រើនសាងរូបព្រះឥសូរគង់ម្នាក់ឯង រឺ ជាមួយយានជំនិះគោនន្ទិ។ ឯសក្តិ (មហេសីអាទិទេព) ព្រះឥសូរមាននាមផ្សេងៗគឺ : បាវ៌តី ឧមា ទុគ៌ា កាលី គោរី ទេវី កុមារី ចន្ទី មហាទេវី ។ ព្រះឥសូរមានបុត្រ ២ អង្គគឺ : ស្កន្ទ (ទេវះតំណាងចំបាំង មានយានជំនិះជាសត្វក្ងោក) និងគណេស (ទេវះខាងបញ្ញាមានដៃ ៤ ពោះកំប៉ោង ក្បាលជាដំរី ភ្លុកតែ១ខាងស្តាំ ភ្លុកឆ្វេងបាក់ក្នុងពេលប្រយុទ្ធជាមួយបរសុរាមៈ ដែលជាអវតារវិស្ណុ មានយានជំនិះជាសត្វកណ្ដុរ) ។

* **នារាយណ៍ .–**

គេឆ្លាក់រូបមនុស្ស ដែលច្រើនតែមានដៃ ៤ មានកេតនភណ្ឌផ្សេងៗ គឺ : ចាស ខ្យងស័ង្ខ ភោង ដុំមូល (ផែនដី) រឺ ផ្កាឈូក (និយមនៅស្រុកឥណ្ឌា) មួកមូលវែង (mytre cylindrique) ។ គេច្រើនសាងព្រះនារាយណ៍ទ្រង់ឈរ ។ នៅតាមក្បាច់សិល្បៈលើជញ្ជាំងប្រាសាទអង្គរវត្ត គេប្រទះឃើញព្រះនារាយណ៍ជិះសត្វគ្រុឌ ។ ជួនកាលគេឆ្លាក់រូបព្រះនារាយណ៍ផ្ទុំលើពស់ឈ្មោះសេសះ នៅកណ្ដាលសមុទ្រ មានដើមឈូកដុះចេញពីផ្ចិត ហើយនៅលើផ្កាឈូកមានរូបព្រះព្រហ្ម ។ សក្តិព្រះនារាយណ៍មាននាមស្រី (តំណាងទ្រព្យសម្បត្តិ) រឺ លក្ស្មី (តំណាងសោភណភាព) ព្រះហស្តកាន់ផ្កាឈូក ។ អវតារព្រះនារាយណ៍ មានទាំងអស់ ៩ គឺ :

- អវតារជារូបមនុស្ស ៖ រាមនៈ បរសុរាម រាម ក្រិស្ណ ។
- **អវតារជារូបមនុស្សក្បាលជាសត្វ ៖ នរសិង្ហ កល្កិន ។**
- **អវតារជារូបសត្វ ៖ មត្ស្យ កូម៌ វរាហ ។**



ព្រះនារាយណ៍

នៅស្រុកខ្មែរយើង គេពុំបានឆ្លាក់រូបអវតារគ្រប់ទាំងអស់ទេ គេប្រទះឃើញនៅតាមជញ្ជាំងប្រាសាទអង្គរវត្ត មានរូប កូម៌ (នៅក្នុងរឿង



កូរសមុទ្រទឹកដោះ) រូបរាម (នៅក្នុងរឿងរាមកេរ្តិ៍) រូបក្រិស្ណ (នៅក្នុងរឿងមហាភារតៈ) រូបក្រិស្ណមួយទៀត លើកដៃទ្រភ្នំ (ឆ្លាក់ជាក្បាច់លោត នៅវត្តកោះ ខេត្តតាកែវ) រូបកល្កិន (រូបមនុស្សក្បាលសេះ) ។

* ហរិហរៈ .—

នៅមុនសម័យអង្គរ គេបានសាងរូបបដិមាហរិហរៈសំគាល់អាទិទេពឥសូរផង វិស្ណុផង ដូចជាហរិហរៈប្រាសាទអណ្តែត ។ គេស្គាល់ព្រះឥសូរដោយសារមុខ (នៅចំហៀងខាងស្តាំរូប) កេតនភណ្ឌ រឺ សក់រួញផ្នត់ៗ ។ ឯព្រះវិស្ណុ គេស្គាល់ដោយសារមុខ (នៅចំហៀងខាងឆ្វេងរូប) និងមួកមូលវែង ។ រូបបដិមា ហរិហរៈនេះមានរាងរៅសមសួនល្អណាស់ ។



ក្រៅពីរូបចំលាក់តំណាងទេវៈសំខាន់ៗដែលបានរៀប

រាប់ខាងលើនៅមានរូបចំលាក់សំគាល់ទេវៈរាយរង់ជាច្រើនទៀតដូចជា :

– ព្រះឥន្ទ្រ គង់លើដំរីឰរាវ័ណក្បាល ៣ កាន់វជ្រៈ ថាស ព្រួញ កង្វេរ ដំរី ។

– ព្រះអគ្និ គង់លើសត្វពពែ កាន់ព្រួញ ភ្លើងចង្កុះ ផ្ចិត ។

– ព្រះវរុណ គង់លើសត្វនាគ ចាំងក្លោះ ។

– ព្រះយម គង់លើសត្វក្របី កាន់ព្រួញ គោន ដាវ កាំបិត ។

– ព្រះចន្ទក៏ដូចព្រះអាទិត្យ គង់លើរទេះសេះ មានពន្លឺចេញពីខ្លួន។ល។

ឯរូបទេវតា ទេពអប្សរនៅក្នុងសិល្បៈ គេច្រើនធ្វើរូបឈរ រឺហោះហើរលើអាកាស ជាអ្នករាំ រឺកាន់បាច់ផ្កា ។ គេធ្វើរូប ទ្វារបាល នៅអមមុខទ្វារប្រាសាទហើយមានកាន់អាវុធផង ។

* សត្វ .–

– សត្វដែលជាយានជំនិះរបស់អាទិទេព : គោនន្ទិ គ្រុឌ ហង្ស ។ល។

– សត្វដែលមានមុខងារជាអ្នកយាមចាំថែរក្សាប្រាសាទ រឺសំរាប់តែងលំអ : នាគ មករ រាហូ សិង្ហ ដំរី ស្វា ។ល។

* ផ្កា-ភ្ញី-ក្បាច់ផ្សេងៗ .–

គេច្រើនឆ្លាក់ផ្កា ភ្ញី ស្លឹកឈើ និងក្បាច់ផ្សេងៗ នៅលើផ្ទៃ សសរ ពេជ្រនិងតាមជញ្ជាំងសំរាប់លំអប្រាសាទ ។



* រឿង .–

ចំលាក់រឿងក៏មានច្រើនដែរនៅតាមជញ្ជាំងប្រាសាទ ដូចជានៅប្រាសាទអង្គរវត្ត មានចំលាក់រឿងដកស្រង់អំពីរឿងរាមកេរ្តិ៍ (រាមាយណៈខ្មែរ) រឿងមហាភារតៈ រឿងរាមាយណៈ (ត្រង់កូរសមុទ្រទឹកដោះដើម្បីបង្កើតទឹកអម្រឹត) ជាដើម ។ នៅប្រាសាទបាយ័ន មានចំលាក់រឿងប្រវត្តិសាស្ត្រ ដូចជាចំបាំងរវាងខ្មែរនិងចាម រឿងជីវភាពពិតប្រាកដរបស់អ្នកស្រុក ដូចជាការបរបាញ់ ការនេសាទត្រី ការលក់ដូរ ល្បែងប្រជល់មាន់ ប្រជល់ជ្រូក ។ល។

## គ. វិវត្តន៍ចំលាក់(5).–

សិល្បៈចំលាក់ក៏ដូចជាសិល្បៈសំណង់ដែរ តែងមានវិវត្តន៍ពីសម័យមួយទៅសម័យមួយមិនឈប់ឈរ ។

* រូបបដិមា .–

នៅរចនាបថភ្នំដា គេបានប្រទះឃើញពុទ្ធបដិមានិងទេវបដិមា ( ខាងព្រាហ្មណ៍សាសនា ) ជាច្រើននៅអង្គរបុរី កំពង់ស្ពឺ ឧដុង្គ ។ ដោយខ្លាចរលំគេធ្វើរូបបដិមាសុទ្ធតែមានទំរើទំនប់មានរាងជាក្រចកសេះ រាងមូលទ្រវែង ជួនកាលបួនជ្រុងទ្រវែង ហើយជួនកាលទៀតគេយកកេតនភណ្ឌ រឺជាយសំពត់របស់រូបបដិមា ទល់រូបចំលាក់នោះតែម្តង ។ ជាទូទៅរូប

បដិមាក្នុងសម័យនោះឈរមិនត្រង់ទេ គឺមានរាងកាច់ចង្កេះនិងមានសំលៀកបំពាក់ដូចឥណ្ឌា (ឧ. រូបក្រិស្នទ្រភ្នំ) ។

រហូតមកដល់រចនាបថព្រៃក្មេង រាងកាច់ចង្កេះបែបឥណ្ឌា ពុំសូវមានទៀតទេ ។ សិល្បៈមានការលូតលាស់ច្រើន មានការសាកល្បងរចនាបែបខ្មែរ ។ រូបបដិមា ហរិហរៈ នៅប្រាសាទអណ្តែត ត្រូវបានគេកោតសរសើរយ៉ាងខ្លាំងហើយចាត់ទុកជាស្នាដៃឯកក្នុងសិល្បៈខ្មែរ ព្រោះរូបចំលាក់នេះបានបង្ហាញអោយឃើញថា សិល្បករខ្មែរមានបច្ចេកទេសខ្ពង់ខ្ពស់ ដោយចេះឆ្លាក់រូបនេះអោយមានរាងទៅសមសួនល្អឥតខ្ចោះ ។ ចំណែកឯទំរនិងទំនប់របស់បដិមា គេសាកល្បងបំបាត់ចោលនៅរចនាបថកំពង់ព្រះ ។ សិល្បៈនៅរចនាបថព្រះគោមានលក្ខណៈខ្មែរសុទ្ធសាធ ។ រូបបដិមារាងត្រង់ៗអស់កាច់ចង្កេះហើយ ប៉ុន្តែមានវិវត្តន៍ខាងសំលៀកបំពាក់ មានលំអដោយគ្រឿងអលង្ការនៅកដៃនិងកដៃ មានចិញ្ចើមរាងត្រង់ជាប់គ្នា មានពុកចង្កា (រូបបដិមាប្រុស) ។ រចនាបថកោះកេរ បានបង្ហាញស្នាដៃប្លែកពីមុន គឺរូបបដិមាមានមាឌមាំៗប្រកបដោយចលនាផ្សេងៗដូចជា : ដើរ រាំ ប្រយុទ្ធគ្នា (ឧ.សុគ្រីពនិងពាលី) ដើម្បីបង្ហាញអំណាចនិងថាមពល ( ពុំសូវគិតគូរពីរៀងស្អាតទេ ឧ.រូបគ្រុឌនៅសារមន្ទីរជាតិ ) ។ ប៉ុន្តែចាប់ពីរចនាបថបន្ទាយស្រីទៅ រូបបដិមាមានរាងតូចៗប្រកបដោយទឹកមុខសុភាព ។ គេប្រទះឃើញមានពុទ្ធរូបកាន់តែច្រើនឡើង ហើយច្រើនតែសាងជាបែបមុទ្រាផ្សេងៗនៅសម័យរចនាបថ



អង្គរវត្ត ។ ការរចនារូបបដិមានៅរចនាបថបាយ័នមានការចំរើនលូតលាស់ជាខ្លាំង ។ គេពុំសូវគិតគូរពីរាងទៅទេ គេផ្ចិតផ្ចង់តែត្រង់ទ្រង់មុខ ដូចជា រូបព្រះពុទ្ធ ព្រះពោធិសត្វលោកេស្វរៈ ព្រះបរមរូបជ័យវរ្ម័នទី ៧ ដែលមានភ្នែកសំលឹងមកក្រោម រឺ បិតជិត បបូរមាត់ញញឹម ។ ទឹកមុខញញឹមសុភាពទន់ភ្លន់ បង្ហាញន័យថា សប្បាយនឹងរកឃើញអ្វីមួយ (ដូចជាធ្វើសមាធិ) ។

www.ameKhmer.org

* សសរពេជ្រ. –

សសរពេជ្រដែលនៅអមសងខាងទ្វារប្រាសាទ ហើយដែលទ្រផ្តែរ មានវិវត្តន៍ពីរាងមូលទៅរាងជ្រុង ហើយពីរាងជ្រុងទៅមូល ។ ចាប់ពីរចនាបថភ្នំដារហូតដល់រចនាបថព្រៃក្មេង សសរពេជ្រមានរាងមូលនៅឡើយ ប្លែកតែចំលាក់នៅលើសសរដែលមាន[illegible] ។ នៅរចនាបថកំពង់ព្រះសសរពេជ្រភាគច្រើននៅមានរាងមូល ប៉ុន្តែមានរាង ៨ ជ្រុងខ្លះៗហើយ ហើយនៅជ្រុងនីមួយៗមានចំលាក់ស្លឹកឈើ ។ គេពុំប្រទះឃើញសសរពេជ្ររាងមូលទៀតទេ នៅរចនាបថគុលែនគឺមានតែសសរពេជ្រ៨ជ្រុងនិង៤ជ្រុង ។ ពីរចនាបថព្រះគោដល់រចនាបថបាពួន សសរពេជ្រមូលមានខ្លះឡើងវិញ ភាគច្រើនមានរាង៨ជ្រុង ។ មកដល់រចនាបថអង្គរវត្តសសរពេជ្រខ្លះមានរាង១៦ជ្រុង ហើយមានក្បាច់ស្អកស្កុះ ។

* ផ្ដែរ.—

គេសង្កេតឃើញក្បាច់នៅលើផ្ដែរមានច្រើនបែបយ៉ាងណាស់ ដូចជាក្បាច់ដងឆ្នូ-សត្វមករ-សត្វកាលៈ-រូបមនុស្ស-រំយោល-កំរង-ផ្កា-ភ្ញី ស្លឹកលាត-ស្លឹកង-វិមកឈើ ។ល។ គេរចនាផ្ដែរនៅសម័យរចនាបថសំបូរ ជាក្បាច់លំអជាងទង (décor orfèvri) ដែលវិវត្តទៅជាក្បាច់ភ្ញីទេស (décor végétal) រហូតដល់រចនាបថកំពង់ព្រះ ។ ចំណែកក្បាច់នៅក្នុងរចនាបថគូលែនពុំមានឯកភាពទេ គេឆ្លាក់ក្បាច់នេះបន្តិច នោះបន្តិច មានលក្ខណៈមិនច្បាស់លាស់ហាក់ដូចជាស្ទាក់ស្ទើរក្នុងចិត្តមិនដឹងជាយករបៀបតាមចាម-ជ្វា មករចនាយ៉ាងណាអោយស្របទៅតាមយោបល់របស់ព្រះបាទជ័យវរ្ម័នទី ២ : គឺជាសិល្បៈមួយដែលកំពុងតែត្រូវត្រាយផ្លូវទៅរកលក្ខណៈថ្មីមួយទៀត ។ មកដល់សម័យព្រះគោទើបក្បាច់ចំលាក់មានលក្ខណៈត្រឹមត្រូវច្បាស់លាស់ជាខ្មែរ ជាផ្ដែរល្អជាងគេបំផុត ព្រោះមានក្បាច់លំអល្អិតល្អន់ប្រកបដោយទឹកដៃល្អស្រស់បំព្រង ព្រមទាំងមានភាពទន់ភ្លន់ទៀតផង។ សម័យក្រោយមកទៀតគេច្រើនចំលងតាមរចនាបថព្រះគោ គ្រាន់តែផ្លាស់ប្ដូរក្បាច់ខ្លះ ។ មកដល់រចនាបថបាពួន គេនិយមឆ្លាក់នៅលើផ្ទៃផ្ដែរជាក្បាច់រឿង (ផ្ដែររឿង = linteau à scène) ដូចជាផ្ដែររឿងអំពីការកូរសមុទ្រទឹកដោះ ។ ផ្ដែររឿងមានតាំងពីរចនាបថសំបូរម្ល៉េះ ប៉ុន្តែមាននៅត្រង់ផ្ទៃក្រោមនៃផ្ដែរ ។ ផ្ដែរនៅរចនាបថអង្គរវត្តមានរូបមនុស្សតូចៗជាច្រើននៅលាយឡំគ្នាជាមួយនិងក្បាច់ស្លឹកឈើ ។



* ហោជាង .—

នៅខាងលើផ្ដែរ គេធ្វើហោជាង (fronton) មានរាងផ្សេងៗ និងចំលាក់ក្បាច់ក្បូរជាច្រើន ដែលប្រែប្រួលទៅតាមសម័យកាល ។

ហោជាងនៅរចនាបថសំបូរ មានរាងក្រចករសេះ ពុំមានក្បាច់រចនាអ្វីនៅសល់ទេ ដោយហេតុតែបាយអដែលបូកនៅលើហោជាងនោះបានរបេះធ្លាក់បាក់អស់ទៅហើយ ។ ហោជាងបូកបាយអមានរហូតដល់រចនាបថព្រះគោ ។ នៅសម័យព្រៃក្មេងនិងកំពង់ព្រះ គេពុំប្រទះឃើញហោជាងទេ ទើបមកដល់សម័យគូលែនមានហោជាងរាងដូចស្នាមជើងឆ្មា (arc polylobé) (គេថាជាឥទ្ធិពលចាម) ។ នៅលើគែម (encadrement) ហោជាងមានក្បាច់វល្លិឈើ ។ នៅលើផ្ទៃ (tympan) ហោជាងមានរូបមនុស្សធំមួយ ជួនកាលអមដោយទេពប្រណម្យពីរទៀត មកដល់រចនាបថព្រះគោ មានប្រែប្រួលខ្លះត្រង់ខាងលើគែមហោជាង គេឆ្លាក់ក្បាច់ស្រួចៗ ដូចធ្មេញរណារ ហើយធ្វើក្បាលសត្វមករនៅចុងគែម ។ មានការបង្កើតថ្មីទៀតនៅរចនាបថកោះកែរកើ ហោជាងមានរាងត្រីកោណ ហើយមានគែមច្រើនជាន់ ដែលវិវត្តក្រោយមកទៀត នៅចុងគែមទី១ មានសត្វមករព្រួសសត្វសិង្ហ នៅចុងគែមទី២ មានសត្វមករព្រួសសត្វគ្រុឌ នៅចុងគែមទី៣ មានសត្វកាលៈព្រួសនាគក្បាលច្រើន ជួនកាលព្រួសរំយោលផ្កា ។ ចំណែកនៅក្នុងផ្ទៃហោជាងគេនិយមឆ្លាក់ក្បាច់រឿង ។

## ឃ - មុខងារចំលាក់ .-

នៅក្នុងសិល្បៈខ្មែររូបចំលាក់បុរាណមានមុខងារសំខាន់ៗ២យ៉ាងគឺ :

– ចំលាក់សំរាប់បូជា ( sculpture cultuelle ) ដូចរូបបដិមាព្រះពុទ្ធ-ពោធិសត្វ-ឥសូរ-ព្រហ្ម-នារាយណ៍ ជាដើម ។

– ចំលាក់សំរាប់លំអ ( sculpture de décoration ) ដូចរូបចំលាក់សត្វខ្លះ; ចំលាក់ក្បាច់ក្បូរផ្សេង ៗ ចម្លាក់ភ្ញីផ្កា ។ល។

* *

*

# ៣-ភ្លេង (18) (19)

ភ្លេងជាសិល្បៈមួយប្រភេទដែលបង្កើតបរិយាកាសរីករាយសប្បាយ អាចបំបាត់ការអផ្សុកឬការនឿយហត់មួយគ្រាដែរ ក៏ប៉ុន្តែការពីរោះក្នុងការស្តាប់ភ្លេង ពុំមែនចេះតែពីរោះដល់ត្រចៀកគ្រប់ ៗ គ្នានោះទេ ព្រោះអ្នកខ្លះនិយមស្តាប់ភ្លេងបុរាណ អ្នកខ្លះនិយមស្តាប់ភ្លេងសម័យ ។ ម្យ៉ាងទៀត បើអ្នកស្តាប់ចេះលេងភ្លេងខ្លួនឯងផង នោះរឹតតែពីរោះស្តាប់ណាស់ទៅទៀត ។

នៅប្រទេសខ្មែរ ការប្រគំភ្លេងជាការចាំបាច់ សំរាប់ញុំាងបរិយាកាសក្នុងពិធីបុណ្យទាន និងពិធីជាទំនាមផ្សេង ៗ អោយមានសភាពលន្លង់លន្លោច រីករាយរុងរឿងរឺ អ៊ឹកធឹកឡើង ។ ភ្លេងដែលខ្មែរនិយមប្រើតាំងពីសម័យបុរាណមានច្រើនប្រភេទណាស់ ។

## ក- ភ្លេងពិណពាទ្យ .-

គេអោយឈ្មោះជាភ្លេងពិណពាទ្យព្រោះក្នុងក្រុមភ្លេងនោះ កាលពីដើមគេនិយមប្រើពិណាចេញផ្តើមមុនគេ ។ មានអ្នកខ្លះហៅភ្លេងពិណ-

ពាទ្យនេះដោយភ័ន្តច្រលំថា ភ្លេងសៀម ។ ការពិត សៀមយកពីខ្មែរយើងទៅវិញទេ ។ សៀមហៅវង់ភ្លេងនេះថា ម៉ីពាទ្យ (ពីផាត) ព្រោះពីដើមគេប្រើប៉ី រឺ ស្រឡៃនាំមុខមុនគេ ។ លោក ឈឹម ក្រសេម ថាភ្លេងពិណពាទ្យមានកំណើតមកពីឥណ្ឌាតាំងពីសម័យព្រេងនាយ លុះដល់មកសម័យក្រោយខ្មែរក៏បានកែប្រែផ្លាស់ប្តូរនិងថែមថយគ្រឿងភ្លេង អោយក្លាយទៅជាភ្លេងរបស់ខ្មែរ ។ សព្វថ្ងៃនេះ គេបានរៀបចំភ្លេងពិណពាទ្យជា២វង់ : ពិណពាទ្យវង់តូច (មានប្រដាប់ ៥ គ្រឿង) ពិណពាទ្យវង់ធំ (មានប្រដាប់១០គ្រឿង) ។ នៅក្នុងព្រះរាជវាំង មានគ្រឿងភ្លេងពិណពាទ្យពិសេសមួយបែបហៅថា ក្រុមមហោរីព្រះរាជទ្រព្យ (មានគ្រឿងចំរុះច្រើនយ៉ាងដល់ទៅ១៦ គ្រឿង) ។

ខ្មែរប្រើវង់ភ្លេងពិណពាទ្យក្នុងការកំដរបាំបូរាណ ក្នុងពិធីបួងសួង (បន់ស្រន់-លាបំណន់) ក្នុងពិធីសាសនា (បុណ្យកឋិន-ផ្កា-បំបួសនាគ-ពុទ្ធាភិសេក ...) ជួនកាលក្នុងពិធីតំកល់សព ។

## ២ – ភ្លេងអារក្ខ. –

គឺជាភ្លេងមួយបែបដែលគេប្រគំឡើងក្នុងពិធីបញ្ចូលខ្មោច បិសាច អារក្ខ អ្នកតា ។ នៅពេលមានមនុស្សឈឺ ហើយបើចង់សាកសួរខ្មោចអំពីបុព្វហេតុនៃជំងឺ គេលេងភ្លេងអារក្ខនេះ ដើម្បីបញ្ចូលខ្មោចសៀង



ខ្មោច ។ ក្រោយពីបានសាកសួរដឹងបុព្វហេតុដែលនាំអោយឈឺ គេអង្វរខ្មោចសុំអោយជាសះស្បើយ ហើយគេក៏រៀបដង្វាយផ្សេងៗថ្វាយខ្មោចនោះទៅ ។ ក្រៅពីលេងក្នុងពិធីបញ្ចូលនិងលៀងអារក្ខ ខ្មោច-ភ្លេងអារក្ខប្រើក្នុងពិធីឡើងអ្នកតាដែរ ។

តាមការស្រាវជ្រាវរបស់លោក ខឹម ឈុំ សមាជិកនៃក្រុមទំនាមទំលាប់ ភ្លេងអារក្ខនេះ មានកំណើតឡើងអំពីរឿងកូនក្មេងលេង “ បាយឡុកបាយឡ ” ។ គេតែងនិយាយរឿងនេះតៗគ្នាមកថា កាលនោះនៅក្នុងភូមិមួយមានក្មេងស្រី-ប្រុសជាច្រើនប្រជុំគ្នាលេង ខ្លះធ្វើភ្ញៀវ ខ្លះធ្វើអ្នកផ្ទះ ខ្លះធ្វើប្តី ខ្លះធ្វើប្រពន្ធ ខ្លះទៀតធ្វើកូន ហើយនាំគ្នាលេងជប់លៀងស៊ីផឹកស្រវឹងដួលដេក សើចហ៊ោកញ្ជ្រៀវយ៉ាងសប្បាយរាល់ៗថ្ងៃ រៀងមក ។ ដំបូងលេងតែពេលថ្ងៃៗទេ លុះយូរៗទៅ ក៏វក់លេងទាំងថ្ងៃទាំងយប់ រហូតដល់ភ្លេចបាយភ្លេចទឹក ភ្លេចដេកពួន ។ ឪពុកម្តាយហាមឃាត់យ៉ាងណាក៏ពុំស្តាប់ ។ ឃើញហេតុខុសពីធម្មតាបែបនេះ ចាស់ៗក៏នឹកថាប្រហែលមានព្រាយ បិសាចណាចូលមកពន្ធក់ចិត្តក្មេងទាំងនោះហើយ ទើបនាំគ្នាបន់ស្រន់ឡើង ។ ឯពួកបិសាច កាលបើគេនឹកនាហៅរកខ្លួន ក៏ឆ្លៀតឱកាសនេះចូលទៅសណ្ឋិតក្នុងរូបក្មេងម្នាក់ភ្លាម ហើយក៏និយាយបញ្ជាអោយចាស់ៗទាំងនោះ រៀបសំណែនដោយមានលេងភ្លេងថ្វាយពួកគេផង ទើបពួកគេជួយរក្សាអោយបានសុខសប្បាយតរៀងទៅ ។ បន្ទាប់មកបិសាចក៏នាំអោយក្មេងធ្វើបទភ្លេងដោយមាត់តាមចិត្តវា ។

ក្រោយដែលបានស៊ីសំណែនឆ្អែតស្កប់ស្កល់ហើយ ពួកបិសាចក៏ចាកចេញទៅ ។ ឯពួកក្មេងក៏ឈប់រំក់លេងដូចមុនទៀត ហើយរស់នៅជាសុខសប្បាយរហូតមក ។ ចាប់តាំងពីពេលនោះមកអ្នកស្រុកក៏ប្រកាន់ជឿខ្មោចអារក្ស ព្រាយ បិសាច ព្រមទាំងយកជាទីគោរពទីពឹងក្នុងគ្រាមានភ័យអាសន្ន

## គ- ភ្លេងខ្មែរ .-

គេចាត់ទុកភ្លេងខ្មែរជាភ្លេងមង្គល ។ ដូចនេះហើយបានជាគេត្រូវប្រគំតែក្នុងពិធីមង្គលតាមប្រពៃណីខ្មែរ ដូចជាពិធីបញ្ចេញម្លប់កូនស្រី ពិធីមង្គលការជាដើម ។ វត្តមានភ្លេងខ្មែរកំដរក្នុងពិធីមង្គល មិនគ្រាន់តែញ៉ាំងបរិយាកាសអោយអឹកធឹកប៉ុណ្ណោះទេ គឺនាំមកនូវសិរីសួស្តី ជ័យមង្គលថែមទៀតដែលចាស់ទុំខ្លះប្រកាន់ជំនឿនេះយ៉ាងខ្ជាប់ខ្ជួន រហូតមកដល់សព្វថ្ងៃ ។ ភ្លេងខ្មែរសំរាប់ពិធីរៀបមង្គលការមានច្រើនបទណាស់ ដែលគេយកមកប្រគំកំដរក្នុងកម្មវិធីនីមួយៗ ដូចជាបទហៅកូនកំលោះចូលរោង-ហែកំណត់-ស៊ីស្លាថង់រង-កាត់សក់-សែនក្រុងពាលី-កូនប្រុសសំពះពេលា-កូនស្រីចេញផ្ទឹម-ចងដៃ-បង្វិលពពិល ។ល។

បទភ្លេងខ្មែរខ្លះមានទំនាក់ទំនងទៅនឹងរឿងព្រេងខ្មែរ ។ បទខ្មោរ-ខ្នងភ្នំ-របងមាស-បន្ទាយប្រាសាទ-ជ្រង-ជ្រងស្រងាត់-ដោះក្រាល-កន្ទុង-



ទ្រាំង ដែលប្រើលេងនៅពេលលៀងភោជនាហារថ្ងៃត្រង់ (ក្រោយពេលស៊ីស្លាកំណត់) មានកំណើតឡើងដោយយកតំរាប់តាម **តាដុខ យាយជ័យ** ដែលបានអោយអ្នកភ្លេងលេងបទទាំងនេះថ្វាយអ្នកតាព្រៃ ដើមបីលាមាត់ លាកគាត់ កាលដែលបានបន់ស្រន់នៅពេលធ្វើដំណើរកាត់ព្រៃទៅរៀបការកូនស្រីឈ្មោះនាង **ត្រចើលដោះក្រាល** និងចៅប្រមាញ់ **ទឹខស៊ុខ** កូនស្រីនេះ គាត់បានផ្ញើនឹងនាងទេនជាប្អូន ហើយវង្វេងផ្លូវ ។

ចំណែកបទព្រះថោង និង បទនាងនាគ ដែលប្រើលេងនៅពេលសំពះផ្ទឹមនោះ មានកំណើតឡើងក្នុងរជ្ជកាល **ព្រះថោង** (ហ៊ុនទៀន) បឋមក្សត្រខ្មែរ ។ ព្រះអង្គទ្រង់បានរៀបអភិសេកជាមួយនាង **ទាវតី** (លីវយី) បុត្រីស្តេចភុជង្គនាគ ។ លុះរៀបមង្គលការនៅស្ថានមនុស្សលោករួចហើយ ស្តេចភុជង្គនាគបាននាំព្រះថោងទៅដប់លៀងម្តងទៀតនៅស្ថានបាតាល ។ ដោយព្រះថោងពុំចេះវិជ្ជាខាងជ្រកទឹក ក៏តោងកន្ទុយនាងនាគ ទើបចុះទៅបាន ។ អាស្រ័យដោយមានរឿងខាងលើនេះហើយ បានជាគេសន្មតឈ្មោះបទភ្លេងថា បទព្រះថោងនិងនាងនាគ ដែលខ្មែរនិយមប្រើលេងជាប់រហូតមកដល់សព្វថ្ងៃនេះ ព្រមទាំងមានទំនាមអោយកូនប្រុសតោងជាយស្បៃកូនស្រីចូលបន្ទប់ទៀតផង ។

## ឃ - ភ្លេងឆៃយ៉ាំ .-

គេលេងភ្លេងឆៃយ៉ាំតែក្នុងពិធីបុណ្យដែលជាទីរីករាយ ដូចជាលេង

កំដរបុណ្យកឋិន បុណ្យផ្កា បុណ្យបំបួសនាគជាដើម ។ ភ្លេងផៃយ៉ាំជាភ្លេងរំភើបសប្បាយហើយរស់រវើកប្លែកពីភ្លេងឯទៀត ។

គេពុំទាន់ដឹងច្បាស់លាស់នៅឡើយទេ អំពីប្រភពនៃភ្លេងផៃយ៉ាំនេះ ។ ដោយចង្វាក់ភ្លេងមានលក្ខណៈលោត ៗ ភ្ញាក់ ៗ អ្នកខ្លះអោយយោបល់ថា ភ្លេងផៃយ៉ាំទំនងជាមានកំណើតចេញពីមនុស្សជំនាន់ដើមដែលតែងមានសភាពភ្ញាក់ផ្អើល ខ្លាចរអើល ប្រៀបបានទៅនឹងសត្វព្រៃភ្ញាក់ផ្អើលនៅពេលឃើញមនុស្ស ។ អ្នកខ្លះទៀតថា នៅពេលមនុស្សបានទទួលជោគជ័យក្នុងកិច្ចការរបស់ខ្លួនមនុស្សតែងត្រេកអរ សប្បាយរីករាយយ៉ាងខ្លាំង ហើយក៏បង្កើតភ្លេងផៃយ៉ាំនេះឡើងដើម្បីរំលឹកនវជ័យជំនះនោះ ។

## ខ - ភ្លេងមហោរី .—

ពាក្យ "មហោរី" សំគាល់ឈ្មោះភ្លេងផង សំគាល់សភាពនៃវង់ភ្លេងផង ។ បទភ្លេងមហោរីមានលក្ខណៈប្រជាប្រិយហើយស្រាលជាងភ្លេងពិណពាទ្យ ។ វង់ភ្លេងមហោរីគេមិននិយមលេងក្នុងពិធីបុណ្យទានផ្ទាល់ទេ ប៉ុន្តែអាចប្រើកំដរបរិយាកាសបានដែរ ។ ជាទូទៅ គេលេងភ្លេងមហោរីកំដរល្ខោនមហោរី ។

## ច - ភ្លេងក្លងឆ្នាក់ .—



ដើម្បីអោយមានបរិយាកាស ស្រងេះស្រងោច លន្លង់លន្លោច គេលេងភ្លេងក្លងឆ្នាក់ក្នុងពិធីតំកល់សព ហែសព បូជាសព ។ អ្នកខ្លះហៅភ្លេងក្លងឆ្នាក់នេះតាមសៀមថា ភ្លេងក្លងខែកដែលមានន័យថា ភ្លេងស្គរផ្លា ។

តាមសេចក្តីអោយការណ៍របស់លោក **ឌួង ឡឹច** ថា : «កាលពីយូរណាស់មកហើយ នៅវត្តពោធិរាមា ស្រុកកោះធំ ខេត្តកណ្តាល ព្រះគ្រូសិរីវង្សា ជាមេគណក្នុងស្រុកនោះមានភ្លេងខ្មែរមួយវង់ សំរាប់លេងទទួលកឋិននិងកំដរបុណ្យទានដែលលោកតែងហៅថា **ភ្លេងខែក** ។ លោកគ្រូអង្គនោះ តែងមានពុទ្ធដីកាប្រាប់អ្នកសិទ្ធស្នាលនឹងលោកថា នេះហើយជាភ្លេងខ្មែរបុរាណយូរយារណាស់មកហើយ» ។

## ឆ - ភ្លេងគងស្គរ .—

អ្នកខ្លះហៅភ្លេងគងស្គរថា ភ្លេង **ឆាំមួង** រឺ **ក្រឡាំមួង** ។ ភ្លេងនេះមានសូរសព្ទគួរអោយស្រងេះស្រងោចណាស់ ហេតុនេះហើយបានជាគេលេងតែនៅពេលមានមនុស្សស្លាប់និងនៅពេលធ្វើបុណ្យលើកខ្មោច ។

តាមការស្រាវជ្រាវរបស់សមាជិកក្រុមជំនុំទំនាមទំលាប់ថា ភ្លេងគងស្គរមានកំណើតឡើងក្នុងរជ្ជកាល **ព្រះបាទត្រសក់ផ្អែម** ។ កាលព្រះអង្គបានឡើងសោយរាជសម្បត្តិ ព្រះអង្គតែងនឹកស្រណោះសំលេងសត្វគ្រប់បែបយ៉ាងលាយឡំនឹងស្នូរខ្យល់ ភ្លៀង ផ្គរ រន្ទះ ដែលព្រះអង្គធ្លាប់បានស្តាប់ទាំងយប់ទាំងថ្ងៃ កាលព្រះអង្គនៅជាម្ចាស់ចំការត្រសក់ផ្អែម ។

ដើមបីគាល់ភ្លេងធម្មជាតិដ៏កំសត់បែបនេះ ព្រះអង្គទ្រង់ចាត់អោយអ្នកព្រ
រាជបណ្ឌិតបង្កើតក្រុមភ្លេងគងស្គរនេះឡើង ។

## ជ – ភ្លេងស្គរយោល. –

នៅសម័យដើមគេប្រើវង់ភ្លេងស្គរយោល ជាវង់ភ្លេងគងទ័ពដែល
ព្យួរនៅលើខ្នងដំរី ។ លុះមកដល់សម័យបច្ចុប្បន្ន គេយកមកប្រើសំរា
កំដរពិធីបុណ្យខ្មោច និងកំដរល្បែងប្រដាល់ដោយសេរី ។

## ឈ – ភ្លេងប៉ីកែវ. –

ភ្លេងប៉ីកែវ គឺជាភ្លេងមួយបែបស្ថិតនៅក្នុងវង់ភ្លេងព្រះរាជទ្រព្យ ។
តាមលោក **ឃាន គេច** គ្រូនៃក្រុមភ្លេងព្រះរាជទ្រព្យថា ភ្លេងប៉ីកែវប្រើ
លេងនៅពេលចាក់ទឹកដូងថ្វាយព្រះបិដរ (សែនដូនតា) នៅក្នុងព្រះ
រាជវាំង ។

## យោបល់រួម. –

ការអធិប្បាយរៀបរាប់រួចមកហើយនេះ បង្ហាញអោយឃើញថា
ភ្លេងខ្មែរបូរាណមានច្រើនប្រភេទ ច្រើនវង់ ហើយវង់នីមួយ ៗ ពុំមែនចេះ
តែយកទៅប្រគំលេងបានគ្រប់ពេលវេលាទេ គឺមានលក្ខណៈពិសេសរបស់



ខ្លួនស្របទៅតាមតំរូវការនៃពិធីបុណ្យទាន រឺពិធីផ្សេង ៗ ថែមទៀត ។
បើនិយាយពីតំលៃវិញបទភ្លេងខ្មែរបូរាណ មានចង្វាក់ស្របទៅនឹងកិច្ចការ
របស់មនុស្សខ្មែរដែលតែងប្រព្រឹត្តទៅតាមសំរួលមិនលឿនពេក មិនយឺត
ពេកក្នុងបរិយាកាសធម្មតា ទុក្ខសោក ស្រនេះស្រណោច លន្លង់លន្លោច
សប្បាយរីករាយ ។ បទភ្លេងខ្លះមានសូរសព្ទរងំ ស្តាប់យូរទៅរឹតតែពី
រោះឡើង ៗ មិនងាយសាបរលាបទៅវិញភ្លាម ៗ បានឡើយ ។ ទាំង
នេះសុទ្ធតែផុសចេញមកអំពីចិត្តគំនិត សញ្ចេតនារបស់ខ្មែរ ព្រលឹងខ្មែរ
នេះឯង ពោលគឺបទភ្លេងនីមួយ ៗ ពុំមែនបង្កើតឡើងដើម្បីគ្រាន់តែពីរោះ
ស្តាប់ រឺបញ្ចើចបញ្ចើតឥតន័យនោះឡើយ ។

* *

*

# ៤- របាំប្រពៃណី

ការស្តាប់ភ្លេងជាការពីរោះមែនហើយ ប៉ុន្តែបើគេធ្វើកាយវិការទៅតាមចង្វាក់ភ្លេងនោះ គេនឹងបានល្អមើលផងហើយពីរោះផង ។ ដូចនេះហើយ ទើបគេបង្កើតអោយមានរបាំឡើង ។

## ក- របាំប្រជាប្រិយ (20) .–

របាំប្រជាប្រិយ គឺជារបាំសំរាប់ប្រជារាស្ត្រ រឺរបាំដែលប្រជារាស្ត្រស្រលាញ់រាប់អាន ។

### * របាំត្រុដិ

ពាក្យសំស្ក្រឹត ត្រុដិ បានន័យថាផ្តាច់ ។ របាំ ត្រុដិ ជារបាំប្រជាប្រិយមួយបែប ដែលគេនិយមលេងតែក្នុងពេលចូលឆ្នាំខ្មែរ ដើម្បីផ្តាច់ឆ្នាំចាស់ចូលទៅក្នុងឆ្នាំថ្មី និងដើម្បីប្រសិទ្ធិសព្វសាធុការពរជូនដល់អ្នកស្រុកក្នុងឱកាសចូលឆ្នាំថ្មីនោះផង ។ ប៉ុន្តែតាមទំលាប់អ្នកស្រុក ជួនកាលគេលេងរបាំនេះម្តងៗដែរ នៅពេលបន់ស្រន់សុំទឹកភ្លៀង ដោយនៅ



ពេលនោះមានការរាំងស្ងួតយូរមកហើយ ។ សព្វថ្ងៃនេះគេប្រទះឃើញមានលេងរបាំត្រុដិតែក្នុងខេត្តសៀមរាប និងខេត្តបាត់ដំបងប៉ុណ្ណោះ ។

តាមសេចក្តីអោយការណ៍ពីលោក មាស យ៉ាំ ( កាលធ្វើជាចៅហ្វាយស្រុកសូទ្រនិគម ) ថា ត្រុដិជារបាំរបស់សាសន៍សំរែ ដែលជាជនជាតិដើមមួយរស់នៅលើទឹកដីយើងតាំងពីបុរាណមក ( សព្វថ្ងៃរស់នៅត្រង់ភូមិភាគខាងជើងនៃទន្លេសាប ) ។ ជនជាតិសំរែនេះធ្លាប់បាននាំយករបាំត្រុដិទៅលេងថ្វាយព្រះពរព្រះរាជាខ្មែរ កាលព្រះអង្គគង់នៅអង្គរវត្ត ជារៀងរាល់ពេលចូលឆ្នាំ ។ អាស្រ័យហេតុនេះហើយ បានជារបៀបរាំត្រុដិនេះនៅសេសសល់ក្នុងខេត្តសៀមរាប ហើយដែលគេនិយមលេងនៅពេលចូលឆ្នាំរហូតមកដល់សព្វថ្ងៃនេះ ។

តាមសេចក្តីអោយការណ៍ពីលោក ឡុង សាន់ នៅខេត្តបាត់ដំបងថា នៅតាមស្រុកជិតឆ្ងាយ យូរៗម្តង រមែងមានសត្វព្រៃចូលមកក្នុងភូមិអ្នកស្រុក ។ អ្នកស្រុកមានជំនឿថា ប្រសិនបើមានសត្វព្រៃណាមួយចូលស្រុកហើយ នឹងកើតឧបទ្រពចង្រៃបែបណាមួយមិនខាន ។ គេក៏នាំគ្នាប្រោះព្រំប្រេងម្សៅអោយសត្វនោះ ហើយសុំពរជ័យពីសត្វនោះវិញ ។ ដោយមានជំនឿបែបនេះហើយ អ្នកស្រុកក៏បង្កើតអោយមានរបាំត្រុដិនេះឡើង ដែលប្រដូចបាន សត្វប្រើស ទន្សោង ក្ងោក សុទ្ធសឹងជាសត្វព្រៃ មកបង្ហាញអោយអ្នកស្រុកអ្នកភូមិ ប្រោះព្រំប្រេងម្សៅ ចងដៃអំបោះតំរង អោយទានជាលុយកាក់ទៅធ្វើបុណ្យរំដោះគ្រោះអោយស្រុក

តែម្តងទៅ ប្រសិនបើមានសត្វព្រៃចូលមកក្រោយទៀត ក៏ចង្រៃឧបទ្រពពុំអាចកើតមានទៀតឡើយ ។

តាមឯកសារលោក សុខ មេភូមិគោកក្រសាំង (សៀមរាប) ថា របាំត្រុដិនេះ មានប្រភពទាក់ទងនឹងរឿងបុរាណមួយដែលដំណាលថា កាលព្រះពុទ្ធនៅជាពោធិសត្វ មុនបានត្រាស់ដឹងទ្រង់យាងចេញទៅសាងព្រះផ្នួស ស្រាប់តែមានមារតំណែងខ្លួនជាសត្វប្រើសមករាំងរាស្ទាក់ផ្លូវព្រះអង្គកុំអោយយាងទៅមុខបាន ។ នៅពេលនោះព្រះពោធិសត្វក៏តាំងអធិដ្ឋានឡើង ក៏ក្តៅដល់ទេវលោក ។ ទេវតាទាំងឡាយក៏ចុះមកតំណែងភេទជាង៉ោះ លបបាញ់ប្រើសក្លែងភេទនោះស្លាប់ទៅ ហើយក៏ដង្ហែព្រះពោធិសត្វទៅសាងព្រះផ្នួសបានសំរេចដូចព្រះបំណង ។ ដោយមានរឿងបែបនេះហើយ បានជាគេសាងជារបាំត្រុដិឡើងដែលមាន :

- ដងកញ្ញា តំណាង ឆ័ត្រក្លស់បាំងព្រះពោធិសត្វ
- ពួកភ្លេង តំណាង ទេវតា
- នាងរាំ តំណាង ទេពអប្សរហោហម
- ប្រើស ទន្សោង តំណាង មារ
- ព្រាន មនុស្សព្រៃ តំណាង ង៉ោះ (ទេវតាកលាខ្លួន) ។

តាមមតិរបស់អ្នកស្រី ឃ្លូ.ប៉ូទេ របាំត្រុដិដែលនិយមកន្ទុយក្អោក ដោយហេតុជនជាតិអាស៊ីយើងនិយមទុកសត្វនេះ ជាតំណាង ព្រះអាទិត្យ



ដែលជំនឿជាន់ដើមទុកជាអាទិទេពមួយដែរ ។ មនុស្សយើងត្រូវការបក់ស្រន់ចំពោះព្រះអាទិត្យ អោយធ្វើអំណោយទឹកភ្លៀងគ្រប់គ្រាន់សំរាប់ធ្វើស្រែចំការ ។ ហេតុនេះបានជាកាលណាគ្មានភ្លៀង គេលេងត្រុដិសុំភ្លៀង ។ នៅពេលចូលឆ្នាំ គេនិយមលេងត្រុដិក៏ចាត់ចង្រៃឧបទ្រពផង ថ្វាយព្រះអាទិត្យផង ដើមបីអង្វរករសុំភ្លៀងអោយស្រួចតាំងពីដើមឆ្នាំទៅ ដូចគ្នានឹងទំលាប់ជនជាតិចិនដែលហែក្បាលគោ ហែនាគនៅរាល់ពេលចូលឆ្នាំដូចនោះដែរ ។

## * របាំស្នែងទន្សោង

ហេតុបានជាគេអោយឈ្មោះបែបនេះ ព្រោះនៅពេលរាំគេពាក់ស្នែងទន្សោងនៅលើក្បាលហើយគេធ្វើកាយវិការត្រាប់តាមសត្វទន្សោង ។

អ្នកភូមិអញ្ចាញរូង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង បានចេះចាំរឿងនិទានមួយដែលទាក់ទងនឹងរបាំស្នែងទន្សោងនេះ ។ ឯរឿងព្រេងនោះមានសេចក្តីជាអាទិ៍ថា កាលនោះមានព្រានព្រៃម្នាក់ឈ្មោះព្រាន ពន បានទទួលព្រះរាជបញ្ជាពីព្រះរាជាអោយទៅរកបាញ់ទន្សោង ។ នៅទីបំផុតព្រាននោះត្រឡប់មកគាល់ព្រះរាជាវិញដោយដៃទទេ ហើយរៀបរាប់ទូលព្រះរាជាថា ខ្លួនបានជួបប្រទះទន្សោងមួយគូ ញី-ឈ្មោល ចេះរាំយ៉ាងល្អប្លែក នាំអោយខ្លួនដក់មើលពុំអាចបាញ់វាកើតឡើយ ។ ម្យ៉ាងទៀតមានខ្លាធំមួយដែលលបមកប្រុងនឹងចាប់ទន្សោងដែរនោះ ក៏ចាប់មិនកើត

បែរជាជួយគោះជើងជាចង្វាក់អោយសត្វនោះទៅវិញ ហើយនៅជុំវិញទន្សោងទាំងពីរ មានកន្លង់មួយហ្វូងហើរប្រទក្សិណ ដោយបញ្ចេញសូរសៀងជួយធ្វើជាភ្លេងកំដរយ៉ាងពីរោះថែមទៀតផង ។ ព្រះរាជា លុះទ្រង់ព្រះសណ្ដាប់សព្វគ្រប់ហើយ ក៏ត្រាស់ប្រើអោយព្រាន ពាន ធ្វើត្រាប់តាមទស្សនីយភាពនោះថ្វាយព្រះអង្គទត ។ ការសំដែងកាយវិការរបស់ព្រាន ពាន នេះហើយដែលកើតបានជារបាំស្នែងទន្សោងនេះឡើងដែលមាន :

– អ្នកពាក់ស្នែងពីរនាក់ តំណាងទន្សោងញី-ឈ្មោល

– សំឡេងគរ តំណាងសន្ទឹកខ្លាធំ

– សំលេងពួយ (ប្រដាប់ផ្លុំពីរោះដូចខ្លុយដែរ) តំណាងសូរសព្ទកន្លង់ ។

ការស្រាវជ្រាវរបស់លោក រ.បារ៉ាដាត់ (R.Baradat) ជាតិបារាំង បានអោយដឹងថា របាំស្នែងទន្សោងមានកំណើតឡើងពីជនជាតិដើមមួយហៅថា ព័រ ដែលច្រើនរស់នៅតាមជួរភ្នំក្រវាញត្រង់ស្រុកភ្នំក្រវាញ (ខេត្តពោធិសាត់) ស្រុកភ្នំស្រួច(ខេត្តកំពង់ស្ពឺ) ស្រុកទឹកផុស (ខេត្តកំពង់ឆ្នាំង) និងស្រុកកំពង់សោម (ខេត្តកោះកុង) ។

ដោយព្រានពាន ជាសាសន៍ព័រ គេក៏សន្និដ្ឋានថារបាំស្នែងទន្សោងប្រាកដជាគេរតំណាមកពីជនជាតិព័រ សំរាប់លេងនៅពេលប្រកបពិធីអ្វីមួយយកលំនាំតាមរបរគ្នាគេជាអ្នកប្រមាញ់ ។ ប៉ុន្តែតាមមតិខ្មែរយើងខ្លះថាថា គេលេងរបាំនេះនៅក្នុងវាំងតែក្នុងព្រះរាជពិធីបុណ្យចូលឆ្នាំ ។



* របាំគោះអង្រែ

កាលពីសម័យដើម គេនិយមលេងរបាំ គោះអង្រែ ស្ទើរតែគ្រប់ភូមិស្រុក ។ ប៉ុន្តែមកដល់សព្វថ្ងៃ របាំនេះនៅសេសសល់បន្តិចបន្តួចតែកន្លែងណាដែលមានអ្នកចង់ថែរក្សាទុកនូវប្រពៃណីនេះ រឺកន្លែងណាដែលឆ្ងាយពីទំនាក់ទំនងជាមួយអរិយធម៌បរទេស. ដូចជាសំរោងទុងកាល់ ដាក់ក្បាលដាដើម ។

មានឯកសារជាច្រើននិយាយអំពីដើមកំណើតនៃរបាំនេះ ។ លោក គុយ ម្សាក បានអោយការណ៍ថា អ្នកស្រុកសូទ្រនិគមហៅរបាំគោះអង្រែថា របាំគួយ និង រាំគួយ ។ ឃើញថាមានជាប់ឈ្មោះកុលសម្ព័ន្ធខ្មែរដើមមួយហៅថា គួយ ដែលជាហេតុនាំអោយគេសន្និដ្ឋានថារបាំគោះអង្រែមានដើមកំណើតមកពីសាសន៍គួយនេះឯង ។

ឯកសារឆ្លើយឆ្លងពីសមាជិកនៃក្រុមជំនុំទំនាមទំលាប់ បានអោយដឹងថារបាំនេះចំលងមកពីប្រទេសហ្វីលីពីន តាំងពីរជ្ជកាលព្រះបាទសម្ដេចព្រះ នរោត្ដម កាលដែលព្រះអង្គទ្រង់យាងទៅក្រុងម៉ានីល ហើយពួកបរិវារព្រះអង្គបានរៀនចេះរបាំនេះ ក៏យកមកលេងនៅប្រទេសខ្មែរយើង ។

ប៉ុន្តែនៅមានមតិរួមមួយទៀតយល់ឃើញថា ជនជាតិគួយក្ដី ហ្វីលីពីនក្ដី សុទ្ធតែជាអ្នកមានកំណើតដើមបង្កើតអរិយធម៌អូស្ត្រូអាស៊ីដូចគ្នា។

ដូចនេះរបាំត្រោះអង្រែនេះមានដើមកំណើតមកពីមនុស្សជាន់ដើមទាំងនោះ មិនប្រាកដជារបស់ជនជាតិណាតែម្នាក់ឯងឡើយ ។

## * របាំយីកេ

ខ្មែរយើងនិយមលេងរបាំយីកេនេះតាំងពីយូរយារណាស់មកហើយ គេច្រើនលេងរបាំយីកេ នៅពេលបុណ្យទាន រឺ នៅពេលសំរាកពីកិច្ចការស្រែចំការ ។ គេតែងបង្កើតវង់របាំយីកេប្រចាំភូមិស្រុករបស់គេ ហើយដែលមានអ្នកស្រុកស្រី - ប្រុស-ក្មេង-ចាស់ ចូលរួមក្នុងវង់របាំនេះដែរ ។ ម្ល៉ោះហើយរបាំនេះ ក៏មានការចំរើនលូតលាស់ដោយសារការនិយមរាប់-អានយ៉ាងខ្លាំងអំពីសំណាក់អ្នកស្រុកនេះឯង ។ ប៉ុន្តែរបាំនេះខ្សត់ខ្សោយទៅវិញ នៅគ្រាដែលប្រទេសយើងមានកើតចលាចល ក្នុងរវាងដើមសតវត្សទី ១៩ រហូតមកដល់សម័យអាណាព្យាបាលបារាំង ។ ដូចនេះហើយ បានជាចាប់ពីពេលនោះមក របាំយីកេនៅសេសសល់បន្តិចបន្តួចប៉ុននោះ ។ លុះមកដល់សម័យឯករាជ្យ ទើបគេរៀបចំរបាំយីកេនេះអោយមានជីវិតឡើងវិញ ។ ចំពោះប្រភពនៃរបាំយីកេ អ្នកស្រាវជ្រាវខ្លះបានអោយដឹងថា របាំនេះមានដើមកំណើតមកពីជ្វា រឺ ម៉លយូ ហើយទំនងចូលមកស្រុកខ្មែរតាមរយៈព្រះបាទជ័យវរ្ម័នទី ២ ដែលបានយាងទៅគង់នៅឯប្រទេសជ្វាអស់ពេលយ៉ាងយូរ រឺ តាមរយៈពួកចាម ។



## * របាំឆៃយ៉ាំ

អ្នកណាក៏បានស្គាល់ របាំឆៃយ៉ាំ ដែរ ព្រោះគេនិយមលេងញឹកញាប់ណាស់ក្នុងពិធីបុណ្យទានដូចជាបុណ្យផ្កា-កឋិន-បំបួសនាគ ជាដើម។ របាំឆៃយ៉ាំធ្វើអោយបរិយាកាសបុណ្យមានសភាពអ៊ឹកធឹកណាស់ ព្រោះចង្វាក់ភ្លេងនៃរបាំនេះមានសន្ទុះហ៊ឹកហ៊ាក់ ស្របតាមកាយវិការលោតចុះលោតឡើង ញាក់មុខ ញាក់ខ្លួន ក្រមាច់ក្រមើម គួរអោយអ្នកស្តាប់ រឺអ្នកមើលរីករាយចិត្តជាខ្លាំង ។ ការស្រាវជ្រាវរកប្រវត្តិនៃរបាំនេះ ពុំទាន់បានលទ្ធផលច្បាស់លាស់នៅឡើយទេ ប៉ុន្តែគេអាចសន្និដ្ឋានបានខ្លះថា របាំឆៃយ៉ាំ ប្រាកដជាមានសំណល់អំពីអរិយធម៌មនុស្សជាន់ដើមដែលរស់នៅលើទឹកដីខ្មែរនេះឯង ។

## * របាំរាំវង់

ហេតុបានជាមានឈ្មោះថារាំវង់ ព្រោះរបាំនេះប្រព្រឹត្តទៅជុំវិញតុផ្កា មានគូប្រុស-ស្រីដើររាំបន្តបន្ទាប់គ្នាជារង្វង់មូល ។ គេថារបាំនេះមានប្រភពពីលាវនិងសៀម ដោយឆ្លងកាត់តាមព្រំប្រទល់ ។ លាវហៅរបាំនេះថា ឡាំសាទរី ឡាំភេន ឯសៀមហៅ ឡាំថូន ។ តាមពិតរបាំរាំវង់ជាសិល្បៈចាស់បូរាណដែលមានប្រភពដើមនៅប្រទេសខ្មែរយើងនេះឯង ។ ប៉ុន្តែរបាំនេះ ក្រោយពេលដែលជនជាតិជិតខាងយកទៅពត់បត់បែនតាម

របៀបគេរួចហើយ ទើបបញ្ចូលមកប្រទេសខ្មែរវិញ ។ សព្វថ្ងៃរបាំរាំវង់ក្លាយទៅជារបាំប្រជាប្រិយទៅហើយ ។ គេតែងសង្កេតឃើញនៅគ្រប់ខេត្ត មានការនិយមរាំវង់ ជាពិសេស នៅពេលបុណ្យចូលឆ្នាំ ។ ជួនកាលគេរាំនៅពេលទំនេរពីការងារ រឺ នៅក្នុងពិធីជប់លៀង ក្នុងឱកាសអាពាហ៍ពិពាហ៍ រឺ ក្នុងពិធីបុណ្យទានក្នុងគ្រួសារដែរ ។

* របាំក្ងោក

របាំក្ងោក ជារបាំប្រជាប្រិយមួយបែប ដែលគេប្រទះឃើញ ជាពិសេសនៅតំបន់ប៉ៃលិន ។ បណ្ដាជននៅប៉ៃលិនច្រើនតែជនជាតិកុឡា ដែលចូលសញ្ជាតិជាខ្មែរ ។ នៅពេលចូលឆ្នាំ គេនិយមរាំក្ងោក អោយបណ្ដាជនមើលកំសាន្ត ។ នៅពេលលេងរបាំនេះម្ដងៗ អ្នកស្រុកអ្នកភូមិសុខចិត្តលះបង់ការងារមួយគ្រាសិន ហើយនាំគ្នាមកចោមរោមមើលយ៉ាងគុះគរ ហាក់ដូចជាពេញចិត្តនឹងរបាំនេះយ៉ាងខ្លាំង ។ តាមមតិអ្នកស្រុកប៉ៃលិនថា របាំក្ងោកនេះមានប្រវត្តិទាក់ទងនឹងរឿងព្រេង ។ ប៉ុន្តែបើតាមការស្រាវជ្រាវ គេបានដឹងថា របាំក្ងោកនេះ សេសសល់ពីអរិយធម៌អូស្ត្រូអាស៊ី ដូចរបាំប្រជាប្រិយឯទៀតៗដែរ ។ រីឯទំនុកច្រៀងនៃរបាំនេះ នៅជាពាក្យកុឡានៅឡើយ ដែលមានន័យជាសេចក្ដីបួងសួងប្រសិទ្ធិពរជ័យដល់អ្នកស្រុក អោយបានសុខចំរើន អោយមានទឹកភ្លៀងគ្រប់គ្រាន់ អោយដីកដីរកត្បូងបានផលល្អ ។ល។



ក្រៅពីរបាំប្រជាប្រិយ ដែលរៀបរាប់រួចមកហើយ នៅមានរបាំប្រជាប្រិយខ្លះទៀតដែរ ដែលសព្វថ្ងៃមិនសូវនិយមយកមកលេងកំសាន្ត ដូចជា របាំបុកអង្រែ របាំអន្តែទី របាំស្នូព្រៀត របាំត្រឡោក របាំនាយក្រាប់ របាំនាយក្លួយ ជាដើម ។

២– របាំតន្ត្រី. –

កាលពីសម័យមុនគេហៅរបាំតន្ត្រីនេះ ថាជា របាំព្រះរាជទ្រព្យ (Ballet royal) ព្រោះជារបាំរបស់ស្ដេច ហើយគេនិយមលេងតែក្នុងវាំងស្ដេច ដូចជាលេងនៅពេលបួងសួង លេងថ្វាយអាទិទេព និងថ្វាយវិញ្ញាណក្ខន្ធស្ដេចដែលបានចូលទីវង្គតទៅហើយ ។ របាំនេះមានកំណើតយូរយារណាស់មកហើយ ។ លុះដល់សម័យអង្គរ គេបានឆ្លាក់រូបទេពអប្សរ ដែលជាស្ត្រីរបាំចុះពីស្ថានសួគ៌មករេរាំនៅតាមជញ្ជាំងប្រាសាទ ។ របាំនេះពុំទទួលឥទ្ធិពលពីខាងក្រៅទេ ព្រោះមានភាពៈជារបាំដង្វាយនៅក្នុងវាំង ។ ផ្នែកខ្លះនៃរបាំនេះ បានដកស្រង់អំពីរឿងរាមកេរ្តិ៍ រឿងមហាភារតៈ និងរឿងព្រេងខ្មែរ ។ ក្រៅពីរបាំដែលទាក់ទងនឹងរឿងរ៉ាវទាំងនេះ មាន របាំថ្វាយពរ របាំទេពមនោរម្យ របាំមេអំបៅ របាំស្វា របាំជាវ ។ល ។

ឯការដែលគួរអោយចាប់អារម្មណ៍ចំពោះរបាំតន្ត្រី រឺ របាំក្បាច់បុរាណ

នេះ គឺកាយវិការនីមួយៗ មានន័យមួយ ហើយមានសភាពទន់ភ្លន់ សុភាព សមតាមចិត្តគំនិតខ្មែរ ដែលជាអ្នកនិយមសុខសន្តិភាព ។ នៅសម័យបច្ចុប្បន្ន របាំក្បាច់បុរាណនេះត្រូវបាននាំទៅលេងឯបរទេសជាញឹកញយ ហើយបានទទួលជោគជ័យយ៉ាងត្រចះត្រចង់នៅលើឆាកអន្តរជាតិ ។ សព្វថ្ងៃ របាំនេះត្រូវបានបញ្ចូលទៅក្នុងសកលវិទ្យាល័យសិល្បៈតាំងពីស្រុកខ្មែរផ្លាស់យករបបសាធារណរដ្ឋវិញ ។

*

* *

# ជំពូកទី៤

# ជំនឿ-ទំនាមទំលាប់-ប្រពៃណី

## ១_នៅពេលកើត (21)

### ក- មុនពេលកើត.-

ដើម្បីរក្សាគភ៌អោយគង់វង់ល្អនិងឆ្លងទន្លេបានរហ័ស ស្ត្រីម្តាយតែងដើរតាមគន្លងប្រពៃណីពីបុរាណ ដោយកាន់ត្រណមជាច្រើនដូចជា:

– កុំបរិភោគអាហារមានជាតិហឹរ នាំអោយក្រហល់ក្រហាយដល់កូនក្នុងផ្ទៃ

– កុំស្លៀកពាក់រឹតតឹងពេក នាំអោយចង្អៀតចង្អល់ដល់កូន

– កុំឈោងយករបស់ដែលនៅខ្ពស់ផុតដៃ នាំអោយរបូតទងសុកពីមាត់កូន

– កុំបរិភោគបបរ នាំអោយកូនកើតមកមិនស្អាត (មិនជ្រះ)

— បើមានសូរ្យគ្រាសរឺចន្ទគ្រាស ត្រូវយកអកកំបោរមកដាក់លើពោះ ដើម្បីជួយសង្កត់ទារកនៅក្នុងផ្ទៃកុំអោយភ័យរឺភ្ញាក់ផ្អើលនឹងមហិទ្ធិរិទ្ធិរាហូ បើមិនបានធ្វើបែបនេះទេ កូនកើតមកនឹងទៅជាល្ងីល្ងើមិនគ្រប់ដប់ (អ្នកខ្លះហៅថាកូនរាហ៍កន្លង) ។ល។

ក្រៅពីត្រណមដែលទាក់ទងនឹងសុខភាពព្រមទាំងចិត្តគំនិតកូន នៅមានត្រណមច្រើនបែបយ៉ាងទៀតដែលទាក់ទងនឹងការកើតកូនបានរហាស់ បានស្រួលធម្មតារបស់ស្ត្រីជាម្តាយដូចជា :

— កុំដេកថ្ងៃ កុំងូតទឹកយប់ នាំអោយកូនថ្លោសពិបាកកើត
— កុំអង្គុយមាត់ទ្វាររឺមាត់ជណ្តើរ ខ្លាចកូនកើតមិនរួច
— កុំទៅសួរសុខទុក្ខអ្នកដែលកើតកូនពិបាក
— កុំដេកដំអក់ ត្រូវរហាស់រហួនក្រោកមុនប្តី នាំអោយកើតកូនបានស្រួល ។ល។

លើសពីនេះត្រូវរកថ្នាំផ្សំជំនួយអោយសំរាលកូនរហាស់ ទុកស្ងោរផឹកនៅពេលគ្រប់ខែ ។

លុះផ្ទៃពោះកាន់តែចាស់ខែហើយ គេត្រូវប្រុងប្រៀបរកទុកជាស្រេចនូវប្រដាប់ប្រដារចាំបាច់ក្នុងពេលឆ្លងទន្លេនិងក្រោយឆ្លងទន្លេមានអុសរឹងផ្សេង ថ្នាំសំរាប់ស្ងោររឺត្រាំស្រា រណ្តាប់សំរាប់រៀបចំពិធីផ្សេងៗ ដូចជាស្រូវពន្លៃ (ស្រូវ ១ល្អីដែលគេដាក់ជូនឆ្មបនៅពេលបង្កក់កូនខ្ចី) ទៀន ធូប ក្រមួនសុទ្ធជាដើម ។



## ខ- ពេលកើត.-

នៅពេលឈឺពោះដំបូង បុរសជាប្តីរឺជាឪពុករឺបងប្អូនស្រីត្រូវតែទៅតាមយាយមបដែលនៅក្នុងភូមិនោះរឺភូមិជិតខាង អោយមកជួយសំរាលកូន ។ សូមបញ្ជាក់ថាឆ្មបនៅសម័យមុនពុំបានរៀនសូត្រខាងវិជ្ជាឆ្មបដូចសម័យនេះទេ គឺគ្រាន់តែចេះដឹងតៗគ្នាតាមរបៀបអ្នកស្រុក ។

នៅតំបន់ខ្លះ ក្នុងពេលកំពុងឈឺពោះ គេរៀបពិធីបន់ស្រន់យ៉ាងតូចមួយដល់វត្ថុស័ក្តិសិទ្ធិ រឺអ្នកដូនអ្នកតា សុំអោយការឆ្លងទន្លេប្រព្រឹត្តទៅដោយសុខសប្បាយកុំបីជួបប្រទះនឹងគ្រោះថ្នាក់រឺឧបសគ្គណាមួយឡើយ ។

## គ- ក្រោយពេលកើត.-

លុះឆ្លងទន្លេរួចហើយ ស្ត្រីជាម្តាយនិយមអាំងភ្លើងចំនួន៣ថ្ងៃរឺមួយអាទិត្យ (បើកូនដំបូង) ។ ដោយមានជំនឿថា ខ្លាចក្រែងមានខ្មោចព្រាយមកបៀតបៀនដល់ម្តាយនិងកូនខ្ចី អាចារ្យបានសូត្រមន្តអាគមព័ទ្ធអំបោះនៅជុំវិញ (ព័ទ្ធសីមា) ប៉ុន្តែគេអាចគូសខ្វែងនៅលើសសរ ដោយកំបោរស រឺបិទខ្វែងដោយក្រមួនសុទ្ធក៏បាន ជួនកាលគេយកកាំបិតរឺកន្ត្រៃទៅដាក់លើក្បាលដំណេកកូនខ្ចីនោះថែមទៀត ។ ក្រៅពីនេះ មានត្រណមចំពោះអ្នកអាំងភ្លើង មិនអោយក្រោកពីដំណេកនិយាយឆ្លើយឆ្លងជាមួយភ្ញៀវរឺញាតិមិត្រដែលមកសាកសួរនោះទេ ប៉ុន្តែអាចនិយាយទាក់ទងជាមួយ

អ្នកថែភ្លើងបានគ្រប់បែបយ៉ាង ។ លុះដល់ថ្ងៃទំលាក់ចង្ក្រានទើបផុតគ្រណាមនេះ ។

មានពិធីមួយប្រព្រឹត្តឡើងនៅពេលទំលាក់ចង្ក្រាន ។ ឆ្មបបានប្រារព្ធពិធីនេះ ដោយយកពំនូតបាយសិន្យាដបួនដុំដាក់លើស្លឹកចេក ហើយសូត្របន់ស្រន់ដល់ព្រះធរណីនិងមេបា សុំអោយជួយការពារម្តាយនិងកូនខ្ចីនេះផង រួចហើយក៏បោះបាយនោះទៅដី ព្រមទាំងសូត្រអន្ទរខ្មោច ព្រាយបិសាចកុំអោយមកយាយី ។ លុះចប់ពិធីហើយ ភ្លើងចង្ក្រានក៏ត្រូវពន្លត់ទៅវិញ ដោយអ្នកដែលបានបង្កាត់ភ្លើងដំបូងនោះ ។ ជាទូទៅ ស្ត្រីម្តាយអាចនៅអាំងភ្លើងច្រើនថ្ងៃទៅទៀតក៏បាន ។

នៅពេលបន្ទាប់នោះ ស្ត្រីម្តាយក៏បានប្រារព្ធពិធីជូនរង្វាន់ និងពិធីសុំខមាទោសចំពោះឆ្មបដែលបាននឿយហត់និងលំបាកផ្សេង ៗ ចំពោះរូបខ្លួន ក្នុងពេលឆ្លងទន្លេ ។ នៅតំបន់ខ្លះ បុរសជាប្តីក៏បានចូលរួមក្នុងពិធីសុំខមាទោសនេះជាមួយភរិយាដែរ ។ ប្រសិនបើគេពុំបានបំពេញការសុំខមាទោសនេះទេ គេមានជំនឿថា ស្ត្រីម្តាយនឹងត្រូវទទួលទណ្ឌកម្មនៅជាតិខាងមុខ ៗ ទៀត ដោយត្រូវទូលកន្ទេលរត់តាមសុំទោសឆ្មបហើយគេថា ឆ្មបនោះមិនទាំងងាកមើលនិងឆ្លើយតបមកវិញផង ។

បន្ទាប់មកទៀត តាមទំនាមទំលាប់គ្រួសារ ឪពុកទារកត្រូវយកសុក ( placenta ) ទៅកប់ រឺទៅដុត រឺដាក់លើប្រគាបឈើ ដោយជ្រើសរើសនូវទិសល្អផង ។



នៅថ្ងៃដដែលនោះ មានពិធីផ្សេងៗប្រារព្ធឡើង ដើម្បីប្រកក់ប្រសិទ្ធិដល់ទារក ។ គេដាក់ទារកនៅចំកណ្តាលបន្ទប់ក្បែរម្តាយ ក្បាលបែរទៅទិសខាងកើត ។ នៅចុងជើងទារកនេះ មានស្រូវពន្លៃនិងថាសដង្វាយដូចជាថាសម្ហូប ថាសសំលៀកបំពាក់និងគ្រឿងអលង្ការជាដើម ។

ឆ្មបចាប់ផ្តើមពិធី ដោយអុជទៀនធូបអញ្ជើញព្រះធរណី ដើម្បីសុំអោយព្រះអង្គជួយទារកអោយបានជោគជ័យគ្រប់ប្រការទៅអនាគត ។ រួចហើយ ឆ្មបនោះយកទឹកខ្មៅចិន ដែលលាយនឹងទឹកដោះម្តាយ រឺស្រាទៅលាបចិញ្ចើមនិងសក់ទារក ។ ពិធីនេះគេហៅថាពិធី “ បើកភ្នែក ” ។ បន្ទាប់មកគេធ្វើពិធីកាត់សក់ព្រៃ គឺកាត់បន្តិចនៅលើបង្ហើយ ដាក់ទៅក្នុងកូនកន្ទោងមួយ ដែលគេបន្ថែមម្ហូបចំណីនិងច្រូចស្រាបន្តិច រួចគេយកកន្ទោងនោះចេញទៅក្រៅ សំរាប់ជាដង្វាយដល់ព្រះធរណី ។ តមកទៀតទើបដល់ពិធីហៅព្រលឹង រឺជញ្ជាត់ព្រលឹង ។ តាមជំនឿ គេថាព្រលឹងមាន១៩ៗ នៅពេលដេកលក់ជាពិសេស គេថាព្រលឹងនោះចាកចេញអំពីខ្លួនមនុស្សហើយហោះហើរទៅតាមការផ្សងព្រេង ។ ប្រសិនបើព្រលឹងនោះទៅបាត់យូរពេក ម្ចាស់ព្រលឹងនឹងធ្លាក់ខ្លួនឈឺ ។ ដូចនេះហើយ បានជាគេនិយមធ្វើពិធីហៅព្រលឹងនេះឯង ។ ចំពោះទារកដែលទើបនឹងកើតថ្មី ៗ ក៏គេប្រារព្ធពិធីនេះដែរ ។ ដំបូង គេយកចិញ្ចៀនមាសមួយវង់ ដោតអំបោះចោលហើយសំបូងសម្រួងហៅរកព្រលឹង ១៩ អោយវិលនៅក្នុងព្រៃទៅ.

ហើយអោយមកថែរក្សាខ្លួនទារកនេះ ។ រួចគេក៏ចងចិញ្ចៀនដែលតំណាងព្រលឹងនោះ ទៅនឹងកដៃទារកម្ខាង កដៃម្ខាងទៀតគេចងអំបោះឆៅ ។ បន្ទាប់មក ទើបគេធ្វើពិធីបង្វិលពពិល (ពិធីនេះគេមិនសូវនិយមធ្វើទេ) ។

ក្រោយពីបានធ្វើពិធីហៅព្រលឹងរួចហើយ គេបិទត្រង់បន្ល្ហើយរបស់ទារកនូវពន្លៃ ដែលគេផ្លាស់ប្តូររាល់ថ្ងៃ ។ ការបិទពន្លៃនេះ មានរយៈពេលរហូតដល់ទារកមានអាយុ ៧ ឬ ៨ ខែ ។ នៅទីបញ្ចប់ ឆ្មបដែលជាអ្នកដឹកនាំពិធី ក៏បានអុជទៀនធូបដោតទៅលើជន្ទាយផ្សេងៗ ហើយអញ្ជើញអស់ដូនតាអោយមកទទួលនូវជន្ទាយនោះ ហើយប្រសិទ្ធិពរដល់កូនចៅ ។ ឪពុកម្តាយ បងប្អូន មិត្តភក្តិចូលម្នាក់ម្តងៗទៅប្រោះព្រំអោយពរជ័យដល់ទារក និងចងដៃទារកតាមធនធានដែលខ្លួនមាន ។

## សេចក្តីសង្ខេប.-

ចំពោះពិធីផ្សេងៗ ប្រារព្ធនៅពេលកើត ដែលបានអធិប្បាយរៀបរាប់រួចមកហើយនេះ គេពុំសូវយកមកអនុវត្តនៅសម័យបច្ចុប្បន្ននេះទេ ។ ប៉ុន្តែនៅតាមស្រុកស្រែចំការ អ្នកខ្លះដែលនៅរក្សាជំនឿ ទំនាមទំលាប់ ប៉ុនអនុវត្តនូវពិធីបុរាណនេះនៅឡើយ ។

* * *

# ២-នៅពេលរៀបការ

នៅក្នុងសង្គមខ្មែរ ពិធីរៀបមង្គលការជាប្រពៃណីមួយដែលមានបញ្ញត្តិប្រហែលគ្នានឹងកាតព្វកិច្ចដែរ ព្រោះអ្នកដែលយកគ្នាជាប្តីប្រពន្ធត្រូវតែរៀបការ បើគេចៀសពិធីនេះ នឹងត្រូវគេចាត់ទុកថាជាអ្នកគ្មានសិរីសួស្តី គ្មានកិត្តិយស ។

ខ្មែរប្រើពាក្យ **អាពាហ៍ពិពាហ៍** រឺ **អាវាហ៍វិវាហ៍** ( < អាវាហ: + វិវាហ: ) សំគាល់ពិធីនេះដែរ ។

អាវាហ: = ការនាំកូនស្រីមកផ្ទះខាងប្រុស

វិវាហ: = ការនាំកូនប្រុសមកផ្ទះខាងស្រីវិញ

អាវាហ៍វិវាហ៍ = មង្គលការគូប្រុសស្រីដែលនាំមក ហើយត្រឡប់ទៅវិញ (ពីរលើក) ។ ប៉ុន្តែតាមប្រពៃណីខ្មែរ គេនាំកូនប្រុសមកកវាងសំនៅកូនស្រីមុន (អាវាហមង្គល) ហើយនាំកូនស្រីទៅឯរោងកូនប្រុសវិញ (វិវាហមង្គល) ។ ប៉ុន្តែទោះបីគេធ្វើត្រឹមតែវិវាហមង្គល (នាំកូនប្រុសមកខាងស្រី) តែម្យ៉ាង ក៏គេនិយមហៅគ្រប់ទាំងពីរយ៉ាងថាអាវាហ៍ពិវាហ៍ដែរ ។

តើអាពាហ៍ពិពាហ៍ខ្មែរមានដើមកំណើតពីណាមក ? មានមតិជាច្រើន ៖

- អ្នកខ្លះថា យកលំនាំតាមពិធីមង្គលការរវាងព្រះរាម និងនាងសីតារបស់មហាឫស៊ីមិថិលា ។

- អ្នកខ្លះថា យកតំរាប់តាមព្រះវេស្សន្តរ កាលទ្រង់រៀបអភិសេកទៅក្រឹស្នា និងនាងជាលី ។

- អ្នកខ្លះទៀតថា ធ្វើតាមពិធីអភិសេកព្រះថោង និងនាងនាគ ។

- ចំណែកលោក ម៉ម ប៊ុណ្ណា (នៅក្នុងសៀវភៅ Les rites de mariage traditionnel khmer) ថា មនុស្សចេះធ្វើពិធីអាពាហ៍ពិពាហ៍តាំងពីមនុស្សចេះអៀនខ្មាស ចេះស្រឡាញ់កិត្តិយស ដោយសំអាងលើរឿងព្រេងក្នុងព្រហ្មញ្ញសាសនា ។

ចំពោះសិទ្ធិនិងច្បាប់រៀបមង្គលការ គេបានជួបប្រទះខ្លះដែរដូចជា:

- នៅសម័យអង្គរ ស្រីខ្មែរមានសេរីភាពគ្រប់គ្រាន់ក្នុងការរើសគូស្រករ ។ ក្រោយពីពិធី ចិន ថាន (១) រឺពិធីបើកមុខកូនស្រី (គ្រួសារអ្នកមានចាប់ធ្វើពីអាយុ ៧ ឆ្នាំដល់ ៩ ឆ្នាំ គ្រួសារអ្នកក្រពីអាយុ ១១ ឆ្នាំ ដោយនិមន្តព្រះសង្ឃ រឺតាបសមកបើកមុខកូនស្រីនោះ) ឪពុកម្តាយលែងមានអំណាចត្រួតត្រា លើកូនស្រីរបស់ខ្លួនទៀតហើយ ។ គេអាចរៀបការជាមួយជាតិសាសន៍ដទៃបាន ប៉ុន្តែមានការប្រកាន់វណ្ណៈ ។ ការចាត់ចែងក្នុងគ្រួសារ ការលះលែងគ្នា ការសាហាយស្មន់ជាសិទ្ធិរបស់ប្រពន្ធ ។

(១) សូមអានកំណត់ហេតុ « ចូវតាក្វាន » បកប្រែជាភាសាខ្មែរចុះក្នុងព្រឹត្តិប័ត្រខ្មែរ-មនលេខ ៧ ឧសភា ១៩៧៤ ទំ. 41.42 ។



- ចាប់ពីសម័យកណ្តាលមក អំណាចដឹកនាំគ្រួសារស្ថិតនៅលើឪពុកទាំងអស់ ។ តាមផ្លូវច្បាប់ លោក Dubreuil ថាប្រុសខ្មែរអាចយកប្រពន្ធបានច្រើន ។ ស្តេចអាចយកប្រពន្ធបាន ១១ នាក់ មន្ត្រីរាស្ត្រអាចយកបាន៣ ។ ប៉ុន្តែប្រពន្ធទាំងអស់នេះមានឋានៈខ្ពស់ទាបខុសគ្នាតាមលំដាប់ ។ ចំណែកឯស្រីវិញយកប្តីបានតែមួយទេ ។

- នៅសម័យបច្ចុប្បន្ន គេអនុវត្តតាមច្បាប់ចុះថ្ងៃ ២០ កុម្ភៈ១៩២០ ( តាមលោក Marcel clairon ) ថ្ងៃ ២៥ កុម្ភៈ ១៩២០ ( តាមលោក G. Thierry ) ។ ប៉ុន្តែច្បាប់ថ្មីនេះត្រូវបានកែសំរួលជាច្រើនលើកមកហើយ (23) ។

នេះជាទំរង់រៀបមង្គលការតាមប្រពៃណីខ្មែរដែលយើងលើកយកមកអធិប្បាយដោយសង្ខេបដូចតទៅនេះ (21) (22) ៖

## ក - មុនពេលរៀបការ. -

### * ពិធីចែចូវ

ដំបូងបង្អស់ឪពុកម្តាយ រឺអាណាព្យាបាលខាងប្រុស បានចាត់ស្រីម្នាក់ដែលស្គាល់ទុកចិត្ត មិនអភ័ព្វគូ ) ក្បួនចាស់ហៅថាអ្នកឃ្លាយ រឺមេ-អណ្តើក ) ហើយធ្លាប់ស្និទ្ធស្នាលនឹងគ្រួសារខាងស្រី អោយទៅស៊ើបការកូនស្រី ។ លុះបានដំណឹងថា នាងនោះនៅទំនេរ ហើយដឹងថាថ្ងៃខែ

ថ្នាំ ត្រូវគ្នាល្អ ទើបគេចូលទៅចែចូវដល់ឪពុកម្តាយ អាណាព្យាបាល របស់កូនស្រីនោះ ។ ឯពិធីចែចូវ ត្រូវប្រព្រឹត្តទៅអស់ ៣ លើក ។ ក្នុងមួយលើក ៗ ត្រូវមាន ស្លា មួ ថ្នាំ កំដរដៃទៅជាមួយផង ។ ក្នុងការចែចូវគេពុំនិយាយគ្នាត្រង់ៗទេ គឺនិយាយបញ្ចិតបញ្ចៀង ។ នៅលើកទី ៣ កាលបើខាងស្រីបើកផ្លូវអោយដើរ ជណ្តើរអោយឡើងហើយ អ្នកចែចូវក៏ត្រឡប់យកពត៌មាននេះមកប្រាប់ខាងប្រុសវិញ ។ ពិធីចែចូវនៅជើងទី ៣ នេះគេហៅថា " ស៊ីស្លាជក់ " ។

## * ពិធីដណ្តឹង

ក្រោយដែលបានចាត់មនុស្ស អោយទៅនិយាយចែចូវ បានដឹងថាគេបើកផ្លូវអោយចូលហើយ ខាងប្រុសត្រូវរៀបចំគិតគូររឿងស្តីដណ្តឹងតទៅទៀត ។ មុននឹងចូលទៅដណ្តឹងថ្ងៃណា ៗ ត្រូវអោយពត៌មានទៅខាងស្រីជាមុនសិន ។ ពិធីដណ្តឹងត្រូវប្រព្រឹត្តទៅ៣ដងដែរ ។ មនុស្សដែលមានភារៈទៅដណ្តឹងកូនស្រីគេ ហៅថា "**អ្នកផ្លូវ ចៅមហា**" ឯអ្នកដែលតំណាងគ្រួសារខាងស្រី គេអោយឈ្មោះថា "**មេបា**" ។

### – លើកទី ១

នៅថ្ងៃដែលបានកំណត់ទុក មនុស្សស្រី ៣ នាក់ ដែលមានគូស្រករសុខនឹងគ្នា ត្រូវខាងប្រុសពឹងអោយធ្វើជាអ្នកផ្លូវទៅដណ្តឹង ដោយមានជំ



រង ១ គូ ស្លា ថ្នាំ វីស្លាផ្កា ចេកទុំ នំអន្សម នំគម នំបត់ រៀបជាគូ ៗ ទៅជូនខាងស្រីផង ។ លើកនេះ មេបាខាងស្រីពុំទាន់សំរេចអ្វីទេ ថាចាំពិគ្រោះគ្នាមើលសិន ។

### – លើកទី ២

ដោយនៅលើកទី ១ ពុំទាន់បានសំរេច គេអោយអ្នកផ្លូវ ៣ នាក់ ទៅដណ្តឹងជាលើកទី២ទៀត ដោយមានជំរង ១ គូ មានកន្សែងប្រជុំក្រោបពីលើ មានស្លា មួ ស្លាផ្កា ទៀន ១ គូ ស្រា ១ ដប ចេកទុំ នំអន្សម នំគម នំបត់ នំបង់ខ្លាញ់ ។ ខាងស្រីមិនទាន់សំរេចទៀត ថាចង់អោយអ្នកផ្លូវប្រុសៗមកម្តងវិញ ព្រោះក្រែងអ្នកផ្លូវស្រី ៗ ទទួលការគ្រប់ចំពូកមិនបាន ម៉្យាងទៀតចង់អោយនាំកូនប្រុសមកមើលផង ។ ពិធីនេះហៅថា " **ស៊ីស្លាកន្សែង** " ។

### – លើកទី ៣

លើកនេះគេអោយស្រី៣នាក់ (អ្នកផ្លូវ) ប្រុស ៣ នាក់ (អ្នកមហា) អោយនាំរណ្តាប់ដែលមានជំរង ១ គូ ស្លាមួ ថ្នាំ ស្លាផ្កា ទៀន ស្រា ចេកទុំ នំអន្សម នំគម នំបត់ នំបង់ខ្លាញ់ នំកន្ត្រំ នំក្រូច អង្ករ ត្រី សាច់ បន្លែ និងផ្លែឈើផ្សេង ៗ ជាគូ ៗ ព្រមទាំងគ្រឿងមាស ពេជ្រ និងសំលៀកបំពាក់

ះទៅជូនខាងស្រី ហើយនាំកូនប្រុសទៅជាមួយផង ។ ក្រោយពីបានសន្ទនារវាងអ្នកផ្លូវ ចៅមហានិងមេបារួចសព្វគ្រប់ហើយ មេបាខាងស្រីសុំពិនិត្យសាមីខ្លួនប្រុស ព្រមទាំងបញ្ជាក់សួរអំពីគំនិតមារយាទសាមីខ្លួនប្រុសនោះផង ។ ចំណែកឯអ្នកផ្លូវចៅមហា ក៏អាចសុំមើលសាមីខ្លួនស្រីវិញដែរ ។ នៅពេលនោះ សាមីខ្លួនស្រីក៏ចេញមកជំរាបសួរភ្ញៀវ ហើយជូនកាលមានពិធីបំពាក់ចិញ្ចៀនទៅវិញទៅមករវាងគូដណ្តឹងផង ។ នៅតំបន់ខ្លះ ពិធីបំពាក់ចិញ្ចៀននេះ គឺជាពិធីហៅព្រលឹងមួយបែបដែរ ។ បន្ទាប់មក អ្នកមហាក៏លើកគ្រឿងស្លាបញ្ជាប់ពាក្យ ជូនទៅមេបាស្រីពិសា ។ ពិធីនេះហៅថា "**ស៊ីស្លាបញ្ជាប់ពាក្យ**"

ដោយមេបានៅមិនទាន់អស់ចិត្តអំពីគំនិតមារយាទរបស់សាមីខ្លួនប្រុស ទើបមានទំនាមថា ត្រូវអោយសាមីខ្លួនប្រុសមកនៅបំរើអនាគតឪពុកម្តាយក្មេករហូតដល់ពេលរៀបការ ប៉ុន្តែធ្វើតែកិច្ចការនៅក្រៅផ្ទះ គឺពុំទាន់មានសិទ្ធិចូលទៅនៅក្នុងផ្ទះបាននៅឡើយទេ ។ ចំណែកទំនាក់ទំនងរវាងគូដណ្តឹង ក៏ត្រូវគោរពច្បាប់យ៉ាងតឹងរ៉ឹង ។

## * ពិធីជូនកំណត់

ចំពោះថ្ងៃ-ខែរៀបមង្គលការ ដែលគេបានជ្រើសរើសនិងគន់គូរដោយម៉ត់ចត់ហើយ (គេពុំរើសខែណាដែលមាន ២៩ ថ្ងៃ (ខែឈ្មោល) រឺខែដែលព្រះសង្ឃចូលវស្សាទេ) គេយកទៅចុះក្នុងផែនក្រដាស់មួយសន្លឹក



ហើយត្រូវរៀបរណ្តាប់គំនរផែងផង មានស្លា ម្លូ ចេកទុំ រសស្លា ដែលដាក់គ្រឿងគ្រប់សព្វ ។

រួចហើយអ្នកផ្លូវ ត្រូវយកក្រដាស់កំណត់ពេលា និងរណ្តាប់ទៅជូនមេបាខាងស្រី ។ មេបាខាងស្រី ក៏បើកក្រដាស់កំណត់ពេលានោះ អានជូនភ្ញៀវស្តាប់ ។ ក្រោយពីបានជូនក្រដាស់កំណត់ពេលាទៅមេបារួច ហើយអ្នកផ្លូវក៏ជូនស្លាកំណត់ទៅមេបាពិសា ។ ពិធីនេះហៅថា "**ស៊ីស្លាកំណត់**" ។

នៅតំបន់ខ្លះ គេសន្មតយកស្លាថង់រង់ រឺស្លាកំណត់ទុកជាការសំគាល់ថា បានរៀបការពាក់កណ្តាលដែរ ហើយប្រសិនបើនៅពេលដែលមានអសន្តិសុខក្នុងស្រុក គេគ្រាន់តែរៀបផ្សំកូនប្រុស កូនស្រីនោះដោយសែនប្រាប់ជូនតាជាការស្រេច គឺពុំចាំបាច់ធ្វើពិធីធំដុំទៀតទេ ។

នៅទីបញ្ចប់ អ្នកផ្លូវសុំអោយមេបាបន្តាប់នូវគ្រឿងបណ្ណាការសព្វសារពើដែលត្រូវជូន និងប្រើប្រាស់ក្នុងឱកាសធ្វើមង្គលការ ។

ចាប់ពីពេលនេះទៅ សាមីខ្លួនប្រុសអាចជួយធ្វើការងារនៅក្នុងផ្ទះអនាគតឪពុកម្តាយក្មេក រឺអាណាព្យាបាលបាន ។ ចំណែកឯសាមីខ្លួនស្រីជាអ្នករៀបចំដំណេកនិងបាយទឹកអោយ ហើយកាលណាមានជំងឺនាងនោះមានសិទ្ធិជួយមើលថែទាំថែមទៀត ។

## ១-ពេលរៀបការ.-

មានការនិយមប្លែកៗគ្នា ចំពោះទីកន្លែងដែលត្រូវរៀបពិធីមង្គលការកូនប្រុសកូនស្រី ។ តាមប្រពៃណីជនជាតិចិន គេនិយមធ្វើពិធីនៅផ្ទះខាងស្រីផង នៅផ្ទះខាងប្រុសផង ប៉ុន្តែទីបំផុតគេនាំកូនស្រីទៅដប់លៀងនៅផ្ទះខាងប្រុស ព្រោះគេអោយតំលៃទៅលើកូនប្រុស ។ ចំណែកជនជាតិឥណ្ឌា មានប្រពៃណី ២ បែប គឺនាំកូនស្រីទៅរៀបការនៅផ្ទះខាងប្រុស (អាវាហមង្គល) ផង នាំកូនប្រុសទៅរៀបការផ្ទះខាងស្រី (វិវាហមង្គល) ផង ។ គេអោយតំលៃទៅប្រុសក៏បាន ស្រីក៏បាន ។

តាមប្រពៃណីជនជាតិខ្មែរវិញ កូនប្រុសត្រូវទៅរៀបការនៅផ្ទះខាងស្រី ព្រោះខ្មែរយើងមានទស្សនៈលើកតំកើងស្រីជាធំក្នុងគ្រួសារ រឺជាអ្នកដឹកនាំក្នុងសង្គម តាំងពីសម័យព្រេងនាយម្ល៉េះ (ទុកមេជាធំ = matriarcat) ។ ដោយអោយតំលៃទៅលើស្រីបែបនេះហើយ បានជាប្រុសត្រូវចូលស្ដីដណ្ដឹង សុំសេចក្ដីយល់ព្រមពីខាងស្រីមុនសិន ។ ទំនាមទំលាប់នេះ ក៏ត្រូវបានយកមកអនុវត្តតៗគ្នា រហូតមកដល់សព្វថ្ងៃ ។ ទោះបីសព្វថ្ងៃសង្គមខ្មែរបានវិវត្តមកដល់ដំណាក់ការមួយ ដែលភេទស្រីត្រូវបាត់បង់ឧត្តមភាពរបស់ខ្លួន ទៅលើភេទប្រុសទៅហើយក៏ដោយ ក៏ប៉ុន្តែសង្គមនេះ នៅរក្សាងានខ្លះល្មមអោយយើងជឿនូវអត្ថិភាព (existence) របស់ទស្សនៈ "មេ" នេះប៉ុននៅឡើយ ។ យ៉ាងណាមិញ របស់ រឺមនុស្សដែលមានភាព រឺ មាននាទីជាចម្បងលើគេទៀត ខ្មែរយើងនៅ



តែហៅថា "មេ" ដូចជា មេដៃ មេជើង មេដែក មេដំបូល មេទ័ព មេស្រុក មេភូមិ មេគយ មេការ មេផ្ទះ ។ល។ តើពិធីរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ប្រព្រឹត្តទៅនៅផ្ទះខាងស្រី យ៉ាងដូចម្ដេចខ្លះ ?

តាមប្រពៃណីបុរាណ ពិធីរៀបមង្គលការប្រព្រឹត្តទៅចំនួន ៣ ថ្ងៃ គឺថ្ងៃចូលរោង ថ្ងៃស៊ីកំណត់ និងថ្ងៃសំពះ ។

— ថ្ងៃចូលរោង

នៅថ្ងៃទី ១ គ្រួសារខាងប្រុស ត្រូវមកសង់រោងការនៅផ្ទះខាងស្រី ។ រោងការច្រើនតែសង់អំពីឫស្សីប្រក់ស្បូវ មាន៣ល្វែង ។ ល្វែងមួយសំរាប់ចុងភៅធ្វើម្ហូបអាហារ ល្វែងមួយទៀតសំរាប់លៀងភោជនាហារ ហើយល្វែងមួយទៀត ជាល្វែងផ្កាស្លាសំរាប់កូនកំលោះសំណាក់នៅរហូតដល់ថ្ងៃចុងក្រោយនៃពិធីការ ។ នៅមុខរោងផ្កាស្លា មានសង់រានទេវតាផង ។ លុះសង់និងតុបតែងលំអរោងរួចហើយ គេនាំគ្នាជញ្ជូនភស្តុភារបណ្ណាការចូលរោងមង្គលការ ហើយគេរៀបចំធ្វើម្ហូបអាហារ និងធ្វើនំផ្សេងៗជាពិសេស នំអន្សម និង នំគម ។ តាមជំនឿលទ្ធិព្រាហ្មណ៍សាសនាគេចាត់នំអន្សមជានិមិត្តរូបលិង្គឥស្សរ ឯនំគមជានិមិត្តរូបយោនីនាងឧមា ហើយអវត្តមាននៃនំទាំងពីរប្រភេទនេះក្នុងពិធីមង្គលការ នឹងនាំអោយគ្មានកូនចៅដល់គូស្វាមីភរិយាថ្មីឡើយ ។

– ថ្ងៃស៊ីស្លាកំណត់

នៅវេលាព្រឹកនៃថ្ងៃទី២គេហែកូនកំលោះ ដោយមានភ្លេងខ្មែរកំដរផង មកកាន់ផ្ទះខាងស្រី ។ កូនកំលោះនោះ ត្រូវចូលទៅនៅក្នុងរោងផ្កាស្លា ។ ចំណែកនៅលើផ្ទះការ មានធ្វើពិធីសែនព្រេន ជំរាបជូនតាអំពីការរៀបចំទុកដាក់កូនចៅអោយមានគូស្រករ និងពិធីស៊ីស្លាកំណត់ (គឺស៊ីស្លាដក់ស្លាកន្សែង ស្លាចង់រង កំណត់រួមគ្នា) ។

នៅពេលរសៀលនៃថ្ងៃដដែលនេះ ពិធីកាត់សក់កូនស្រីប្រព្រឹត្តទៅនៅលើផ្ទះការ ឯពិធីកាត់សក់កូនប្រុសនៅក្នុងរោងផ្កាស្លា ។ សព្វថ្ងៃ គេអាចកាត់សក់កូនប្រុស-ស្រីរួមគ្នានៅលើផ្ទះការក៏បាន ។ តាមទំនាមជាង អ្នកកាត់សក់ត្រូវកាន់កន្ត្រៃ កាន់ក្រាស់ ច្រៀងរាំជាមុនសិន ។ សក់ដែលគេកាត់ ត្រូវដាក់ក្នុងកន្ទោងស្លឹកចេកមួយ ហើយត្រូវយកទៅចោល ដើម្បីអោយអស់ចង្រៃឧបទ្រព ។ បន្ទាប់មក គេរៀបដង្វាយក្រុងពាលី ដើម្បីជូនពត៌មាននៃពិធីការនេះដល់ម្ចាស់ទឹកដី ។ ឯពិធីសូត្រមន្ត ក៏ប្រព្រឹត្តទៅនៅផ្ទះការផង នៅរោងផ្កាស្លាផង ។ ប៉ុន្តែគេអាចសូត្រមន្តរួមគ្នានៅលើផ្ទះការក៏បានដែរ ។ នៅពេលសូត្រមន្តនោះ សាមីខ្លួនទាំងពីរនាក់ត្រូវចេញមកស្តាប់ ហើយទទួលទឹកមន្តដើម្បីអោយជ្រះចង្រៃនិងរោគាផ្សេងៗ ហើយអោយបានសេចក្តីសុខ-ចំរើន ។

នៅវេលាយប់ គេរៀបរៀងផ្លែឈើ គឺខ្ចប់នំជាកញ្ចប់ៗតាមទំនាម



បូរាណទុកជូនមេបា ។ បន្ទាប់មក គេធ្វើពិធី ចុកស័ក្តិ ធ្វើ ឈ្នួញ អោយសាមីខ្លួនស្រី (ពិធីនេះបើបានធ្វើនៅពេលចេញពីម្លប់ហើយ ពុំបាច់ធ្វើទៀតទេ) ។ បន្ទាប់មកទៀត មានដាវ រី កាត់ថ្លៃខាន់ស្លា ជាប្រាក់សុទ្ធ ១ រៀលទម្ងន់ ១៦៖ ។ លុះទៀបភ្លឺ គេរកស្រី៣នាក់ ដែលមានគូស្រករគបទីងគ្នា អោយរៀបដោតផ្កាស្លា ដោយយកខ្នរស្លា ដែលដាក់ស្លាទ្រមន្តពីថ្ងៃរសៀលនោះ មកដោតជា៣ជុំ គឺ ៖ ផ្កាស្លាទី១ត្រូវដោតស្លា ២១ ផ្លែ ម្លូ ២១ សន្លឹក (ផ្កាស្លាច្បង) ផ្កាស្លាទី២ ត្រូវដោតស្លា ១២ ផ្លែ ម្លូ ១២ សន្លឹក (ផ្លែស្លា កណ្តាល) ផ្កាស្លាទី ៣ ត្រូវដោតស្លា ៦ ផ្លែ ម្លូ ៦ សន្លឹក (ផ្កា ស្លា ពៅ) ។

– ថ្ងៃសំពះ

នៅថ្ងៃទី ៣ លុះភ្លឺស្រាងៗ ឡើង សាមីខ្លួនប្រុស និងសាមីខ្លួនស្រី ត្រូវរៀបចំស្លៀកពាក់តាមបែបបូរាណ ។ អាចារ្យអ្នកកាន់ពេលា ត្រូវនាំកូនប្រុសទៅថ្វាយបង្គំពានទេព្ត ហើយត្រូវអង្គុយបែរមុខទៅទិសខាងកើត ចាំយកពេលានៅទីនោះ ។ លុះពេលាល្អដល់ហើយ (ពេលាដែលព្រះអាទិត្យរះ) អាចារ្យវាយឃ្មោះ ៣ដង ហើយកូនកំលោះក៏ក្រាបថ្វាយបង្គំព្រះអាទិត្យ ៣ ដងដែរ ។ ការយកពេលាក្នុងពិធីការនេះ គឺជាការយកពេលដ៏បរិសុទ្ធ ដែលជាពេលមង្គល ដើម្បីជាប្រផ្នូលអោយគូស្វាមីភរិយា បាននូវសេចក្តីចំរើនរុងរឿងទៅអនាគត ។ កាលបើបាន

ពេលាល្អហើយ គេដង្ហែកូនកំលោះទៅសំពះផ្កាស្លានៅលើផ្ទះការ ។ ដំបូង អាចារ្យកាន់ដាវបើកផ្លូវ បន្ទាប់មកមហា ៣ នាក់ អ្នកកាន់ទៀប ២ នាក់ អ្នកកាន់ផ្កាស្លា ៣ នាក់ អ្នកកាន់រងប្រាក់ខាន់ស្លា ប្រាក់ស្នាប់ទឹកដោះ អាចារ្យ កូនកំលោះ អ្នកបាំងឆ័ត្រអោយកូនកំលោះ ក្រោយបំផុតគឺពួកភ្លេង ។ លុះហែទៅដល់មាត់ជណ្ដើរ គេវាយឃ្មោះ ៣ ដង ជាសញ្ញាអនុញ្ញាតអោយកូនកំលោះឡើងលើផ្ទះបាន ។ នៅពេលនោះ មានក្មេងប្រុស រឺស្រីម្នាក់ ដែលត្រូវជាប្អូន រឺជំនិតនឹងសាមីខ្លួនស្រីបានមកទទួលដោយកាន់ទឹកមួយផ្តិលមកលាងជើងអោយកូនកំលោះ ព្រមទាំងជូនស្លាមួយម៉ាត់ផង ។ ចំណែកកូនប្រុសនោះ ក៏បានអោយប្រាក់កាក់ដល់ក្មេងនោះវិញ ហើយក្មេងនោះក៏ដឹកដៃកូនប្រុសឡើងលើផ្ទះ ។ គេអោយសាមីខ្លួនប្រុសអង្គុយលើកន្ទេល បែរមុខទៅកើត ចាំមេបានិយាយការ ។ នៅពីខាងមុខ មានរៀបពានផ្កាស្លា ពានទៀនពេលា ទៀបពីរដាក់បាយខុន ក្បាលជ្រូកមួយ រឺមាន់ស្ងោរមួយ នំអន្សម នំគម ។ បន្ទាប់មក គេអោយកូនកំលោះសំពះស្លាព្រះពរ (មួដែលគេមូរមានចំនួន៣ត្រួយ) ដែលដាក់នៅលើខ្នើយ ។ តមកទៀត អ្នកផ្ទួរស្រីម្នាក់អុជទៀនបិទនៅរង ហើយកាន់រងនោះចូលទៅអញ្ជើញកូនស្រីអោយចេញមកផ្ទឹម ។ ពេលនោះគេរាំច្រៀងបើកវាំងនន ។ សាមីខ្លួនកូនក្រមុំត្រូវអង្គុយផ្ទឹម ជិតកូនកំលោះខាងឆ្វេង ។ នៅតាមតំបន់ខ្លះ មានរាំកាន់ដាវ រាំបើកគ្របទៀប រួចហើយគេយកដាវទៅដាក់លើម្រាមដៃកូនកំលោះកូនក្រមុំ ។ ជូន



កាលអាចារ្យដាក់អកកំពោរនិងប្រទាក់ ដើម្បីជាដំណឹងប្រាប់ការរួបរួមចងជាប់គ្នា ។ ក្រោយមក គេប្រារព្ធពិធីបង្វិលពពិល នៅជុំវិញគូស្វាមីភរិយា ។ អ្នកកាន់ពពិលបង្វិល មានប្រុស៥នាក់ ស្រី៤នាក់ ដែលជាអ្នកមានខាន់ស្លាហើយមិនអភ័ព្វគ្នា ។ គេបុចពពិលបន្តគ្នា ពីដៃស្ដាំទៅដៃឆ្វេង ហើយអាចារ្យសូត្រធម៌ជ័យន្ដោបណ្ដើរ ។ លុះចប់ពិធីនេះហើយ អាចារ្យត្រូវសូត្រអោយពរផ្កាស្លា ។ រីឯពួកមេបា ត្រូវចងដៃកូនប្រុសស្រី ដោយអំបោះស ព្រមទាំងអោយពរសព្ទសាធុការរៀងៗខ្លួន ។ រួចហើយ គេស្រាយផ្កាស្លាកណ្ដាលនិងផ្កាស្លាពោ ចែកអោយញាតិមិត្តបាចអោយពរដល់គូស្វាមីភរិយា ។ លុះចប់ហើយ សាមីខ្លួនប្រុស-ស្រីងើបអង្គុយឡើង បែរមុខរកគ្នា ហើយគេវាយឃ្មោះអោយកូនក្រមុំ និងកូនកំលោះចូលក្នុងបន្ទប់ ។ ពេលនោះសាមីខ្លួនប្រុសដើរតាមសាមីខ្លួនស្រីដោយតោងជាយស្បៃរបស់សាមីខ្លួនស្រី ។ នៅក្នុងបន្ទប់ សាមីខ្លួនស្រីត្រូវបញ្ចុកស្លា មួដល់សាមីខ្លួនប្រុស រឺអុជបារីអោយជក់ ។ រួចហើយ ទាំងពីរនាក់ត្រូវផ្លាស់គ្រឿងសំអាងចេញ ហើយទៅអង្គុយកណ្ដាលទីប្រជុំ។ លំដាប់នោះ មានការកាន់ដាវច្រៀងរាំសាកន្ទេល ។ លុះចប់ពិធីនេះហើយ គូស្វាមីភរិយាត្រូវចេញទៅបំរើមេបា ក្នុងការលៀងភោជនាហារ។ សម័យបុរាណ គេលៀងភ្ញៀវ ២ លើកធំៗ គឺ នៅល្ងាចថ្ងៃស៊ីកំណាត់ និងនៅព្រឹកថ្ងៃសំពះ ។

លុះយប់ប្រហែលជាម៉ោង ៨-៩ គេប្រារព្ធពិធីផ្សំដំណេក នៅក្នុងបន្ទប់ដេករបស់គូស្វាមីភរិយាថ្មី ។ គេជ្រើសរើសស្រីមានចំណាស់ ២ នាក់ អោយរៀបចំពិធីនេះ ។ ត្រូវមានចំអាប ១ ចាស បង្អែម ១ ចាស បាយសី ១ ដូងខ្ចី១ ។ ដំបូងគេអុជទៀនធូបសែនដូនតា ហើយដួសទឹកដូងខ្ចីមញ្ចុកកូនប្រុស ៣ ស្លាបព្រា កូនស្រី ៣ ស្លាបព្រា ។ បន្ទាប់មក គេអោយសាមីខ្លួនស្រីបកចេកបញ្ចុកសាមីខ្លួនប្រុស ឯសាមីខ្លួនប្រុសត្រូវបញ្ចុកសាមីខ្លួនស្រីវិញ ជានិមិត្តរូបនៃការអោយចេះស្រឡាញ់គ្នារហូតមួយជីវិត ។

## គ- ក្រោយពេលរៀបការ.-

ក្រោយពីរៀបការបាន ៣ ថ្ងៃមក គេនាំគូស្វាមីភរិយាថ្មីនេះ ដោយយកផ្កាស្លាធ្យូង ចំអាប បង្អែម ស្លាបារី ទៅថ្វាយបង្គំសុំពរពីព្រះសង្ឃវត្ត ហើយអោយលោកបាចផ្កាស្លានោះដើម្បីប្រសិទ្ធិពរអោយសុខចំរើនតទៅ ។

តាមច្បាប់អត្រានុកូលដ្ឋាន ឪពុកម្តាយទាំងសងខាងត្រូវនាំកូនប្រុសស្រីទៅសាលាឃុំសង្កាត់ ដើម្បីសុំចុះសំបុត្រអាពាហ៍ពិពាហ៍ ដោយមានសាក្សីពីរនាក់ផង ។ ចាប់ពីពេលនេះទៅ គេមានឈ្មោះជាប្តីប្រពន្ធពេញច្បាប់ហើយ ។



ថ្ងៃក្រោយមកទៀត គេនាំស្វាមីភរិយាថ្មីនេះដើរសាកសួរញាតិមិត្តទាំងខាងប្រុសទាំងខាងស្រី ។

## សេចក្តីសង្ខេប.-

ពិធីរៀបអាពាហ៍ពិពាហ៍តាមទំនាមទំលាប់ខ្មែរបូរាណ ដែលបានអធិប្បាយរៀបរាប់រួចមកហើយនេះ ឃើញថាវែងឆ្ងាយណាស់ ។ សព្វថ្ងៃពិធីទាំងនោះពុំត្រូវបានយកមកអនុវត្តទាំងអស់ទេ ។ គេច្រើនតែកាត់ៗ ដោយជ្រើសរើសយកតែពិធីសំខាន់ៗប៉ុណ្ណោះ ។ សមសព្វថ្ងៃស្រុកទេសយើងត្រូវឈ្លានពានដោយពួកសត្រូវផង ហើយអ្នកស្រុកមិនសូវសម្បូណ៌ប្រាក់កាសផង ម្ល៉ោះហើយពិធីរៀបមង្គលការកូនចៅ ប្រព្រឹត្តទៅយ៉ាងឆាប់រហ័ស គឺកាត់មកនៅត្រឹមមួយថ្ងៃរឺមួយព្រឹកដោយលៃលកអោយចប់ពិធីយ៉ាងសង្ខេប ។

ចំពោះពិធីខ្លះក្នុងមង្គលការ តាមការស្រាវជ្រាវថា មានទំនាក់ទំនងទៅនឹងរឿងព្រេងជាច្រើនដូចជា :

- ការតោងដាយស្បៃកូនស្រីចូលបន្ទប់ ទាក់ទងទៅនឹងរឿង **ព្រះថោង នាងនាគ** ។
- ការកាន់ដាវសំពះការនិងការរាំសាកន្ទេល ទាក់ទងទៅនឹងរឿង**អាមាត្យ**ម្នាក់ដែលបានដណ្តើមកូនស្រីអ្នកស្រុក ហើយបានសម្លាប់គូដណ្តឹងថ្មីរបស់

នាងនោះ នៅពេលកំពុងរៀបការ ។

– ការដោតផ្កាស្លា ៣ យ៉ាង ទាក់ទងទៅនឹងអ្នករៀនសិល្បសាស្ត្រ ៤ នាក់ អំពីអាចារ្យទិសាបាមោក្ខ ។

– ការបង្វិលពពិល ទាក់ទងទៅនឹងរឿង **ព្រះឥស្សរ** និង **ព្រះជ័យសុរិយាកុមារ** ។

– ការស្រែកថា **ជ័យហោង សួស្តីហោង** ទាក់ទងទៅនឹងរឿង **ជ័យ** និង **សួស្តី** ជាកូនរបស់ស្រីកំសត់ម្នាក់ ។

*

* *

# ៣-នៅពេលស្លាប់

នៅក្នុងគ្រួសារខ្មែរក៏ដូចជាគ្រួសារជាតិសាសន៍ដទៃទៀត កាលបើមានមនុស្សស្លាប់ គេតែងរៀបចំធ្វើបុណ្យជូនដំណើរខ្មោចនោះតាមទំនាមទំលាប់ ដែលប្រែប្រួលទៅតាមសម័យកាល និងប្លែកគ្នាខ្លះតាមតំបន់នីមួយៗ ។

ខ្មែរចាត់ទុកពិធីបុណ្យខ្មោចឬបូជាសព ជាករណីយកិច្ចមួយដែលគ្រួសារសពត្រូវបំពេញ ។ កាលណាគេរំលងប្រពៃណី ដោយទុកអោយឪពុកម្តាយ ជីដូនជីតា បងប្អូន ស្លាប់ដូចសត្វធាតុ នោះនឹងត្រូវទទួលការរិះគន់ពីសង្គម ហើយនឹងមានការស្តាយក្រោយជាពុំខាន ។

ការស្លាប់មានច្រើនបែបយ៉ាងណាស់ ដូចជាស្លាប់ដោយលង់ទឹក-ចងក-ខ្នុះបាញ់-គ្រោះថ្នាក់ផ្សេងៗ ជាដើម ។ មនុស្សដែលស្លាប់បែបនេះ គេហៅថា «**ខ្មោចតាយហោង**» គឺស្លាប់មិនតាមកាលដែលគេពុំអាចប្រុងប្រៀបទុកជាមុនបាន ។ តាមទំនាម គេពុំយកខ្មោចតាយហោងទៅបូជាទេ គេយកទៅកប់សិន ចាំបានពេលល្អ ទើបគាស់យកឆ្អឹងមកធ្វើបុណ្យវិញ ។ ប៉ុន្តែសព្វថ្ងៃនេះ គេពុំសូវយកទៅកប់ទេ ដោយខ្វះដីកប់ផង ហើយ

ដោយទំនាមទំលាប់ប្រែប្រួលផង គេក៏យកខ្មោចប្រភេទនេះមករៀបចំធ្វើបុណ្យបូជាដែរ ។ ឯមនុស្សស្លាប់តាមកាល ដូចជាស្លាប់ដោយមានជំងឺមើលពុំជា រឺស្លាប់ដោយចាស់ជរា (ទុំជ្រុះ) គេអាចប្រុងប្រៀបរៀបចំជាមុនបានដូចមានសេចក្តីអធិប្បាយខាងក្រោមនេះ(21) (24) :

## ក – មុនពេលស្លាប់.–

នៅពេលជិតស្លាប់ គេនិមន្តព្រះសង្ឃ ៤ អង្គ រឺ ១ អង្គក៏បាន មកសូត្រធម៌អោយអ្នកជំងឺស្តាប់ ។ គេត្រូវរកអាចារ្យម្នាក់នៅជួយមើលខុសត្រូវរហូតដល់ដង្ហើមចុងក្រោយ ។ នៅពេលនោះដែរមិត្តភក្តិ បងប្អូនកូនចៅក្តី ដែលបានប្រព្រឹត្តមិនគប្បីចំពោះអ្នកនោះ ត្រូវមកសុំខមាទោស ។ បន្ទាប់មកគេអោយអ្នកជំងឺទន្ទេញធម៌ថា " ពុទ្ធោ អរហំ " ហើយអោយតាំងស្មារតីអោយនឹង ក្នុងអំពើល្អដែលខ្លួនបានធ្វើហើយ កុំអោយខ្វល់ខ្វាយជំពាក់ចិត្តទៅលើគ្រួសារ លើទ្រព្យសម្បត្តិជាដើម ។

នៅខណៈនោះ គេនាំគ្នារៀបចំគ្រឿងបន្ទុង មានគ្រឿងបរិភោគ ឧបភោគ និងរបស់ផ្សេងៗសំរាប់ថ្វាយព្រះសង្ឃនៅពេលស្លាប់ទៅ ។ ប្រដាប់ប្រដារទាំងនោះ ត្រូវយកទៅបង្ហាញអ្នកជំងឺអោយបានឃើញ ហើយត្រេកអរនឹងកុសលផលបុណ្យនោះផង ។ ចំណែកអាចារ្យក៏រៀបចំលុញ ទៀនអសល្យ ទៀនគោល ធ្វើ ស្លាត្រួយ ទង់ព្រលឹង និង សុពារ-



បាត ៦ សន្លឹក (ជាបន្ទះធ្វើដោយមាស រឺប្រាក់ រឺទង្គា រឺស្លឹករិត រឺក្រដាសក៏បានទុកដាក់ដល់ពេលស្លាប់នៅត្រង់ ថ្ងាស ក្បាល បបូរមាត់ លើចង្កា ក្នុងដៃប្រណាម្យ និងលើដើមទ្រូង) ។ គេអុជទៀនកល្យនៅពេលជិតដាច់ខ្យល់និងនៅពេលស្លាប់ ។ ឯស្លាត្រួយ គឺស្រទាប់ស្លឹកចេកដែលគេដោតស្លា ម្លូ ធូប ហើយដែលគេធ្វើទុកសំរាប់អោយអ្នកជំងឺកាន់ថ្វាយដល់ ព្រះចូឡាមណី (ចេតិយនៅឋានត្រៃត្រឹង្ស ដែលបញ្ចុះព្រះកេសា និងស្នៀតព្រះកេសរបស់ព្រះពុទ្ធ) នៅពេលដែលកំលាំងកាន់តែខ្សោយទៅ ។ គេធ្វើទង់ព្រលឹង ដោយកំណាត់សប្រវែងប្រហែល ១ ហត្ថនៃអ្នកជំងឺ ។ នៅលើទង់ព្រលឹងនោះ ជួនកាលគេទុកទំនេរ ជួនកាលគេចារគាថា ជួនកាលទៀតគេគូររូបព្រះចូឡាមណី ។ នៅតាមតំបន់ខ្លះ គេគូររូបក្រពើ តំណាងក្រុងពាលី ។ គេដាក់ទង់ព្រលឹងនោះ នៅក្បាលគ្រែអ្នកជិតស្លាប់ ហើយបន្តអំបោះពីទង់ព្រលឹងទៅដល់រូបព្រះពុទ្ធ រឺព្រះចូឡាមណី ។ គេមានជំនឿថា លុះអ្នកនោះស្លាប់ទៅ ទង់ព្រលឹងនេះឯងនឹងទ្រព្រលឹង រហូតដល់ពេលចាប់ភពជាថ្មី ។ នៅជុំវិញ និងនៅខាងលើអ្នកជំងឺ គេចងកំណាត់សរី ព្រះបង់ (បដាដែលគេគូរជីវប្រវត្តិព្រះពុទ្ធ) ។

## ខ – ក្រោយពេលស្លាប់.–

លុះមនុស្សនោះផុតដង្ហើមទៅហើយ អាចារ្យចូលទៅបិទភ្នែកនិងមាត់ខ្មោច ហើយយកសុពារបាតទាំង ៦ សន្លឹក មកដាក់តាមកន្លែងដែល

ត្រូវដាក់ ។ រំពេចនោះ គេយកទៀនកល្បមកអុជបិទនៅក្បាលក្រែ ហើយយកទៀនគោល ៥ ទៀតមកអុជបិទក្បែរក្បាល ស្មា និងជើងរបស់ខ្មោច ។ ចំណែកឯទៀនកល្ប ដែលគេបានអុជតាំងពីពេលជិតស្លាប់នោះ ត្រូវអុជបន្តទៅក្នុងចង្កៀងប្រេងកាតជំនួសវិញ ។ បន្ទាប់មកគេរៀបឡៀនត្បូង ដែលមានស្រូវពេន្លៃ ១ ល្អី ប្រាក់ ១ បាត សំពត់ស ៥ ហត្ថ ចេកទុំ ១ ស្និត និងចង្កៀងប្រេងកាតនោះ ដាក់តំកល់នៅចុងជើងខ្មោច ។ នៅក្រោមកន្លែងតំកល់ទៀនត្បូងនោះ គេដាក់ផ្នុំ ១ ដុំ និងទឹក ១ ក្អម ។ តាមជំនឿគេថា ការអុជបន្តភ្លើងទៀនកល្ប មកចង្កៀងប្រេងកាត ជានិមិត្តរូបនៃជីវិតដែលរលត់ពីរូបមួយទៅបន្តក្នុងរូបថ្មីទៀត ។ តាមទំនាមទំលាប់នៅតំបន់ខ្លះ គេយកដីអាចម៍បំណះមួយដុំដាក់ក្នុងល្អីស្រូវពេន្លៃ ជាការសំគាល់ថា រូបកាយនឹងត្រូវក្លាយទៅជាដីវិញ ហើយក្នុងពេលដ៏ឆាប់ នឹងផ្តុំផ្សំកើតបានជារូបកាយមនុស្សជាថ្មី ។ នៅមុខផ្ទះខ្មោច មានដោតទង់ក្រពើមួយ រឺមួយគូជាសញ្ញាអោយដឹងថា នៅផ្ទះនោះមានមនុស្សស្លាប់ថ្មីៗ ។

មុននឹងដាក់ខ្មោចទៅក្នុងមឈូស តាមទំនាមទំលាប់ គេត្រូវលើកខ្មោចនោះចំអាសទឹកសិន(១) ហើយលាបទឹកអប់ សិតសក់(សិតទៅក្រោយ

(១) ការចំអាសទឹកអោយខ្មោច តាមជំនឿពួកព្រាហ្មណ៍ ថាជាការលាងបាបនៅពេលស្លាប់ ។ កាលនៅរស់មនុស្សនោះលាងបាបខ្លួនឯងមួយឆ្នាំម្តងនៅក្នុងទន្លេគង្គា ។ តាមជំនឿខ្មែរយើងវិញ ថា ការផ្ងូតទឹកអោយខ្មោច គឺជាការដឹងគុណដល់អ្នកនោះខ្លះ ថាធ្វើអោយព្រះក្តិរមិនល្អក្នុងពេលតំកល់ ។



៣ ដង រួចសិតមកមុខ ៣ ដង ដើម្បីជាប្រស្នាថា ការវិលកើត-ស្លាប់ត្រលប់ចុះឡើងក្នុងភព ៣ ) ។ បន្ទាប់មកគេយកសំពត់ស ៤ ហត្ថស្លៀកអោយខ្មោចដាក់ផ្នត់មកខាងមុខ សំពត់ស ៤ ហត្ថទៀតស្លៀកដាក់ផ្នត់ទៅខាងក្រោយវិញ (ដើម្បីជាប្រស្នាថា មានអវិជ្ជាបិទមុខបិទក្រោយនិងតណ្ហាចាក់ស្រែះឆ្នា) សំពត់ ៤ ហត្ថទៀតពានាពាក់ពីលើស្មាខាងស្តាំ ។ រួចហើយគេយកខ្សែបាសចងខ្មោចត្រង់ ក-កដៃ និងកជើង ។ ការចងខ្មោចបែបនេះ មានទំនាក់ទំនងទៅនឹងផ្លូវធម៌ថា មនុស្សយើងមានចំណងលោកិយ ៣ ប្រការ គឺ៖ ប្រពន្ធ រឺប្តី កូន និងទ្រព្យសម្បត្តិ ។ បើអ្នកណាផុតពីចំណងនេះបាន នឹងរួចផុតពីសំសារវដ្ត ។ តមកទៀតគេយកមាសរឺប្រាក់មួយកាក់ទៅបង់ក្នុងមាត់ខ្មោច ( ដើម្បីជាគ្រឿងពិចារណាថា នៅពេលស្លាប់គេពុំអាចយកទ្រព្យសម្បត្តិទៅផងបានទេ សូម្បីតែប្រាក់មួយកាក់ក្នុងមាត់នេះ ក៏យកទៅពុំបានដែរ ) ។ នៅទីបញ្ចប់ គេយកសំពត់សប្រវែងមួយចំអាម ៤ ជ្រុង គ្របមុខអោយខ្មោច រួចលើកខ្មោចដាក់លើស្នប ( សំពត់រុំខ្មោចប្រវែង ១២ ហត្ថ ) ។ លុះរុំខ្មោចរួចហើយ គេចងខ្សែបាសម្តងទៀត ទើបលើកដាក់ទៅក្នុងក្តារមឈូស ។ ខណៈនោះ គេនិមន្តព្រះសង្ឃបង្សុកូល ។

ចំពោះគ្រួសារក្រខ្សត់ ពិធីបូជាសពអាចប្រព្រឹត្តទៅនៅថ្ងៃនោះ ។ ចំពោះគ្រួសារអ្នកមានគ្រាន់បើ អាចតំកល់សពនោះទុកក្នុងរោង ពីររឺបីថ្ងៃទៀត ។ ចំណែកសពស្តេច រឺព្រះសង្ឃថៅអធិការវត្ត គេតំកល់ដាក់

ក្នុងកោដ្ឋទុកយូរថ្ងៃទើបបូជា ។

## គ – ក្បួនដង្ហែនិងពិធីរំលាយសព.–

លុះថ្ងៃឈាបនកិច្ចមកដល់ គេត្រូវរៀបក្បួនដង្ហែសពនោះឆ្ពោះទៅកាន់ឈាបនដ្ឋាន ។ មុនរំកិលសពចេញពីទីតំកល់ គេនិមន្តព្រះសង្ឃបង្សុកូល ជួនកាលគេប្រារព្ធពិធីបង្វិលពពិល ៣ ជុំជុំវិញមឈូស បន្ទាប់មកទៀតតាមទំនាមទំលាប់ នៅពេលរំកិលសពចេញទៅ អាចារ្យយោគីយកក្អមទឹកស្រោចរំអាប់ដុំថ្ម រួចទាត់ទំលាក់ចោលទៅដីនូវក្អមទឹកនិងដុំថ្មនោះ ( ប្រហែលមានន័យធ្វើរូបអោយបែកធ្លាយទៅ ) ។ ឯក្បួនដង្ហែសពមានរបៀបដូចតទៅនេះ :

- ព្រះសង្ឃព្រះអភិធម្ម } ជួនកាលព្រះសង្ឃនៅជាមួយសពមានសូត្រធម៌ផង
- ព្រះសង្ឃមាតិកា }
- អាចារ្យយោគីកាន់ទង់ព្រលឹង
- វង់ភ្លេងខ្មោច ( បើមាន )
- អ្នកប្រាយលាជ ( ក្មេងស្រីស្លៀកសពាក់ស ជាកូនរឺសាច់ញាតិរបស់សព បាចលាជទៅស្តាំម្តង ឆ្វេងម្តង ដោយទន្ទេញធម៌បណ្តើរផង ហើយមើលទៅមុខជានិច្ច ។ គ្រាប់លាជដែលបាចនៅដីជាតំណាងឆ្អឹងនៃខ្មោចដែលនៅរាយប៉ាយលើដី ) ។



- អ្នកបួសមុខភ្លើង ( ក្មេងប្រុស ជាកូនរឺសាច់ញាតិរបស់សព គោរសក់ស្លៀកសពាក់ស ។ នៅជុំវិញក្បាល មានខ្សែស្បូវភ្លាំងរឺស្មៅផ្លូងចងបន្តពីមឈូសមក ។ គេថាខ្សែស្បូវភ្លាំងនោះជានិមិត្តរូបនៃជាតកជីវិតដែលបន្តគ្នាដូចច្រវ៉ាក់ ( chaine d' existences ) ហើយការបួសមុខភ្លើងនេះ គឺជាកិច្ចតបស្នងសងគុណមួយដែរ ។
- អ្នកភ្លូក ( អ្នកដុតខ្មោច ) ៤ នាក់ សែងមឈូសយកជើងទៅមុខ ( សព្វថ្ងៃគេនិយមដាក់មឈូសលើរថយន្ត ) ។
- អ្នកទូលទៀនត្បូង ( ក្មេងរឺអ្នកបំរើពេញចិត្តរបស់សព ) ។
- គ្រួសារនិងញាតិមិត្តរបស់សព ។

លុះដល់ទីប៉ាឆាហើយ គេហែប្រទក្សិណា ៣ ជុំជាឧត្តរាពត៌ ( ពីខាងឆ្វេងនៃប៉ាឆា ) រួចហើយដាក់មឈូសលើជើងថ្ករ យកក្បាលទៅទិសខាងលិច ។ គេបើកគំរបមឈូសឡើង អាចារ្យក៏បើកស្នប បើកកន្សែងគ្របមុខ ( កូនចៅសពខ្លះយកកន្សែងនេះទុកឡើង ជានាំអោយមានសិរីសួស្តីរកស៊ីមានបាន ) រួចកាត់ចំណងខ្សែបាស ហើយនិមន្តលោកបង្សុកូល ។ បន្ទាប់មកទើបញាតិមិត្តនាំគ្នាយកផ្កា ទៀន ធូបទៅដាក់លើសព សុំខមាទោសជាចុងក្រោយ ។ រួចហើយអាចារ្យយោគីនិងអ្នកភ្លូក ៤ នាក់អុជចន្លុះមួយដើមម្នាក់ដើរព័ទ្ធជុំវិញមឈូស ៣ ជុំជាឧត្តរាពត៌ ហើយអាចារ្យក៏ដុតភ្លើងបូជាសពនោះទៅ ។ ចំពោះសពអ្នករដ្ឋការ គេនិយមសូត្រសុន្ទរកថា ថ្លែងពីជីវប្រវត្តិសព និងរំយោគទុក្ខនៃញាតិមិត្តមុនពេលបូជា ។

នៅពេលដែលភ្លើងកំពុងឆេះសព គេនិមន្តលោកបំបួសអ្នកបួសមុខភ្លើង ហើយនិមន្តទេសនាមុខភ្លើងទៀត ។ គេអាចផ្សឹក អ្នកបួសមុខភ្លើងនៅពេលបូជាសពរួច ឬនកាលគេទុករហូតដល់ព្រឹកស្អែកទើបដាក់ផ្នួស ។

លុះ ៥ រឺ ៦ ម៉ោងក្រោយមក រូបនៃសាកសពក៏ឆេះសុះអស់ ។ អ្នកភ្លុកយកសំពត់គ្របមឈូសចោលរំលងភ្លើង ៣ ដង ដើម្បីរំងាប់ចង្រៃឧបទ្រព ។ យោគីយកទឹកមន្ត ( ទឹកសំបូរមាស ) មួយផ្តិល អ្នកភ្លុកកាន់ក្អមទឹកម្នាក់មួយដើរប្រទក្សិណជាឧត្តរាពត៌ ៣ ជុំ ហើយលត់ភ្លើង ។ បន្ទាប់មក គេបាចគ្រាប់ស្រូវ សណ្តែក លូ នៅលើគំនរធ្យូងនិងផេះដើម្បីប្រារព្ធពិធីប្រែរូប ។ ឯគ្រាប់ធញ្ញជាតិដែលបាចនោះ ជានិមិត្តរូបនៃការស្លាប់ដែលជាសំណាបនៃជីវិតថ្មី ។

ពិធីប្រែរូបប្រព្រឹត្តទៅ ៣ ដង ( ដើម្បីអោយពិចារណាទៅតាមភពទាំង ៣ ) ។ ដំបូងយោគីយកចបប្រមូលធ្យូងធ្វើជារូបមនុស្ស មានក្បាលទៅខាងកើត ហើយសួរថាល្អរឺទេ? អ្នកភ្លុកឆ្លើយថា មិនល្អទេ ក៏ធ្វើរូបមនុស្សម្តងទៀតមានក្បាលទៅខាងលិច ហើយសួរដូចមុនទៀត ។ គេឆ្លើយថានៅមិនទាន់ល្អទេ ។ លើកទី ៣ អាចារ្យធ្វើរូបមនុស្ស មានក្បាលទៅទិសខាងកើតវិញ រួចសួរបញ្ជាក់ថាល្អហើយរឺនៅ ? គេឆ្លើយថាល្អហើយ ទើបយកស្លឹកចេកមួយធាងគ្របលើរូបនោះ ហើយយកកំណាត់ស ៥ ហត្ថមកដាក់លើស្លឹកចេក ។ នៅទីបញ្ចប់ គេនិមន្តលោកបង្សុកូលរំគេអោយយោគីបង្សុកូលឆាកយកសំពត់សនោះទៅ ។ លំដាប់មក ទើប



គ្រួសារសពនាំគ្នារើសធាតុយកមកលាងទឹកម្ហូរ ទឹកសំបូរមាស និងទឹកដូងខ្ចី ។ នៅពេលរើសធាតុ កូនចៅណារើសបានប្រាក់កាក់រឺធ្មេញរបស់សព គេចាត់ទុកប្រាក់រឺធ្មេញនោះ ថាជាអំណោយពិសេសរបស់សពដល់កូនចៅនោះ ហើយត្រូវថែរក្សាអោយបានគង់វង់ ។ ឯធាតុដែលលាងស្អាតហើយ គេយកទៅដាក់ក្នុងកោដ្ឋតូចមួយដែលគេយកទៅតាំងនៅក្នុងផ្ទះ ។

នៅយប់ថ្ងៃដដែលនេះ គេនិមន្តព្រះសង្ឃសូត្រមន្ត ទេសនា ហើយព្រឹកស្អែក គេធ្វើចង្ហាន់ប្រគេនលោកទៀត ដើម្បីបញ្ជូនមគ្គផលដល់វិញ្ញាណក្ខន្ធនៃសព ។ លុះដល់ខួប ៧ ថ្ងៃ បន្ទាប់មកខួប ១០០ ថ្ងៃ ក៏គេប្រារព្ធធ្វើបុណ្យដូចនេះទៀត ។ ក្រោយពីបានធ្វើបុណ្យខួប ១០០ ថ្ងៃហើយ គេអាចទុកធាតុនៅក្នុងផ្ទះតទៅទៀតក៏បាន រឺក៏យកទៅបញ្ចុះក្នុងចេតិយនៅវត្តក៏បាន ។ អំណើះតទៅមុខទៀត គេគ្រាន់តែរំលឹកគុណដោយធ្វើបុណ្យឧទ្ទិសកុសលតាមពេលវេលាជាប្រពៃណីតទៅ ។

ចំពោះការកាន់ទុក្ខ គ្រួសារផ្ទាល់នៃសពនិយមកោរសក់ ស្លៀកពាក់ស រឺខ្មៅ រឺស្លៀកខ្មៅពាក់ស ។ ជាទូទៅ គេកាន់ទុក្ខចំនួន ១០០ ថ្ងៃ ប៉ុន្តែមានអ្នកខ្លះ កាន់រហូតដល់ ១ ឆ្នាំក៏មាន ។

## សេចក្តីសង្ខេប (១) –

( ១ ) ដកស្រង់ក្នុងអត្ថបទ « ហ្វូណនជារដ្ឋខ្មែរ ឬពុំមែនទេ ? » របស់លោកត្រឹង ងា ចុះផ្សាយក្នុងព្រឹត្តិប័ត្រខ្មែរ-មន លេខ ៥ សីហា ១៩៧៣ ត្រង់ទំព័រ ២៥ ។

**សម័យហ្វូណន.**– ក្នុងករណីកាន់ទុក្ខ គេត្រូវតែកោរសក់ និងកោរពុកមាត់ ។ វិធីរំលាយសពមាន ៤ យ៉ាងគឺ :

១ – បោះសពចោលទៅក្នុងទឹកទន្លេ

២ – បូជាដោយភ្លើង

៣ – យកសពទៅកប់

៤ – យកសពទៅដាក់ចោលក្នុងព្រៃស្មសានអោយសត្វស៊ី ។

ក្នុងករណីបូជាដោយភ្លើង គេតែងប្រមូលធាតុដែលនៅសល់យកទៅដាក់ក្នុងកោដ្ឋមួយបិទជិត ហើយយកទៅបោះចោលក្នុងទឹកទន្លេ ។ បើជាព្រះមហាក្សត្រ កោដ្ឋនោះធ្វើពីមាស បើជានាម៉ឺនសព្វមុខមន្ត្រី គេប្រើ កោដ្ឋប្រាក់ ហើយបើជារាស្ត្រសាមញ្ញ គេប្រើ កោដ្ឋដី ។

**សម័យចេនឡា.**–អ្នកដំណើរចិនឈ្មោះ **ម៉ាទួនលិន** បានសរសេរទុកថា ក្នុងករណីមានទុក្ខ ពួកកូនចៅនៃសពត្រូវកោរសក់ យំស្រែកយ៉ាងខ្លាំង ហើយអត់បាយអស់រយៈពេល ៧ ថ្ងៃទៀតផង ។ សពត្រូវគេយកទៅបូជា ហើយគេប្រមូលធាតុដាក់ក្នុងកោដ្ឋធ្វើពីមាស រឺពីប្រាក់ ហើយបោះចោលទៅក្នុងទឹកដ៏ជ្រៅ ។ ពួកអ្នកក្រគេប្រើកោដ្ឋធ្វើពីដី ហើយមានលាបពណ៌ផ្សេងៗ ។ មានអ្នកខ្លះទៀត ពេលមានមនុស្សស្លាប់ គ្រាន់តែយកទៅដាក់ចោលក្នុងព្រៃភ្នំទុកអោយសត្វស៊ីជាការស្រេច ។

**សម័យអង្គរ.**– លោក **ជីវតាក្វាន់** បានកត់សំគាល់ឃើញថា ពេលមានមនុស្សស្លាប់ គេឥតមានដាក់ក្នុងមឈូសទេ គេយកតែកន្ទេលក្រាលពី



ក្រោម យកកំណាត់សំពត់គ្រាលពីលើ ហើយគេយកទៅព្រៃ ។ លុះសែងដល់ក្រៅក្រុង ដល់កន្លែងណាមួយស្ងាត់ គេក៏ដាក់ខ្មោចនោះចោល ហើយត្រឡប់មកវិញ ដើម្បីទុកអោយសត្វមកស៊ី ។ ប៉ុន្តែលោក ជីវតាក្វាន់ ក៏បានសង្កេតឃើញថា មានគេយកខ្មោចទៅដុតបូជាខ្លះៗ ហើយ ។ ពេលកាន់ទុក្ខគេឥតស្លៀកពាក់សទេ តែគ្រាន់តែកោរសក់ (ប្រុសៗ) រឺកាត់សក់ (ស្រីៗ) ។

**សម័យបច្ចុប្បន្ន.**– ខ្មែរយើងសព្វថ្ងៃ ឃើញថានិយមប្រើវិធីបូជាជាងគេ ឯខ្មែរនៅកម្ពុជាក្រោម ច្រើននិយមយកសពទៅកប់អស់មួយរយៈពេល រួចទៅគេធ្វើបុណ្យ “លើកសព” រើសធាតុដាក់ក្នុងកោដ្ឋយកទៅទុកក្នុងផ្ទះ រឺយកទៅតំកល់ក្នុងចេតិយដែរ ។

*

* *

# ៤ បុណ្យផ្សេងៗ (25) (26)

ខ្មែរភាគច្រើនជាអ្នកកាន់ពុទ្ធសាសនា ។ គេតែងមានជំនឿលើកម្មផល-បុណ្យ-បាប-នរក-សួគ៌-និព្វាន ។ល។ ជាពិសេសជឿថា មានជាតិខាងមុខទៀត បានសេចក្តីថា មនុស្សយើងកាលណាស្លាប់ទៅមិនសូន្យទេ នឹងត្រូវកើតទៀត ។ ដូចនេះ ដើម្បីរចនាខ្សែជីវិតគេអោយបានល្អប្រសើរទៅអនាគត (ក្នុងបច្ចុប្បន្នក្តី អនាគតក្តី) គេនិយមធ្វើបុណ្យទាន ។ បុណ្យទានដែលជាប្រពៃណីរបស់ខ្មែរយើងមានជាអាទិ៍ៈ បុណ្យពិសាខបូជា - មាឃបូជា - ភ្ជុំបិណ្ឌ - ចូលឆ្នាំ-កឋិន-ផ្កា - ចូលវស្សា-ចេញវស្សា ។

ដោយពុំមានឱកាសអធិប្បាយបុណ្យទាំងអស់បាន យើងសូមលើកយកតែបុណ្យខ្លះមកសង្ខេបដូចតទៅនេះ :

## ក-បុណ្យពិសាខបូជា.-

ពិសាខបូជា ជាពិធីបូជាយ៉ាងធំដែលពុទ្ធបរិស័ទ្ធប្រារព្ធឡើង ដើម្បីរំលឹកដល់ព្រះពុទ្ធគោតម ។ គេកំណត់យកថ្ងៃពេញបូណ៌មី (១៥ កើត) ខែពិសាខ ព្រោះជាថ្ងៃ-ខែមហាមង្គល ដែលត្រូវនឹងថ្ងៃ-ខែដែលព្រះពុទ្ធ



ទ្រង់ប្រសូត ទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ និងទ្រង់រលត់ខន្ធចូលបរិនិព្វាន ។ ដូចនេះព្រះពុទ្ធទ្រង់ប្រសូត ត្រាស់ដឹង និង បរិនិព្វាន សុទ្ធតែក្នុងថ្ងៃពេញបូណ៌មី (១៥កើត) ខែពិសាខ ខុសគ្នាតែឆ្នាំប៉ុននោះ ។

តាមទំនាមពិធីបុណ្យពិសាខបូជា ប្រព្រឹត្តទៅនៅវេលាយប់ក្នុងវត្ត។ ដូចនេះហើយ បានជាគេឃើញនៅគ្រប់វត្តអារាម មានអុជគ្រឿងប្រទីបផ្កាលាបូជាភ្លឺព្រោងព្រាត ហើយមានមហាជនប្រុស-ស្រី-ក្មេង-ចាស់ ប្រកបដោយគ្រឿងសក្ការៈបូជា មានផ្កាភ្ញី ទៀនធូប ជាដើម ទៅប្រជុំគ្នាយ៉ាងអ៊ឹកធឹក ។ នៅយប់នោះ រហូតដល់ភ្លឺ គេនាំគ្នាស្តាប់ការសំដែងទេសនាអំពីពុទ្ធប្រវត្តិ តាំងពីដើមរហូតដល់ចប់ ដើម្បីអោយមានបសាទសទ្ធា ចំពោះព្រះរតនត្រ័យកាន់តែខ្លាំងក្លាឡើង ។

តាមការស្រាវជ្រាវ គេបានដឹងថា បុណ្យពិសាខបូជាទំនងជាធ្វើនៅក្រោយពុទ្ធបរិនិព្វានច្រើនរយឆ្នាំ ។ គេថាប្រទេសឥណ្ឌានិងប្រទេសលង្កា បានប្រារព្ធពិធីបុណ្យនេះយូរយារមកហើយ ។ ចំណែកប្រទេសសៀម និងប្រទេសខ្មែរ ទើបនឹងចាត់ចែងធ្វើនៅគ្រិស្តសតវត្ស ទី១៩នេះ។ នៅប្រទេសសៀម ស្តេច រាមា បានផ្តើមធ្វើនៅ ឆ្នាំ ១៨១៧ ។ ចំណែកនៅប្រទេសខ្មែរ បុណ្យពិសាខបូជា ត្រូវបានចាប់ធ្វើឡើងនៅឆ្នាំ ១៨៥៥ ដោយព្រះមហា ប៉ាន ដែលស្តេចសៀមបានបញ្ជូនមកកាន់ឧត្តុង្គ តាមសេចក្តីស្នើសុំរបស់ព្រះបាទ អង្គឌួង ។ ដំបូង ពិធីបុណ្យនេះប្រារព្ធឡើងដោយគណៈធម្មយុត្តិក៍ ហើយក្រោយមក ទើបជ្រួតជ្រាបទៅដល់គណៈ

មហានិកាយ ( យល់ព្រមដោយព្រះបាទ ស៊ីសុវត្ថិ ) ។

## ខ- បុណ្យមាឃបូជា.-

មាឃបូជា គឺជាពិធីបូជាមួយយ៉ាងធំដែរ ដែលពុទ្ធសាសនិកនាំគ្នាប្រារព្ធធ្វើនៅថ្ងៃពេញបូណ៌មី ខែមាឃ ។ គេកំណត់យកថ្ងៃពេញបូណ៌មី ( ១៥ កើត ) ខែមាឃ ព្រោះថ្ងៃ-ខែនេះទាក់ទងទៅនឹងពុទ្ធប្រវត្តិដូចពិសាខបូជាដែរ ។ គឺនៅថ្ងៃពេញបូណ៌មីខែមាឃ ក្នុងឆ្នាំដំបូង ដែលព្រះពុទ្ធបានត្រាស់ដឹង ( ក្នុងព្រះជន្មាយុ ៣៥ វស្សា ) មានមហាសន្និបាតមួយដែលមានព្រះអរហន្តចំនួន ១២៥០ អង្គ ( ក្រុមបុរាណជដិល ១០០០ ក្រុមអគ្គសាវ័ក ២៥០ ) ។ នៅពេលជួបជុំគ្នា ព្រះពុទ្ធទ្រង់សំដែងឱវាទបាតិមោក្ខ ហើយទ្រង់តាំង សារីបុត្រ ជាបឋមសាវ័ក ព្រះ មោគ្គល្លាន ជាទុតិយសាវ័ក ។

ក្នុងបច្ឆិមវ័យ លុះព្រះជន្មគំរប់ ៨០ វស្សា មុនថ្ងៃបរិនិព្វាន ៣ ខែ គឺនៅថ្ងៃពេញបូណ៌មីខែមាឃ មានក្រុងមារមកនិមន្តព្រះពុទ្ធអោយចូលបរិនិព្វាន ព្រះអង្គទ្រង់ឆ្លើយប្រាប់មារថា ព្រះអង្គនឹងបរិនិព្វាននៅ ៣ ខែទៀត គឺដល់ថ្ងៃពេញបូណ៌មី ខែពិសាខខាងមុខ ។ នៅពេលព្រះអង្គទ្រង់ដាក់ព្រះជន្មាយុសង្ខារនោះ មានការកក្រើកញាប់ញ័រផែនដីយ៉ាងខ្លាំង ព្រមទាំងផ្គរលាន់កងរំពងពេញផ្ទៃមេឃ ។ អាស្រ័យដោយថ្ងៃពេញបូណ៌មី ខែមាឃ ជាថ្ងៃអស្ចារ្យ ២ បែបនេះហើយ ( ប្រជុំអរហន្ត



និងដាក់អាយុសង្ខារ ) បានជាពុទ្ធបរិស័ទនាំគ្នារៀបចំគ្រឿងសក្ការៈបូជាព្រះរតនត្រ័យ រំលឹកដល់ថ្ងៃខួបនោះជាប្រពៃណី ។ នៅប្រទេសខ្មែរ គេផ្តើមធ្វើបុណ្យមាឃបូជានៅឆ្នាំប្រហែលគ្នានឹងបុណ្យពិសាខបូជាដែរ ។

ពិធីបុណ្យមាឃបូជា ប្រព្រឹត្តទៅនៅពេលយប់ក្នុងវត្តអារាមនីមួយៗ។ តាមទំនាមពុទ្ធបរិស័ទត្រូវដើរប្រទក្សិណព្រះវិហារ ៣ ជុំសិនមុននឹងចូល ។ គេយកទេយ្យវត្ថុរៀបដាក់នៅមុខពុទ្ធរូប រួចអុជទៀនធូប ។ លុះជួបជុំគ្នាហើយ ព្រះសង្ឃ ១ អង្គ ដែលចាស់វស្សាជាងគេសូត្រសិក្ខាបទ ។ បន្ទាប់មកព្រះសង្ឃ ២ អង្គ ដែលគង់នៅមុខទេយ្យវត្ថុសូត្រសរសើរគុណព្រះពុទ្ធ ( ពុទ្ធគុណ ) លុះចប់បទខាងដើម ព្រះសង្ឃមួយអង្គសំដែងទេសនា អំពីជីវប្រវត្តិរបស់ព្រះពុទ្ធ ។ ការសូត្រពុទ្ធគុណនិងការសំដែងទេសនា ប្រព្រឹត្តឆ្លាស់គ្នារហូតដល់អធ្រាត្រ ជួនកាលរហូតដល់ភ្លឺ ។ ពេលនោះគេប្រគេនយាគូដល់ព្រះសង្ឃ ដើម្បីបញ្ចប់ពិធីបុណ្យ ។

## គ- បុណ្យភ្ជុំបិណ្ឌ.-

តាមទំនាម គេធ្វើពិធីបុណ្យកាន់បិណ្ឌចំនួន១៥ថ្ងៃ គឺចាប់ផ្តើមធ្វើតាំងពីថ្ងៃ ១ រោចរៀងទៅដល់ថ្ងៃ ១៥ រោច ខែ ភទ្របទ ។ ថ្ងៃ ១ រោចដល់ទៅ ១៤ រោច គឺថ្ងៃកាន់បិណ្ឌ រឺ ដាក់បិណ្ឌ ។ ថ្ងៃ ១៥ រោច គឺថ្ងៃភ្ជុំបិណ្ឌ ព្រោះថ្ងៃនេះ អ្នកស្រុកតែងមកប្រជុំគ្នាធ្វើនៅក្នុងវត្តគ្រប់ៗគ្នា ។ ពាក្យថា “បិណ្ឌ” បានន័យថា ពំនូតបាយ ដែលគេឧទ្ទិសដល់ខ្មោចដែល

បានស្លាប់ទៅ ។ សព្វថ្ងៃ បាយបិណ្ឌ គឺពំនូតបាយដំណើប ចំអិនជាមួយខ្ទិះដូង ហើយលាយជាមួយគ្រឿងផ្សំផ្សេងៗទៀត ទៅតាមការនិយមរបស់អ្នកស្រុកក្នុងតំបន់នីមួយៗ ។ គេដាក់បាយបិណ្ឌក្នុងចានមួយយកទៅវត្ត ។ នៅកណ្ដាលបាយបិណ្ឌ មានបាយបិតបូរដែលគេដាក់លើជើងពានតូចមួយ ។ បាយបិតបូរ ដូចគ្នានឹងបាយបិណ្ឌដែរ ប៉ុន្តែគេធ្វើរាងស្រួចដូចសាជី ហើយធ្វើតំរបស្លឹកចេកគ្របពីលើ ដោយចោះកំពូលទុកដោត ទៀន ធូប និងផ្កា ។ នៅតំបន់ខ្លះ គេធ្វើបាយបិណ្ឌដាក់ក្នុងកន្ទោងចំនួន ៨ ព័ទ្ធជុំវិញបាយបិតបូរ ហើយក្នុងកន្ទោងនីមួយៗ មានពំនូតបាយបិណ្ឌពី១ដុំទៅ ១៥ ដុំ ។

ក្រៅពីដង្វាយផ្សេងៗ នៅក្នុងសាលាបុណ្យនៃវត្ត គេនាំគ្នារៀបចំតុបតែងធ្វើ **ផ្កាបិណ្ឌ** ដែលមានរាងមូលស្រួចដូចសាជី ។ នៅលើកំពូលផ្កាបិណ្ឌ គេធ្វើរូបហង្សទ្រទៀនដែលគេអុជរាល់យប់នៅពេលកាន់បិណ្ឌ ។ គេថា ផ្កាបិណ្ឌនេះ ជាដង្វាយចំពោះព្រះចូឡាមណី ។

មុនថ្ងៃភ្ជុំបិណ្ឌ ១ ថ្ងៃ គឺថ្ងៃ ១៤ រោច នៅតាមផ្ទះនីមួយៗ គេនិយមធ្វើនំអន្សម នំគម នំផ្លែសំរាប់យកទៅប្រគេនលោក ឧទ្ទិសដល់អ្នកបានស្លាប់ទៅហើយផង ចែកចាយដល់អ្នកជិតខាង រឺមិត្តភក្តិផង ។ នៅវេលាយប់នៃថ្ងៃនោះ នៅឯវត្តមានធ្វើពិធីបង្សុកូលដល់វិញ្ញាណក្ខន្ធអ្នកដែលបានបាត់បង់ជីវិតទៅហើយ មានការសូត្រធម៌ និងសំដែងទេសនារហូតដល់ភ្លឺ ។ លុះស្អែកឡើង ថ្ងៃ ១៥ រោច ខែភទ្របទ ដែលជាថ្ងៃចុងក្រោយនៃពិ



ធីកាន់បិណ្ឌ ហើយដែលជាថ្ងៃសំខាន់ជាងគេ អ្នកស្រុកគ្រប់ផ្ទះនាំគ្នាធ្វើដំណើរទៅប្រជុំនៅវត្ត ។ អ្នកខ្លះកាន់បាយបិណ្ឌ បាយបិតបូរខ្លះកាន់នំអន្សម នំគម នំផ្លែ និងនំចំណីផ្សេងៗ ខ្លះទៀតកាន់ចានស្រាក់ដាក់ចង្ហាន់ទៅប្រគេនព្រះសង្ឃ ។

ក្រៅពីពិធីកាន់បិណ្ឌដែលធ្វើនៅវត្ត មានពិធីសែនព្រេននៅតាមផ្ទះនីមួយៗ នៅវេលាយប់នៃថ្ងៃបង្ហើយនោះ ។ នៅកណ្ដាលល្វែងផ្ទះ គេក្រាលកន្ទេលមួយ ហើយដាក់ខ្នើយមួយនៅលើក្បាលកន្ទេលនោះ រួចយកសំពត់សមកក្រាលពីលើខ្នើយ និងកន្ទេលមួយជាន់ទៀត ។ នៅជុំវិញកន្ទេលគេរៀបចាស ម្ហូប នំ ចំណី បាយបិតបូរ បាយបិណ្ឌ ផ្តិលទឹក ពានស្លាម្លូ ពានបារី ។ រួចហើយគ្រួសារទាំងអស់ត្រូវមកអង្គុយជុំវិញរណ្ដាប់ទាំងនោះ ។ លុះជុំគ្នាហើយមេគ្រួសារអុជ ទៀន ធូប អញ្ជើញវិញ្ញាណក្ខន្ធដូនតាមកពិសាក្រយានេះអោយបរិបូណ៌ ហើយសុំអោយជួយថែទាំកូនចៅដែលនៅរស់អោយបានសុខសប្បាយផង ។

លុះព្រឹកព្រហាមឡើង គេរៀបដាក់នំចំណីក្នុងកូនទូកធ្វើអំពីដើមចេក ហើយបណ្ដែតលើទឹក ដើម្បីជូនដំណើរដូនតាទៅវិញ ។

ចំពោះកាលបរិច្ឆេទនៃការចាប់ផ្ដើមធ្វើបុណ្យភ្ជុំបិណ្ឌនេះ នៅស្រុកខ្មែរពុំមានឯកសារណានិយាយអោយបានច្បាស់លាស់ទេ ។ គេប្រទះឃើញរាជពង្សាវតារក្រុងកម្ពុជា ក្នុងរជ្ជកាលព្រះបាទអង្គឌួង (១៨៤៨-១៨៥៩) ដែលបាននិយាយអំពីរឿងបុណ្យភ្ជុំបិណ្ឌបន្តិចថា : “ថ្ងៃ ១ រោច ខែភទ្របទ កាន់បិណ្ឌក្នុងព្រះរាជវាំង ថ្ងៃ ១៤ រោច ខែភទ្របទ ព្រះរាជា

ទ្រង់ចេញផ្កាយព្រះបិតរ ថ្ងៃ ១៥ រោច ខែភទ្របទ ទេសនា គាថាពាន់"។

តើហេតុអ្វីបានជាគេនិយមធ្វើបុណ្យភ្ជុំបិណ្ឌក្នុងរនោច ខែភទ្របទ? គម្ពីរនានាខាងពុទ្ធសាសនាបានចែងថា "មនុស្សដែលស្លាប់ទៅ" តែងទៅកើតក្នុងកំណើតផ្សេងៗ តាមផលនៃកម្ម។ មនុស្សចិត្តអាក្រក់ ដែលបានធ្វើអំពើបាបផ្សេងៗ លុះស្លាប់ទៅតែងទៅកើតក្នុងកំណើតមួយហៅថា "ប្រេត"។ គម្ពីរមិលិន្ទបញ្ហាសំដែងថា ប្រេតមាន ៤ ពួកគឺ ៖

- ប្រេតដែលចិញ្ចឹមជីវិតដោយខ្ទុះឈាម
- ប្រេតដែលស្រេកឃ្លានអាហារជានិច្ច
- ប្រេតដែលភ្លើងឆេះជានិច្ច
- ប្រេតដែលចិញ្ចឹមជីវិតដោយផលដែលបុគ្គលដទៃឧទ្ទិសអោយ ។

គឺពួកប្រេតទី ៤ នេះហើយ ដែលគេតែងធ្វើបុណ្យភ្ជុំបិណ្ឌឧទ្ទិសផលវិសេសអោយ ។ គេនិយមរើសយកថ្ងៃរនោច ខែភទ្របទ ព្រោះពេលវេលានោះព្រះចន្ទពុំសូវមានពន្លឺ ហើយចេះតែងងឹតទៅៗ ។ ឱកាសនោះហើយដែលយមរាជដោះលែងពួកប្រេតទាំងនោះ អោយមករស់នៅលាយឡំជាមួយមនុស្ស ចាំទទួលភាគផលដែលបងប្អូនធ្វើបុណ្យឧទ្ទិសអោយ ព្រោះពួកប្រេតខ្លាចពន្លឺណាស់ ។ ប្រសិនបើក្នុងរយៈ ១៥ ថ្ងៃពួកប្រេតបានដើររកគ្រប់ ៧ វត្ត ពុំឃើញមានបងប្អូនណាធ្វើបុណ្យបញ្ជូនកុសលទៅអោយទេ ពួកប្រេតនោះ នឹងអត់បាយ អត់ទឹក ស្រេកឃ្លានវង្វេងទាំងក្រៃលែង ហើយនឹងជេរប្រទេចផ្ដាសាពួកញាតិកាទាំងឡាយ អោយវិនាសហោចទ្រព្យ



សម្បត្តិ ព្រាត់ប្រាស់ ម្ដាយ ឪពុក ប្ដីប្រពន្ធ កូនចៅ ញាតិផៅទាំង ៧សន្ដាន ជាដើម ។

## ឃ- បុណ្យចូលឆ្នាំ.-

មនុស្សគ្រប់ជាតិសាសន៍តែងប្រារព្ធធ្វើពិធីបុណ្យចូលឆ្នាំថ្មី ។ គេនិយមកំណត់ពេលវេលានិងរៀបចំពិធីនៃបុណ្យនេះប្លែកៗគ្នាស្របទៅតាមជំនឿ ទំនៀមទំលាប់ និងប្រពៃណីរបស់គេ ។ ជនជាតិខ្មែរយើងបាននាំគ្នាធ្វើបុណ្យចូលឆ្នាំតាំងពីបុរាណកាលរៀងរាល់ឆ្នាំរហូតមក ។ យើងមានឯកសារជាច្រើនស្ដីពីបុណ្យចូលឆ្នាំ ។

បុព្វហេតុដែលនាំអោយបញ្ចប់ឆ្នាំចាស់ហើយចូលឆ្នាំថ្មីនេះ ដោយអ្នកខ្លះមានជំនឿតាមរឿងព្រេងមួយដែលមានសេចក្ដីជាអាទិ៍ថា "កបិលមហាព្រហ្ម បានចោទប្រស្នា ៣ ខ ដល់ធម្មបាលកុមារ ជាកូនសេដ្ឋីដែលបានរៀនចេះចប់នូវត្រៃវេទ និងចេះភាសាបក្សីទាំងពួង ហើយបានសន្យាថា បើដោះស្រាយមិនរួចទេ នឹងកាត់ក្បាល ធម្មបាល ផ្ទុយទៅវិញ បើស្រាយប្រស្នានោះរួច កបិលមហាព្រហ្ម នឹងកាត់ក្បាលវិញ ។ ធម្មបាល ទាល់ប្រាជ្ញា ប៉ុន្តែទីបំផុតបានស្ដាប់សត្វឥន្ទ្រី ញី-ឈ្មោល សន្ទនាគ្នាអំពីប្រស្នានោះ ទើបបានយល់ឡើង ហើយដល់ថ្ងៃកំណត់ ក៏បានឆ្លើយថា :

ខ ទី ១- វេលាព្រឹកសិរីស្ថិតនៅមុខ ទើបមនុស្សត្រូវយកទឹកលុបមុខ ។

ខ ទី ២- វេលាថ្ងៃត្រង់សិរីស្ថិតនៅទ្រូង ទើបមនុស្សត្រូវយកទឹកមកលាងទ្រូង ។

ខ ទី ៣-វេលាល្ងាចសិរីស្ថិតនៅជើង ទើបមនុស្សត្រូវយកទឹកលាងជើង។

**កបិលមហាព្រហ្ម** ត្រូវកាត់ក្បាលបូជា **ធម្មបាល** ហើយអោយកូនស្រីទាំង ៧ នាក់ យកពានមកទទួលក្បាល រួចអោយកូនច្បងហែប្រទក្សិណភ្នំព្រះសុមេរុ ៦០ នាទី ទើបយកទៅទុកក្នុងមណ្ឌបនៅក្នុងគុហា**គន្ធមាលី** នៃភ្នំកៃលាស ។ លុះគំរប់ឆ្នាំសង្ក្រាន្ត ទេពធីតា ទាំង ៧ ក៏ផ្លាស់វេនគ្នាហែក្បាលកបិលមហាព្រហ្មប្រទក្សិណភ្នំព្រះសុមេរុ រាល់ៗឆ្នាំរហូតមក ” ។ ហេតុនេះហើយបានជាមានសង្ក្រាន្ត រឺទំនាមដាច់ឆ្នាំចាស់ចូលឆ្នាំថ្មីនេះ ។

អ្នកខ្លះទៀតមានជំនឿថា ក្នុងរវាង ១ ឆ្នាំដែលរស់នៅ ជួនកាលគេជួបប្រទះចង្រៃឧបទ្រព ជួនកាលមានជំងឺប្រចាំកាយ ជួនកាលទៀតបានប្រព្រឹត្តអំពើសៅម៉ងផ្សេង ៗ ជាដើម ។ លុះផុតឆ្នាំចាស់នេះទៅ គេធ្វើបុណ្យ គេស្លៀកពាក់ថ្មី ៗ ដើរលេងអោយសប្បាយ អោយអស់កង្វល់ អោយបាត់នឿយហត់ រួចទើបចាប់ផ្តើមសាងជីវភាពថ្មី អោយបានជួបប្រទះសុភមង្គលគ្រប់ប្រការនិងអាយុយឺនយូរតទៅមុខទៀត ។

តាមទំនាម ពិធីចូលឆ្នាំប្រព្រឹត្តទៅចំនួន ៣ ថ្ងៃ ។ ថ្ងៃដំបូងជាថ្ងៃ**មហាសង្ក្រាន្ត** ថ្ងៃទី ២ ជាថ្ងៃ **វនបត** ថ្ងៃទី ៣ ជាថ្ងៃ **ឡើងស័ក** ។ ឯការកំណត់ខែ ថ្ងៃ ម៉ោង នាទី ដែលឆ្នាំចាស់ត្រូវផុតកំណត់ហើយដែលទេព្តាឆ្នាំថ្មីត្រូវចុះមកទទួលពីវេណពីទេព្តាឆ្នាំចាស់នោះ គេអាចដឹងបានយ៉ាងទៀងទាត់ ដោយអាស្រ័យក្បួនហោរាសាស្ត្រតាមបែបបុរាណ គឺ: ក្បួនមហាសង្ក្រាន្តនេះឯង ។



នៅប្រទេសខ្មែរ តើថ្ងៃចូលឆ្នាំថ្មីត្រូវលើខែណា? ថ្ងៃណា? ចាប់ពីគ្រឹមសម័យក្រុងនគរធំឡើងទៅ ខ្មែរយើងប្រើចន្ទគតិ (វិធីដើរនៃព្រះចន្ទ) ទើបកំណត់យកខែ មិគសិរ ជាខែចូលឆ្នាំហើយជាខែទី ១ ខែកត្តិកជាខែទី ១២ ។

លុះក្រោយមក ទើបគេនិយមប្រើសុរិយគតិ (វិធីដើរនៃព្រះអាទិត្យ) ជាសំខាន់វិញ ហើយកំណត់ចូលឆ្នាំក្នុងខែចេត្រ (ខែទី ៥) ដែលជាដើមឆ្នាំកំណត់ព្រះអាទិត្យចូលកាន់មេសរាសី ឯថ្ងៃចូលឆ្នាំរមែងត្រូវលើថ្ងៃទី ១៣ នៃខែមេសៈ (ចេត្រ) រៀងរាល់ឆ្នាំ ប៉ុន្តែយូរ ៗ ទៅប្រហែលជាមានភ្លាត់ម្តង ៗ ចូលឆ្នាំក្នុងថ្ងៃទី ១៤ ក៏មានខ្លះដែរ ។ មហាសង្ក្រាន្តដែលប្រើរបៀបគន់គូរតាមសុរិយគតិ មានឈ្មោះថា “ **សាមញ្ញសង្ក្រាន្ត** ” (ព្រះអាទិត្យដើរត្រង់ពីលើក្បាលជាសង្ក្រាន្ត) ។ ឯមហាសង្ក្រាន្ត ដែលប្រើរបៀបគន់គូរតាមចន្ទគតិហៅថា “ **អាយន្តសង្ក្រាន្ត** ” (ពេលដែលព្រះអាទិត្យដើរបញ្ឆៀងមិនត្រង់ពីលើស្មោះ) ។ គេនៅប្រើចន្ទគតិអែបគ្នានិងសុរិយគតិដែរ ព្រោះចន្ទគតិមានទំនាក់ទំនងនឹងពុទ្ធបញ្ញត្តិ ជាច្រើន ។ ចំណែកឯថ្ងៃចូលឆ្នាំតាមចន្ទគតិមិនបានទៀងជាថ្ងៃណាមួយទេ ជួនកាលចូលឆ្នាំក្នុងវេលាខ្មើត ជួនកាលទៀតក្នុងវេលារនោចទៅវិញ ប៉ុន្តែនៅក្នុងរវាង ១ ខែ គឺមិនមុនថ្ងៃ ៤ កើតខែចេត្រ និងមិនហួសថ្ងៃ ៤ កើត

ខែពិសាខទេ ដូចនេះឃើញថា សង្ក្រាន្តខ្លះធ្លាក់ទៅក្នុងខែពិសាខក៏មាន ។

ក្រៅពីនេះ យើងមានឯកសារខ្លះទៀតដែលបញ្ជាក់ថា ខ្មែរយើងប្រារព្ធពិធីចូលឆ្នាំនៅខែចេត្រ ដូចជាអត្ថបទរបស់លោក ជីវ៉ាតាវ៉ាន់ ថា នៅខែចេត្រខ្មែរយើងបានធ្វើបុណ្យដោយមានលេងល្បែងបោះឈូងផង ហើយមានប្រមូលព្រះពុទ្ធរូបពីគ្រប់ទិសទីមកស្រង់ទឹកផង ។ ឯសិលាចារឹកនៅប្រាសាទព្រះខាន់ ក៏បានចែងថា ខ្មែរបានធ្វើបុណ្យក្នុងខែចេត្រដែរ ។

ចំពោះពិធីផ្សេង ៗ ក្នុងឱកាសទទួលឆ្នាំថ្មី ខ្មែរយើងបានរៀបចំតាមប្រពៃណីដូចតទៅនេះ :

នៅពេលមុនចូលឆ្នាំ គេនាំគ្នាប្រុងប្រៀបរកស្បៀងអាហារ សំអាតផ្ទះសម្បែង កាត់សំលៀកបំពាក់ថ្មី ៗ ជាដើម ។ ថ្ងៃចូលឆ្នាំមកដល់ គេរៀបពលីការចាំទទួលទេព្តាថ្មីដែលមានជាអាទិ៍ : ទៀន ៥ ធូប៥ ផ្កា ៥ លាជ ៥ បាយសី ៥ ថ្នាក់ ១ គូ បាយសីបាក្លាម ១ គូ ស្លាធម៌ ១ គូ ស្លាបារី ១ ពាន ផ្កា ផ្លែឈើ ។ លុះរណ្តាប់រៀបរួចស្រេចហើយ គេនាំកូនចៅអន្តេវាសិកជុំគ្នានៅជិតកន្លែងរៀបពលីការនោះ ហើយអុជទៀនធូបបន់ស្រន់សុំសេចក្តីសុខចំរើនគ្រប់ប្រការពីទេព្តាថ្មី រួចនាំគ្នាសូត្រនមស្ការថ្វាយបង្គំព្រះហើយក៏បែកគ្នាទៅ ។ ឯពិធី ៣ ថ្ងៃនៃថ្ងៃចូលឆ្នាំនោះគឺ :

ថ្ងៃទី ១.– គេយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅវត្ត ។ ពេលល្ងាចគេនាំគ្នាដញ្ជូនខ្សាច់សាងវាលុកចេតិយ នៅជុំវិញព្រះវិហារវិជុំវិញដើមពោធិណាមួយក្នុងវត្តនោះ ។ នៅពេលព្រលប់គេប្រគេនភេសជ្ជៈដល់ព្រះសង្ឃនិមន្តលោកចំរើនព្រះបរិត្ត និងសំដែងធម្មទេសនា ។



ថ្ងៃទី ២ – កូនចៅជូនសំលៀកបំពាក់ និងចំណី លុយកាក់ដល់អ្នកមានគុណមានឪពុកម្តាយជីដូនជីតាជាដើម ។ គេធ្វើទានដល់មនុស្សបំរើ អ្នកក្រីក្រទៀត ។ ពេលរសៀល គេនាំគ្នាទៅពូនភ្នំខ្សាច់ទៀត ហើយសូត្រធម៌អធិដ្ឋានភ្នំខ្សាច់ដែលគេសន្មតទុកដូចជាទ្រាមណីចេតិយ ហើយនិមន្តព្រះសង្ឃប័ង្សុកូលចេតិយ បញ្ជូនមគ្គផលដល់វិញ្ញាណក្ខន្ធបងប្អូនដែលបានស្លាប់ទៅហើយ ។

ថ្ងៃទី៣.– ពេលព្រឹកនិមន្តព្រះសង្ឃឆ្លងភ្នំខ្សាច់ ។ ពេលល្ងាចនិមន្តព្រះសង្ឃស្រង់ទឹក ( តាមការនិយមនៃស្រុកខ្លះ ) និងស្រង់ព្រះពុទ្ធរូប ។

នៅក្នុងឱកាសចូលឆ្នាំថ្មីនេះ បណ្តាជននាំគ្នាលេងល្បែងប្រជាប្រិយកំសាន្តជាច្រើន ដូចជាលេងបោះឈូង បោះអង្គុញ ទាញព្រ័ត្រ មានរបាំត្រុដិ ( ច្រើននៅបាត់ដំបង-សៀមរាប ) ជាដើម ។

* * *

# ផ្នែកទី៣

# សង្គមធម៌

## របបសង្គមខ្មែរ

( 27 - 28 - 29 - 30 - 31 - 32 - 33 )

ក្រៅពីវប្បធម៌ របបសង្គមក៏មានមុខងារសំខាន់ណាស់ដែរក្នុងការគូសបញ្ជាក់លក្ខណៈរបស់ប្រជាជាតិនីមួយៗ ។ តើអ្វីទៅដែលហៅថារបបសង្គម ហើយមានសារៈសំខាន់យ៉ាងដូចម្ដេចខ្លះ ?

របបសង្គមនីមួយៗមានធាតុសំខាន់៣ជាមូលដ្ឋានគឺ នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច ។

**នយោបាយ** ( នយ + ឧបាយ ) គឺជាឧបាយក្នុងការដឹកនាំសង្គមមនុស្សអោយដើរឆ្ពោះទៅរកគោលដៅណាមួយ ។ អ្នកនយោបាយដែលកាន់កាប់វាសនារបស់ប្រទេសជាតិនីមួយៗ មានភារកិច្ចត្រិះរិះរកឧបាយយ៉ាងណា អោយប្រទេសជាតិនោះបានរស់រានមានជីវិតយូរ



អង្វែងតទៅ ព្រមទាំងបានប្រកបដោយសេចក្ដីសុខចំរើនគ្រប់វិស័យទៀតផង ។ ជនជាតិមននិងជនជាតិចាម ដែលបណ្ដោយអោយធ្លាក់ខ្លួនក្នុងឋានៈជាអ្នកឥតមានរដ្ឋ ឥតមានទឹកដីផ្ទាល់ ឥតមានអធិបតេយ្យ បង្ហាញអោយឃើញថា ខុះការប៉ិនប្រសប់ក្នុងរឿងនយោបាយ ។ ឯជនជាតិខ្មែរយើងក្នុងសម័យមុនៗ ដែលបានបណ្ដោយអោយបែកបាក់សាមគ្គី ជាហេតុនាំអោយបាត់បង់ទឹកដី ហើយរិះៗតែរលាយជាតិអស់នៅ ស.វ. ទី ១៨-១៩ ក៏ឃើញថាមានការឆ្គាំឆ្គងប្រហែសច្រើនក្នុងផ្នែកនយោបាយនេះដែរ ។

ដោយហេតុតែនយោបាយមានមុខងារសំខាន់ក្នុងការដឹកនាំប្រទេសជាតិនីមួយៗ នេះហើយ បានជាវាមានឥទ្ធិពលខ្លាំងទៅលើវិស័យឯទៀតៗ មានវប្បធម៌ សេដ្ឋកិច្ច និងសង្គមកិច្ច ជាដើម ( នយោបាយវប្បធម៌-នយោបាយសេដ្ឋកិច្ច-នយោបាយសង្គមកិច្ច ។ល។ ) ។

**សេដ្ឋកិច្ច** ( សេដ្ឋ + កិច្ច ) គឺសកម្មភាពទាំងឡាយណាដែលដើរឆ្ពោះទៅរកការបង្កើត ការប្រើប្រាស់ ការដូរនិងការចែកផលសំរាប់សេចក្ដីត្រូវការរបស់សង្គមមនុស្ស ។ សត្វតិរច្ឆានមិនចេះធ្វើសកម្មភាពសេដ្ឋកិច្ចទេ ការដែលវាស្វែងរកចំណីអាហារសំរាប់បំពេញសេចក្ដីស្រេកឃ្លានរបស់វា គឺធ្វើតែទៅតាមសភាវគតិប៉ុណ្ណោះ ។

**សង្គមកិច្ច** (សង្គម + កិច្ច) គឺកិច្ចការទាំងឡាយ ដែលមានគោលដៅបំរើផលប្រយោជន៍រួមរបស់សង្គម ។ ការចែកដីធ្លី-ផ្ទះសំបែង ការលើក

ផ្លូវថ្នល់ ការសង់ស្ពាន សាលារៀន មន្ទីរពេទ្យ ការជួយសង្គ្រោះជនរងគ្រោះដោយសង្គ្រាម រឺដោយមហាភ័យធម្មជាតិ ការបង្ក្រាបល្បែងស៊ីសង ការកំចាត់ជនទុច្ចរិត ។ល។ ទាំងនេះសុទ្ធតែជាកិច្ចការសំរាប់សំរាលទុក្ខវេទនា រឺផ្តល់សេចក្តីសុខស្រួលដល់សង្គមនេះឯង ។

## ក - នយោបាយខ្មែរ. -

ខ្មែរយើងជាជាតិមានចំណាស់ : ការសិក្សាស្រាវជ្រាវបានបង្ហាញអោយឃើញថា ខ្មែរជាជាតិមួយស្ថិតនៅក្នុងអំបូរខ្មែរ-មន ដែលជាអំបូរមនុស្សមួយកកើតឡើងនៅភូមិភាគអាស៊ីអគ្នេយ៍នេះ ។ ក្នុងសម័យបុព្វប្រវត្តិសាស្ត្រដ៏យូរលង់ហើយ សង្គមខ្មែរប្រហែលជាស្ថិតលើការរៀបចំជាក្ន **សម្ព័ន្ធ** ( tribus ) ។ រដ្ឋខ្មែរមានរូបរាងច្បាស់លាស់នៅដើមគ្រិស្តសករាជ ។ ថានៈជារដ្ឋនេះ បើតាមយោបល់របស់អ្នកប្រាជ្ញខ្លះថាបានមកពីឥទ្ធិពលឥណ្ឌា ។ ចំណែកយើង យើងមិនយល់ស្របទាំងស្រុងទេ ព្រោះនៅពេលដែលព្រាហ្មណ៍ហ៊ុនទៀនមកដល់ នាងសឹងយើបានលើកទ័ពទៅតទល់និងអ្នកចំណូលថ្មី ។ ត្រង់នេះសអោយឃើញថា នៅសម័យនោះសង្គមខ្មែរមានការរៀបចំយ៉ាងម៉ត់ចត់ទៅហើយ រឺក៏ថាខ្មែរ**មានរដ្ឋរួចហើយក៏ថាបាន** ព្រោះធាតុសំខាន់ៗដែលផ្គុំជារដ្ឋ គឺ ទឹកដី មនុស្ស របបគ្រប់គ្រងនិងអធិបតេយ្យមានគ្រប់សព្វអស់ទៅហើយ ។



រដ្ឋខ្មែរមានការចំរើនលូតលាស់ជាលំដាប់ ហើយបានឡើងដល់ថានៈជាកំពូលនៅ ស.វ.ទី ១២ នៅពេលដែលយើងកសាងប្រាសាទអង្គរវត្ត ។ ចាប់ពីស.វ.ទី ១៣ ខ្មែរយើងធ្លាក់អាប់អោនជាលំដាប់រហូតមកដល់សព្វថ្ងៃនេះ ។ តើមូលហេតុស្ថិតនៅត្រង់ណា?

គួរគប្បីជ្រាបថា នៅមុនព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ ប្រទេសខ្មែរយើងស្ថិតនៅក្នុងរបបរាជាធិបតេយ្យ :

– ពីស.វ. ទី ១ ដល់ស.វ.ទី ១៤ រាជាធិបតេយ្យខ្មែរមានឈ្មោះថាសម្បូរណាញាសិទ្ធិរាជ (monarchie absolue) ។ នៅមុនសម័យអង្គរព្រះរាជាជាតំណាងអាទិទេព ដល់មកសម័យអង្គរលទ្ធិទេវរាជបានផ្តល់អោយព្រះរាជានូវថានៈជាអាទិទេព ។ វត្ថុជានិមិត្តរូបទេវរាជជាលិង្គព្រះឥសូរដែលគេត្រូវតំកល់លើប្រាសាទភ្នំ ជាតំណាងភ្នំព្រះសុមេរុ ។

– ពី ស.វ. ទី ១៥ ដល់ដើម ស.វ. ទី ២០ រាជាធិបតេយ្យខ្មែរ ជារាជាធិបតេយ្យជ្រើសរើស ( monarchie élective ) : មានអន្តរាគមន៍របស់ពួកមន្ត្រីសេនាបតី ក្នុងការជ្រើសរើសព្រះរាជាថ្មីអោយឡើងសោយរាជ្យជាតំណាងវង្ស ។

– នៅពាក់កណ្តាល ស.វ. ទី២០ រាជាធិបតេយ្យខ្មែរជារាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ( monarchie constitutionnelle ) ។

ក្នុងរបបរាជាធិបតេយ្យ អំណាចទាំងឡាយចេញមកពីព្រះរាជា អំណាចសំខាន់ទាំងបីគឺ : នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងនីតិតុលាការ សុទ្ធ

តែមានប្រភពចេញពីស្ដេចផែនដី ។ ក្នុងសម័យបុរាណ ព្រះរាជាកាន់កាប់នយោបាយទាំងក្នុងប្រទេសទាំងក្រៅប្រទេស ព្រះរាជាជា "អម្ចាស់ជីវិតលើត្បូង" មានអំណាចអោយ "ស្លាប់ រឺរស់" ទៅលើសព្វសត្វដែលស្ថិតក្រោមការត្រួតត្រារបស់ព្រះអង្គ ។ តំណែងសំខាន់ៗ ត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់វង្សានុវង្ស រឺមន្ត្រីជាន់ខ្ពស់ ។ រចនាសម្ព័ន្ធសក្ដិភូមិ បណ្ដាលអោយមានការប្រណែននិន្ទាឈ្នានីស អោយមានអំពើពុករលួយនិងអយុត្តិធម៌ក្នុងសង្គមគ្រប់បែបយ៉ាង ហើយជាពិសេសគឺបណ្ដាលអោយមានអស្ថិរភាពក្នុងផ្នែកនយោបាយនេះឯង ។

ដូចនេះ ឃើញថាអំណាចរបស់អ្នកដឹកនាំរដ្ឋក្នុងរបបរាជាធិបតេយ្យមានទំហំទូលំទូលាយណាស់ ហើយពុំមានក្បួនច្បាប់ណាអាចមកកំរិតព្រំដែនបានឡើយ ក្រៅតែមនសិការផ្ទាល់របស់អ្នកដឹកនាំនោះតែម្ដង ។ គួរកត់សំគាល់ដែរថា ទោះបីមានគុណវិបត្តិច្រើនបែបយ៉ាងនេះក៏ដោយ ក៏របបរាជាធិបតេយ្យមានលក្ខណៈល្អម្យ៉ាងត្រង់អាចសំរេចកិច្ចការរដ្ឋធំៗ បានឆាប់រហ័សប្រសិនបើអ្នកដឹកនាំមានចិត្តស្នេហាជាតិពិតប្រាកដ ។ តែបើតាមសង្កេតឃើញថា ព្រះរាជាក្នុងសម័យបុរាណច្រើនមិនសូវប្រកបដោយទសពិធរាជធម៌ ច្រើនតែបណ្ដោយអោយតណ្ហាជិះជាន់ គិតប្រយោជន៍ផ្ទាល់ខ្លួនជាងប្រយោជន៍ប្រទេសជាតិ ។ ដោយហេតុនេះហើយ បានជាព្រះរាជានៅសម័យអង្គរ ដោយចង់លើកតំកើងឋានៈព្រះអង្គអោយស្មើអាទិទេព បានតំរូវអោយប្រជារាស្ត្រកសាងប្រាសាទថ្មធំៗជាច្រើន



(ប្រាសាទភ្នំ) ។ បន្ទុកដ៏សែនធ្ងន់នេះរួមនិងចម្បាំងរាំងជល់ដែលមានមិនចេះអស់មិនចេះហើយ ធ្វើអោយរាស្ត្រនឿយណាយយ៉ាងខ្លាំង អស់មានសេចក្ដីទុកចិត្តទៅលើអ្នកដឹកនាំ រហូតដល់មានបដិវត្តន៍យ៉ាងធំនៅស.វ.ទី១៤ ។ ប៉ុន្តែរាជវង្សថ្មីដែលនាយត្រសក់ផ្អែមបានបង្កើតឡើងមិនយូរប៉ុន្មាន ក៏បានធ្លាក់ទៅក្នុងដានចាស់ ។ នៅសម័យដែលខ្មែរយើងលើករាជធានីចេញពីក្រុងអង្គរ អ្នកដឹកនាំរដ្ឋច្រើនតែលោភលន់អំណាច រហូតដល់បែកបាក់សាមគ្គីគ្នា បណ្ដាលអោយមានចម្បាំងបង្ហូរឈាមគ្នាឯងច្រើនលើកច្រើនគ្រា ស្ទើរតែរាប់មិនអស់ (ចម្បាំងសុរិយោទ័យ-ស្រីរាជា-ធម្មរាជា ស.វ.ទី១៥-ចម្បាំងស្រីសុគន្ធបទ-ស្ដេចកន-អង្គចន្ទ ស.វ.ទី១៦ ។ល។) នៅស.វ.ទី១៧ នៅពេលដែលខ្មែរចងស្ពានមេត្រីជាមួយយួន ដោយជ័យជេដ្ឋាទី២រៀបការជាមួយបុត្រីស្ដេចយួន វិបត្តិរាជវង្សមានកាន់តែញឹកញាប់ឡើងស្ទើរតែរកចាំអោយអស់ពុំកើត ។ ប្រទេសត្រូវធ្លាក់ក្នុងភាពច្របូកច្របល់រកទីបំផុតគ្មាន : ដោយគិតតែខាងឈ្នះ តែខាងបានអំណាច គូប្រឆាំងមិនញញើតរត់ទៅសុំជំនួយពីបរទេសជិតខាងអោយគេជួយ ។ នេះហើយជាហេតុនាំអោយបរទេសមានឱកាសយ៉ាងល្អដើម្បីលូកដៃចូលជ្រៀតជ្រែកក្នុងនយោបាយផ្ទៃក្នុងរបស់ខ្មែរ ហើយនៅទីបំផុតបានប្រលេះយកទឹកដីខ្មែរមួយផ្នែកធំ ដោយវិធីសុំចូលនៅដោយសន្តិវិធីផង និងដោយយោធាវិធីផង : កម្ពុជាក្រោម បាត់ដំបង សៀមរាប-អង្គរ (មុន ១៩៤៦) ត្រូវបាត់បង់ក៏ដោយសារតែផ្ទៃក្នុងរបស់យើងមានការ

ប្រែះឆាដូចនេះឯង ។ នៅស.វ.ទី១៩ ជាតិខ្មែរពិះតែរលាយ ប្រទេសខ្មែរពិះតែបាត់ស្រមោលពីផែនទីសកលលោក ព្រោះបរទេសជិតខាងគេបានសំរេចជាត្រូវតែរំលាយជាតិខ្មែរ ។ នេះហើយជាហេតុដែលនាំអោយខ្មែរធ្លាក់ទៅនៅក្រោមអាណាព្យាបាលបារាំង (១៨៦៣) អស់រយៈកាល ៩០ ឆ្នាំ ។ តែក្រោយពីបានឯករាជ្យពេញលេញនៅឆ្នាំ១៩៥៣ មក អ្នកដឹកនាំជាតិនៅតែបណ្តោយអោយជាតិធ្លាក់ទៅក្នុងអន្លង់ទុក្ខដដែល រហូតដល់មានបដិវត្តន៍ជាថ្មីម្តងទៀតនៅថ្ងៃ ១៨ មីនា១៩៧០ ។

សាធារណរដ្ឋត្រូវបានប្រកាសឡើងតាំងពីថ្ងៃ ៩ តុលា ១៩៧០ ។ ប្រជារាស្ត្រខ្មែរមានសង្ឃឹមថា របបថ្មីនេះនឹងអាចផ្តល់សុភមង្គលដល់ខ្លួនគ្រាន់បើជាងរបបចាស់ ។ ប៉ុន្តែយើងយល់ថា យើងនឹងអាចសំរេចគោលដៅរបស់យើងបានខ្លះ លុះណាតែអ្នកនយោបាយជាតិយើងស្គាល់អោយច្បាស់ហើយចៀសវាង នូវកំហុសដែលអ្នកដឹកនាំជំនាន់មុនបានប្រព្រឹត្ត បានសេចក្តីថា ត្រូវចេះដកស្រង់មេរៀនចេញពីប្រវត្តិសាស្ត្រ ដើម្បីកុំអោយជាតិធ្លាក់ទៅក្នុងអន្លង់ចាស់ទៀត ។ ជាតិខ្មែរនឹងអាចគង់វង់ ហើយនឹងអាចចំរើនលូតលាស់បាន លុះណាតែអ្នកដឹកនាំស្រលាញ់ជាតិស្រលាញ់រាស្ត្រពិតប្រាកដ ហើយរំលាយខ្លួនអោយចូលនឹងរាស្ត្រទៀតផង ។ បើនិយាយមួយបែបទៀត គឺថា ទាល់តែអ្នកដឹកនាំមុកការចំរើនរាស្ត្រជាធំ និយមលទ្ធិប្រជាធិបតេយ្យពិតប្រាកដ បើអោយរាស្ត្រចូលរួមក្នុងការដោះស្រាយបញ្ហាជាតិ ស្របទៅតាមគោលការណ៍ដែលថែ



www.amelkhmer.org

ថា "ការគ្រប់គ្រងជារបស់រាស្ត្រ ធ្វើដោយរាស្ត្រនិងសំរាប់ផលប្រយោជន៍រាស្ត្រ" ។ ឧត្តមគតិនេះ យើងនឹងអាចសំរេចបាន លុះណាតែរាស្ត្របានទទួលការអប់រំគ្រប់គ្រាន់ គឺត្រូវបានទទួលចំណេះវិជ្ជាដ៏ខ្ពង់ខ្ពស់ ត្រូវមានមនសិការជាតិ ស្គាល់បញ្ហាជាតិអោយច្បាស់លាស់ គឺមានការថែរក្សាជាតិខ្មែរអោយនៅគង់វង់ ថែរក្សាទឹកដីខ្មែរដែលរួញតូចណាស់ទៅហើយ និងរីកសាងជាតិអោយមានការចំរើនលូតលាស់ ដោយផ្សំគំរែជាតិនិងឥទ្ធិពលដ៏ចំរើនរបស់បស្ចិមប្រទេស (វិទ្យាសាស្ត្រ តិចនិច ។ល។) ។ បញ្ហាអប់រំទាំងនេះ គឺជាបន្ទុករបស់អ្នកដឹកនាំជាតិ ។ ប៉ុន្តែអប់រំទទេ មិនទាន់គ្រប់គ្រាន់ ត្រូវអោយតំរាប់ថែមទៀតទើបអាចសំរេចគោលដៅបាន ។

## ២- សេដ្ឋកិច្ចខ្មែរ.-

ជាយូរលង់ណាស់មកហើយ សេដ្ឋកិច្ចខ្មែរមានមូលដ្ឋានស្ថិតលើកសិកម្ម ។ ខ្មែរចេះធ្វើស្រែចំការតាំងពីសម័យបុព្វប្រវត្តិសាស្ត្រម៉្លេះ ភស្តុតាងគឺអ្នកស្រាវជ្រាវបានរកឃើញនៅត្រង់ស្ថានីយសំរោងសែន អន្លង់ផ្តៅនិងមូលព្រៃ នូវកណ្តៀវធ្វើពីថ្មរលីងក៏មាន ធ្វើពីឆ្អឹងសត្វក៏មាន ធ្វើពីលង្ហិនក៏មាន ។ នៅមុនសម័យអង្គរ កសិកម្មខ្មែរមានការចំរើនលូតលាស់ណាស់ទៅហើយ: រូបថតពីលើយន្តហោះ បង្ហាញអោយឃើញនូវបណ្តាញព្រែកជីកយ៉ាងញឹក នៅត្រង់ភូមិភាគខាងលិចកម្ពុជាក្រោមសព្វថ្ងៃ ។ តាម

ពោលរបស់អ្នកជំនាញការ ព្រែកជីកទាំងនោះសំរាប់បង្ហូរទឹកជំនន់ចេញពីទន្លេធំ ៗ ដើម្បីយកទៅលាងជាតិប្រៃដែលជ្រួតជ្រាបទៅក្នុងដីស្រែ ។ ចូលក្នុងសម័យអង្គរ កសិកម្មក៏តែមានការលូតលាស់ជាងពេលណាៗទាំងអស់ ព្រោះពេលនោះ ខ្មែរមានការប៉ិនប្រសប់ក្នុងនយោបាយទឹកៈ ធ្វើស្រែគេមិនរំពឹងតែទៅលើមេឃទេ គេចេះជីកបារាយធំ ៗ សំរាប់ទប់យកទឹក ( បារាយលលៃ បារាយខាងកើត បារាយទឹកថ្លា ) ហើយអាចបង្កើតផលដល់ទៅបីដងក្នុងមួយឆ្នាំ ។ ដោយសារតែសេដ្ឋកិច្ចលូតលាស់សំបើមដូចនេះហើយ បានជាខ្មែរមានលទ្ធភាពអាចកសាងប្រាសាទថ្មធំៗដែលមានសេសសល់រហូតមកដល់សព្វថ្ងៃនេះឯង ។ នៅសម័យក្រោយអង្គរ ដំណាំស្រូវក៏នៅជាមូលដ្ឋាននៃសេដ្ឋកិច្ចខ្មែរ ៖ ទោះបីពេលស្រុកកើតចម្បាំងក៏ដោយ តែដល់រដូវធ្វើស្រែ គេត្រូវតែបញ្ឈប់ចម្បាំងធ្វើស្រែសិន សមដូចពាក្យបុរាណលោកពោលថា " ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ " ។ គួរកត់សំគាល់ថា នៅសម័យនោះ ដំណាំប្រទេសក្តៅខ្លះក៏មានការចំរើនលូតលាស់ណាស់ដែរ ដូចជា ត្នោត ថ្នាំ មន អំពៅ ។ នៅ ស.វ. ទី ១៩ ជនជាតិចិនបាននាំដើមម្រេចយកមកដាំនៅតំបន់កំពត ហើយរបរដាំម្រេចនេះច្រើនតែចិនទេជាអ្នកប្រព្រឹត្ត ។ ដល់មកក្រោយសង្គ្រាមលោកលើកទី ១ បារាំងបាននាំកៅស៊ូយកមកដាំនៅតំបន់ដីក្រហមកំពង់ចាម ក្រចេះ ។

ដំណើរវិវត្តន៍ខាងលើបានបង្ហាញអោយឃើញថា ដំណាំស្រូវជា



មូលដ្ឋាននៃសេដ្ឋកិច្ចខ្មែរ ។ ត្រង់នេះ មិនបានសេចក្តីថាដូនតាយើងពីបុរាណមិនបានធ្វើសកម្មភាពផ្សេង ៗ ទៀតទេ កំពង់ផែធំនៅអូរកែវសម័យអាណាចក្រភ្នំបង្ហាញថា នៅពេលនោះពាណិជ្ជកម្មក៏មានការលូតលាស់ណាស់ដែរ ព្រោះខ្មែរមិនគ្រាន់តែបានទាក់ទងជាមួយឥណ្ឌា និងជ្វា ចាម ប៉ុននោះទេ តែរហូតជាមួយចក្រភពរ៉ូម៉ាំងនិងពិភពអ៊ីរ៉ង់ថែមទៀតផង ។ នៅសម័យអង្គរ របរជំនួញនៅតែមានលក្ខណៈសកម្មដដែល ហើយក្រៅពីនេះ ខ្មែរបានប្រកបរបរនេសាទត្រី ជាពិសេសនេសាទត្រីនៅបឹងទន្លេសាប (ចំលាក់លើប្រាសាទបាយ័នអាចបញ្ជាក់រឿងនេះ ) ។ ក្នុងច្បាប់ផ្សេង ៗ ចាស់បុរាណលោកបានប្រដៅទូន្មានអោយកូនចៅខិតខំធ្វើរបរជំនួញ ខ្លាំងណាស់ដែរ (ច្បាប់អរិយសត្យា - កេរ្តិ៍កាល - បណ្តាំបិតា ) ។

សរុបសេចក្តីមកឃើញថា ដូនតាយើងលោកស្គាល់ច្បាស់ណាស់ពីសារៈសំខាន់របស់សេដ្ឋកិច្ចក្នុងការរស់នៅជាសង្គម ។ បើប្រៀបធៀបទៅនឹងសម័យអង្គរ រឺសម័យមុននេះទៅទៀត យើងត្រូវទទួលសារភាពថា សេដ្ឋកិច្ចខ្មែរសម័យបច្ចុប្បន្ននេះមានភាពទន់ខ្សោយណាស់ ។ តើមូលហេតុមកពីអ្វី ?

គួរគប្បីជ្រាបថា នៅប្រទេសខ្មែរយើងកសិករមានដល់ទៅ ៨៣ % នៃប្រជាជនក្នុងប្រទេស តែកំរិតជីវភាពរបស់គ្នានៅទាបពន់ពេកណាស់ ។ ការសិក្សាពីរឿងនេះ បានបង្ហាញអោយឃើញថាមកតែពី ៖

១ / មធ្យោបាយបង្កើតផលមិនទាន់សម័យ

២ / គ្មានការកែទំរង់ដីស្រែ

៣ / អន្តរាគមន៍របស់រដ្ឋាភិបាលខ្វះប្រសិទ្ធិភាព ។

យ៉ាងណាមិញ កិច្ចការស្រែចំការបានប្រព្រឹត្តទៅតាមតែចំណាំពីបុរាណ ។ គេប្រើតែកម្លាំងមនុស្សនិងសត្វ ដែលជាហេតុអោយខាតពេលវេលាច្រើន តែបានទិន្នផល ( rendement ) តិច ។ ម្យ៉ាងទៀតកសិករភាគច្រើនគ្មានដីផ្ទាល់និងដើមទុន ។ មានប្រមាណ ៣០ % នៃអ្នកស្រែត្រូវប្រវាស់ដី ហើយខ្ចីបុលលុយការគេយកធ្វើដើមទុន ។ ក្នុងផល ១០០% ដែលបានមក អ្នកស្រែបានទទួលសំរាប់ខ្លួនឯង និងគ្រួសារតែ ២៥ % ក្រៅពីនេះបានទៅម្ចាស់បំណុល ( ៣៨% ) ពន្ធដា ( ១៤ % ) និងការដឹកនាំ ( ២៣ % ) ។ គួរកត់ចំណាំថា ការរកស៊ីចងការច្រើនហួសប្រមាណនេះ ជាជំងឺមហារីកមួយដែលបំផ្លិចបំផ្លាញសង្គមខ្មែរ ។ នៅពេលដែលមានគ្រោះខាតតើអោយអ្នកស្រែគ្មានទៅណា ? មានផ្លូវតែមួយ គឺរត់ទៅរកខ្ចីបុលពីពួកនាយទុនដែលយកការប្រាក់ដល់ទៅ ២០ % រឺខ្ចីយកស្រូវក្នុង ១០០ យក ៤-៥ ថាំង ។ ដោយហេតុនេះហើយបានជាកសិករខ្លះដែលមានស្រែបន្តិចបន្តួច យូរៗទៅធ្លាក់ទៅក្នុងដៃនាយទុនអស់ទៅ ។

ដីស្រែនៅប្រទេសខ្មែរច្រើនតែមានទំហំតូចៗ មានជាមធ្យមពី ១ ដល់ ២ ហិចតា ។ រឿងនេះមកតែពីការបែងចែកតៗគ្នាជាកេរមត៌ក ព្រោះមនុស្សកើនឡើងតែមួយកន្លែងច្រើនពេក ។ ក្នុងករណីនេះ គេមិនអាចប្រើ



ម៉ាស៊ីនហើយស្រែធ្វើបានតែម្តងក្នុងមួយឆ្នាំ ។ ដោយហេតុតែគេបានទទួលផលយ៉ាងស្តួចស្តើង សំរាប់ផ្គត់ផ្គង់គ្រួសារយ៉ាងត្រដាបត្រដួសទៀតផង (មធ្យមពី ១,១ ដល់ ១,៦ តោនក្នុង ១ ហិចតា) ។

ក្នុងសម័យមុនៗគេបានសង្កេតឃើញថា អន្តរាគមន៍របស់រដ្ឋាភិបាលក្នុងការជួយលើកស្ទួយជីវភាពកសិករនេះមិនសូវមានប្រសិទ្ធិភាព ព្រោះអង្គការដែលបានបង្កើតឡើងយូរៗទៅ ក្លាយជាឧបករណ៍របស់នាយទុនទៅវិញ ។ រដ្ឋាភិបាលច្បាស់ជាបានជ្រាបស្រាប់ហើយថា ប្រទេសនីមួយៗចំរើនបានទាល់តែរាស្ត្រមានជីវភាពខ្ពស់ ។ និងអាចទៅជាដូចនេះបានទាល់តែរាស្ត្រ មានផលសេសសល់ល្មមនាំយកទៅលក់នៅក្រៅប្រទេសបាន ។ ហើយដរាបណាសេដ្ឋកិច្ចគ្រួសារល្អតលាស់ហើយ ដរាបនោះសេដ្ឋកិច្ចរដ្ឋក៏មានឈ្មោះថាល្អតលាស់ដែរ ។ ដោយកសិកម្មជាមូលដ្ឋាននៃសេដ្ឋកិច្ចស្រាប់ រដ្ឋត្រូវតែជួយវិស័យនេះអោយបានពេញដៃពេញជើង ហើយអោយមានប្រសិទ្ធិភាពទៀតផង :

* ត្រូវតែហ៊ានធ្វើការកែទំរង់ដី ដើម្បីអោយកសិករមានដីគ្រប់ៗគ្នា ហើយអោយដីនោះមានទំហំធំៗទៀតផង ។ ក្រៅពីនេះ គួរស្វែងរកដីថ្មីសំរាប់កសិកម្មដែរ ។ ធ្វើយ៉ាងនេះទៅកសិករយើងនឹងមានលទ្ធភាពប្រើគ្រឿងយន្តអោយបានទូទៅ ហើយអាចយកផលបានយ៉ាងតិច ២ ដងក្នុង ១ ឆ្នាំ ។

* ត្រូវជម្រុញអោយកសិករ ប្រើមធ្យោបាយទំនើបតាមបែបវិទ្យា

សាស្ត្រ :

១ / ប្រើគ្រឿងយន្តក្នុងការភ្ជួររាស់-ច្រូតកាត់-បូមទឹកដាក់ស្រែ

២ / បង្ហាញវិធីប្រើជីគីមី

៣/ រើសយកពូជល្អៗដើម្បីបានផលច្រើន

៤/ ថែរក្សាដោយកំចាត់សត្វល្អិត

៥/ ធ្វើនយោបាយទឹកអោយបានម៉ឺងម៉ាត់ ( កុំសង្ឃឹមតែលើទឹកភ្លៀង ត្រូវធ្វើទំនប់តូចធំអោយបានច្រើន)

៦/ អប់រំអ្នកបច្ចេកទេសអោយមានចំនួនច្រើន ដើម្បីជួយបង្ហាត់បង្ហាញកសិករនូវវិធីទំនើបៗក្នុងរបរកសិកម្ម ។

*រដ្ឋត្រូវធ្វើយ៉ាងណា កុំអោយកសិករដើរខ្ចីបុលពីនាយទុន ដោយត្រូវបង់ការច្រើនហួសហេតុពេក ។ ធនាគារកសិកម្មផងមានរួចហើយ ជាជំហាន១ទៅមុខ តែរដ្ឋត្រូវខិតខំអោយច្រើនថែមទៀតក្នុងរឿងនេះ ។

*រដ្ឋត្រូវកំរិតតំលៃនិងជួយទិញផលពីរាស្ត្រ កុំបណ្តោយអោយឈ្មួញកំរិតតាមចិត្ត ។

*ត្រូវអប់រំអោយកសិករនិយមយករបៀបបង្កើតផលតាមបែបវិទ្យាសាស្ត្រ អោយមានជំនឿលើវិទ្យាសាស្ត្រ លះបង់ចោលនូវការបន់ស្រន់ជឿលើមេឃ លើវាសនា ដោយឥតមានការតស៊ូ អោយចេះផ្តុំការងារដែលខ្មែរមានទំលាប់របៀបនេះស្រាប់ហើយ : សហករណ៍បង្កើតផល



គួរបង្កើតអោយមាន ដើម្បីជាមធ្យោបាយអោយកសិករប្រមូលផ្តុំដើមទុននិងស្រូបយកវិធីថ្មីបច្ចេកទេស សហករណ៍ឧបភោគ - បរិភោគ ក៏ត្រូវអោយមានដែរ ដើម្បីជួយផ្តល់វត្ថុចាំបាច់ដល់កសិករ ។

*ចំពោះស្រូវនិងដំណាំឯទៀតៗ (ពោត កៅស៊ូ កប្បាស ក្រចៅ ថ្នាំ មន ។ល។ ) ត្រូវធ្វើយ៉ាងណាអោយបានគ្រប់គ្រាន់សំរាប់ការប្រើប្រាស់ក្នុងប្រទេសផង ផ្តល់ជាវត្ថុធាតុដើមដល់រោងចក្រផង និងមានសល់សំរាប់លក់ទៅក្រៅយករូបិយប័ណ្ណបរទេសទៀតផង ។

ក្រៅពីកសិកម្ម គួរខ្មែរយើងខិតខំក្នុងវិស័យផ្សេងៗទៀត ដូចជាការចិញ្ចឹមសត្វ ការនេសាទត្រី តាមបឹងទន្លេនិងសមុទ្រ ការធ្វើអាជីវកម្មលើព្រៃឈើ ការការពារនិងអោយតំលៃដល់សិប្បកម្មគ្រប់ប្រភេទ ការពង្រីកទេសចរណ៍ជាតិនិងអន្តរជាតិ ។

ឧស្សាហូបនីយកម្ម ជាហេតុការណ៍ថ្មីមួយក្នុងសេដ្ឋកិច្ចខ្មែរ ហើយច្រើនមានប្រភពចេញពីកសិកម្ម : កិនស្រូវ បិទស្រា ចំរាញ់ជ័រកៅស៊ូ ធ្វើក្រដាស់-ក្តារបន្ទះ-ស្ករ-សំបកកង់ឡាន-បារីក្រចៅ ត្បាញកុំណាត់សំពត់ ។ នេះជាហេតុមួយទៀតជំរុញអោយយើងពង្រីកកសិកម្ម ជាពិសេសខាងផ្នែកដំណាំឧស្សាហកម្ម ប៉ុន្តែឧស្សាហកម្មឯទៀតៗ ដូចជាធ្វើស៊ីម៉ង់-កែវ-ជី-តំលើងត្រាក់ទ័រ ចំរាញ់ប្រេងកាត ក៏គួរយើងពង្រីកដែរ ដើម្បីអោយមានរបស់ប្រើគ្រប់គ្រាន់ផង មិនខាតរូបិយប័ណ្ណទិញពីបរទេសផង ។

ក្នុងវិស័យពាណិជ្ជកម្ម យើងកំពុងជួបឧបសគ្គយ៉ាងធំ ដោយសារតែវិស័យនេះធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់បរទេសស្ទើងទាំងស្រុងទៅហើយ ហើយពួកបរទេស ដែលបានស្រូបយកទ្រព្យសម្បត្តិលុយកាក់ធនធានរបស់ជាតិខ្មែរនេះ ឃើញថាមានឥទ្ធិពលលើនយោបាយរបស់ប្រទេសយើងកាន់តែខ្លាំងជាលំដាប់ ។ បើយើងបណ្ដោយតទៅទៀត ឃើញថាមុខជាមានគ្រោះថ្នាក់ដែលមានទំហំស្មើនឹងការឈ្លានពានរបស់សត្រូវពីខាងក្រៅដែរ ។ ដូចនេះមួយផ្នែកគួររដ្ឋខិតខំកាលៃចិត្តគំនិតរបស់បរទេសនោះអោយមានលក្ខណៈជាខ្មែរ ដើម្បីអោយពួកនេះជួយបំរើផលប្រយោជន៍ខ្មែរផង មួយផ្នែកទៀតជួយលើកទឹកចិត្ត ជួយផ្ដល់ដើមទុន ជួយការពារដល់ជនជាតិខ្មែរណាដែលប្រណាំងប្រជែងជាមួយជនបរទេស ហើយសូមកុំពង្រីកសកម្មភាពរបស់វាតទៅទៀត ។

## គ - សង្គមកិច្ចខ្មែរ . -

ដូនតាខ្មែរពីបុរាណកាល បានយល់ច្បាស់ណាស់នូវសារៈសំខាន់នៃសង្គមកិច្ច ។ ឯកសារប្រវត្តិសាស្ត្រជាតិក្ដី បរទេសក្ដីសុទ្ធតែបានបង្ហាញថាខ្មែរចេះឆ្កាព្រៃ ជីកស្រះ-ព្រែក-ប្រឡាយទឹក-បារាយ ធ្វើទំនប់ កសាងផ្លូវថ្នល់-ស្ពាន-សាលាសំណាក់-មន្ទីរពេទ្យ។ដោយហេតុនេះហើយបានជាខ្មែរមានប្រពៃណីចេះជួយសង្គ្រោះគ្នាទៅវិញទៅមក : សព្វថ្ងៃនេះខ្មែរនៅតែធ្វើស្រែយកដៃគ្នាជួយគ្នាក្នុងកិច្ចការផ្សេងៗ មានសង់ផ្ទះ បុណ្យ



ផ្កា បុណ្យខ្មោចជាដើម ។ ឥទ្ធិពលព្រះពុទ្ធសាសនា ធ្វើអោយប្រពៃណីនេះរឹតតែមានសភាពប្រសើរឡើងទៀត ព្រោះពុទ្ធបរិស័ទតែងនិយមបំពេញកិច្ចការជាប្រយោជន៍រួម ដើម្បីបានទទួលអានិសង្សច្រើន ( សង់សាលា ធ្វើផ្លូវថ្នល់ សង់ស្ពាន ។ល។ ) ។ ម្យ៉ាងទៀត ការសមាទានសីលដ៏ខ្ជាប់ខ្ជួនអាចជុសខាត់សង្គមអោយកាន់តែស្អាតបរិសុទ្ធ ឯការប្រមូលគ្នាទៅវត្តអារាម ជាឱកាសល្អប្រសើរ ព្រោះគេអាចឆ្លៀតពិភាក្សាគ្នាអំពីកិច្ចការជាប្រយោជន៍រួមបានយ៉ាងស្រួល ។

ដូចនេះ ឃើញថាប្រពៃណីជាតិ និងព្រះពុទ្ធសាសនាបានរួមចំណែកយ៉ាងសកម្មក្នុងវិស័យសង្គមកិច្ច ។ តែប្រសិនបើរដ្ឋចូលជួយយ៉ាងពេញដៃជើងទៀត នោះប្រជារាស្ត្រខ្មែរមុខជាបានជួបសុភមង្គលមិនខាន ។ ឯរបបសាធារណរដ្ឋនិងលទ្ធិប្រជាធិបតេយ្យនឹងអាចមានជំហររឹងប៉ឹងនិងមានអាយុយឺនយូរស្ថិតស្ថេរទៅបាន លុះណាតែរាស្ត្រមានកំរិតជីវភាពខ្ពស់ គឺត្រូវបានទទួលការអប់រំ មានលំនៅ មានសំលៀកបំពាក់ មានការងារធ្វើ មានការធានារ៉ាប់រងពីរដ្ឋខាងវិជ្ជាជីវៈ មានសន្តិសុខខាងសង្គមកិច្ច (សហជីព ម៉ោងធ្វើការ សំរាក ឈឺ គ្រោះថ្នាក់ ការងារ ប្រាក់បំណាច់ ប្រាក់ចូលនិវត្តន៍) ហើយជាពិសេស ត្រូវហាមនិងខិតខំបំបាត់ដោយគ្រប់មធ្យោបាយ នូវអំពើពុករលួយនិងអយុត្តិធម៌ក្នុងសង្គមថែមទៀតផង ។

សរុបសេចក្ដីមក ឃើញថានយោបាយក្ដី សេដ្ឋកិច្ចក្ដី សង្គមកិច្ចក្ដី សុទ្ធតែមានមុខងារសំខាន់ក្នុងការបំរើប្រយោជន៍សង្គម ហើយមានទំនាក់

ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នាថែមទៀតផង ។ យ៉ាងណាមិញ បើអ្នកដឹកនាំរដ្ឋមិនភាន់វង្វេងក្នុងផ្នែកនយោបាយទេ នោះជាតិក៏មិនអាចនៅគង់វង់បានដែរ ។ បើសេដ្ឋកិច្ចទន់ខ្សោយ រាស្ត្រមុខជាគ្មានអ្វីទ្រទ្រង់អត្ថិភាពរបស់ខ្លួនឡើយ ហើយបើសង្គមកិច្ចគ្មានប្រសិទ្ធិភាពទេ រាស្ត្រមុខជាធ្លាក់ទៅក្នុងរណ្តៅទុក្ខ ពុំអាចស្គាល់ពន្លឺសុភមង្គលឡើយ ។ គេតែងសង្កេតឃើញថា តែកាលណានយោបាយមានវិបត្តិ សង្គមកិច្ចនិងសេដ្ឋកិច្ចក៏ទទួលផលវិបាកអាក្រក់ដែរ បើសេដ្ឋកិច្ចមិនរឹងប៉ឹង នយោបាយសង្គមកិច្ចក៏មានភាពមិននឹងនរដែរ ហើយផ្ទុយទៅវិញ បើសង្គមមានរបៀបរៀបរយហើយ ផលិតកម្មក្នុងផ្នែកសេដ្ឋកិច្ចមុខជាសម្បូណ៌ហូរហៀរមិនខាន ។

វិធីទាំង៣ ខាងលើ មានគោលដៅតែមួយ គឺបំរើសង្គម បំរើផលប្រយោជន៍រាស្ត្រ រកសុភមង្គលអោយរាស្ត្រ ។ ប៉ុន្តែនឹងសំរេចគោលបំណងនេះបាន ទាល់តែអ្នកដឹកនាំមានចិត្តស្រលាញ់ជាតិពិតប្រាកដស្រលាញ់ប្រយោជន៍ទូទៅជាងប្រយោជន៍ផ្ទាល់ខ្លួន បានសេចក្តីថាត្រូវតែអនុវត្តគោលការណ៍ " ការគ្រប់គ្រងជារបស់រាស្ត្រធ្វើដោយរាស្ត្រនិងដើម្បីប្រយោជន៍រាស្ត្រ " អោយបានសកម្មជាទីបំផុត ។

*

* *

# ផ្នែកទី៤

# ទីលំពិសេសនៃអរិយធម៌ខ្មែរ

រួមសេចក្តីទាំងអស់មក យើងឃើញថាខ្មែរជាជាតិមួយធ្លាប់មានអរិយធម៌ពិតប្រាកដមែន ។ អរិយធម៌ខ្មែរពុំមែនទើបតែដុះដាលឡើងនៅពេលថ្មីៗនេះទេ តែជាអរិយធម៌មួយមានចំណាស់ក្នុងចំណោមអរិយធម៌ដែលចាស់ជាងគេក្នុងពិភពលោក ព្រោះវាបានកកើតឡើងនៅភូមិភាគអាស៊ីអគ្នេយ៍នេះ ក្នុងសម័យបុព្វប្រវត្តិសាស្ត្រដ៏យូរលង់ណាស់មកហើយ គឺនៅពេលដែលខ្មែរយើង មិនទាន់បានប្រាស្រ័យទាក់ទងជាមួយនិងជាតិនានាមាន ចិន ឥណ្ឌា រ៉ូម៉ាំង ពែរ្ស ជាដើម ។

អរិយធម៌នេះចេះតែចំរើនលូតលាស់ជាលំដាប់ដោយបានស្រូបយកឥទ្ធិពលបរទេសមកផ្សំផ្សំនិងធាតុដើមរបស់ខ្លួន ដើម្បីបង្កើតអោយបានជាអរិយធម៌ចំរុះមួយបែប ដែលបែកជាមែកជាធាងសាខា បីដូចជាដើមឈើដែលដាំលើដីមានដីជាតិល្អ មានទឹក មានកំដៅព្រះអាទិត្យគ្រប់

គ្រាន់ ក៏ដុះដាលលូតលាស់ឡើងមានពណ៌ស្រស់បំព្រងដូចនោះដែរ ។

អរិយធម៌ខ្មែរសម្បូណ៌មែកធាងណាស់ : យើងមានតាំងពីអក្សរ ភាសា អក្សរសិល្ប៍ សិល្បៈ ទស្សនវិជ្ជា សាសនា ទំនាមទំលាប់ ប្រពៃណី ។ល។ ហើយទាំងនេះ សុទ្ធតែប្រកបដោយ ក្បួនច្បាប់ត្រឹមត្រូវហើយ ច្បាស់លាស់ថែមទៀតផង ។ ឧទាហរណ៍ដូចជាក្នុងភាសាខ្មែរ បទដើម (បទមុខ) រឺបទជ្រែក (បទកណ្តាល) នីមួយ ៗ សុទ្ធតែមានមុខងារជាក់លាក់ក្នុងកំលាយពាក្យចេញពីរឹសដើម : បទដើម « ក » មានមុខងារធ្វើអោយន័យសេចក្តីនៃពាក្យនីមួយ ៗ មានភាពកាន់តែខ្លាំងឡើងរឺកាន់តែញាប់ឡើង (ក + កាយ > កកាយ) ឯបទជ្រែក « ្ម » សំគាល់នូវ «មនុស្សដែលធ្វើអំពើ» (ចាំ > ឆ្មាំ-ដួញ > ឈ្មួញ) ។ បទជ្រែក « ្ន » សំគាល់នូវ «វត្ថុសំរាប់ប្រើប្រាស់» (ជាន់ > ឈ្នាន់-ចាប់ > ឆ្នាប់) ។ គួរកត់សំគាល់ថា កំលាយពាក្យដោយប្រើបទជ្រែករបៀបនេះគ្មានទេនៅក្នុងភាសាជនជាតិជិតខាងយើង ។ តំលៃមួយបែបទៀត ដែលគេអាចរកឃើញនៅក្នុងអរិយធម៌ខ្មែរ គឺការនិយមយកអ្វីដែលជាការពិត រូបិយ ជាការត្រិះរិះមកធ្វើជាមូលធម៌ : ក្នុងអក្សរសិល្ប៍ខ្មែរ ផ្នែករឿងព្រេងនិងច្បាប់ផ្សេង ៗ បានលាតត្រដាងនូវការពិតក្នុងការរស់នៅក្នុងសង្គម គឺបង្ហាញពីវិបត្តិទាស់ផ្សេង ៗ និងផ្លូវដោះស្រាយ ធ្វើយ៉ាងណាអោយជីវភាពបានប្រកបដោយសុខដុមរមនាទេវិញ ។ នៅក្នុងរឿងវេស្សន្តរជាតក ពោធិសត្វអង្គនេះទ្រង់បានខិតខំកសាងទានបារមី រហូតដល់ហ៊ានលះបង់ព្រះមហេសីនិងបុត្រ



ដាក់ទាន ព្រោះតែប្រាថ្នាចង់បានសំរេចនិព្វាន តែនៅទីបំផុត ព្រះអង្គបែរជាយល់ព្រមត្រឡប់មកសោយរាជ្យក្នុងនគរព្រះបិតាវិញ គឺត្រឡប់មករកអ្វីដែលមានរូបរាងពិតប្រាកដក្នុងលោកនេះឯង ។ ក្នុងផ្នែកសិល្បៈស្ថាបត្យកម្ម ខ្មែរយកទស្សនៈឥណ្ឌាដែលយល់ថា "អាទិទេពមានទីលំនៅនៅលើភ្នំ" នោះមកស្ថាបនាជាប្រាសាទភ្នំ ដើម្បីតំកល់លិង្គព្រះឥសូរ គឺធ្វើយ៉ាងណាអោយគំនិតក្លាយជាអ្វី ដែលមនុស្សអាចមើលឃើញច្បាស់លាស់ ។ល។

ដោយអាស្រ័យនូវហេតុដូចបានរៀបរាប់ពីខាងលើនេះហើយ បានជាអរិយធម៌ខ្មែរបានក្លាយទៅជាអរិយធម៌មួយដ៏ខ្ពង់ខ្ពស់ ហើយបានផ្សាយឥទ្ធិពលរបស់ខ្លួនទៅលើជនជាតិជិតខាង ដូចជាសៀម-លាវនេះជាដើម: អក្សរ ភាសា សិល្បៈ ទំនាមទំលាប់ ព្រះពុទ្ធសាសនារបស់ខ្មែរត្រូវបានជនជាតិនេះយកទៅប្រើប្រាស់ និងប្រតិបត្តិតាមរៀងរហូតមកដល់សព្វថ្ងៃ ។ ម្យ៉ាងទៀតអរិយធម៌ដ៏ថ្លៃថ្នូររបស់ខ្មែរ ក៏ត្រូវបានផ្សព្វផ្សាយទៅគ្រប់ទិសទីក្នុងពិភពលោក ដោយអ្នកសិក្សាស្រាវជ្រាវបរទេស ដែលបានចំណាយពេលវេលានិងប្រាក់កាសជាច្រើន ដើម្បីធ្វើការសិក្សាចាប់តាំងពី ស.វ. ទី ១៩ រៀងមក ។ អរិយធម៌នេះ ដូនតាយើងលោកបានកសាងរាប់សតវត្សមកហើយ ហើយលោកបានតស៊ូនឹងសត្រូវគ្រប់ទិសទី ដើម្បីថែរក្សាទុកជាកេរដំណែលដល់យើងជំនាន់នេះ ។ ដូចនេះ ករណីយកិច្ចរបស់យើងជាកូនចៅ គឺត្រូវរៀនអោយចេះ អោយស្គាល់ របស់ជាតិ

ខ្លួន ។ម្យ៉ាងទៀត យើងត្រូវចេះអោយតំលៃ ចំពោះសិល្បៈខ្មែរ ... ខំពង្រីកនិងរក្សាការពារ ព្រោះវាជាសរសៃស្នូល-មូលដ្ឋាន វប្បធម៌របស់ជាតិនេះតែម្តង : បើមិនស្គាល់អរិយធម៌ជាតិទេ គឺមិនស្គាល់អ្វីដែលជាជាតិរបស់ខ្លួនទេ ។

* ចប់ *

*

# ឯកសារពិគ្រោះ


1 - អត្ថបទដើម ជាអត្ថបទវាយអង្គុលីលេខរបស់លោក ត្រឹង ង៉ា អគ្គលេខាធិការនៃវិទ្យាស្ថានខ្មែរ - មន - ភ្នំពេញ ១៩៧១

2 - សាសនាគឺអ្វី? របស់លោក ម៉ុញ ន៉ាគ្រី - ភ្នំពេញ ១៩៥១

3 - វិប្បធម៌អរិយធម៌ខ្មែរ - ឥណ្ឌារបស់ព្រះភិក្ខុ ប៉ាង ខាត់ - ភ្នំពេញ - ១៩៦៨

4 - M. Giteau, Guide du musée national - sculpture-Phnom-penh 1960

5 - ប្រវត្តិវិទ្យាថ្នាក់ទី ៥ - ខេមរយានកម្ម - ភ្នំពេញ ១៩៧២

6 - ពុទ្ធប្រវត្តិសង្ខេបរបស់លោក ឈិម ស៊ុម - ភ្នំពេញ ១៩៦៩

7 - ពន្លឺអាស៊ីទ្វីប - ពុទ្ធសាសនបណ្ឌិត្យ - របស់លោកញ៉ុក ថែម និងលោកហ៊ាយ ប៊ុក - ភ្នំពេញ ១៩៦៧

8 - Louis Finot , le Bouddhisme , phnompenh 1957

9 - ទស្សនវិជ្ជាពុទ្ធសាសនារបស់ព្រះភិក្ខុ ប៉ាង ខាត់ - ភ្នំពេញ ១៩៦៨

10 - ប្រវត្តិពុទ្ធសាសនាប្រទេសខ្មែរ របស់ព្រះភិក្ខុ ប៉ាង ខាត់ - ភ្នំពេញ ១៩៦១

1- ទម្រង់សូរវិទ្យាខ្មែរ (ភាគ១) របស់លោកឃួន សុខម - ភ្នំពេញ ១៩៧០

12- ព្រឹត្តិបត្រវិទ្យាស្ថានខ្មែរ-មនលេខ១ មករា ១៩៧២

13- វិវត្តន៍នៃអក្សរខ្មែររបស់លោក ឌឹក គាម-ភ្នំពេញ ១៩៦៥

14- ព្រឹត្តិបត្រវិទ្យាស្ថានខ្មែរ -មនលេខ ២ មេសា ១៩៧២

15- Georges Maspéro, Grammaire de la langue khmère, Paris 1915

16- វិវត្តន៍នៃអក្សរសាស្ត្រខ្មែររបស់លោក លី ធាម តេង និង ម៉ា ឡាយខេម-ភ្នំពេញ ១៩៧២

17- ប្រវត្តិអក្សរសាស្ត្ររបស់លោក គឹម សែត-ភ្នំពេញ ១៩៦០

18- អំពីលំនាំសង្ខេបនៃភ្លេងខ្មែរ - ពុទ្ធសាសនបណ្ឌិត្យ - ភ្នំពេញ - ១៩៧០

19- **Musique khmère ( U R B A ), Phnompenh,1969**

20- របាំប្រជាប្រិយខ្មែរ-ក្រុមជំនុំទំនៀមទំលាប់ខ្មែរ-ភ្នំពេញ ១៩៦៤

21- ពិធីក្នុងគ្រួសារខ្មែរ-ពុទ្ធសាសនបណ្ឌិត្យ-ភ្នំពេញ ១៩៥៨

22- ក្បួនទម្រង់ការរបស់ឧត្តមប្រឹក្សា ចាបពិន-ភ្នំពេញ ១៩៦៥

23- ពិធីអាពាហ៍ពិពាហ៍ (ទាញម៉ាស៊ីន) ស្រាវជ្រាវដោយក្រុមនិស្សិត (វិញ្ញាបនប័ត្រឧត្តមសិក្សាផ្នែកវប្បធម៌អរិយធម៌) នៃមហាវិទ្យា-



ល័យអក្សរសាស្ត្រ និង មនុស្សសាស្ត្រ ឆ្នាំសិក្សា ១៩៧៣-៧៤

24- អរិយធម៌ខ្មែរ-មន របស់លោក ពៅ ឈិន-ភ្នំពេញ ១៩៧២

25- ពិធីទ្វាទសមាស (cérémonies des douze mois) - ភ្នំពេញ

26- ព្រះរាជពិធីទ្វាទសមាសភាគ១ - ភាគ២ - ភាគ៣ - ពុទ្ធសាសនបណ្ឌិត្យ-ភ្នំពេញ ១៩៦០

27- ជនបទខ្មែរ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់លោក ឡាំង ប៉េង ស៊ៀក -ភ្នំពេញ ១៩៧១

28- សន្និសីទស្តីពី "សេដ្ឋកិច្ចខ្មែរ" ធ្វើដោយលោកសាស្ត្រាចារ្យ ប៉ៅ សៅ នៅមហាវិទ្យាល័យច្បាប់ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច កាលពីថ្ងៃទី ៥ សីហា១៩៧៣.

29- ច្បាប់ផ្សេងៗ-ពុទ្ធសាសនបណ្ឌិត្យ-ភ្នំពេញ១៩៦៧

30- J- Delvert, le Paysan cambodgien, Paris 1961

31- Revue française présente le Cambodge, 1968

32- S.O.S Angkor, le courrier Unesco, Décembre 1971

33- J- Imbert, Histoire des Institutions khmères, Phnompenh 1961

- ទស្សនាវដ្តីមេយានកម្ម ឆ្នាំ៣ លេខ១ តុលា១៩៦៨

- ព្រឹត្តិបត្រវិទ្យាស្ថានខ្មែរ-មន លេខ ៥ សីហា ១៩៧៣
- ព្រឹត្តិបត្រវិទ្យាស្ថានខ្មែរ-មន លេខ ៧ ឧសភា ១៩៧៤
- Louis Renou et Jean Filliozat, L'Inde classique tomme I, Payot, Paris 1947
- Le Bouddhisme au Cambodge à l'époque du Nokor Phnom Nº 6, Série culture et civilisation khmères, Phnompenh
- Revue France-Asie Nº Spécial pour la civilisation khmère, 1955.

*

* *